ដាំដើមជីវិត
LIFE GROWTH

អ្នកក្រអានហើយនឹងមាន អ្នកមានអានហើយ មិនត្រឡប់ទៅជាក្រវិញទេ

# ១០០ គំនិត
# យកឈ្នះភាពក្រីក្រ



មានរូបភាពដៀមដាមដាក់អ្នកក្រ តែជួយជំរុញអ្នកក្រឱ្យតស៊ូយ៉ាងក្រៃលែង



Bestseller លក់ដាច់រាប់លានក្បាលទូទាំងអាស៊ី
យកឈ្នះចិត្តមនុស្សគ្រប់លំដាប់ថ្នាក់ឱ្យព្យាយាមឡើង

និពន្ធដោយ Gugu

ប្រែសម្រួលដោយ ប្រាជ្ញ វិជ័យ

ថវិកា
បណ្ណាល័យ ហ៊ុន សែន
ឆ្នាំ: ២០16
153.42
គួគ
ក.ប

*អ្នកក្រអានហើយនឹងមាន អ្នកមានអានហើយមិនត្រឡប់ទៅជាក្រវិញទេ*

# ១០០ គំនិត
# យកឈ្នះភាពក្រីក្រ

... មានរូបភាពជឿរអេជាមជាក់អ្នកក្រ តែជួយជំរុញអ្នកក្រឱ្យគស៊ូយ៉ាងក្រៃលែង ...

Bestseller លក់ដាច់រាប់លានក្បាលទូទាំងអាស៊ី
យកឈ្នះចិត្តមនុស្សគ្រប់លំដាប់ថ្នាក់ឱ្យព្យាយាមឡើង

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
00027446

និពន្ធដោយ គូគូ
ប្រែសម្រួលដោយ ប្រាជ្ញ វិជ័យ

# ដាំដើមជីវិត


| | |
|---|---|
| ចាងហ្វាងបោះពុម្ពផ្សាយ | ប្រាជ្ញ វិជ័យ |
| នាយកប្រតិបត្តិ | ខុំ ដារុយ |
| ទីប្រឹក្សា | សាស្ត្រាចារ្យ ចេះ ប្រាចិន |
| សហការីប្រែសម្រួល | រស់ សុខលៀង |
| បណ្ណាធិការ | ស៊ូ សាមាន |
| ពិនិត្យអក្ខរាវិរុទ្ធ | គណៈកម្មការដាំដើមជីវិត |
| រចនាក្រប | ឈាវ រតនៈ |
| ប្រធានទីផ្សារ | ស៊ុម ភាក់ា និង ឆាយ ណាទី |
| តម្លៃ | ១៨៥០០ រៀល |
| លេខ ISBN | ៩៧ ៨៩ ៩៩ ៦៣ ៤២ ៩១២ |
| បោះពុម្ពលើកទី ១ | ៣០០០ |



**រក្សាសិទ្ធិដោយគ្រឹះស្ថានបោះពុម្ពដាំដើមជីវិត**



ធ្វើនៅភ្នំពេញឆ្នាំ ២០១៤



ទំនាក់ទំនងជាវដុំ និងរាយតាមរយៈ

០១៧ ៨១៥ ៦១៥/ ០១០ ៨១៥ ៦១៥/ ០២៣ ៦៦ ៧៥ ១៦៨

www.lifegrowthbook.com

Facebook.com/lifegrowthbook

Email: Lifegrowthbook@yahoo.com

## អារម្ភកថារោងពុម្ព

១០០ គំនិតយកឈ្នះភាពក្រីក្រ បានធ្វើឱ្យរង្គោះរង្គើមនុស្សទូទាំងប្រទេសចិន ហុងកុង តៃវ៉ាន់ សិង្ហបុរី កូរេខាងត្បូង និងប្រទេសជាច្រើនទៀតដែលបានបកប្រែសៀវភៅមួយក្បាលនេះមកហើយ។ ដោយអត្ថន័យក្នុងនេះ បានសាងកម្លាំងជំរុញចិត្ត ឱ្យមនុស្សដែលមានទម្លាប់រាថយ និងអស់សង្ឃឹម ឱ្យតាំងនៅលើវិថីឆ្ពោះទៅរកភាពជាសេដ្ឋី និងឱ្យក្រោកឡើងមកតស៊ូសាជាថ្មីម្តងទៀត ដោយការផ្លាស់ប្តូរទស្សនៈ និងចង់ជំរុញឋានៈរបស់ខ្លួនឱ្យប្រសើរឡើងដោយវិធី «ផ្លាស់ប្តូរគំនិត»។

អ្នកនិពន្ធបានរៀបរៀង ឱ្យអ្នកអានដឹងតាំងពី **ចំណុចខ្សោយស្ថានភាព ទស្សនៈ របស់អ្នកក្រ** និងបញ្ចប់ដោយ **វិធីយកឈ្នះភាពក្រីក្រ** ហើយពេលដែលយកទៅបញ្ចូលជាមួយរូបភាពថ្លុក ដែលឆ្លុះបញ្ចាំងពីជីវិតក្នុងទស្សនៈផ្សេងៗជាកំប្លែងបែបដៀមដាមទៀតនោះ កាន់តែបន្ថែមអត្ថន័យឱ្យកាន់តែមានភាពរស់រវើកឡើង។ សៀវភៅមួយក្បាលនេះជួយផ្តល់កម្លាំងចិត្តដល់មនុស្សបានយ៉ាងល្អ (ជាពិសេសមនុស្សដែលមានស្ថានភាពគ្រួសារមិនសូវល្អ) អាចនិយាយបានថា «ត្រូវចិត្តអ្នកក្រ ឆ្លុះបញ្ចាំងពីរូបភាពរបស់អ្នកមាន»។

យើងរីករាយនឹងបញ្ជូនកម្លាំងជំរុញចិត្តនេះ ដល់មិត្តអ្នកអាន ហើយសង្ឃឹមថា លោកអ្នកនឹងបានទទួលកម្លាំងចិត្តពីអត្ថន័យត្រង់ៗ និងរូបភាពថ្លុកនៅក្នុងសៀវភៅនេះ។

# អារម្ភកថាអ្នកនិពន្ធ

បច្ចុប្បន្ននេះ តើអ្នកមានមើលឃើញពីអនាគតរបស់ខ្លួនឯងខ្លះដែរឬទេ? តើអ្នកកំពុងតែកង្វល់ពីរឿងទិញផ្ទះ ទិញឡាន ចិញ្ចឹមឪពុកម្ដាយ ឬផ្ដល់ឱ្យកូនរៀនដែរឬទេ? តើអ្នកមានអារម្មណ៍ថាចង់ធ្វើឱ្យខ្លួនឯងមានជាងបច្ចុប្បន្នដែរឬទេ?

បើចង់មាន អ្នកត្រូវតែចាប់ផ្ដើមផ្លាស់ប្ដូរខ្លួនឯង។ ការក្លាយជាអ្នកក្រតែមួយរយៈពេលខ្លី ឬខូចខាតប្រាក់មួយរយៈពេលនោះ មិនមែនជារឿងដែលគួរឱ្យខ្លាចរហូតដល់លឺបក្បាលដូចអណ្ដើកនោះទេ តែអ្វីដែលគួរឱ្យខ្លាចជាងនេះទៀតនោះគឺ អ្នក «មិនដឹងខ្លួន» ថាហេតុអ្វីទើបក្រ និងក្រខ្លាំងទៀតផង។ មនុស្សយើងអាចផ្លាស់ប្ដូរវាសនាបាន លុះត្រាតែមានកម្លាំងជំរុញចិត្តអ្វីម្យ៉ាង ហើយកម្លាំងជំរុញចិត្តនោះ អាចស្ថិតនៅក្នុងពេលបច្ចុប្បន្ន នៅក្នុងអនាគត ឬនៅក្នុងសៀវភៅមួយក្បាលនេះ។

ខ្ញុំបានសរសេរអត្ថន័យទាំង ១០០ រឿង ឱ្យត្រូវចិត្តគ្រប់ៗគ្នា និងមានរូបថ្លុកធ្វើគំរូតាមឱ្យងាយយល់ ដើម្បីបង្ហាញឱ្យឃើញច្បាស់ពីកំហុស និងធាតុពិតរបស់អ្នកក្រ ហើយបើកបង្ហាញពីវិធីលើកកម្ពស់ឋានៈខ្លួនឯងពីអ្នកក្រឱ្យក្លាយទៅជាអ្នកមាន។ បើបានអាន ហើយចាប់ផ្ដើមផ្លាស់ប្ដូរនូវព្រឹត្តិកម្ម អានដដែលៗ ធ្វើដដែលៗ រាល់ថ្ងៃ ធានាបានថា ការរស់នៅនិងស្ថានភាពប្រាក់កាក់របស់អ្នកនឹងល្អប្រសើរឡើងជាលំដាប់។ ជីវិតនឹងល្អប្រសើរឡើងជាលំដាប់ **«មិនត្រឡប់ទៅក្រ»** វិញជាដាច់ខាត។

GUGU គូគូ

# មាតិការឿង

## ជំពូកទី ១ ស័ក្យអំពី ចំណុចខ្សោយរបស់អ្នកក្រ


១. អ្នកក្រតែងតែគិតនិងនិយាយពីចំណុចខ្សោយរបស់ខ្លួន............៣
២. ប្រាក់របស់អ្នកក្រ....................................................... ៦
៣. អ្នកក្រស្រលាញ់កិត្តិយសខ្លាំងពេក ................................... ៩
៤. អ្នកក្រច្រើនតែលោភលន់ ............................................ ១២
៥. អ្នកក្រច្រើនតែច្រឡោតតោតតូង...................................១៥
៦. អ្នកក្រតែងព្រងើយកន្តើយចំពោះកិរិយាមារយាទនៅក្នុងសង្គម ....១៨
៧. អ្នកក្រតែងតែធ្វើអ្វីដែលហួសហេតុ................................. ២១
៨. អ្នកក្រចង់ក្លាយជាសេដ្ឋីថ្មី ...........................................២៤
៩. អ្នកក្ររាងចាលនឹងភាពក្រីក្រ....................................... ២៧
១០. អ្នកក្រតែងតែពាក់មាសពេជ្របង្អួតគ្នា............................. ២០
១១. អ្នកក្រតែងតែលើកតម្កើងខ្លួនឯង និងបង្អាប់អ្នកដទៃ ..........៣៣
១២. អ្នកក្រមិនចេះសន្សំសំចៃ ........................................... ៣៦
១៣. នាមបណ្ណរបស់អ្នកក្រ................................................. ៣៩
១៤. អ្នកក្រចង់ធ្វើជាបងធំ ................................................៤២
១៥. អ្នកក្រពេលមានបានហើយ នឹងផ្តាច់ខ្លួនពីអតីតកាល...........៤៥
១៦. អាហារបំប៉នរបស់អ្នកក្រ ............................................៤៨
១៧. អ្នកក្រញៀនមើលទូរទស្សន៍..........................................៥១
១៨. អ្នកក្រមានសាច់ញាតិច្រើន ..........................................៥៤
១៩. អ្នកក្រជជែកគ្នាបែកពពុះមាត់ ....................................... ៥៧

២០. អ្នកក្របណ្តាក់ទុនរឿងអំណោយ ................................................. ៦០
២១. អ្នកក្រប៉ាវបាយ អ្នកក្រខ្លួនឯងច្រើនតែមិនឆ្លែត ................. ៦៣
២២. អ្នកក្រគិតតែពីរឿងសងសឹក ..................................................... ៦៦
២៣. អ្នកក្រចាយវាយដូច «អ្នកដែលមានប្រាក់ខែខ្ពស់» .............. ៦៩
២៤. រៀបការជាមួយអ្នកក្រ ............................................................. ៧២

## ជំពូកទី ២ សិក្សាអំពី ស្ថានភាពរបស់អ្នកក្រ

២៥. អ្នកក្រគឺជាគ្រោះរបស់សង្គម ............................................... ៧៦
២៦. អ្នកក្រគឺជាធនធានរបស់ប្រទេសជាតិ ...................................... ៩៧
២៧. គុណដ៏ច្រើនលើសលុបរបស់អ្នកក្រ ......................................... ៨២
២៨. អ្នកក្រត្រូវគេគ្រប់គ្រង ............................................................ ៨៥
២៩. អ្នកក្រតែងតែគិតមិនបានវែងឆ្ងាយ ....................................... ៨៨
៣០. អ្នកក្រមានដើមទុនតិច តែមានហានិភ័យខ្ពស់.......................... ៩១
៣១. អ្នកក្រតែងតែបានទីតាំងមិនល្អ................................................ ៩៤
៣២. អ្នកក្រគឺជាអ្នកទន់ខ្សោយជានិច្ច............................................. ៩៧
៣៣. អ្នកក្រមានការសិក្សាទាប ...................................................... ១០០
៣៤. អ្នកក្រមានជីវិតដែលគ្មានសុវត្ថិភាព ................................... ១០៣
៣៥. អ្នកក្រងាយនឹងត្រូវគេបោកប្រាស់ណាស់ ............................ ១០៦
៣៦. អ្នកក្រធ្វើការមិនបានសម្រាក .............................................. ១០៩
៣៧. តើអ្នកក្រនឹងទិញរបស់ដែលថ្លៃៗបានយ៉ាងដូចម្តេចទៅ ? .. ១១២
៣៨. អ្នកក្រមិនអាចឈឺបានទេ ..................................................... ១១៥
៣៩. អ្នកក្រមិនមានសមត្ថភាពប្តឹងតវ៉ារឿងក្តីទេ ......................... ១១៨

៤០. អ្នកក្រត្រូវទទួលរងកម្មពីពួកពុករលួយ ............................ ១២១
៤១. អ្នកក្រចាំមានតាមក្រោយ ............................ ១២៤
៤២. អ្នកក្រចង់បានភាពរីកចម្រើន ............................ ១២៧
៤៣. អ្នកក្រមួយថ្ងៃៗគិតតែពីស្រមើស្រមៃ ............................ ១៣០
៤៤. អ្នកក្រចេះជួយអ្នកក្រដូចគ្នា ............................ ១៣៣
៤៥. ព្រះជាម្ចាស់បោះបង់ចោលអ្នកក្រ ............................ ១៣៦

## ជំពូកទី ៣ សិក្សាអំពី ទស្សនៈរបស់អ្នកក្រ

៤៦. អ្នកក្រចាប់អារម្មណ៍តែពីរឿងប្រាក់ ............................ ១៤០
៤៧. អ្នកក្រតែងតែមើលមិនបានវែងឆ្ងាយ ............................ ១៤៣
៤៨. អ្នកក្រខ្វះខាតគ្រប់យ៉ាងថែមទាំងអស់សង្ឃឹមទៀតផង ...... ១៤៦
៤៩. អ្នកក្រខ្លាចការប្រថុយ ............................ ១៤៩
៥០. អ្នកក្រប្រៀបដូចជាក្បាលឡេាស៊ីមួយ ............................ ១៥២
៥១. អ្នកក្រខ្លាចបាត់បង់ការងារ ............................ ១៥៥
៥២. អ្នកក្រលិចលង់នៅក្នុងសង្គមរបស់អ្នកក្រ ............................ ១៥៨
៥៣. ឱ្យគេជួយរុញពីក្រោយរមែងដើរមិនបានឆ្ងាយ ............................ ១៦១
៥៤. អ្នកក្រផ្ញើជីវិតលើអង្គភាព ............................ ១៦៤
៥៥. អ្នកក្ររំពឹងតែប្រាក់ខែ ............................ ១៦៧
៥៦. អ្នកក្រពូកែបារម្ភ ............................ ១៧០
៥៧. អ្នកក្រខ្លាចនេះខ្លាចនោះជានិច្ច ............................ ១៧៣
៥៨. អ្នកក្របានត្រឹមតែជួយសាងអំណាច ............................ ១៧៦
៥៩. អ្នកក្រតែងតែទិញឆ្នោត ............................ ១៧៩

៦០. អ្នកក្រផ្តល់ភាពសំខាន់ចំពោះសិល្បៈនិងវិជ្ជាជីវៈ ............ ១៨២
៦១. អ្នកក្រត្រូវបានគេជ្រើសរើស ............................ ១៨៥
៦២. អ្នកក្រស្រមៃចង់ក្លាយជាតារា ............................ ១៨៨
៦៣. ការវិនិយោគទុនរបស់អ្នកក្រ ............................ ១៩១
៦៤. អ្នកក្រមិនចេះរៀបចំគម្រោង ............................ ១៩៤
៦៥. អ្នកក្រតែងតែអាងលើវាសនា ............................ ១៩៧
៦៦. អ្នកក្រចូលចិត្តលេងល្បែងភ្នាល់គ្នា ............................ ២០០
៦៧. អ្នកក្រចង់រកប្រាក់ឱ្យបានច្រើន ............................ ២០៣
៦៨.កូនអ្នកក្រចាប់ផ្តើមឃើត ............................ ២០៦
៦៩. អ្នកក្រស្រមើស្រមៃខ្ពស់ហួសមាឌ ............................ ២០៩
៧០. អ្នកក្រតែងតែជឿអ្នកធំ ............................ ២១២
៧១. ប្រាក់របស់អ្នកក្រមិនមែនជាប្រាក់ដើមទុនទេ ............ ២១៥
៧២. ពេលវេលារបស់អ្នកក្រគ្មានតម្លៃ ............................ ២១៨
៧៣. អ្នកក្រស្អប់ភាពមិនស្មើភាពគ្នា ............................ ២២១

## ជំពូកទី ៤ សិក្សាអំពី វិធីយកឈ្នះភាពក្រីក្រ

៧៤. អ្នកគឺជាអ្នកក្រ តើអ្នកខ្លាចអ្វីទៅ? ............................ ១២៥
៧៥. អ្នកក្រត្រូវមានគំនិត ............................ ២២៨
៧៦. អ្នកក្រត្រូវតែមានមហិច្ឆតា ............................ ២៣១
៧៧. អ្នកក្រត្រូវតស៊ូ ............................ ២៣៤
៧៨. អ្នកក្រត្រូវតែមានកម្លាំងជំរុញដើម្បីឱ្យផ្លាស់ប្តូរជីវិត ......... ២៣៧
៧៩. អ្នកក្រត្រូវតែហ៊ានទទួលស្គាល់ការពិត ............................ ២៤០

៨០. អ្នកក្រត្រូវរកមុខរបរជំជុំ.....................................................២៤៣
៨១. អ្នកក្រត្រូវតែលេងអ៊ិនធើណែត ...............................................២៤៦
៨២. អ្នកក្រត្រូវអត់ធ្មត់ ...................................................................២៤៩
៨៣. បណ្តាក់ទុនជាមួយអ្វីដែលខ្លួនជំនាញគឺល្អបំផុត..............................២៥២
៨៤. ចង់ក្លាយជាអ្នកមានត្រូវមានគុណសម្បត្តិគ្រប់យ៉ាង .........................១៥៥
៨៥. ការសិក្សាអាចផ្លាស់ប្តូរជីវិតបាន ...................................................២៥៨
៨៦. ចូរធ្វើការងារមួយៗរហូតដល់ជំនាញ.............................................២៦១
៨៧. ការព្យាយាមគឺជាជ័យជម្នះ .........................................................២៦៤
៨៨. អ្នកក្រត្រូវហ៊ានធ្វើកិច្ចការធំ .......................................................២៦៧
៨៩. អ្នកក្រត្រូវតែហ៊ានប្រឈមមុខនឹងអ្នកមាន......................................២៧០
៩០. អ្នកក្រត្រូវមានចំណេះដឹងជាអាវុធ ...............................................២៧៣
៩១. ផ្តល់ភាពសំខាន់លើឯកសារកិច្ចសន្យា..........................................២៧៦
៩២. គួរតែសាងគ្រួសារឱ្យបានគង់វង្ស ................................................២៧៩
៩៣. អ្នកក្រត្រូវធ្វើតាមបក្សីផ្លាស់លំនៅ...............................................២៨២
៩៤. ទោះយ៉ាងណា អ្នកក្រក៏ត្រូវតែពឹងប្រាក់ដែរ....................................២៨៥
៩៥. ចូរស្រឡាញ់ប្រាក់ឱ្យដូចស្រឡាញ់ខ្លួនឯង.......................................២៨៨
៩៦. អ្នកក្រកុំធ្វើខ្លួនឱ្យដូចជាអ្នកក្រ ...................................................២៩១
៩៧. អ្នកក្រមិនចាំបាច់ដឹងគុណអ្នកមានច្រើនពេកទេ ............................២៩៤
៩៨. កុំឱ្យគេមកបោកប្រាស់យើងបាន ...............................................២៩៧
៩៩. អ្នកក្រមិនគួរចំណាយរហូតអស់ពីខ្លួនទេ ......................................៣០០
១០០. អ្នកក្រមិនគួរដើរផ្លូវខុសទេ .....................................................៣៣៣

កូនខ្មែរ
បើតាំងចិត្តធ្វើអ្វី
មិនចាញ់សាសន៍ដទៃលើលោក!

# ជំពូកទី ១

សិក្សាអំពី

# ចំណុចខ្សោយរបស់អ្នកក្រ


ផ្ទះខ្ញុំនៅលើភ្នំដាច់ស្រយាល
ខ្វះខាតយ៉ាងខ្លាំងនៅលើលោកនេះ
រៀនអាន និងសរសេរជាមួយគ្រូនៅលើភ្នំ
ក ខ គ
មានតិចហូបមិនសូវឆ្អែត
មុខមាត់អាក្រក់បំផុត បើឪពុកម្តាយបង្កើតមកឱ្យមានមុខមាត់បែបនេះ
ខ្ញុំមិនឈ្នះចៅកែទេ ទាំងវង្សត្រកូល ទាំងចំណេះដឹង ទាំងអាយុ ថែមទាំងមានក្បាលភ្លឺរលោងទៀតផង បង្ហាញពីភាព ពូកែនិងឆ្លាតបំផុត...លោកលើសខ្ញុំគ្រប់យ៉ាង

# ១

## អ្នកក្រតែងតែគិត និងនិយាយពីចំណុចខ្សោយរបស់ខ្លួន

ពេលដែលអ្នកក្រប្រៀបធៀបខ្លួនឯងជាមួយនឹងអ្នកមាន តែងតែយកចំណុចខ្សោយរបស់ខ្លួន ទៅប្រៀបធៀបជាមួយនឹងចំណុចពិសេសរបស់អ្នកមាន ដូចជា អ្នកក្រតែងតែគិតថា «ខ្ញុំមិនស្អាតដូចគេ» «ខ្ញុំមិនបានកើតលើគំនរមាសគំនរប្រាក់» ឬ «ខ្ញុំកើតនៅជនបទដាច់ស្រយាល» ... កាន់តែប្រៀបធៀបកាន់តែបាត់បង់កម្លាំងចិត្ត រហូតដល់មិនចង់ប្រៀបធៀបតទៅទៀត។

តែអ្នកមានគេគិតផ្ទុយពីនេះ ព្រោះពេលដែលមានប្រាក់នឹងមានភាពជឿជាក់ និងព្រមទទួលស្គាល់នូវចំណុចខ្សោយរបស់ខ្លួនឯង។ គេតែងតែគិតថា «ទោះបីជាខ្ញុំមានមុខមាត់អាក្រក់ តែខ្ញុំជាមនុស្សសុភាពរាបសាទន់ភ្លន់ និងគួរឱ្យស្រលាញ់»។

*តើឃើញឬទេថា អ្នកមានគេនឹងបង្ហាញពីចំណុចពិសេសរបស់គេចេញមកដោយវិធីដូច្នេះ។*

ជាទូទៅ អ្នកក្រព្រមទទួលនូវចំណុចខ្សោយនោះ ដើម្បីរកលេសឱ្យភាពក្រីក្ររបស់ខ្លួន។ ចំណែកអ្នកមានវិញព្រមទទួលនូវចំណុចខ្សោយដែលខ្លួនមាន ដើម្បីបង្ហាញពីថាមពលដ៏អស្ចារ្យដែលនៅខាងក្នុង ហើយ

ពិសោធឱ្យគេឃើញថាអាច «យកឈ្នះចំណុចខ្សោយបាន» រហូតដល់មានដូចសព្វថ្ងៃនេះ។

*ដូច្នេះ ការបង្ហាញចំណុចខ្សោយរបស់អ្នកក្រ ត្រូវបានគេវាយសេចក្តីទូទៅថា បង្ហាញមកដើម្បីធ្វើឱ្យអ្នកដទៃយល់ចិត្តយល់ថ្លើម។ ឯចំណែកចំណុចខ្សោយរបស់អ្នកមាន ធ្វើឱ្យគ្រប់យ៉ាងត្រូវគេវាយសេចក្តីទៅក្នុងផ្លូវដែលល្អទាំងអស់។*

ឧទាហរណ៍ដូចជា បើអ្នកមានគេមានក្បាលទំពែក មនុស្សទូទៅតែងតែយល់ថា ក្បាលដែលភ្លឺរលោងនោះបានបញ្ចេញរស្មីនៃបញ្ញា ប៉ុន្តែបើអ្នកក្រមានក្បាលទំពែកវិញនោះ គេបែរជាមើលឃើញថា ខ្វះសារជាតិអាហារ ចាស់មុនអាយុ ឬរលាកស្បែកក្បាលជាដើម។

ទោះជា អ្នកមាននិងអ្នកក្រ មានចំណុចខ្សោយដូចគ្នាបេះបិទក៏ដោយ តែខ្សែភ្នែករបស់អ្នកដទៃដែលសម្លឹងមកនោះខុសគ្នាស្រឡះ។ អ្នកមានអាចធ្វើឱ្យអ្នកដទៃព្រមទទួលស្គាល់បានសូម្បីតែនៅស្ងៀមៗ ឯអ្នកក្រវិញ បើទោះបីជាខំប្រឹងនិយាយរហូតដល់បែកពពុះមាត់ ក៏បានត្រឹមតែគេមើលងាយប៉ុណ្ណោះ។

ប៉ុន្តែ ការដែលអ្នកមានអួតក្អេងក្អាងនោះ យើងបន្ទោសគេតែម្ខាងក៏មិនបានដែរ នោះដោយសារតែអ្នកក្រមិនជឿជាក់លើខ្លួនឯង មើលស្រាលខ្លួនឯង ទើបធ្វើឱ្យមនុស្សភាគច្រើន ឬសូម្បីតែខ្លួនឯង ក៏កោតសរសើរពីគំនិតរបស់អ្នកមានដែរ ថែមទាំងជឿទាំងងងឹតងងុលទៅតាមសង្គមទៀតផង។


មិនឱ្យឡើងទេ
ចៀសចេញមើល
ទៅឱ្យឆ្ងាយទៅ!
ទឹកដីសេដ្ឋី
នរកឱ្យច្បាស់ក្រឡែត
ប្រាក់ក្លែងក្លាយ
សន្សំប្រាក់បានច្រើនពេលណា ខ្ញុំនឹងទិញផ្ទះ ទិញឡាន សងសឹកពួកដែលតាបសង្កត់អ្នកស្រែវិញម្តង

# ២

## ប្រាក់របស់អ្នកក្រ

អ្នកក្រតែងតែគិតថា «ភាពលំបាកគឺការមិនមានប្រាក់» ដូច្នេះបើមានប្រាក់ពេលណា នឹងយកទៅបណ្តាក់ទុនដើម្បីរកកម្រៃ។ ពេលដែលបានកម្រៃហើយនឹងមាន បានក្លាយទៅជាថៅកែសមដូចបំណង អង្គុយគងអន្ទាក់ខ្លាចាំចង្កុល និងចាំគាបសង្កត់គេវិញម្តង។

បើចង់ប្រាប់ថា «អ្នកក្រមិនមានប្រាក់» ក៏មិនខុសអ្វីដែរ។ ព្រោះមានប្រាក់ចំណូលតែបន្តិចបន្តួចក្នុងមួយខែៗ ល្មមនឹងចម្អែតក្រពះ ចិញ្ចឹមខ្លួនឯង ចិញ្ចឹមឪពុកម្តាយ ចិញ្ចឹមកូនៗ ថែមទាំងត្រូវបង់ពន្ធនៅក្នុងសង្គមទៀត គ្មានប្រាក់នៅសល់ទេ។

តែបើប្រាប់ថា «អ្នកក្រមានប្រាក់» ក៏មិនខុសដែរ។ ព្រោះជាច្រើនលើកច្រើនសា ពេលដែលមានការប្រមូលទុន ទិញសញ្ញាបណ្ណដែលផ្តល់ការប្រាក់ ៣០% ក្នុងមួយឆ្នាំនោះ អ្នកក្រតែងតែប្រមូលប្រាក់មកពីគ្រប់ទិសទីដើម្បីយកទៅទិញសញ្ញាបណ្ណនោះព្រោះខ្លាចអស់។

ជាច្រើនឆ្នាំកន្លងមកហើយ នៅក្នុងប្រទេសចិនមានការបោកបញ្ឆោតប្រមូលដើមទុនដ៏ធំមួយ បោករហូតដល់រលំរលាយអស់គ្មានសល់។ នៅទីបំផុត អ្នកដែលបណ្តាក់ទុនមិនបានអ្វីត្រឡប់មកវិញឡើយ

សូម្បីតែប្រាក់ដើមទុន។ ទើបអ្នកសេដ្ឋកិច្ចចេញមកនិយាយថា «ហេតុអ្វីបានជាពួកអ្នកទាំងអស់គ្នាល្ងង់បែបនេះ តើនរណាមកឱ្យផលកម្រៃដល់ទៅ ៣០% ដោយងាយៗ ថែមទាំងប្រាប់ថានឹងសងប្រាក់ដើមទុនឱ្យវិញទៀតនោះ បើមាននោះគឺជាធុរកិច្ចប្រភេទយកប្រាក់របស់យើងទិញទំនិញរបស់យើងនោះឯង»។ តាមពិតទៅ អ្នកប្រមូលដើមទុននោះ គឺមិនបានបោកយកប្រាក់របស់អ្នកទៅទាំងអស់ទេ សុំត្រឹមតែ ៧០% នៃប្រាក់ដែលអ្នកឱ្យទៅគឺគ្រប់គ្រាន់ហើយ។ ចំណែកដែលនៅសល់ ៣០% ទៀត គេនឹងសងឱ្យអ្នកវិញភ្លាម ដោយប្រាប់ថា ជាការប្រាក់ក្នុងឆ្នាំដំបូង គ្រាន់តែប៉ុណ្ណេះអ្នកពេញចិត្ត ថែមទាំងអរគុណគេជាខ្លាំងទៀតផង ដោយមិនដឹងទេថា ពួកបោកប្រាស់ទាំងនេះមានពេលរត់គេចយ៉ាងតិចណាស់ ៣៦៥ ថ្ងៃ យូរល្មមនឹងអាចឱ្យគេគេចខ្លួនបានយ៉ាងសប្បាយ។

*បម្រាមមួយចំណុចរបស់ការធ្វើធុរកិច្ចគឺ* មិនគួរយល់ព្រមធ្វើធុរកិច្ចដោយនៅមិនទាន់ស្គាល់ភាគីម្ខាងទៀតបានច្បាស់លាស់ ឬក្នុងពេលដែលយើងមិនអាចគ្រប់គ្រងស្ថានការណ៍ដោយខ្លួនឯងបាននោះទេ។ បើអ្នកព្រមបណ្ដាក់ទុនធ្វើធុរកិច្ចក្នុងលក្ខណៈបែបនេះ ទីបំផុត ប្រាកដជាមានបញ្ហាកើតឡើងជាមិនខាន។


មិនព្រម
ឱនក្បាល
សុម្បីតែ
ខ្លួនខ្ពស់
ហួសដំបូលផ្ទះ
កំដោយ
ខ្ញុំមិនចៀសចេញទេ!
គ្មានផ្លូវដែលខ្ញុំត្រូវចៀសទេ!
នរណាប្រើឱ្យមកជួយ?
ទោះស្លាប់ក៏ត្រូវមានកិត្តិយសដែរ!

# ៣

## អ្នកក្រស្រលាញ់កិត្តិយសខ្លាំងពេក

អ្នកក្រដែលស្រលាញ់កិត្តិយស តែងតែប្រៀបធៀបខ្លួនឯងជាមួយនឹង «ថៅយួនមិង» កវីឯកសម័យរាជវង្សតុងជិន ជាជនដែលស្រលាញ់កិត្តិយស ព្រមលាចេញពីតំណែងចៅហ្វាយស្រុកដោយមិនសោកស្ដាយបុណ្យសក្តិឡើយ។ ប៉ុន្តែ អ្នកក្រភ្លេចថា ថៅយួនមិង មានដីស្រែជាច្រើនហិកតា ថ្វីត្បិតតែមិនសូវសម្បូរមាសប្រាក់កែវកង ប៉ុន្តែរឿងក្រពះមិនបាច់បារម្ភឡើយ។ គាត់លាឈប់ពីការងាររាជការ មិនមែនព្រោះតែទ្រាំមើលភាពអាម៉ាស់នៅក្នុងរាជការមិនបាននោះទេ ប៉ុន្តែ គាត់ត្រូវការរស់នៅស្ងប់ស្ងាត់ ធ្វើជាកវី អង្គុយក្រេបស្រា មើលទេសភាពយ៉ាងសប្បាយចិត្តនៅស្រុកកំណើតច្រើនជាង។ ឃើញថា អ្នកក្រចូលចិត្តប្រៀបធៀបខ្លួនឯងជាមួយនឹងអ្នកដទៃដោយវិនិច្ឆ័យពីសំបកខាងក្រៅ ដោយមិនវិភាគឱ្យបានស៊ីជម្រៅ។

ប៉ុន្តែ អ្នកក្រដែលមិនគិតពីកិត្តិយស ព្រោះមិនចង់អត់ឃ្លានស្លាប់ ព្រមឱនក្បាលឱ្យ «ប្រាក់» ហើយយល់ថាពេលដែលក្រលំបាក កិត្តិយសស៊ីមិនបានទេនោះក៏ហួសហេតុពេកដែរ។

តាមពិតនោះ មុខមាត់នៅក្នុងសង្គមក៏ធ្វើឱ្យមនុស្សយើងរស់នៅបានរលូនដែរ។ ជាធម្មតា អ្នកមានគេមានវាស្រាប់ទៅហើយ ចំណែកអ្នកក្រមានកិត្តិយសជាទីពឹងខាងផ្លូវចិត្ត តែជាច្រើនលើកច្រើនសាក៏ប្រកាន់ខ្ជាប់

កិត្តិយសខ្លាំងហួសហេតុពេក រហូតមិនហ៊ានចេញធ្វើអ្វីដែលជាប្រយោជន៍ដែរ។

ដូចជា «អាឃីវ» តួនៅក្នុងប្រឡោមលោកចិនដ៏ល្បីមួយរឿង ទោះបីជាជិតដល់ពេលត្រូវប្រហារជីវិតហើយ ក៏នៅតែច្រៀងចម្រៀងសំឡេងខ្លាំងៗតាមដងផ្លូវដែរ ដោយខ្សែភ្នែកសម្លឹងរកមើល «អ៊ូម៉ា» គូស្នេហ៍របស់គេនៅក្នុងហ្វូងមហាជន។ គេគិតតែម្នាក់ឯងថាខ្លួនជាបុគ្គលសំខាន់ គឺជាអ្នកតំណាងជនជាតិចិនដែលត្រូវបានគេគាបសង្កត់ ប៉ុន្តែកិត្តិយសបែបនេះ មើលទៅដូចជាមិនសមទំនង ព្រោះតាមពិតទៅ គេជាមនុស្សដែលគ្មានបក្ស បក្សកុម្មុយនីស្តចិនមិនចាប់អារម្មណ៍នឹងគេទេ ហើយនាង អ៊ូម៉ា ទៀតសោត ក៏មិនយល់ពីចិត្តរបស់គេដែរ។ នៅទីបំផុត អាឃីវ បានត្រឹមតែមោទនភាពចំពោះកិត្តិយសរបស់ខ្លួនតែម្នាក់ឯង។

ភាពស្មោះត្រង់ក៏ដូចគ្នានេះដែរ។ អ្នកខ្លះ «ស្មោះត្រង់ដោយភាពឈ្លាសវៃ» ទើបមានមនុស្សក្រាបសំពះទុកជាបុព្វបុរស តែអ្នកខ្លះបែរជា «ស្មោះត្រង់ទាំងងងឹតងងុល» រហូតដល់អ្នកដទៃសើចចំអក ហើយអ្នកក្រភាគច្រើនរមែងស្ថិតនៅក្នុងប្រភេទក្រោយនេះឯង។

ការបោះបង់ចោលកិត្តិយសមិនមែនជារឿងងាយទេ តែក៏មិនមែនជារឿងលំបាកដែរ។ អ្នកមិនចាំបាច់ផ្លាស់ប្តូរទង្វើអ្វីច្រើនទេ គ្រាន់តែផ្លាស់ប្តូរគំនិតគឺគ្រប់គ្រាន់ហើយ។



ពេលក្រហូបមិនឆ្អែត
ពេលមានហើយហូបឱ្យចាស់ដៃតែម្តង
ពេលក្រគ្មានអាវធំពាក់
ពេលមានហើយពាក់ទៅ!
ពេលក្រនៅផ្ទះជួល
ពេលមានហើយនៅក្នុងគេហដ្ឋានដ៏ស្កុកស្កុះ
ពេលក្រមិនបានសោយសុខ
តែពេលដែលក្រ
លោកមិនដែល
បាត់បង់
សេរីភាព
ដូច្នេះទេ

# ៤

## អ្នកក្រច្រើនតែលោភលន់

មន្ត្រីរាជការពុករលួយមានស្ទើរគ្រប់ប្រទេស។ នៅពេលដែលគេសើរើប្រវត្តិរបស់ពួកគេទាំងនោះ យកទៅកាត់ទោសដើម្បីធ្វើជាឧទាហរណ៍នោះ ការពិតក៏បានបង្ហាញឡើង។ ដូចជា នៅក្នុងប្រទេសចិនមន្ត្រីរាជការដែលពុករលួយទាំងនេះមានដើមកំណើតជាអ្នកក្រ ហើយអ្វីដែលចម្លែកនោះគឺថា ពួកគេបែរជាកំណាញ់ស្វិត មិនព្រមចាយប្រាក់ដែលកេងប្រវ័ញ្ចបាននោះទៅវិញ។

អ្នកក្រស្ដាប់ហើយប្រហែលជាមិនជឿទេ។ អ្នកក្រកើតមក ព្រមជាមួយនឹងភាពលំបាកវេទនា ទើបត្រូវអប់រំឱ្យអត់ធ្មត់ កាន់តែក្រកាន់តែត្រូវអត់ធ្មត់ តស៊ូពុះពារគ្រប់បែបយ៉ាង។ អ្នកដែលទទួលបានជោគជ័យចាត់ទុកថាជាមនុស្សដែលរឹងប៉ឹងបំផុត។

អ្នកក្រមានរឿងលាក់ទុកនៅក្នុងចិត្តជាច្រើន ប្រៀបដូចជារ៉ុស័រដែលយើងសង្កត់វាទុក បើយើងលែងវាពេលណានោះ រ៉ុស័រនោះនឹងធាក់ឡើងយ៉ាងខ្លាំងគួរឱ្យខ្លាច។

ពេលដែលមនុស្សយើងក្រយូរៗទៅ កាន់តែខ្លាចភាពខ្វះខាត។ ដូច្នេះ ការលោភលន់ដែលបង្កប់នៅក្នុងអឌ្ឍសម្បជញ្ញៈ គឺប្រៀបដូចជា

គ្រាប់ពូជដែលកប់នៅក្នុងដី មានទឹកស្រោចពេលណា (មានឱកាស) នឹងដុះចេញជាផ្លែផ្កាភ្លាម ដែលនោះគេហៅថាជាភាពលោភលន់ដែលមិនអាចទប់ទាំបាន។

ដូច្នេះ បើយើងចង់យកឈ្នះការចង់មានចង់បាន មិនគួរដើរផ្លូវកាត់ ដូចជា កេងប្រវ័ញ្ចគេទេ តែត្រូវសុចរិត រកស៊ីទៅតាមលទ្ធភាព «ធ្វើការងារប្តូរយកប្រាក់» ហើយបើចង់លើកកម្ពស់នូវឋានៈឱ្យមានគ្រប់យ៉ាងរហូតដល់គេកោតសរសើរនោះត្រូវប្រឹងប្រែងឱ្យបានខ្លាំងឡើង។


ថយចេញទៅ
ហ្គក!
សងប្រាក់ខែខ្ញុំមក
ប្រាក់ខែមិនប៉ុន្មានរៀល ហេតុអ្វីក៏ក្រៃផ្សេងដល់ថ្នាក់នេះ?
បងមកកាត់ប្រាក់យើងធ្វើអ្វី?

# ៥

## អ្នកក្រច្រើនតែច្រឡោតគោតតួង

បើប្រៀបធៀបអ្នកក្រជាមួយអ្នកមាននោះ តើនរណាបានទទួលការអប់រំច្រើនជាង? តើនរណាមានកម្រិតវប្បធម៌ច្រើនជាង?

អ្នកក្រគួរឱ្យអាណិត និងគួរឱ្យយល់ចិត្តខ្លាំងណាស់។ ភាពក្រីក្រនាំឱ្យខ្វះការអប់រំពីសាលារៀន ខ្វះការអប់រំពីសាលារៀននាំឱ្យខ្វះសតិបញ្ញា ខ្វះសតិបញ្ញានាំឱ្យខ្វះគុណធម៌។ ប្រាកដណាស់ថា អ្នកក្រមិនចង់ក្លាយទៅជាដូច្នេះទេ តែមនុស្សតែងតែទាញយកភាពក្រីក្រ ភាពល្ងង់ខ្លៅ និងអំពើព្រៃផ្សៃបញ្ចូលគ្នា។ បើនិយាយទៅអ្នកក្រក៏ «ទទួលរងនូវអំពើអយុត្តិធម៌» មិនតិចដែរ។ ប៉ុន្តែជាច្រើនលើកច្រើនសា យើងតែងតែឃើញហេតុការណ៍ដ៏សាហាវកើតឡើងនោះ គឺជាផលដែលបានមកពីភាពក្រីក្រនេះឯង។

ពាក្យដែលគេនិយាយថា «មានតែគ្មានគុណធម៌» នោះមានមកជាយូរហើយ ដែលបានបង្ហាញថាបាបរបស់អ្នកមានក៏ច្រើនដែរ។ ប៉ុន្តែបើអ្នកថ្លឹងថ្លែង រវាងអ្នកមាននិងអ្នកក្រ នឹងឃើញថា «ភាពកាចសាហាវរបស់អ្នកក្រ» មានច្រើនប្រការណាស់ ដូចអ្នកសេដ្ឋសាស្ត្របានលើកឡើងថា «ការគ្មានលុយជាប្រភពនៃអំពើអាក្រក់» តែការមានលុយក៏ជាប្រភពនៃអំពើអាក្រក់បានដែរ។

យើងត្រូវជួយអ្នកក្រ តែអ្វីដែលយើងត្រូវការនោះ មិនមែនឱ្យអ្នកក្រមកជំនួសកន្លែងអ្នកមានទេ តែជាការលើកកម្ពស់ជីវិតមនុស្សនៅក្នុងសង្គម ដោយមិនបាច់ទៅផ្តួលរំលំ ឬបំផ្លាញនរណាឬជាន់នរណាពន្លិចទៅក្នុងដីឡើយ ព្រោះចន្លោះរវាងអ្នកមាន និងអ្នកក្រពិតជាគ្មានថ្ងៃស្មើសូន្យបានទេ ប៉ុន្តែយើងអាចធ្វើឱ្យអ្នកមាន និងអ្នកក្រនៅជាមួយគ្នាប្រកបដោយសន្តិភាពនៅក្នុងសង្គម និងលើកកម្ពស់ជីវិតរបស់មនុស្សឱ្យល្អប្រសើរឡើងបាន។




បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.

# ៦

## អ្នកក្រតែងព្រងើយកន្តើយចំពោះកិរិយាមារយាទនៅក្នុងសង្គម

តាមពិត សតិបញ្ញានិងកម្លាំងរបស់មនុស្ស មិនខុសគ្នាខ្លាំងទេ មនុស្សម្នាក់អាចធ្វើរឿងមួយបាន មនុស្សម្នាក់ទៀតក៏អាចធ្វើបានដូចគ្នាដែរ។ តែលទ្ធផលដែលទទួលបានខុសគ្នា ព្រោះកិរិយាមារយាទ ដែលឆ្លុះបញ្ចាំងពីធាតុពិតរបស់មនុស្សម្នាក់ៗនោះឯង។

ជាទូទៅ អ្នកក្រមិនសូវផ្ចិតផ្ចង់ចំពោះរឿង «កិរិយាមារយាទ» ទេ អាចដោយសារតែមានចំណេះដឹងតិច មិនសូវបានចូលក្នុងសង្គមនឹងគេ ឬបរិបទដែលអប់រំមក។ អ្នកក្រតែងលួងលោមចិត្តខ្លួនឯង និងព្យាយាមធ្វើឱ្យអ្នកដទៃជឿជាក់លើខ្លួន ដើម្បីបិទបាំងកិរិយាមារយាទមួយចំនួន ដូចជាភាពច្រឡោត និងការមិនសុភាពជាដើម។

អ្នកក្រជឿថា សមត្ថភាពដែលជាការចេះដឹងពិតប្រាកដទៅវិញទេ ដែលជាអាវុធក្នុងការរស់នៅ ចំណែកឯរឿងផ្សេងៗគ្រាន់តែរឿងតូចតាចប៉ុណ្ណោះ មិនបាច់ផ្តល់ភាពសំខាន់ក៏បានដែរ។

អ្នកខ្លះមានឫកពាល្អ ទោះជាមិននិយាយអ្វីក៏ធ្វើឱ្យអ្នកដទៃគេគោរពកោតក្រែងបានដែរ។ ប៉ុន្តែ អ្នកខ្លះនិយាយរហូតដល់បែកពពុះមាត់ អ្នកស្តាប់បែរជាងឿងឆ្ងល់ទៅវិញ។

ជាសច្ចៈ ក្នុងសង្គមបច្ចុប្បន្ននេះ «បុគ្គលិកលក្ខណៈនិងកិរិយាមារយាទដែលសមរម្យ» ចាត់ទុកថាជាអាវុធដ៏សំខាន់ ព្រោះធ្វើឱ្យអ្នកដទៃដែលបានជួបខ្លួននោះពេញចិត្ត និងធ្វើឱ្យខ្លួនបានទទួលនូវឱកាសល្អៗផងដែរ។

គុណសម្បត្តិរបស់មនុស្សយើងមានជាច្រើនប្រភេទ ដូចជា គំនិតបុគ្គលិកលក្ខណៈ ការអប់រំ បទពិសោធ គុណធម៌ និងចរិយាធម៌ ។ល។ ចំណែកគុណវិបត្តិរបស់មនុស្សយើងវិញក៏មានជាច្រើនប្រភេទដែរ ដូចជា មិនចេះប្រើគំនិត បុគ្គលិកលក្ខណៈមិនល្អ គ្មានការអប់រំ គ្មានបទពិសោធ គ្មានគុណធម៌និងចរិយាធម៌ និយាយខ្វះសីលធម៌ ។ល។ និង ។ល។ ដែលអាចឃើញបានភ្លាម នៅពេលដែលមនុស្សយើងប្រាស្រ័យទាក់ទងគ្នាដោយមិនអាចក្លែងបន្លំភ្នែកអ្នកដទៃបានឡើយ។ ជាការពិត អ្វីៗនឹងបង្ហាញរូបចេញមកតាមរយៈកិរិយាមារយាទ ដែលមានផលប៉ះពាល់ដល់អ្នកដទៃដោយភាគច្រើនសាមីខ្លួនអាចមិនបានដឹងខ្លួនឡើយ មិនត្រឹមប៉ុណ្ណោះ វាក៏ជះឥទ្ធិពលយ៉ាងខ្លាំងចំពោះគ្រប់ផ្នែកនៃអនាគតយើងផងដែរ។

ដូច្នេះ បើអ្នកក្រចង់ធ្វើកិច្ចការធំ គឺត្រូវចាប់ផ្ដើមពីរឿងកំប៉ិកកំប៉ុកដូចជា កិរិយាមារយាទនេះជាមុនសិន។


ខ្ញុំចង់អប់រំកូន
យ៉ាងម៉េចក៏បានដែរ
មិនទាក់ទងនឹងឯងទេ
ប្តីប្រពន្ធគេឈ្លោះគ្នា
កុំមករវល់!
ខ្ញុំទារថ្លៃប្រាក់ឈ្នួលរបស់ខ្ញុំ
កុំរកចេះ
សង
ថ្លៃ
ប្រាក់
ឈ្នួល
យើងមក
បន្តិចទៀតនឹងលោតហើយ
កុំមកបង្ខំ
សង
ប្រាក់
ឈ្នួល
យើង
មក
តើលោតឬមិនលោត?
លើកពូកលែងរួចហើយ
ធុញណាស់!
199

# ៧

## អ្នកក្រតែងតែធ្វើអ្វីដែលហួសហេតុ

យោងតាមការស្រាវជ្រាវឃើញថា អ្នកក្រមានភាពហួសហេតុពីរផ្នែកគឺ ឆ្កួតហួសហេតុ និងទន់ខ្សោយហួសហេតុ។

ព្រោះអ្នកក្ររស់នៅក្នុងភាពលំបាកវេទនាអស់ពេលជាយូរ ធ្វើឱ្យពួកគេមានអារម្មណ៍នឹកដល់តែភាពអយុត្តិធម៌ និងឧបសគ្គទាំងឡាយ ពួកគេអាចជ្រើសរើសថានឹងគេច ឬបើមិនដូច្នោះទេ នឹងប្រឆាំងយ៉ាងខ្លាំង។ ហើយបើពួកគេជ្រើសរើសយកផ្លូវណាមួយហើយ នឹងជ្រើសរើសយកផ្លូវនោះរហូតមិនផ្លាស់ប្តូរឡើយ ទីបំផុតនឹងក្លាយទៅជាឧបនិស្ស័យប្រចាំខ្លួន។

ក្មេងដែលធំដឹងក្តីឡើង នៅក្នុងគ្រួសារដែលគំរោះគំរើយ តែងតែមិនដឹងថា អ្វីគួរធ្វើនិងអ្វីមិនគួរទេ អ្នកខ្លះសុខចិត្តបាត់បង់កិត្តិយសដើម្បីប្តូរជាមួយនឹងសេចក្តីសុខ ព្រមធ្វើតាមដើម្បីកុំឱ្យឈឺខ្លួន។ ប៉ុន្តែ អ្នកខ្លះប្រើអំពើហិង្សាប្រឆាំងត្រឡប់ទៅវិញ គឺប្រើវិធីបន្ទាមុតយកបន្លាមកជួស ដើម្បីរក្សាកិត្តិយសរបស់ខ្លួន។

ការប្រើវិធីសងសឹកគ្នាទៅវិញទៅមក ឬការមិនព្រមអត់ឱនឱ្យគ្នា គឺជាវិធីដែលគេនិយមប្រើក្នុងក្រុមអ្នកក្រ តែមិនអាចសរុបបានទេថា តើវាសមរម្យឬអត់ព្រោះអាស្រ័យទៅលើស្ថានការណ៍។

ចំណែកអ្នកមានវិញ នឹងផ្តោតសំខាន់ទៅលើរឿងលម្អិតបន្តិចបន្តួច ដែលខុសពីអ្នកក្រដែលយល់ថា មិនចាំបាច់ត្រូវលម្អិតខ្លាំងពេកទេ មួយផ្នែកគឺ ដោយសារតែគ្មានប្រាក់គ្រប់គ្រាន់ល្មមនឹងអាចធ្វើបាន។

ពេលអ្នកមាន និងអ្នកក្រសេពគប់គ្នា តែងតែមានរឿងឈ្លោះប្រកែកគ្នាជាញឹកញាប់រហូតដល់ពេលខ្លះដល់ថ្នាក់បង្ហូរឈាមគ្នាទៀតផង។ ដូច្នេះតាមធម្មជាតិ អ្នកមានគេនឹងមិនឈ្លោះគ្នាជាមួយអ្នកក្រទេ ទាំងនេះក្រៅតែពីរក្សាកិត្តិយសដោយសញ្ជាតិញ្ញាណហើយ នៅគិតពីសុវត្ថិភាពរបស់ខ្លួនទៀតផង។



និយាយមិនសូវដឹងរឿងទេ
ធ្វើឫកនិយាយខ្លួសព្វផង
ស្ងប់ បញ្ឈប់គ្រប់រឿង
អានត្រូវខ្លះខុសខ្លះតែធ្វើឫក
ដូចឯងរៀនខ្ពស់
ដៃដែលធ្លាប់កាន់ចប
ឥឡូវនេះចូលចិត្តកាន់
ឈើវាយកូនហ្គោលទៅវិញ
MBA
រៀន ! រៀន ! រៀន
ហេតុអ្វីបានជានាំគ្នាស្អប់ពួកសេដ្ឋីថ្មីខ្លាំងយ៉ាងនេះ ?
ខ្ញុំគ្រាន់តែជាកម្សួចមនុស្ស
នៅមិនទាន់ក្លាយជាសេដ្ឋីទេ

# ៨

## អ្នកក្រចង់ក្លាយជាសេដ្ឋីថ្មី

អ្នកក្រចូលចិត្តមើលងាយបណ្តាសេដ្ឋីថ្មីៗ តែក៏លួចសង្ឃឹមដែរថា ថ្ងៃណាមួយនឹងបានក្លាយទៅជាសេដ្ឋីថ្មីនឹងគេ។

អ្នកក្រដឹងច្បាស់ថា ខ្លួនឯងមានដើមកំណើតដែលតូចទាប បើមិនរកវិធីតាមផ្លូវកាត់ខ្លះទេ ជាតិនេះប្រហែលជាមិនបានមាននឹងគេទេ។

យ៉ាងណាក៏ដោយ សេដ្ឋីថ្មីខ្លះក៏មានកំហុសក្នុងរឿងនេះដែរ ព្រោះធ្វើឱ្យអ្នកក្រលួចមានសង្ឃឹម។ អ្នកក្រតែងតែគិតថា «មនុស្សបែបនេះនៅអាចមានបាន ខ្ញុំក៏ត្រូវតែមានឱ្យបានដែរ» ឬ «ពួកសេដ្ឋីថ្មីភាគច្រើនគឺជាអ្នកក្រពីមុន»។

សេដ្ឋីថ្មីខ្លះរមែងតែធ្វើគ្រប់វិធី ដើម្បីឱ្យបាននូវអ្វីដែលខ្លួនត្រូវការ ទោះបីជាត្រូវយកប្រៀបលើអ្នកដទៃក៏ដោយ ដែលអ្នកក្រជាច្រើននាក់មានអារម្មណ៍ថាជារឿងធម្មតាដែលត្រីធំតែងស៊ីត្រីតូច នរណាដែលរឹងប៉ឹងជាងនឹងរស់។ ដូច្នេះ ឱ្យតែរកប្រាក់បាន ទោះជាត្រូវប្រើវិធីអ្វីក៏ព្រមដែរ។

សេដ្ឋីថ្មីខ្លះចូលចិត្តអួតក្អេងក្អាងថា «ខ្លួនមាន» ឬទើបតែមានមិនទាន់បានប៉ុន្មានផងក៏ឈ្លក់វង្វេងនឹងកីឡាវាយកូនហ្គោលទៅហើយ ថតរូបពេលទៅលេងវាយកូនហ្គោលទុកអួតគេ ឬជួលមនុស្សដែលពូកែឱ្យមក

ការសរសេរពីជីវប្រវត្តិរបស់ខ្លួនដើម្បីស្អិតស្អាងបុគ្គលិកលក្ខណៈរបស់ខ្លួន និងដើម្បីកត់ត្រាទុកនៅក្នុងទំព័រប្រវត្តិសាស្ត្រ។

ចំណែកអ្នកក្រវិញ ចូលចិត្តរៀនបរិញ្ញាបត្រដើម្បីទុកជាការបើកផ្លូវដូច្នេះ បើអ្នកក្រមានឱកាសបានណែនាំខ្លួនឯងពេលណានោះ នឹងមិនព្រមឱ្យបាត់បង់ឱកាសនោះឡើយ នឹងអួតពីចំណេះ និងសញ្ញាបត្រភ្លាម។

ជាច្រើនលើកច្រើនសា ភាពមានបានដែលកើតឡើងភ្លាមៗសឹងតែដកដង្ហើមមិនទាន់នោះច្រើនតែជាការចៃដន្យ តែការដែលរក្សាការចៃដន្យនេះឱ្យបានជានិច្ចនោះត្រូវចំណាយពេលសិក្សានិងហ្វឹកហាត់។


មុននឹងបង្កើតក្រុមហ៊ុន
ប៉ាធ្លាប់ធ្វើជាកម្មករនៅទីនេះ
លំបាកនិងក្រខ្លាំងណាស់
មិនធ្លាប់មានសម្លៀកបំពាក់
ល្អៗបែបនេះទេ
មិនធ្លាប់បានញ៉ាំសាច់ ជ្រូក មាន់ ទា ទាំងនេះទេ
មិនដែលទំនេរបានអានសៀវភៅ
ប្រភេទនេះទេ
ធ្វើជាអ្នកក្រក៏ល្អម្យ៉ាងដែរ
មិនបាច់ស្តាប់ប៉ារអ៊ូរាល់ថ្ងៃ

# ៩

## អ្នកក្រវាងចាលនឹងភាពក្រីក្រ

នៅក្នុងប្រទេសចិន អ្នកមានបានទទួលប្រយោជន៍ជាច្រើន រហូតដល់មានអារម្មណ៍ថា ជាហង្សនៅក្នុងហ្វូងក្អែក។ ពេលដែលពួកគេចង់សាងកេរ្តិ៍ឈ្មោះនោះ ៗ ពួកគេអាចធ្វើបានដោយមិនខ្លាចក្រែងនរណាទាំងអស់ ពេលខ្លះក្លែងបន្លំតួលេខជាច្រើន ដើម្បីឱ្យអ្នកដទៃកោតសរសើរ ដោយមិនខ្លាចពួកពន្ធដារនឹងមកយកពន្ធឡើយ។

ប៉ុន្តែ ពេលខ្លះអ្នកមានក៏មិនគួរក្រអឺតក្រទមដែរ ទៅនៅជាមួយនឹងអ្នកក្រខ្លះ ឬទៅតថ្លៃបន្លែនៅក្នុងផ្សារដូចអ្នកក្រខ្លះ ដើម្បីឱ្យដឹងអំពីរសជាតិជីវិត។

តាមពិតនោះ ប្រទេសចិនមានអ្នកមានតាំងតែពីកំណើតនោះតិចតួចណាស់ ភាគច្រើនជាសេដ្ឋីថ្មី នៅមិនទាន់មានអ្នកបន្តភាពជាអ្នកមានដល់ទៅ ៣ ជំនាន់នៅឡើយទេ។ ដូច្នេះអ្នកមានពិតប្រាកដក្នុងប្រទេសចិនក្នុងសម័យបច្ចុប្បន្ននេះគឺ ជាមនុស្សធម្មតាដែលធ្លាប់ស្គាល់ពីរសជាតិ នៃភាពលំបាកយ៉ាងច្បាស់។

ដូច្នេះ បទពិសោធជីវិតរបស់សេដ្ឋីថ្មីជនជាតិចិនក្នុងរយៈពេល ២០ ឆ្នាំមកនេះគឺជាបទពិសោធក្នុងការចាប់ផ្តើមធ្វើធុរកិច្ច។

យ៉ាងណាក៏ដោយ សេដ្ឋីជនជាតិចិនមានចំណុចខ្សោយដ៏សំខាន់នោះគឺ ព្រហើននិងឆេវឆាវ។ អ្នកដែលខិតខំរកប្រាក់ទាំងថ្ងៃទាំងយប់នោះមិនមែនជាអ្នកមានពិតប្រាកដទេ ព្រោះនៅមិនទាន់មានអារម្មណ៍ថាខ្លួនមានសុវត្ថិភាព តែងគិតព្រួយកង្វល់ និងនៅមិនទាន់អាចរកការសប្បាយបានពេញលេញនៅឡើយទេ។

ប្រទេសដែលនៅក្រីក្រនោះ ក្រៅអំពីអ្នកក្រកើតទុក្ខហើយ អ្នកមានក៏កើតទុក្ខមិនចាញ់អ្នកក្រដែរ។ ហើយមានរឿងព្រួយបារម្ភប្រហាក់ប្រហែលគ្នា នោះគឺអ្នកក្រខ្លាចថាខ្លួនឯងនឹងកាន់តែក្រ ចំណែកអ្នកមានខ្លាចថា នឹងត្រឡប់ទៅជាអ្នកក្រដូចពីមុន។ សរុបទៅគឺ មនុស្សគ្រប់គ្នាមិនអាចជួបនឹងសេចក្តីសុខដ៏ពិតប្រាកដបានឡើយ។

ត្រី [illegible] នេះបើមិនមែនជាអ្នកមានទេ ក៏មិនបានញ៉ាំដែរ



អាវធំនេះបើមិនមែនជាអ្នកមានទេ ក៏មិនបានពាក់ដែរ



ប្រេងអូលីវនេះ បើមិនមែនជា
អ្នកមានទេក៏មិនបានញ៉ាំដែរ



កុន 3D នេះបើមិនមែនជា
អ្នកមានទេក៏មិនបានមើលដែរ



ការមកលេងថ្ងៃដូច្នេះ បើមិនមែនជាអ្នកមានទេ ក៏មិនអាចធ្វើបានដែរ



តាក់ស៊ីនេះ បើមិនមែនជាអ្នកមានទេ ក៏មិនអាចជិះបានដែរ




ខាត់ទាល់តែស្លាប់ក៏មិនភ្លឺដែរ
ធ្មេញស្រោបទង់ដែងដូច្នេះនោះ

ធ្មេញមាស បើមិនមែនជាអ្នកមានទេ
មិនអាចធ្វើបានទេ



# ១០

## អ្នកក្រតែងតែពាក់មាសពេជ្របង្អួតគ្នា

ភាពហ៊ឺហា របៀបរស់នៅនិងឫកពាជាអ្នកមាន សុទ្ធតែជាអ្វីដែលអ្នកក្រប្រាថ្នាចង់បាន។ ក៏ប៉ុន្តែ បើអ្នកក្រនៅតែបូជាអ្នកមានមិនឈប់ឈរដូច្នេះ គ្រប់យ៉ាងដែលពាក់ព័ន្ធនឹងអ្នកមាននឹងមានតម្លៃ ហើយនៅតែជាទីពេញនិយមរហូតនិងជានិរន្តរ៍។

អ្នកមានខ្លះ មានរហូតដល់ធុញ ទើបបែរមកនិយមរបស់ដែលអ្នកក្រប្រើ ដូចជា ខោខៅប៊ិយរហែក ពាក់ស្បែកជើងជជុះ។ ការនិយមរយីករយាកដូចអ្នកក្រដូច្នេះ គឺមានតែអ្នកមានប៉ុណ្ណោះដែលធ្វើបាន ហើយមើលទៅ នៅតែស្អាត។ ពេលដែលអ្នកមានចេះរក្សាឫកពា មិនអួតក្អេងក្អាងថាខ្លួនឯងមាន មិនក្រអឺតក្រទម នោះនឹងមើលទៅឃើញថា អ្នកមានមានចិត្តទូលាយ។ តែអ្នកក្របែរជាមិនមានមោទនភាពចំពោះភាពរយីករយាករបស់ខ្លួនសោះឡើយ។

ទោះយ៉ាងណាក៏ដោយ អ្នកក្រដែលគិតចង់ធ្វើតាមអ្នកមាននោះគឺត្រូវចំណាយពេល ព្រោះអ្នកក្រដើរយឺតជាងអ្នកមានមួយជំហាន ដូចជាខណៈដែលអ្នកមានពាក់មាសពេជ្រកែវកងហើយនោះ អ្នកក្រទើបតែកាត់បន្ថយនូវស្នាមប៉ះនៅលើសម្លៀកបំពាក់ ឬខណៈដែលអ្នកមានព្យាយាមត្រឡប់ទៅរកជីវិតដែលសាមញ្ញវិញនោះ អ្នកក្រទើបតែមានឱកាសបាន

ពាក់មាសពេជ្រកែវកង និងពាក់អាវធំដែលមិនទាន់កាត់ផ្លាកចេញនៅឡើយទេ។

អ្នកមានបង្កើតនូវការនិយមថ្មីៗ ទៅតាមតម្រូវការរបស់ខ្លួនបានជានិច្ច ចំណែកអ្នកក្រគ្រាន់តែជាអ្នកដើរតាមគេប៉ុណ្ណោះ។ ហើយនៅក្នុងខណៈដែលអ្នកក្រកំពុងតែនិយមរបស់អ្វីមួយនោះ អ្នកមាននឹងចាប់ផ្តើមប្រមូលប្រាក់ចូលហោប៉ៅរបស់ខ្លួន ដោយការធ្វើធុរកិច្ច លក់របស់របរឡូយឆាយដែលជាតម្រូវការរបស់អ្នកក្រយ៉ាងសប្បាយ។

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ


ផ្លែឈើដែលឯងលក់នោះ ល្អួយអស់ទៅហើយ តើនរណានឹងទិញទៅ?
ក្ដៅស្ទើរស្លាប់ នៅស្លៀកខោជើងវែងទៀត ចំជាស្រែមែន!
ស្រោមជើងក៏មិនពាក់ អន់ណាស់!
យើងគឺជាអ្នកលក់ដែលក្រដូចតែគ្នាទេ ហេតុអ្វីឯងមើលងាយយើងម្ល៉េះ?
បើមិនធ្វើដូច្នេះទេ តើយើងនឹងអាច លើកខ្លួនឯងបានយ៉ាងដូចម្ដេចទៅ?

# ១១

## អ្នកក្រតែងតែលើកតម្កើងខ្លួនឯង និងបង្អាប់អ្នកដទៃ

ការផ្ដល់នូវភាពសំខាន់ចំពោះមុខមាត់ នៅក្នុងសង្គមខ្លាំងប៉ុនណា រមែងឆ្លុះបញ្ចាំងពីការអាក់អន់ស្រពន់ចិត្តច្រើនប៉ុណ្ណោះដែរ។ អ្នកដែលពាក់ស្រោមជើងថ្លៃៗ តែពាក់ស្បែកជើងជុះថោកៗនោះ ដោយសារតែជាការនិយមបែបអ្នកមានដែលតែងខ្លួនរយីករយាក។ ប៉ុន្តែ អ្នកដែលពាក់ស្បែកជើងស្បែកថ្លៃៗតែបែរជាពាក់ស្រោមជើងរហែក ចាត់ទុកថាជារឿងដែលគួរឱ្យអាម៉ាស់ នរណាឃើញក៏សើចចំអកដែរ។ កិត្តិយសក្លែងក្លាយរបស់អ្នកក្រច្រើនតែជាប្រភេទក្រោយគឺ ល្អតែខាងក្រៅ តែរលួយក្នុង។

អ្នកក្រតែងតែយកអ្វីដែលល្អបំផុតមកដាក់នៅខាងក្រៅ ដើម្បីឱ្យអ្នកដទៃចាប់អារម្មណ៍ អំពីភាពលេចធ្លោរបស់ខ្លួន។ សត្វឈ្មោលជាច្រើនប្រភេទក៏មានលក្ខណៈខាងក្រៅលេចធ្លោដែរ។ ដូចជា កន្ទុយរបស់ក្ងោកឈ្មោល រោមនៅលើ-ករបស់សិង្ហឈ្មោល និងស្នែងរបស់ក្ដាន់ឈ្មោល ។ល។ ក្រៅពីការទាក់ទាញចំណាប់អារម្មណ៍របស់ភេទផ្ទុយហើយ នៅអាចគំរាមសត្វភេទដូចគ្នាបានទៀតផង។

សម័យនេះ អ្នកហ៊ានគឺជាអ្នកឈ្នះ ការវាយប្រហារអ្នកដទៃដោយប្រើយុទ្ធវិធីដែលមិនបាច់បញ្ចេញកម្លាំង ចាត់ទុកថា ជាឧបាយកលម្យ៉ាង។ ការលើកតម្កើងខ្លួនឯង និងបង្អាប់អ្នកដទៃ ក៏ជាកំពូលឧបាយកលមួយក្នុង

ការរស់នៅដែរ។ មិនថាជាមនុស្សអស្ចារ្យ ឬជាមនុស្សតូចតាចទេ សុំឱ្យតែមានអាកប្បកិរិយាល្អជាមុនសិន គឺអស់ទាស់ហើយ។ រឿងផ្សេងទៀតចាំនិយាយគ្នានៅពេលក្រោយ។

អ្នកក្ររមែង «លើកតម្កើងខ្លួនឯងនិងបង្អាប់អ្នកដទៃ» គិតតែពីគំរាមអ្នកដទៃ មិនឱ្យមកប្រៀបស្មើនឹងខ្លួន ព្រោះមានតែវិធីនេះប៉ុណ្ណោះដែលធ្វើឱ្យខ្លួនឯង មិនត្រូវអ្នកដទៃប្រមាថ រហូតដល់បាត់បង់ការជឿជាក់។ ទើបកិត្តិយសក្លែងក្លាយ និងភាពសាហាវឃោរឃៅតែងតែដើរទន្ទឹមគ្នាជានិច្ច។ តែវិធីប្រមាថអ្នកដទៃដែលអ្នកក្រជ្រើសរើសប្រើគឺ ដើម្បីលើកតម្កើងខ្លួនឯង ព្រោះរឿងបែបនេះគ្មាននរណាអាចជួយបានទេក្រៅអំពីខ្លួន។

កាន់តែប្រៀបធៀបកាន់តែឈឺចាប់ កាន់តែឈឺចាប់កាន់តែក្រ។


កាបូបថ្មីប៉ាយកប្រាក់ឈ្នួល
មួយសប្តាហ៍របស់ប៉ាទិញឱ្យណា៎
សម្លៀកបំពាក់នេះម៉ាក់យកប្រាក់សន្សំ
រយៈពេលកន្លះឆ្នាំទិញឱ្យកូនណា៎
ស្បែកជើងថ្មីមួយគូនេះ
តាខំបង្កត់ពីរខែ
ដើម្បីទិញឱ្យចៅណា៎
ឡូយណាស់កូនប៉ា
កុំឱ្យគេហៅថា «កូនអ្នកក្រ»
ទៅបានហើយ
ឡាន Benz C-Class ជិះចាត់ទុកថាឡូយណាស់ហើយកូនអើយ
ពេលមិត្តរបស់កូនចុះ អន់ណាស់
ស្វាគមន៍
សិស្សថ្មី
LV

# ១២

## អ្នកក្រមិនចេះសន្សំសំចៃ

អ្នកក្រត្រូវសន្សំសំចៃ មិនមែនព្រោះតែសតិសម្បជញ្ញៈទេ តែដោយសារតែស្ថានការណ៍បង្ខំ។ ភាគច្រើន អ្នកក្រក៏ចង់ចាយវាយខ្ជះខ្ជាយដែរ តែដោយសារតែមានព្រំដែនផ្នែកខាងហិរញ្ញវត្ថុ ទើបមិនអាចធ្វើបាន ហើយទោះបីជាអ្នកក្រប្រើប្រាស់របស់ដែលសក្តិសមនឹងឋានៈ ឬថ្លៃហួសពីឋានៈរបស់ខ្លួនក៏ដោយ ក៏អ្នកដទៃនៅតែយល់ថាប្រើរបស់អន់ដដែល។

អ្នកក្រមានឱកាសចាយវាយខ្ជះខ្ជាយ បានចំពោះតែថ្ងៃពិសេសប៉ុណ្ណោះ។ គេខិតខំប្រើសមត្ថភាពរកប្រាក់មកពីគ្រប់កន្លែង ដើម្បីចាយវាយទៅតាមបំណងរហូតក្លាយទៅជាមនុស្សអួតក្អេងក្អាងពីរឿងមានបានដោយមិនដឹងខ្លួន ព្រោះការចាយវាយខ្ជះខ្ជាយអាចបង្ហាញពីភាពមានបាន ចាត់ទុកថានេះជាការបង្អួតកិត្តិយសម្យ៉ាង។

បើសិនជាអ្នកក្រមិនអាចចាយវាយខ្ជះខ្ជាយ នៅក្នុងថ្ងៃបុណ្យសំខាន់ៗ ឬពិធីសំខាន់ៗដើម្បីជប់លៀងទេនោះ គេនឹងគិតថា វាជារឿងដែលគួរឱ្យសោកសៅ និងគួរឱ្យអាម៉ាស់ជាខ្លាំង។

ក្នុងពេលជាមួយគ្នា ពួកគេក៏កោតសរសើរពីវិធីនៃការសន្សំសំចៃរបស់អ្នកមានដែរ ដូចជា «មើលចុះ! ថៅកែម្នាក់នោះនៅហូបមីតាមចិញ្ចើម

ផ្ទាល់ទៀត មានក្រុមហ៊ុនធំប៉ុណ្ណឹងហើយ នៅប្រើក្រដាសដែលប្រើរួចហើយ មកថតចម្លងឯកសារទៀត...» សំឡេងសរសើររបស់អ្នកក្រនេះហើយដែល ធ្វើឱ្យបុគ្គលិកលក្ខណៈរបស់អ្នកមានកាន់តែល្អប្រសើរខ្លាំងឡើង។

ការសន្សំសំចៃរបស់អ្នកមាន អ្នកក្រគួរតែយកជាគំរូ។ ប៉ុន្តែ ពេលខ្លះ បើអ្នកក្រធ្វើដូចគ្នានឹងអ្នកមាននោះ បែរជាត្រូវអ្នកក្រដទៃទៀតប្រមាថទៅវិញ។ បើអ្នកគិតថា ខ្លួនឯងក្រខ្លាំង វិធីដែលល្អបំផុតក្នុងការសាងភាពជឿជាក់នោះគឺ ខាំធ្មេញទ្រាំសន្សំសំចៃសិនទៅ ដើម្បីធ្វើឱ្យខ្លួនឯងមាននៅក្នុងថ្ងៃណាមួយ នោះគឺ អ្នកក្រមិនអាចរស់នៅដោយគ្មានគម្រោងនិងដោយមិនសន្សំសំចៃបានទេ។


ពូកម៉ាក នេះគឺជានាមបណ្ណរបស់គ្នា
គ្រាន់បើ នេះឯងប្តូរទៅធ្វើការរាជការហើយ
លោកគ្រូ នេះគឺជានាមបណ្ណរបស់ខ្ញុំ
គ្រាន់បើ បានធ្វើដល់ទៅមន្ត្រីរាជការនៅក្នុងក្រសួងផង
លោកប្រធាន នេះគឺជានាមបណ្ណរបស់ខ្ញុំ
អស្ចារ្យណាស់ ភាសាអង់គ្លេសក៏ចេះ ភាសាជប៉ុនក៏អាចនិយាយបាន
លោកអគ្គនាយក នេះគឺជានាមបណ្ណរបស់ខ្ញុំ
ល្អណាស់ ចូលចិត្តសរសេរជក់របស់ចិនផង
លោកនាយក នេះគឺជានាមបណ្ណរបស់ខ្ញុំ
ប្រសើរណាស់ លេខាសរអាតបស្អូចត្រី ខ្ញុំក៏ចូលចិត្តស្អូចត្រីដែរ

# ១៣

## នាមបណ្ណរបស់អ្នកក្រ

នាមបណ្ណរបស់អ្នកក្រ មានពីរប្រភេទគឺ ប្រភេទសរសេររឿងលម្អិតច្រើនហួសហេតុពេក និងប្រភេទគ្មានសរសេររឿងលម្អិតអ្វីឡើយ។

ប្រភេទមានរឿងលម្អិតច្រើន ព្រោះតំណែងទាំងឡាយដែលធ្លាប់ធ្វើនោះ មិនមែនបានមកដោយងាយទេ ដូចជា ប្រធានផ្នែក ប្រធានក្រុម ថែមទាំងដាក់ក្នុងវង់ក្រចកបញ្ជាក់ទៀតថា «ស្មើនឹងតំណែង...»។ ព្រោះអ្នកក្រគិតថា នាមបណ្ណត្រូវសរសេរទិន្នន័យទៅតាមការពិត រឿងតំណែងមិនអាចបោកប្រាស់បានទេ សូម្បីតែតំណែងខ្លះជារបស់អង្គភាពឯកជនតូចៗក៏ដោយ ក៏គួរតែដាក់បញ្ចូលទៅដែរ ព្រោះស្ថិតនៅក្នុងលំដាប់ប្រធាន ដូចជា លេខាសមាគមស្នូចត្រី (ព្រោះត្រូវធ្វើការជាមួយនឹងស្រះស្នូចត្រីជាច្រើនកន្លែង...)។

មនុស្សលំដាប់ បារ៉ាក់ អូបាម៉ា ក៏ត្រូវបោះនាមបណ្ណបែបសាមញ្ញៗដើម្បីណែនាំថាជា «ប្រធានាធិបតីនៃសហរដ្ឋអាមេរិក» បើសរសេររឿងលម្អិតច្រើនជាងនេះ នឹងមើលទៅមិនមានកិត្តិយសទេ។ ដូច្នេះ «ភាពសាមញ្ញ» ទើបជាវិធីដែលមានកិត្តិយស អ្នកក្រត្រូវចាំចំណុចនេះ។

ប៉ុន្តែ នាមបណ្ណរបស់អ្នកខ្លះក៏ប្លែកដែរ គឺសាមញ្ញពេក មិនបានបញ្ជាក់ពីតំណែងអ្វីឡើយក្រៅអំពីឈ្មោះ អាស័យដ្ឋាន និងលេខទូរសព្ទ ប៉ុណ្ណោះ អ្នកគិតថា តើអ្នកជានរណា ជាម្ចាស់ហាងស្រាថ្នាក់ខ្ពស់នៅក្នុងផ្លូវតូចៗដែលមានមនុស្សតាមទៅផឹកឬ?

*អ្នកក្រអើយ! ចូរកុំធ្វើខ្លួនឱ្យអាថ៌កំបាំងនៅលើនាមបណ្ណខ្លាំងពេក។*

អ្នកក្រចង់ធ្វើតាមអ្នកមាន សូម្បីរឿងនាមបណ្ណ។ ប៉ុន្តែនៅចាញ់គេឆ្ងាយណាស់ ព្រោះអ្នកក្រតែងធ្វើអ្វីៗដោយយកពាក្យ «ពេក» មកជាមួយគឺ «ហួសហេតុពេក» ឬ «សាមញ្ញពេក»។ សាកល្បងគិតបែបងាយៗថា ហេតុអ្វីទើបស្ត្រីជនជាតិបារាំងមានមន្តស្នេហ៍ពេញពិភពលោក នោះដោយសារតែនាងមានដើមកំណើតជាជនជាតិបារាំង មិនមែនគ្រាន់តែអាចនិយាយភាសាបារាំងបានមិនប៉ុន្មានម៉ាត់ ក៏ក្លាយទៅជាជនជាតិបារាំងនោះទេ។

ដូច្នេះ អ្នកមានធ្វើអ្វីក៏មើលទៅនៅតែជាអ្នកមាន អ្នកក្រធ្វើអ្វីក៏មើលទៅនៅតែជាអ្នកក្រដដែល។

សរុបទៅគឺ បើថ្ងៃនេះ នៅមិនទាន់មានទេ ចូរសរសេររឿងលម្អិតនៅក្នុងនាមបណ្ណក្នុងលក្ខណៈសាមញ្ញប្រសើរជាង។

*ការខ្មាស ការសង្ស័យ និងការភ័យខ្លាច ជាឧបសគ្គស្លាក់នូវភាពជោគជ័យ។*


បងប្អូន សម្រុកចូល!


ពួកឯងត្រូវតែស្លាប់


ចាំបងសម្រុះសម្រួលឱ្យ


ថ្ងៃស្អែកត្រូវក្រោកមកលក់ជំឡូងចាក់ងផង
កុំគិតតែពីដេកយល់សប្តិនោះ
បងគឺជាបងធំ
មិនខ្លាចនរណាទាំងអស់!

# ១៤

## អ្នកក្រចង់ធ្វើជាបងធំ

នរណាៗក៏ចង់ធ្វើបងធំដែរ។ បងធំកាលពីសម័យមុន មើលទៅគួរឱ្យខ្លាចក្រែងណាស់ រាល់ពេលដែលបង្ហាញខ្លួនម្តងៗ គ្រាន់តែញាក់ស្មាក៏មានកូនចៅមកអមមុខអមក្រោយ គ្រាន់តែឈោងដៃ កូនចៅក៏ប្រញាប់ហុចរបស់ដែលបងធំត្រូវការឱ្យភ្លាម។

ការធ្វើជាកូនចៅគេឃើញថា មិនសប្បាយទេ សុំធ្វើជាបងធំប្រសើរជាង។ ប៉ុន្តែ មិនសូវមាននរណាគិតថា ការធ្វើជាបងធំដ៏ល្អគឺជារឿងដែលពិបាកទេ បើបងធំមិនអាចការពារកូនចៅបាន មិនអាចជួយដោះស្រាយបញ្ហាឱ្យកូនចៅបាន ឬសូម្បីតែធ្វើជាអ្នកដឹកនាំគ្រប់គ្រងពួកគេមិនបានផង តើនឹងមានកូនចៅឯណាមកចោមរោមមុខក្រោយនោះ។ ដូច្នេះ មិនអាចធ្វើជាបងធំបានដោយងាយៗទេ។

ការធ្វើជា «បងធំ» មិនអាស្រ័យលើអាយុទេ តែត្រូវតែជាមនុស្សដែលមានបទពិសោធជោកជាំ ជួបរឿងជាច្រើន និងតស៊ូពុះពារឧបសគ្គដែលចូលមកនៅក្នុងជីវិតបាន។

បងធំនៅក្នុងសម័យដែលសង្គមមានសន្តិសុខ និងការអភិវឌ្ឍនេះ គឺសំដៅដល់ អ្នកដែលទទួលបានជោគជ័យក្នុងផ្នែកការងារ ចំណែកឯ

ឧបករណ៍វាស់ភាពជោគជ័យក្នុងការងារគឺ គេចមិនផុតពី «ប្រាក់» និង «អំណាច» ទេ។

ក្រុមឥទ្ធិពលឯងឹត នៅក្នុងសម័យមុនអាស្រ័យលើខ្លួនឯង និងដាវមួយគូនោះ គឺអាចរស់នៅបានហើយ ប៉ុន្តែសម័យនេះមិនបានទេ។

នៅក្នុងប្រទេសខ្លះ ក្រុមនេះតែងតែជាប់ពាក់ព័ន្ធជាមួយនឹងក្រុមដទៃទៀតជាច្រើន ធ្វើឱ្យបងធំនៅក្នុងសម័យនេះពាក់អាវធំចងក្រវ៉ាត់ក បើបើកក្រុមហ៊ុនធ្វើធុរកិច្ចវិញ ចៃដន្យអាចនឹងក្លាយទៅជាមនុស្សល្បីទៀតផង។

សម័យនេះ ថៅហ្វាយនាយមានសិទ្ធអាចចេញបញ្ជាបាន ព្រោះមានអំណាចឱ្យប្រាក់ខែ។ ប្រាកដណាស់ថា កូនចៅក៏មានសិទ្ធប្រឆាំងឬបដិសេធនឹងថៅហ្វាយនាយបានដែរ។ ប៉ុន្តែ ត្រូវត្រៀមខ្លួនប្រឈមនឹងភាពលំបាកនាពេលអនាគត។ ចាំទុកថា មិនថាអ្នកនៅទីណាទេ ក៏ត្រូវតែរកបាយចិញ្ចឹមជីវិតដែរ។

បងធំត្រូវតែជាអ្នកមាន បើអ្នកក្រចង់ធ្វើជាបងធំនោះគឺបានត្រឹមតែ «យល់សប្តិកណ្តាលថ្ងៃត្រង់» ប៉ុណ្ណោះ។


នោះគឺជាអា ចយ ដែលកាលពីក្មេង
ហៀរសំបោរ ឥឡូវវាមានហើយ
នោះគឺអា ចយ កាលពីនៅក្មេង
ចូលចិត្តកុហក ឥឡូវវាមានហើយ
អេ! អា ចយ កាលពីនៅក្មេងឯងញ៉ៀវយើងណាក
ឥឡូវនេះមានហើយ រៀបការឬនៅ?
នោះគឺជាអា ចយ ដែលពីក្មេងលួចត្រសក់របស់ខ្ញុំ
ឥឡូវនេះវាមានហើយឬ?
នោះគឺជាអា ចយ ដែលកាលពីនៅក្មេង
តែងតែជុះនោមដាក់ខោ អាក្មេងល្ងង់
ក៏អាចមានបានដែរ!
ត្រឡប់មកស្រុកវិញធ្វើអ្វីខ្ញុំ
គុំកួនក្នុងរូងសិនណា
កូនកណ្ដុរតូច!

# ១៥

## អ្នកក្រពេលមានបានហើយ នឹងផ្ដាច់ខ្លួនពីអតីតកាល

ពេលអ្នកក្រក្លាយទៅជាអ្នកមាន រឿងដំបូងដែលត្រូវធ្វើគឺ លើកដៃលាបណ្ដាអ្នកក្រដូចគ្នា។

ដូចពេលដែល «ឡៅបុាំង» ស្ថាបនាខ្លួនឯងឱ្យក្លាយទៅជាក្សត្រដំបូងគេរបស់រាជវង្សហាន់ គេអង្គុយនៅលើបល្ល័ង្កមាស នៅពីក្រោមមានបណ្ដាមន្ត្រីនិយាយសរសើរយ៉ាងទ្រហឹង បរិយាកាសគួរឱ្យរំភើបណាស់។ ប៉ុន្តែបើនៅសុខៗ មានសាច់ញាតិរបស់ ឡៅបុាំង ដើរចូលមក ហើយហៅថា «អា ឡៅបុាំង» ហើយនិយាយរឿងដែលគួឱ្យអាម៉ាស់របស់គេកាលពីអតីត និងធ្វើនូវសេចក្ដីស្និទ្ធស្នាលជាមួយនឹងគេទៀតផងនោះ តើអ្នកគិតថាស្ដេចដូចជា ឡៅបុាំង នឹងសើចចេញដែរឬ?

ពេលដែលអ្នកក្រក្លាយទៅជាអ្នកមាននោះ នឹងតែងខ្លួនស្អាតបាតជិះយន្តហោះមកស្រុកកំណើត មានរថយន្តមកចាំទទួល មានកូនចៅអមពីមុខពីក្រោយ និងមានអ្នកដឹកនាំហ្វូងមនុស្សចាំទទួល នៅឯសណ្ឋាគារព្រោះថា សេដ្ឋីថ្មីប្រាកដជាមិនត្រឡប់ទៅគេង នៅផ្ទះចាស់ជាដាច់ខាត។ ដូច្នេះ ទើបអ្នកមានគ្មានឱកាសបានជួបនឹងមិត្តចាស់កាលពីសម័យនៅក្មេងទេ បើទោះបីជាមានពេលចូលទៅលេងផ្ទះចាស់ តែចូលបានតែមួយភ្លែត

ប៉ុណ្ណោះ។ ចំណែកឪពុកម្ដាយវិញ បានសួរសុខទុក្ខត្រឹមតែ ៥ នាទីនោះគឺចាត់ទុកថាប្រសើរណាស់ហើយ។

ពេលដែលអ្នកក្រក្លាយទៅជាអ្នកមាននោះ ចាំបាច់ត្រូវតែកាត់ផ្ដាច់ពីអតិតកាល ទោះបីជានឹកដល់ផ្ទះចាស់ខ្លាំងយ៉ាងណា ក៏មិនត្រឡប់ទៅវិញដែរ ព្រោះមិនអាចហាមមនុស្សមិនឱ្យមករកខ្លួនបាន។ ដូច្នេះ ទើបអ្នកមានដែលឆ្លាតរកលេខដាក់គ្មាន នឹងកាត់ផ្ដាច់អតីតកាលចោលទាំងអស់ មិនសូវត្រឡប់មកស្រុកកំណើតទេ ដើម្បីការពារកុំឱ្យមានភាពស្មុគស្មាញតាមមក។


យើងក៏ញ៉ាំដែរ...
តែជាមីកញ្ចប់!
យើងក៏ប្រើដែរ...
តែជាប្រេងឆា!
អ្នកមានគេញ៉ាំមី
ធ្វើដោយដៃ
អ្នកមានគេប្រើប្រេង
អូលីវនាំចូលពីបរទេស!
យើងក៏ញ៉ាំដែរ...តែជាស៊ុប
កន្ទាយដែលចម្រាញ់ហើយ
យើងក៏ញ៉ាំដែរ
តែជាទឹកថាំងផៅ
អ្នកមានគេញ៉ាំស៊ុប
កន្ទាយបំប៉នរាងកាយ
អ្នកមានគេញ៉ាំ
ថាំងផៅ
រឿងនេះយើងដកថយប្រសើរជាង
អ្នកមានគេវះកាត់ប្តូរអវយវៈបាន

# ១៦

## អាហារបំប៉នរបស់អ្នកក្រ

ពេលដែលអ្នកក្រទៅសួរសុខទុក្ខអ្នកមាន ចូលចិត្តទិញអាហារបំប៉នរាងកាយជាច្រើនទៅផ្ញើ អ្នកមានក៏ញញឹមទទួលពីអ្នកក្រ។ ប៉ុន្តែ ពេលនៅពីក្រោយខ្នង ពួកគេនឹងយករបស់ទាំងនោះទៅទុកក្នុងទូ ពេលខ្លះលាក់ទុករហូតដល់ខូចអស់ ទីបំផុតត្រូវយកទៅបោះចោល ឬបើមិនដូច្នោះទេក៏យកទៅឱ្យអ្នកក្របន្តទៀត។

អ្នកមានមិនហូបរបស់ប្រភេទនេះទេ ព្រោះមិនដឹងថា នៅក្នុងកញ្ចប់ពណ៌មាសដ៏ស្អាតមួយនេះបានដាក់អ្វីខ្លះមកទេ អ្នកមានគេបារម្ភពីសុខភាពរបស់ខ្លួនបំផុត ទើបមិនហ៊ានហូបអ្វីដែលមិនស្គាល់ច្បាស់។ បើគេចង់ហូបកន្ទាយ នឹងទៅទិញយកមកទាំងរស់ យកមកចំហុយដោយដៃខ្លួនផ្ទាល់។ ក្នុងទស្សនៈរបស់អ្នកមាន ស៊ុបកន្ទាយដែលគេចម្រាញ់រួចដាក់លក់នោះ មិនមានជីវជាតិអ្វីសល់ទៀតទេ។

អ្នកក្រក៏ចង់ហូបកន្ទាយដែរ តែវាថ្លៃពេក។ គិតមើលឱ្យបានច្បាស់ស៊ុបកន្ទាយដែលគេចម្រាញ់ ឈ្មោះក៏បានប្រាប់ហើយថា «ចម្រាញ់» បង្ហាញថា ត្រូវចម្រាញ់អ្វីដែលល្អបំផុតរបស់កន្ទាយចេញអស់ហើយ (តែនៅលើគម្រប បែរជាសរសេរថា មានផ្សំថ្នាំចិនថ្នាក់កំពូលជាច្រើន បើបាន

ហូបមួយថ្ងៃបន្តិចនឹងជួយបំប៉នរាងកាយ មិនក្តៅក្នុង) ចង់ទៅរករបស់ល្អៗតម្លៃថោកដូច្នេះបាននៅឯណាទៀត?

របស់ល្អតម្លៃថោក ភាគច្រើនគឺផលិតឱ្យអ្នកក្រជាករណីពិសេស ពេលដែលអ្នកក្រមើលថា របស់មួយល្អឬអត់នោះតែងតែវិនិច្ឆ័យលើតម្លៃរបស់វា។ ប្រាកដណាស់ របស់ដែលអាច «ថោក» បាន គឺដោយសារតែផលិតក្នុងបរិមាណច្រើន ដូច្នេះរមែងមិនមានការផ្ចិតផ្ចង់។

អ្នកក្រស្លៀកសម្លៀកបំពាក់ ដែលកាត់ពីក្រណាត់គ្មានគុណភាព ហូបអាហារកែច្នៃ បើទិញកន្ទាយទាំងរស់មកចំហុយហូបនោះក៏អាចហូបបានដែរ តែបានតែមួយពេលប៉ុណ្ណោះ គេគិតថាខ្ជះខ្ជាយខ្លាំងពេក។

«មានស៊ុបកន្ទាយចម្រាញ់ឱ្យហូបនោះគឺប្រសើរណាស់ហើយ» តែអ្នកក្របែរជាគិតថា នេះគឺជាការលើកកម្ពស់ខ្លួនឯងទៅវិញ។

អ្នកក្រគិតថា របស់ដូចគ្នា តែតម្លៃថោកជាង បានប៉ុណ្ណោះចាត់ទុកជាប្រសើរខ្លាំងណាស់ហើយ។



ទីបំផុតតួឯកប្រុសនិងតួឯកស្រីត្រូវបែកគ្នា...
ទីបំផុតពួកចោរត្រូវបានចាប់ដាក់គុក...
តើតួឯកប្រុសនឹងទៅជាយ៉ាងណាទៅ?
តើពួកគេនឹងនៅក្នុងគុកដោយរបៀបណា?
មើលរឿងភាគ
មើលរឿងស៊ើបអង្កេត
ខ្ញុំសុំមើលផង
ខ្ញុំចង់មើល
ជួយផង!
ផាំង
គ្រាំងៗ
ផាំង

# ១៧

## អ្នកក្រញៀនមើលទូរទស្សន៍

សម្រាប់អ្នកក្រ «តម្លៃថោក» ជាលក្ខខណ្ឌដំបូងដែលអូសទាញឱ្យគេទិញទំនិញនោះយកមកប្រើ។

ដូច្នេះហើយ ទើបទូរទស្សន៍ក្លាយទៅជារបស់ដែលមានតម្លៃបំផុតរបស់អ្នកក្រ មានតែមួយគ្រឿងហាក់ដូចជាមើលឃើញពិភពលោកទាំងមូលដូច្នោះដែរ ព្រោះជួយឱ្យអ្នកក្របានទទួលនូវការកម្សាន្ត តាមរយៈកម្មវិធីជាច្រើន ថែមទាំងអាចបើកមើលបានដោយមិនកំណត់ពេលវេលាទៀតផង។

កម្មវិធីដែលមានអត្ថន័យត្រូវចិត្តអ្នកក្រជាពិសេសបំផុតនោះគឺ ម៉ោងរឿងភាគដែលអ្នកមានធ្វើជាតួប្លុក អ្នកក្រចូលចិត្តខ្លាំងណាស់ ហើយបើបានឃើញមនុស្សអាក្រក់ត្រូវប៉ូលីសចាប់នោះ អ្នកក្រនឹងពេញចិត្តបំផុត។ម្យ៉ាងទៀត រឿងភាគចិនបុរាណដែលតួអាចហោះហើរលើអាកាសបាន ពិតជាតបស្នងនូវតម្រូវការរបស់ទស្សនិកជនដែលចូលចិត្តស្រមើស្រមៃថា «ខ្លួនជាអ្នកក្លាហាន» អាចកម្ចាត់មនុស្សអាក្រក់បាន។ ចំណែកមេផ្ទះចូលចិត្តមើលរឿងទាក់ទងនឹងជីវិត និងរឿងមនោសញ្ចេតនា ពេលដែលមើលជាបន្តបន្ទាប់នឹងចូលតួ យំអាណិតតួឯកស្រីដែលមានជីវិតស្នេហាដ៏វន្ទត់។

មានតែទូរទស្សន៍ប៉ុណ្ណោះដែលដឹងចិត្តអ្នកក្រ បើកឱកាសឱ្យអ្នកក្របានបង្ហាញខ្លួនតាមកម្មវិធីផ្សេងៗ ដូចជា ការលេងហ្គេម ការប្រកួតសមត្ថភាព សុំឱ្យតែអ្នកក្រមកចុះឈ្មោះនោះ នឹងអាចចូលលេងក្នុងកម្មវិធីបានភ្លាម បើពូកែនិងមានសំណាងល្អទៀតនោះ នឹងអាចប្រមូលរង្វាន់ត្រឡប់ទៅវិញបានជាច្រើន។

ឱកាសមានជានិច្ច មិនចាំបាច់ខ្មាសអៀនទេ បើមានពេលទំនេរទៅចុះឈ្មោះធ្វើជាទស្សនិកជនរបស់កម្មវិធីទូរទស្សន៍ ទៅអង្គុយទះដៃអង្គុយហ៊ោ រកបទពិសោធ ផ្លាស់ប្តូរបទពិសោធខ្លះ អ្នកនឹងបានហូបនំបន្តិចបន្តួច បានទទួលរង្វាន់ពីអ្នកឧបត្ថម្ភកម្មវិធីត្រឡប់មកផ្ទះវិញ គឺចូលក្នុងលក្ខណៈ «មានប្រយោជន៍» ទាំងអ្នកនិងម្ចាស់កម្មវិធី។


លោកពូ ពួកយើងមកលេង
សាច់ញាតិក្រៗ
មកសុំឱ្យជួយ
ទៀតហើយ
លោកពូ...
ចាំមួយភ្លែត
បើកទូរសព្ទសិន
លោកពូ...
ឈប់
ឆែកមើល SMS សិន
លោកពូ...
ជល់កែវមួយសិន
ចាំនិយាយគ្នា
លោកពូ...
ចាក់តែថែមសិន
បានមកលេងសាច់ញាតិអ្នកមាន
មើលទៅយើងដូចជាឡូយខ្លាំងណាស់

# ១៨

## អ្នកក្រមានសាច់ញាតិច្រើន

អ្នកមានរាប់អានមិត្តភក្តិ អ្នកក្ររាប់ញាតិ។ យើងមិនអាចជ្រើសរើសសាច់ញាតិបានទេ ព្រោះមានទំនាក់ទងជាសាច់ឈាមគ្នា ចង់ស្រលាញ់ឬស្អប់ក៏ត្រូវតែរាប់អានដែរ។ សាច់ញាតិមានទាំងមានទាំងក្រលាយឡំគ្នា។ អ្នកក្រទៅលេង «សាច់ញាតិអ្នកមាន» មិនមែនដើម្បីប្រយោជន៍ជានិច្ចនោះទេ តែចាត់ទុកថា ជាកិត្តិយសសម្រាប់ខ្លួនឯងច្រើនជាង។ កុំគិតថាអ្នកក្រយកមេមាន់ទៅជូនសាច់ញាតិអ្នកមានដើម្បីយកចិត្តនោះ តាមពិតអ្នកមានលួចសប្បាយចិត្តដែលមានសាច់ញាតិ «ក្រជាង» មកលេងទៅវិញទេ ព្រោះមាន់ស្រែជាអាហារដែលគ្មានជាតិគីមី។

ពេលដែលសួរសុខទុក្ខគ្នាចប់ហើយ សាច់ញាតិអ្នកមានក៏ប្រាប់ថា «បើខ្វះខាតអ្វី ចូរប្រាប់មក» និយាយមិនទាន់ចប់ផង ទូរសព្ទក៏រោទ៍ឡើងត្រូវចេញទៅធ្វើការហើយ ធ្វើឱ្យអ្នកក្រមិនចង់មករំខានទៀត បើដូច្នេះអ្នកក្រត្រូវជួយអ្នកមានធ្វើម្ហូប លាងចាន និងធ្វើមាន់ដែលខ្លួនយកមកជូននោះ។

ទីបំផុត អ្នកក្រគ្មានឱកាសបានប្រាប់ពីបញ្ហារបស់ខ្លួនឯងឡើយ មាន់ក៏អស់ ផ្ទះក៏នៅឆ្ងាយ សាច់ញាតិអ្នកមានមិនងាយនឹងបានមកលេងទេ។ តែទោះជាអ្នកមានមានទឹកចិត្តជួយសាច់ញាតិក៏ដោយ ក៏អាចធ្វើបាន

តែមួយគ្រាៗតែប៉ុណ្ណោះ មិនបានរហូតអស់មួយជីវិតទេ ... បើសាច់ញាតិអ្នកក្រយល់ពីការពិតមួយចំណុចនេះ នឹងមិនស្រមើស្រមៃតទៅទៀតទេ ហើយគេក៏មិនមើលងាយយើងតទៅទៀតដែរ។

ផ្ទុយទៅវិញ ពេលដែលអ្នកមានគេមកសួរសុខទុក្ខ «សាច់ញាតិអ្នកក្រ» គេគ្រាន់តែហាមាត់ថា ចាំយកអង្ករដែលហូបមិនអស់ និងរបស់របរដែលមិនបានប្រើមកឱ្យ សាច់ញាតិអ្នកក្រពេញចិត្តណាស់ទៅហើយ ថែមទាំងអាចអួតអ្នកស្រុកបានទៀតផង។

ហេតុអ្វីបានជាអ្នកក្រលើកតម្កើងអ្នកមានខ្លាំងម្ល៉េះ? តាមពិតទៅការដែលមានសាច់ញាតិអ្នកមាន ចាត់ទុកថា ជាកិត្តិយសដល់អ្នកក្រជាខ្លាំង ធ្វើឱ្យរីកមុខរីកមាត់ប៉ុនជញ្ជាំងវិហារ។


Chat room របស់អ្នកក្រ
«ហើយ...»
Chat room របស់អ្នកក្រ
«បើកវេប្សាយធំធ្វើអ្វី ខ្ញុំរកទំនិញបាន ១០០ ត្រូវគេផាកអស់ ៥០...»
Chat room របស់អ្នកក្រ
«ឯងគ្រាន់បើដែលនៅធ្វើការបាន ខ្ញុំត្រូវឡានបុក ដេកវង់ចាំថ្លៃព្យាបាល នៅឯមន្ទីរពេទ្យ...»
Chat room របស់អ្នកក្រ
«ឯងគ្រាន់បើនៅមានសង្ឃឹម ចំណែកខ្ញុំអត់បាយមកពីរថ្ងៃហើយ មិនដឹងថានឹងមានបាយហូប ឬអត់ទេ
Chat room របស់អ្នកក្រ
«ឯងគ្រាន់បើនៅមានសតិ ខ្ញុំនៅមិនទាន់ដឹងខ្លួនផងថា ខ្លួនជានរណា និយាយជាមួយនរណា និយាយពីអ្វីទេ»
អូ! សុំទោសពួកអ្នកក្រទាំងឡាយ ឆ្មាវាមកជាន់ Keyboard របស់ខ្ញុំ ទើបជ្រែកខុសកន្លែង...

# ១៩

## អ្នកក្រជជែកគ្នាបែកពពុះមាត់

នៅពេលដែលអ្នកមាន គេមានបញ្ហាអ្វី តែងតែនៅស្ងៀម លាក់អារម្មណ៍ ម៉ឹងម៉ាត់តែទន់ភ្លន់ និងចិត្តត្រជាក់ ប៉ុន្តែអ្នកក្រវិញមិននៅស្ងៀមទេ។ ហេតុដែលអ្នកក្រចូលចិត្តជជែកគ្នានោះ មិនមែនមកពីខ្លួនឯងទំនេរទេ តែដោយសារតែមានគេមើលងាយរហូតមក ទើបមានគំនុំនៅក្នុងចិត្ត និងលាក់រហូតដល់ត្រូវរកផ្លូវបញ្ចេញខ្លះ។

*អ្នកក្រជជែកគ្នាមិនឈប់ឈរព្រោះតែ*

១. ដើម្បីសិក្សាពីស្ថានភាពរបស់មនុស្សម្នាក់ៗ ឬតាមការនិយមរបស់សង្គមឱ្យទាន់។

២. ដើម្បីរកចម្លើយឱ្យខ្លួនឯងនិងវិនិច្ឆ័យ

៣. ដើម្បីកម្សាន្ត និងរកសេចក្តីសុខដាក់ខ្លួន។

សង្គមបច្ចុប្បន្ននេះ ប្រញាប់ប្រញាល់ណាស់ ធ្វើឱ្យយើងជជែកគ្នាមិនបានល្អិតល្អន់ទេ ព្រោះត្រូវធ្វើការ ពេលសម្រាកពីការងារក៏ប្រញាប់ត្រឡប់ទៅផ្ទះ។ ប៉ុន្តែអ្នកក្រនៅតែរកវិធីជជែកគ្នាឱ្យខានតែបាន ដូចជារកមិត្តភក្តិសន្ទនាគ្នាតាមប្រព័ន្ធអ៊ិនធើណែត Web Board, Chat Room,

Twitter, Facebook ។ល។ នឹងជួបអ្នកដែលចង់ជជែកគ្នាពីរឿងតែមួយ ជាមួយនឹងខ្លួន រួមគ្នាជាសង្គមតូចៗគ្រប់ពេល ដែលនេះនឹងធ្វើឱ្យលែងអផ្សុកតទៅទៀត។

នៅក្នុង Chat Room Online មានមនុស្សជាច្រើននៅលាយឡំគ្នា អ្នកមិនមែនជាអ្នកដឹកនាំគេទេ អ្នកគ្រាន់តែជាកូនបង្កាតូចមួយដែលមានស្រះឱ្យហែលលេងបានយ៉ាងសេរី និងជជែកគ្នាពីរឿងរ៉ាវដែលចាប់អារម្មណ៍ជាមួយនឹងបង្កាដទៃទៀតបានដោយសេរីតែប៉ុណ្ណោះ។ តែទោះជាយ៉ាងណា នេះហាក់ដូចជាត្រូវចិត្តអ្នកក្រមែនទែន ព្រោះនេះមិនចាំបាច់អស់ប្រាក់ លើកលែងតែថ្លៃភ្លើង និងថ្លៃអ៊ិនធើណែតប៉ុណ្ណោះ សួរថាតើមានកន្លែងណាដែលល្អជាង «សង្គម Online» ទៀតនោះ?

ការជជែកគ្នាក្នុងសង្គម Online ពិតជាត្រូវចិត្តអ្នកក្រខ្លាំងណាស់។



បានកំរៃរាយៗ
ឱ្យ ប៉ា ម៉ាក់
ដូចដើម
ឱ្យ មិត្ត
បានត្រឡប់មកវិញ
បន្តិចបន្តួច
ឱ្យ ប្រធាន ផ្នែក
បានពាក្យអរគុណ
ឱ្យ អ្នក គ្រប់ គ្រង
ឱ្យទៅច្រើនជាងគេ
តែជាមិនបានអ្វីឡើយ
គេមិនជេរយើងនោះចាត់
ជាប្រសើរហើយ
ឱ្យ អគ្គ នាយក

# ២០

## អ្នកក្របណ្ដាក់ទុនរឿងអំណោយ

ក្នុងពិធីបុណ្យចូលឆ្នាំសកល ឬចូលឆ្នាំចិន វាគឺជាឱកាសដែលល្អបំផុតក្នុងការប្រគល់អំណោយ។ អ្នកក្រក្នុងពេលដែលនៅក្រ រកព្រឹកខ្វះល្ងាចស្រាប់ហើយនោះ នៅត្រូវយួរផ្លែឈើទៅផ្ញើសាច់ញាតិ លុះពេលដែលមានជីវភាពល្អប្រសើរឡើងហើយ ត្រូវឱ្យអំណោយដល់ចៅហ្វាយនាយ។

ពេលមានបុណ្យទាន ជាពេលដែលមានការទិញដូរជាច្រើន ហើយអ្នកដែលទិញច្រើនជាងគេនោះគឺអ្នកក្រ។ នៅក្នុងសង្គមចិន កូនចៅត្រូវជ្រើសរើសអំណោយដោយផ្ចិតផ្ចង់ឱ្យចៅហ្វាយនាយ ឯចៅហ្វាយនាយក៏ត្រូវតែជ្រើសរើសរបស់ថ្លៃៗ ដើម្បីប្រគល់ឱ្យថ្នាក់លើរបស់ខ្លួនមួយជាន់ទៀតដែរ។ ដូច្នេះមានតែចៅហ្វាយថ្នាក់កំពូលតែប៉ុណ្ណោះ ដែលទទួលបាននូវប្រយោជន៍។

អំណោយដែលអ្នកក្រឱ្យអ្នកមាន ភាគច្រើនជារបស់ដែលអ្នកក្រមិនធ្លាប់បានប្រើ ព្រោះហួសពីសមត្ថភាព។ ប៉ុន្តែពេលដែលអំណោយទៅដល់ដៃរបស់អ្នកមាន មិនប្រាកដជាថា អ្នកមានគេនឹងប្រើវានោះទេ។ អ្នកមានទទួលអំណោយព្រោះតែចង់បាន «ភាពស្មោះត្រង់» ហើយពេលដែលទទួលបាននូវ «ភាពស្មោះត្រង់» ហើយ ក៏ត្រូវប្រគល់ «ក្ដីមេត្តា» តបស្នងទៅវិញ។

សរុបទៅ ពេលដែលប្រគល់អំណោយ អ្នកគ្រប់គ្រងអំណាចខ្ពស់បំផុតបានចំណេញច្រើនជាងគេ អ្នកដែលមានអំណាចថ្នាក់កណ្តាលរួចខ្លួន តែកូនចៅតូចតាចបែរជាត្រូវចំណាយប្រាក់ច្រើនបំផុតទៅវិញ។ ដូច្នេះសុំឱ្យអ្នកក្រគិតថា វាជាការបណ្តាក់ទុនទៅចុះ ប៉ុន្តែ តើពេលណានឹងទទួលបាន «ដើម» ត្រឡប់មកវិញខ្លះទៅ?

សរុបទៅ អ្នកដែលឈឺចាប់បំផុតនោះគឺភរិយា ព្រោះស្វាមីខំប្រឹងទិញអំណោយឱ្យគេរាល់ឆ្នាំ តែមិនបានអ្វីត្រឡប់មកវិញឡើយ ភរិយារអ៊ូថា «បានមកមិនបានមួយចំណិតដែលឱ្យទៅទេ» រហូតដល់ស្វាមីឆ្លើយទៅវិញថា «សុំឱ្យតែគេមិនស្អប់យើងនោះគឺប្រសើរណាស់ទៅហើយ!»។



សាច់ចម្លូកមាន!
ក្បាលជ្រូកមាន!
កន្ទុយជ្រូកមាន!
ក្បាលមាន់មាន!
ពាបត្រកូនឱ្យខ្លះមក!
ក្បាលត្រីមាន!
សំបុក ត្រចៀកកាំ មាន!
ពោះ ត្រីឆ្លាម មាន!
សម្បុរ មាន

# ២១

## អ្នកក្រប៉ាវបាយ អ្នកក្រខ្លួនឯងច្រើនតែមិនឆ្អែត

ពេលដែលអ្នកក្រប៉ាវបាយ ច្រើនតែប៉ាវជាតុចិន អាហារគរដូចភ្នំ។ បើចានដែលជាសាច់វិញ ត្រូវជ្រើសរើសសាច់ដែលឆ្ងាញ់បំផុត និងដាក់ឱ្យលេចធ្លោបំផុត។

អ្នកក្រច្រើនតែមិនហូបសាច់ដែលឆ្ងាញ់បំផុតទេ តែនឹងចាប់យកទៅដាក់ក្នុងចានរបស់ភ្ញៀវ (បើភ្ញៀវជាអ្នកមាន) គេនឹងសម្លឹងរកតែបន្លែបៃតងដើម្បីបំប៉នសុខភាព។ ប៉ុន្តែពេលដែលអ្នកក្រទៅហូបអាហារប៊ូហ្វេ (buffet) បែរជាតម្រង់ទៅរកសាច់ ដួសឡើងពេញចាន ព្រោះគិតថាបើមិនហូបសាច់ឱ្យបានច្រើនទេនឹងមិនចំណេញទេ។

ផ្ទុយទៅវិញ ពេលដែលអ្នកមានជប់លៀងបែរជាសង្កត់ធ្ងន់ទៅលើរឿងបរិយាកាសជាសំខាន់ ហើយរឿងហូបជារឿងបន្ទាប់ទៅវិញ។ អាហារដែលអ្នកមានគេកុម្ម៉ង់ អ្នកក្រមិនដែលហូបបានឆ្អែតទេ ព្រោះឃើញចានតូចៗ រៀបរៀងយ៉ាងស្អាត ស្ទើរតែមិនហ៊ានហូប និងមិនឆ្ងាញ់ទៀតផង។

អ្នកក្រត្រូវហូបយ៉ាងស្ងប់ស្ងាត់ និងប្រយ័ត្នប្រយែង កុំឱ្យមើលទៅដូចជាល្មោភពេក ត្រូវតែព្យាយាមមិនសម្លឹងអាហារចានធំៗ តែក៏មិនអាចទ្រាំបាន ពេលខ្លះស្រទ្បាំងកាំងនឹងការ៉ុតដែលឆ្លាក់ជាផ្កា តុបតែងនៅលើ

ចាន រហូតដល់គាបយកមកហូប ហើយក៏រអ៊ូរទាំថាសាប គ្មានរសជាតិអ្វី ឡើយ...នេះគឺជារឿងដែលអាម៉ាស់បំផុតនៅក្នុងយប់ជប់លៀង។

ប៉ុន្តែ អ្វីដែលអាក្រក់ជាងនេះទៀតនោះគឺ ពេលអ្នកក្រទៅដល់ផ្ទះ វិញត្រូវទៅរកអ្វីមកហូបបន្ថែមទៀត ហ៊ើយ...ចំណាយប្រាក់អស់ជាច្រើន តែបែរជាហូបមិនឆ្អែតទៅវិញ។


យឺត ៥ នាទី
ត្រូវកាត់ប្រាក់ខែ
បំណុលនេះត្រូវតែជម្រះ!
អ្នកដែលត្រូវគេកាត់ប្រាក់ខែ
ខ្ញុំមិនបានអាហារូបករណ៍ទៅរៀន
នៅបរទេស
បំណុលនេះត្រូវតែជម្រះ!
អ្នកដែលទទួលបាន
អាហារូបករណ៍
អ្នកដែលឡើងតំណែង
មិនមានឈ្មោះខ្ញុំ
បំណុលនេះ
ត្រូវតែជម្រះ!
បញ្ជីឈ្មោះអ្នកចូលនិវត្តន៍មិនមាន
ឈ្មោះខ្ញុំ បំណុលនេះត្រូវតែជម្រះ!
ប្រាក់ចូលនិវត្តន៍មិនឡើង
បំណុលនេះត្រូវតែជម្រះ!
សៀវភៅ
បញ្ជី
ធនាគារ
ដើរលេងរួចហើយ
នៅមិនទាន់ទៅសងសឹក
ទៀតឬ?
នៅមិនទាន់ដល់ពេល...

# ២២

## អ្នកក្រគិតតែពីរឿងសងសឹក

អ្នកក្ររមែងតែចាញ់ប្រៀបអ្នកដែលមានឥទ្ធិពលខ្លាំងជាង ទោះបីជាលំបាកវេទនាយ៉ាងណាក៏ដោយ អ្នកក្រចាំបាច់ត្រូវតែអត់ទ្រាំ ដូច្នេះហើយ ទើបមានគេនិយាយថា ១០ ឆ្នាំទៀតចាំត្រឡប់មកសងសឹកវិញក៏មិនទាន់ហួសពេលដែរសម្រាប់កូនប្រុស។

មិនមែនចំពោះតែអ្នកក្រប៉ុណ្ណោះទេដែលមានគំនុំ គ្រប់គ្នារមែងមានគំនុំទាំងអស់ គ្រាន់តែគំនុំនោះមិនបានបន្តតែប៉ុណ្ណោះឯង។ ការសងសឹក គឺជាកាំបិតមុខពីរ ព្រោះការធ្វើបាបអ្នកដទៃ គឺស្មើនឹងធ្វើបាបខ្លួនឯង ដូច្នេះអ្នកដែលមានហេតុផល និងព្រមទទួលយកការពិតបាន នឹងមិនមានគំនុំនៅក្នុងចិត្តទេ។

បើសាកល្បងថ្លឹងថ្លែងពីផលល្អនិងផលអាក្រក់នោះ គេសុខចិត្តធ្វើជាអ្នកចាញ់ប្រៀបប្រសើរជាង និងខិតខំអត់ធ្មត់រហូតត្រូវមានការផ្លាស់ប្តូរ។ ពេលដែលមនុស្សយើងចាប់ផ្តើមបន្ធូរបន្ថយជាបណ្តើរៗនោះ ចិត្តនឹងស្ងប់សុខ ចំណែកពាក្យថា ១០ ឆ្នាំក្រោយទៀតចាំសងសឹកនៅមានឬអត់នោះ នឹងមកនិយាយគ្នាសាជាថ្មីម្តងទៀត។

អ្នកដែលគិតបានដូច្នេះ បង្ហាញថា ជាមនុស្សដែលសម្លឹងបានវែងឆ្ងាយ មានហេតុផល និងមានការអត់ធ្មត់ ចាត់ថាមានចិត្តទូលាយ។

រយៈពេល ១០ ឆ្នាំតែមួយប៉ប្រិចភ្នែកប៉ុណ្ណោះ នឹងកន្លងហួសហើយ អ្វីៗក៏ផ្លាស់ប្តូរ សភាពចិត្តក៏ផ្លាស់ប្តូរទៅដែរ។ លុះដល់ពេលនោះគំនិតចង់សងសឹកនឹងមិនមាននៅសេសសល់តទៅទៀតឡើយ។ ពេលជួបគូសត្រូវចាស់ អ្នកអាចនឹងចូលទៅទះស្មាគេ ហើយនិយាយរាក់ទាក់គេយ៉ាងស្និទ្ធស្នាលរហូតដល់គេឆ្ងល់និងធ្វើខ្លួនមិនត្រូវក៏ថាបាន។

ប៉ុន្តែ ១០ ឆ្នាំ សម្រាប់អ្នកក្រមិនអាចរំសាយគំនុំបានទេ ព្រោះចងចិត្តឈឺចាប់មិនព្រមលែង ប្រកាន់យកខ្លួនឯងជាសំខាន់ហួសហេតុពេក។ សុំឱ្យអ្នកក្រទាំងឡាយគិតឱ្យបានច្បាស់លាស់ថា បើមិនមែនជាគំនុំធ្ងន់ធ្ងរអ្វីទេនោះ គ្មាននរណាគេតាមសងសឹកគ្នាឡើយ។

*ពេលវេលាមិនអាចវិលត្រឡប់មកវិញបានទេ គ្រប់យ៉ាងរមែងរសាយទៅតាមពេលវេលាជានិច្ច។*


អ្នក មានគេប្រើរបស់
ដែលមានម៉ាកល្បីៗ
អ្នកមានគេស៊ី
បរិភោកាស
ឡានគឺបងម្ចាស់
ទិញរបស់ប្រើ
បណ្ដាគណទាន
ចាយប្រាក់ឪពុកម្ដាយ
ខ្វះលុយចតឡាន ៥០០០០
បងជួយខ្ញុំបន្តិចទៅ
KTV
អ្នកមានគេច្រៀង
ខារ៉ាអូខេនៅហាងធំៗ
អ្នកមានគេដើរលេងកន្លែងស្អាតៗ!
ទេសចរណ៍ទៅ កូរ៉េ ជប៉ុន
ពុទ្ធោអើយ!
អ្នកមានក្លែងក្លាយ

# ២៣

## អ្នកក្រចាយវាយដូច «អ្នកដែលមានប្រាក់ខែខ្ពស់»

កុំគិតថា អ្នកក្រគ្មានប្រាក់ឱ្យសោះ ហើយក៏កុំគិតថា អ្នកដែលមានប្រាក់មិនមែនជាអ្នកក្រ។ បច្ចុប្បន្ននេះ អ្នកក្រនៅក្នុងទីក្រុងដែលមានប្រាក់ខែ សុទ្ធតែត្រូវគេហៅថាជា «មនុស្សដែលមានការនិយមខ្ពស់តែចំណូលទាប»។

អ្នកដែលមានប្រាក់ខែ ៦៥០ - ១០០០ ដុល្លារ ដែលគ្មានភារៈតែងតែទិញរបស់ និងដើរលេងយ៉ាងសប្បាយចិត្ត ចាប់អារម្មណ៍តែពីរឿងសុខភាពនិងភាពទ្បូយឆាយ មិនចាប់អារម្មណ៍ពីរឿងតម្លៃទេ ចង់ទៅដើរលេងទៅភ្លាម ចង់ទិញអីវ៉ាន់ទិញភ្លាម រស់នៅខ្ជះខ្ជាយហាក់ដូចអ្នកមានស្រួលមិនស្រួល អាចនឹងខ្ជះខ្ជាយជាងអ្នកមានទៅទៀត។ ប្រាក់ខែគ្រាន់ចាយត្រឹមតែមួយខែៗប៉ុណ្ណោះគ្មានប្រាក់សន្សំទេ អ្នកខ្លះរស់នៅជាមួយឪពុកម្តាយ ឱ្យប្រាក់ថ្លៃចិញ្ចឹមលោកតែបន្តិចបន្តួចប៉ុណ្ណោះ លុះចុងខែអស់លុយក៏ហូបបាយផ្ទះ។

អ្នកក្រដែលមានការនិយមខ្ពស់ហួសមាឌតែងតែគិតថា ការលំបាកនិងការនឿយហត់របស់ឪពុកម្តាយមិនមានប្រយោជន៍អ្វីទេ ព្រោះគិតតែពីធ្វើការមិនទាន់សម័យ ចំណែកខ្ញុំវិញដើរទាន់ពិភពលោក រៀនបានខ្ពស់ធំដឹងក្តីឡើងនៅក្នុងសម័យ IT ប្រើអ៊ិនធើណែតយ៉ាងជោកជាំ ស្គាល់ច្បាស់

ពីផ្សារភាគហ៊ុន ហើយជឿថាប្រាក់គ្រាន់តែជាតួលេខប៉ុណ្ណោះ។ ការធ្វើការធ្ងន់ដើម្បីសន្សំប្រាក់ទុកចាយពេលចាស់នោះ គឺជាការនិយមដែលហួសសម័យហើយ មិនអាចប្រៀបនឹងការរស់នៅប្រកបដោយសេចក្តីសុខបានទេ។ នៅក្នុងខ្សែភ្នែករបស់ពួកគេ «ប្រាក់គឺប្រាក់ រកបានមកត្រូវតែចាយ» នឿយហត់ក្នុងការរកប្រាក់បានមកហើយ ត្រូវតែសោយសុខ ចំណែកឯផលប្រយោជន៍ពីការចុះដើមទុន មិនអាចប្រៀបនឹងសេចក្តីសុខពីការចាយប្រាក់បានទេ។

អ្នកក្រដែលមានប្រាក់ខែខ្ពស់ តែងតែប្រាប់ថា ខ្លួននឹងមិនព្រមក្លាយទៅជាទាសកររបស់ប្រាក់ទេ តែងតែសើចចំអកអ្នកដែលព្យាយាមសន្សំសំចៃ តែតាមពិតនោះ បែរជាជួបនឹង «វិបត្តិខាងហិរញ្ញវត្ថុ» ទៅវិញ ព្រោះបើមិនប្រឹងប្រែងធ្វើការងារទេ ឬមិនធ្វើជាទាសករប្រាក់ទេ ជីវិតស្ទើរតែមិនអាចរស់នៅបានឡើយ ព្រោះគ្មានប្រាក់មកសោយសុខ។


គ្រាន់តែសុំឱ្យសន្សំសំចៃថ្លៃចាយបន្តិច ក៏រអ៊ូៗ
គ្រាន់តែសុំឱ្យសន្សំសំចៃថ្លៃស្រាបន្តិចក៏ថាៗ...
គ្រាន់តែសុំឱ្យចេញទៅធ្វើការងារ ក្រៅម៉ោងក៏ ជេរៗ...
គ្រាន់តែសុំចែកប្រាក់មកទិញ គ្រឿងសម្អាងខ្លះក៏វាយតប់ដែរ..
តើពេលណាទើបឯងស្រលាញ់ខ្ញុំ ពិតប្រាកដទៅ?
ពេលដែលមានប្រាក់នោះអី! អីចឹង ខ្ញុំប្រហែលជាអស់សង្ឃឹមហើយ!

# ២៤

## រៀបការជាមួយអ្នកក្រ

ទស្សនៈស្រមើស្រមៃខ្លះលើកឡើងថា «កូនស្រីអ្នកមានរៀបការជាមួយនឹងអ្នកក្រ នឹងរស់នៅជាមួយគ្នាប្រកបដោយសេចក្ដីសុខជានិរន្តរ៍» ជាពាក្យស្រមើស្រមៃដែលមិនច្បាស់លាស់។

មូលហេតុសំខាន់ដែលមនុស្សស្រីរៀបការជាមួយអ្នកក្រ គឺសេចក្ដីស្នេហា តើសេចក្ដីស្នេហានឹងអាចធ្វើឱ្យឆ្អែតក្រពះរហូតបានដែរឬទេ? ចម្លើយគឺ មិនច្បាស់លាស់ទេ។ តាមពិត មានបុរស និងស្ត្រីជាច្រើនគូដែលស្រលាញ់គ្នាស្ទើរលេប ទីបំផុត ត្រូវបែកគ្នាព្រោះបញ្ហារឿងប្រាក់។

ការរៀបការជាមួយអ្នកក្រ មិនមែនជាការធានាថា នឹងធ្វើឱ្យមានសេចក្ដីសុខជានិច្ចទេ។ អ្នកក្រមិនអាចជំនួសការគ្មានប្រាក់ ដោយសារតែការសុភាព ទន់ភ្លន់ និងផ្ដល់កិត្តិយសដល់គូស្នេហ៍ទេ។ ផ្ទុយទៅវិញ បើអ្នកក្ររស់នៅដោយលំបាក និងអាក់អន់ស្រពន់ចិត្តបន្តិចបន្តួច ក៏អាចនឹងធ្វើឱ្យងាយមានអារម្មណ៍មួម៉ៅដែរ ហើយបើរៀនមិនបានខ្ពស់ អាចនឹងដោះស្រាយបញ្ហាដោយអារម្មណ៍គំរោះគំរើយ។

មនុស្សស្រីតែងតែគិតថា មនុស្សប្រុសក្រៗ គួរតែជាមនុស្សដែលស្មោះត្រង់ ចំណែកបុរសអ្នកមាន ចូលចិត្តប្រព្រឹត្តផ្ដេសផ្ដាសនៅក្រៅផ្ទះ។

ប៉ុន្តែ តើដឹងឬទេថា បុរសអ្នកក្របើអាក្រក់វិញនោះ គឺអាក្រក់ជាងអ្នកមានទៅទៀត ព្រោះថាបុរសអ្នកក្រមិនមានអ្វីត្រូវខូចខាតទេ តែបុរសអ្នកមាន នឹងគិតដល់លទ្ធផលដែលតាមមក។ បើឈ្លោះគ្នារហូតដល់ត្រូវលែងលះគ្នានោះ យ៉ាងហោចណាស់មនុស្សស្រីត្រូវបានទទួលទ្រព្យសម្បត្តិក្រោយពេលអាពាហ៍ពិពាហ៍ពាក់កណ្ដាល ឬបើមិនមានទ្រព្យសម្បត្តិទេ យ៉ាងហោចណាស់ក៏បានថ្លៃចិញ្ចឹមកូនដែរ។ ចំណែកបុរសអ្នកក្រវិញ តើគេចិត្តល្អដូច្នេះឬទេ? ព្រោះគេមិនមានមាសប្រាក់ ទ្រព្យសម្បត្តិ សម្រាប់ជាសំណងប្រគល់ឱ្យមនុស្សស្រីទេ ដូច្នេះពេលដែលលែងលះគ្នាមនុស្សស្រីអាចនឹងត្រូវខាតបង់គ្រប់យ៉ាង។

មនុស្សស្រីអាចរៀបការជាមួយនឹងអ្នកក្របាន តែត្រូវមើលឱ្យបានល្អ កុំរៀបការជាមួយនឹងអ្នកក្រដែលមាននិស្ស័យអាក្រក់ គ្មានសម្បជញ្ញៈឱ្យសោះ បើមិនដូច្នោះទេក្នុងជាតិនេះនឹងគ្មានសេចក្ដីសុខអស់មួយជីវិត។

# ជំពូកទី ២

សិក្សាអំពី

## ស្ថានភាពរបស់អ្នកក្រ

បើមិនធ្វើស្រែទេ
អ្នកនឹងគ្មានបាយហូបទេ!



បើមិនចិញ្ចឹមជ្រូកទេ
អ្នកក៏មិនបានហូបភ្លៅជ្រូកដែរ!



បើមិនមានកម្មករទេ
អ្នកក៏គ្មានផ្ទះល្អនៅដែរ!



បើមិនជីកយកធ្យូងថ្មទេ
អ្នកនឹងរងា!



បើមិនសាងផ្លូវថ្នល់ទេ
អ្នកក៏គ្មានផ្លូវធ្វើដំណើរដែរ!



បើមិនមានអ្នកបម្រើទេ
អ្នកក៏មិនបានសោយសុខដែរ!



បើគ្មានអ្នកត្រសាងត្រិះទុកឱ្យទេ
អ្នកមានប្រហែលជាល្វេលត្រាំងចាត់ទៅហើយ!



# ២៥

## អ្នកក្រគឺជាគ្រឹះរបស់សង្គម

បើមើលឱ្យបានល្អិតល្អន់នោះ អ្នកក្រគឺជាមូលដ្ឋានគ្រឹះសម្រាប់មនុស្សនៅក្នុងសង្គមទាំងអស់ ផ្គត់ផ្គង់ឱ្យគ្រប់ជីវិតទាំងអស់អាចរស់នៅបាន ប្រៀបដូចជា «ដី» ដែរ។

ដីគឺជារបស់តូចទាបគ្មានតម្លៃ។ នៅពេលដល់រដូវស្លឹកឈើលាស់ផ្កាទាំងឡាយរីកស្គុះស្គាយ ដីនឹងពោរពេញទៅដោយស្នាមជើង។ ពេលដល់រដូវរងា ដីនឹងក្លាយទៅជាទីជម្រកសម្រាប់មនុស្សគ្រប់គ្នា ឬសឈើនាំគ្នាលក់ស្កប់ស្កល់នៅក្រោមដី ប៉ុន្តែដីខ្លួនឯងបែរជាគ្មានកន្លែងជ្រកកោនទៅវិញ ត្រូវទ្រាំនឹងភាពរងាឯកាម្នាក់ឯង។

ដីបានធ្វើអំពើល្អជាច្រើន តែគ្មាននរណាមើលឃើញទេ ដូចគ្នានឹងភាពជោគជ័យនានានៅក្នុងសង្គមដែរ តែងមិនផ្តល់ភាពសំខាន់ឱ្យអ្នកក្រ ចំណែកគ្រោះមហន្តរាយនៅលើលោកនេះ អ្នកដែលទទួលរងគ្រោះច្រើនបំផុតនោះគឺអ្នកក្រ ប៉ុន្តែរឿងល្អៗដែលមានប្រយោជន៍តែងតែត្រូវអ្នកមានដណ្តើមយកបានមុនជានិច្ច។

បើយើងយកដីដែលជីកមកពីក្នុងព្រៃដាក់នៅក្នុងផើងផ្កា នោះយើងមិនចាំបាច់ដាក់ជីទៀតទេ ព្រោះដីនៅក្នុងព្រៃសម្បូរជីជាតិខ្លាំងណាស់ តម្លៃ

ថោកទៀត។ សួរថាពួកផ្កាដែលរីកលូតលាស់ឡើងពីដីក្នុងព្រៃ តើមានផ្កាណាខ្លះដែលមានតម្លៃថោក? ហើយបើផ្កាទាំងនេះមិនមានដីដ៏មានជីជាតិជួយចិញ្ចឹមទេនោះ តើពួកវានឹងអាចរីកលូតលាស់ដែរឬទេ? គ្រប់យ៉ាងអាចរស់បានដោយសារពន្លឺព្រះអាទិត្យនិងដោយសារតែដី។ តែព្រះអាទិត្យបានទទួលការកោតសរសើរច្រើនល្មមគ្រប់គ្រាន់ហើយ ចំណែកដីបែរជាគ្មាននរណាសរសើរឡើយ។

អ្នកក្រគ្រាន់តែជាចំណែកតូចៗរបស់សង្គមតែប៉ុណ្ណោះ ចង់បន្ថែមម្នាក់ ឬកាត់បន្ថយម្នាក់ក៏មិនសំខាន់អ្វីដែរ។ ប៉ុន្តែ អ្នកក្រគ្រប់គ្នាជួយគាំទ្រសង្គមច្រើនណាស់ បើគ្មានអ្នកក្រដែលទទួលរងទុក្ខវេទនាទេ ក៏គ្មាននរណាអាចរស់នៅប្រកបដោយសេចក្តីសុខដែរ។


បើខ្ញុំមិនញ៉ាំទឹកទេរោងចក្រ
ផលិតទឹកនឹងរលំជាមិនខាន!
បើខ្ញុំមិនបើកភ្លើងទេ
អគ្គិសនិប្រាកដជារលំ!
បើខ្ញុំឈប់ជក់បារី
រដ្ឋនឹងប្រមូល
ពន្ធបានតិចជាមិនខាន!
បើខ្ញុំមិនធ្វើដំណើរទេ ស្ថានីយ៍
រថភ្លើងនឹងត្រូវបិទ !
បើខ្ញុំមិនមើលទូរទស្សន៍ទេ
ស្ថានីយប្រាកដជាត្រូវបិទ!
បើខ្ញុំមិននិយាយទូរសព្ទទេ
ការទំនាក់ទំនងនឹងគ្មានថ្ងៃរីកលូតលាស់ទេ!
កេសផ្ទុះ
កំប៉ុង
បើអ្នកក្រមិនបរិភោគ
ទេ
ក្រុមហ៊ុនធំៗប្រាកដជា
ដួលរលំជាមិនខាន

# ២៦

## អ្នកក្រគឺជាធនធានរបស់ប្រទេសជាតិ

អ្នកក្រគឺជាក្រុមមនុស្សភាគច្រើន ដូច្នេះការរស់នៅរបស់អ្នកក្រនឹងមានផលជាខ្លាំងចំពោះតម្រូវការនៅក្នុងសង្គម ទោះបីជាអ្នកក្រគឺជាវណ្ណ-កម្មករក៏ដោយ តែក៏ជាអ្នកផលិតនិងជាអ្នកបរិភោគដែរ។ អ្នកក្រគឺជាផ្សារខ្នាតធំ ធ្វើឱ្យនាយទុនទាំងឡាយសម្លឹងរកផលប្រយោជន៍តែពីក្រុមនេះប៉ុណ្ណោះ។ បើអ្នកក្របាត់ពីពិភពលោកនេះទៅ នោះសេដ្ឋកិច្ចមិនអាចរីកចម្រើនរុងរឿងបាន ដូចដែលបានឃើញនេះទេ ពិភពលោកអាចនឹងទទេស្អាត គ្មានអ្វីឡើយ។ អ្នកក្រជាធនធានដ៏សំខាន់ មិនមែនត្រឹមតែជាកម្មករជាទីផ្សារ ឬជាអ្នកការពារសន្តិសុខប៉ុណ្ណោះទេ។

ទោះបីជាអ្នកក្រ គឺជាអ្នកការពារសន្តិសុខនៅក្នុងបុរីរបស់អ្នកមាន ឬជាអ្នកយាមវង្គសាលរបស់អ្នកមានក៏ដោយ ប៉ុន្តែក៏ជាអ្នកលះបង់ដើម្បីការពារប្រទេសជាតិនិងប្រជាជន (ព្រមទាំងអ្នកមាន) ដែរ។

*គ្រប់ជីវិតទាំងអស់រស់នៅប្រកបដោយភាពស្ងប់សុខបាននោះ គួរតែអរគុណអ្នកក្រ។*

អ្នកមាន និងអ្នកក្រត្រូវពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកនៅក្នុងសង្គម។ ពិភពលោកយល់ពីចំណុចនេះបានច្បាស់បំផុត ក្នុងប្រការនេះ

ឃើញថា ប្រទេសដែលមានតែងតែបន្ធូរបន្ថយ ឬលើកលែងបំណុលឱ្យប្រទេសដែលក្រីក្រ ឬក៏បរិច្ចាគប្រាក់ជួយប្រទេសដែលក្រីក្រជាញឹកញាប់។

មនុស្សយើងកើតមកសុទ្ធតែជាមិត្តរួមលោកនឹងគ្នា ត្រូវរស់នៅជាមួយគ្នាដោយសុខសប្បាយ ទោះជាមានឋានៈ ស្ថានភាព ឬអ្វីខ្លះៗខុសគ្នាក៏ដោយ។ បើនិយាយតាមការពិតទៅ អ្នកក្រគឺជាចំណែកដ៏សំខាន់ដែលធ្វើឱ្យអ្នកមានអាចរស់នៅបាន ដូច្នេះអ្នកក្រគឺជាធនធានដ៏មានតម្លៃ ដូចការស្រាវជ្រាវរបស់បរិដ្ឋានវិទ្យាបានលើកឡើងថា «បើគ្មានសត្វថ្នាក់ទាបទេ សត្វថ្នាក់ខ្ពស់ក៏មិនអាចរស់នៅបានដែរ»។

ដូច្នេះពេលដែលអ្នកបានទទួលការជួយសង្គ្រោះពីអ្នកមាននោះ មិនបាច់ក្រែងចិត្ត និងមិនបាច់មានអារម្មណ៍ថាវាថោកទាបទេ ព្រោះនោះគឺជាអ្វីដែលអ្នកគួរតែបានទទួល។

ខ្ញុំតែងតែភ្លេចអរគុណបុគ្គលិក...



# ២៧

## គុណដ៏ច្រើនលើសលុបរបស់អ្នកក្រ

បើទោះបីជាអ្នកក្របានសាងគុណូបការៈបានច្រើនបំផុតក៏ដោយ ប៉ុន្តែ ជីវិតរបស់អ្នកក្រក៏មើលទៅហាក់ដូចជាគ្មានតម្លៃបំផុតដែរ ព្រោះមិនថាជាការផលិតទឹក ភ្លើង ត្បូងថ្ម ហ្គាស ប្រេង ដែក ឬឧបករណ៍ប្រើប្រាស់ជាសាធារណៈ ដែលចាំបាច់ដទៃទៀត សុទ្ធតែផលិតដោយស្នាដៃរបស់អ្នកក្រទាំងអស់ ហើយច្រើនតែជាការងារដែលគ្រោះថ្នាក់ទៀតផង។

*ក្នុងប្រទេសចិន ហេតុអ្វីទើបអណ្តូងរ៉ែត្បូងថ្មកើតនូវឧបត្តិហេតុជាញឹកញាប់?*

នោះដោយសារត្បូងថ្មមានតម្លៃខ្ពស់ ការធ្វើអណ្តូងរ៉ែត្បូងថ្មមានកម្រៃយ៉ាងច្រើនមហាសាល ហេតុនេះទើបម្ចាស់អណ្តូងរ៉ែព្យាយាមធ្វើគ្រប់វិធីដើម្បីជីកយកត្បូងថ្មចេញមក ទោះបីជាអណ្តូងរ៉ែត្បូងថ្មគ្រោះថ្នាក់យ៉ាងណាក៏ដោយ។ សួរថា ហេតុអ្វីទើបមានមនុស្សជាច្រើនចង់ទៅធ្វើជាកម្មករទៀត? ងាយណាស់ បើសួរភរិយារបស់កម្មករអណ្តូងរ៉ែដែលស្លាប់ទៅនោះនឹងបានទទួលចម្លើយថា «ប្រាក់ខែដល់ទៅ ១៦០ ដុល្លារ ក្នុងមួយខែឯណោះ វាច្រើនគួរសម»។

១៦០ ដុល្លារ គឺជាថ្លៃអាហារមួយពេលរបស់អ្នកមានប៉ុណ្ណោះ ហើយមិនមែនជាអាហារដែលល្អបំផុតទេ ប៉ុន្តែបែរជាមានអ្នកក្រជាច្រើន ព្រមធ្វើការនឿយហត់ នៅក្នុងកន្លែងដែលគ្មានពន្លឺព្រះអាទិត្យ ថែមទាំង ប្រថុយជីវិតទៀតផង។

អ្នកមានរស់នៅក្នុងគេហដ្ឋានដ៏ស្កឹមស្កៃ បើកឡានស៊េរីទំនើប ប្រើ ជាមពលខ្ជះខ្ជាយ តើអ្នកក្រត្រូវចំណាយញើសឈាមដើម្បីភាពខ្ជះខ្ជាយ របស់អ្នកមានដូច្នេះទៀតឬ?

អ្នកក្រគឺជាអ្នកក្រ មានតម្រូវការដែលគួរឱ្យសង្វេគ ធនធានដែល ពួកគេរកបាននោះ តើនឹងអាចប្រើបានប៉ុន្មានទៅ សុំឱ្យតែបានហូបឆ្អែត ដេកលក់ស្រួល កូនបានចូលរៀន មានប្រាក់ចិញ្ចឹមឪពុកម្តាយគឺគ្រប់គ្រាន់ ហើយ។

ធ្វើល្អជាមួយនឹងអ្នកក្រខ្លះទៅ ព្រោះអ្នកក្រមានគុណចំពោះពួក យើងគ្រប់គ្នាយ៉ាងច្រើន។


ប្រយ័ត្នថូផ្កា
ចោសនៅជ្រុងនោះផង
កុំចាក់រហូតដល់ហៀរដូច្នេះ
ស្រាលដៃបន្តិច
ចង់មានគេមកចាក់ទឹកឱ្យផឹក ប្រាប់ស្នាឱ្យដាំបាយឱ្យហូប នឹងគេដល់ហើយ...

# ២៨

## អ្នកក្រត្រូវគេគ្រប់គ្រង

អ្វីដែលសំខាន់របស់សត្វលោកគឺ ការរស់នៅ និងការបន្តពូជពង្ស ទើបចាំបាច់ត្រូវគ្រប់គ្រងប្រភពនៃធនធានឱ្យបានច្រើនបំផុតដើម្បីឱ្យខ្លួន និងកូនចៅមានភាពរុងរឿង។

នេះជាសញ្ជាតិញ្ញាណនៃការរស់នៅ បើនរណាគ្មានសញ្ជាតិញ្ញាណ នេះទេ ក៏ពិបាកនឹងរស់នៅក្នុងសង្គមដែរ។ ដូច្នេះ មិនមានអ្វីប្លែកទេ បើមនុស្សយើងលោភលន់ នោះព្រោះមនុស្សក៏ជាសត្វមួយប្រភេទដែរ។

យោងតាមការសង្កេតជាក់ស្តែងឃើញថា ព្រំដែនធនធានសម្រាប់មនុស្សមានការពង្រីកមិនមានទីបញ្ចប់ទេ រាប់តាំងពីវត្ថុដែលអាចប៉ះពាល់បានរហូតដល់វត្ថុដែលមិនអាចប៉ះពាល់បាន មានដូចជា ចំណេះដឹង គំនិត និង ទិន្នន័យ ។ល។ ប៉ុន្តែ វត្ថុដែលនៅលើលោកនេះទាំងអម្បាលម៉ានមិនអាចនឹងតបស្នងនូវតម្រូវការរបស់មនុស្សបានគ្រប់គ្រាន់ដែរ ព្រោះមនុស្សតែងតែប្រាថ្នាលើសពីភាពចាំបាច់។

ក្នុងខណៈជាមួយគ្នានេះ មនុស្សក៏បានក្លាយទៅជាផ្នែកមួយនៃធនធានដ៏សំខាន់ដែរ ព្រោះអាចសាងភាពរីកចម្រើនរុងរឿងបាន ដូច្នេះទើបនៅក្នុងការគ្រប់គ្រងមានពាក្យថា «ធនធានមនុស្ស»។

តើអ្នកចង់ធ្វើជាអ្នកគ្រប់គ្រង «ធនធានមនុស្ស» ឬជាអ្នកគ្រប់គ្រងប្រភពនៃធនធាន?

មនុស្សរមែងមិនពេញចិត្តនឹងស្ថានភាពរបស់ខ្លួន មិនចង់ឱ្យអ្នកដទៃមកគ្រប់គ្រង ចង់មានឥទ្ធិពលមហាសាល ចង់មានទាំងប្រភពនៃធនធាន និងមានអំណាចគ្រប់គ្រង កាន់តែច្រើនកាន់តែល្អ។

គ្មាននរណាចង់ត្រូវគេគ្រប់គ្រងទេ ដូច្នេះទើបពិភពលោកនេះមានការដណ្ដើមយកគុណសម្បត្តិ ដែលចាត់ទុកថាជាច្បាប់ធម្មជាតិ។ តែមិនថាសង្គមនឹងផ្លាស់ប្ដូរទៅជាយ៉ាងណាទេ ទីបំផុត អ្នកដែលត្រូវគេគ្រប់គ្រងនោះគឺ «អ្នកក្រ» ជានិច្ច នេះគឺវាសនារបស់អ្នកក្រ។


តំណែងនាយកមិនទំនេរទេ
ធ្វើជានាយករងសិនបានទេ ?
ក្រុមហ៊ុនកំពុងកែទម្រង់ រចនាសម្ពន្ធ ទៅនៅផ្នែកចេញម៉ូងសិនទៅ
មានការងារធ្វើនោះ គឺប្រសើរណាស់ហើយ
កាត់ បន្ថយ ប្រាក់ខែ

# ២៩

## អ្នកក្រតែងតែគិតមិនបានវែងឆ្ងាយ

ហេតុអ្វីបានជាអគារធំៗ នៅក្នុងប្រទេសចិន ច្រើនតែជាស្នាដៃរបស់ស្ថាបនិកបរទេស? អ្នកធុរកិច្ចអចលនវត្ថុដ៏ល្បីឈ្មោះម្នាក់ បាននិយាយលេងសើចថា «ស្ថាបនិកជនជាតិចិនច្រើនតែផ្លាស់ប្តូរគំនិតរបស់ខ្លួនភ្លាមៗដើម្បីប្រាក់ ប៉ុន្តែ ស្ថាបនិកបរទេសតែងតែប្រកាន់ខ្ជាប់នូវគំនិតធ្វើឱ្យស្នាដៃល្អនិងលេចធ្លោជាង មានកេរ្តិ៍ឈ្មោះជាង និងមានតម្លៃខ្ពស់ជាង»។

*ម្នាក់ក្បាលរឹងខ្លាំង ចំណែកឯម្នាក់ទៀតទន់ខ្លាំងពេក នេះហើយគឺជាភាពខុសគ្នារបស់អ្នកមាននិងអ្នកក្រ។*

មិនមែនថា ស្ថាបនិកចិន មិនមានការជឿជាក់លើខ្លួនឯងនោះទេ គ្រាន់តែពួកគេត្រូវការប្រាក់ច្រើនជាង។ បើស្ថាបនិកព្រមធ្វើគ្រប់យ៉ាងដើម្បីប្រាក់បន្តិចបន្តួច ខ្លាចអត់ឃ្លានស្លាប់បើគ្មានការងារធ្វើ (ស្ថាបនិកបរទេសទារថ្លៃចេញម៉ូដថ្លៃជាងស្ថាបនិកចិនប្រហែលជា ១០ ដង) មិនបានឧទ្ទិសខ្លួនដើម្បីសិល្បៈ និងស្នាដៃពិតប្រាកដទេនោះ ពេលនៅចំពោះមុខថៅហ្វាយនាយក៏គ្មានថ្ងៃនឹងបញ្ចេញគំនិតប្លែកៗចេញមកបានដែរ។

ការឧទ្ទិសខ្លួន ឬមានស្មារតីទទួលខុសត្រូវ គឺជារឿងដែលគួរឱ្យកោតសរសើរជាខ្លាំង គ្រប់គ្នាអាចធ្វើបាន សុំកុំឱ្យបាត់បង់ការជឿជាក់លើ

ខ្លួនឯង គឺគ្រប់គ្រាន់ហើយ។ ក្នុងនោះបើមិនជឿជាក់លើខ្លួនឯងទេ ការ
ឧទ្ទិសខ្លួនគ្រាន់តែជាខ្យល់ប៉ុណ្ណោះឯង។

ពេលខ្លះ «ឧត្តមគតិរបស់អ្នកក្រ» គេចមិនផុតពីការក្លាយជាខ្យល់ទេ ព្រោះសង្គមបង្ខំឱ្យអ្នកក្រគ្មានផ្លូវ និងគិតឱ្យបានវែងឆ្ងាយឡើយ។ អ្នកក្រតែងតែក្លាយជាអ្នកដែលត្រូវគេគាបសង្កត់ និងត្រូវគេគ្រប់គ្រង។ ជាច្រើនលើកច្រើនសា អ្នកក្រត្រូវតែព្រមដើម្បីរស់ រហូតដល់គ្រប់គ្នាមើលរំលងសមត្ថភាពពិតប្រាកដ ទើបអ្នកក្របាត់បង់ឱកាសអភិវឌ្ឍខ្លួន។ ទីបំផុតត្រូវធ្វើតាមពាក្យបញ្ជារបស់ចៅហ្វាយនាយ ហើយរស់នៅក្នុងស្ថានភាពដូចដើមបន្តទៀត។

បើអ្នកក្រមិនចាប់ផ្តើមគិតឱ្យបានវែងឆ្ងាយទេ អ្នកក្រនឹងគ្មានថ្ងៃបានរីកចម្រើនឡើយ។



យើងនៅសល់ពងមាន់
តែមួយគ្រាប់ប៉ុណ្ណោះ
ត្រូវតែភ្ញាស់វា...
យកពងមាន់ភ្ញាស់
ជាកូនមាន់
យកមាន់ទៅប្ដូរ
យកចៀម
ពេលដែលកើត
កូនចៀមហើយ
យកទៅប្ដូរ
យកគោ
លក់កូនគោ
ទៅទិញស្រែ
សង់ផ្ទះ
រកប្រពន្ធកុងម្នាក់
ពិតជាអាក្រក់មែន!
ខ្ញុំស្អប់ពងមាន់មួយគ្រាប់នេះណាស់
ពុទ្ធោអើយ!
នាងធ្វើឱ្យក្ដីស្រមៃរបស់ខ្ញុំ
រលាយអស់ហើយ...

# ៣០

## អ្នកក្រមានដើមទុនតិច តែមានហានិភ័យខ្ពស់

ដើមទុនកាន់តែតិច ហានិភ័យកាន់តែខ្ពស់ ពេលដែលអ្នកក្រមានពងមាន់ត្រឹមតែមួយគ្រាប់ បើកាន់មិនប្រយ័ត្នធ្វើឱ្យពងមាន់ធ្លាក់បែកនោះគ្រប់យ៉ាងនឹងត្រូវចប់ នេះហើយគឺជាចំណុចខ្សោយរបស់អ្នកក្រ។

*វិថីដែលមិនបានក្រាលទៅដោយស្រទាប់ផ្កាកុលាប ធ្វើឱ្យអ្នកក្រត្រូវតែគិតពិចារណាឱ្យបានល្អ និងល្អិតល្អន់។*

តាមពិតទៅ បើអ្នកក្រចេះវិធីរកប្រាក់ និងមានដើមទុនបន្តិចនោះភាពជោគជ័យនឹងនៅមិនឆ្ងាយពីដៃទេ ដូចជា ប៊ីល ហ្គេត (Bill Gates) ក៏ធ្លាប់ជាអ្នកកសាងខ្លួននៅក្នុងពេលដំបូងដោយដើមទុនតិច មិនខុសអ្វីពីពងមាន់មួយគ្រាប់ដែរ។ តែគាត់អាចមានរហូតដល់ជាប់លំដាប់ពិភពលោកបាន ប៉ុន្តែតើអ្នកអាចធ្វើបានដូចជា ប៊ីល ហ្គេត ឬអត់នោះ ក៏ពិបាកនឹងនិយាយដែរ។

ចំណុចចាប់ផ្ដើមរបស់អ្នកក្រនោះទាបណាស់ ទោះជាមានឱកាសល្អបំផុតក៏ដោយ ក៏ដើមទុនរបស់អ្នកក្រមិនអាចកើនឡើងបាន ក្នុងរយៈពេលមួយប៉ប្រិចភ្នែកដែរ ដោយសារតែដើមទុនតិច ទើបមិនអាចចុះទុនបានពេញទំហឹងព្រោះមានកំណត់។

ការដែលអ្នកក្រអាចពង្រីកធុរកិច្ចតូចឱ្យទៅជាធុរកិច្ចធំបាននោះ គឺប្រៀបដូចជាការប្តូរពងមាន់មួយគ្រាប់ឱ្យទៅជាគោមួយហ្វូងដូច្នោះដែរ។

វិធីនៃការផ្លាស់ប្តូរនេះ មានបច្ច័យនិងដំណាក់កាលផ្សេងៗជាច្រើន បើអ្នកមិនអាចឆ្លងកាត់ដំណាក់កាលទាំងអស់បានទេ អ្នកក៏មិនអាចបានភ្លក្សរសជាតិជាអ្នកមានបានដែរ។

ភាពមានបានក៏ជាសម្ពាធសម្រាប់អ្នកក្រដែរ ដូចជា អ្នកជ្រមុជទឹកដែលដឹងច្បាស់ថា បើមុជចុះទៅជ្រៅក្នុងសមុទ្រយ៉ាងឆាប់រហ័សនោះ នឹងធ្វើឱ្យចេញឈាមតាមទ្វារទាំង ៩ បាន។



សុំងាកបន្តិច
សុំផ្លូវបន្តិច
សុំផ្លូវម្តងទៀត
លើកម្ហូបរំលងក្បាលខ្ញុំរហូត
ឈប់ហូបហើយ!
ឆាប់ត្រឡប់ទៅវិញភ្លាមទៅ
បានកន្លែងអង្គុយប្រសើរណាស់ហើយ
នៅរៀងច្រើនទៀត!

# ៣១

## អ្នកក្រតែងតែបានទីតាំងមិនល្អ

អ្នកក្រជនជាតិចិនទៅហូបបាយ ផឹកតែ ប្រជុំ ឬក្នុងឱកាសដែលមានមនុស្សច្រើន នឹងត្រូវចាត់ឱ្យមាន «កន្លែងអង្គុយ» មិនមានផលល្អ។

អ្នកដែលមានតំណែងធំបំផុត ត្រូវតែអង្គុយកន្លែងដែលល្អបំផុតគឺខ្នងទល់ទៅនឹងជញ្ជាំង មុខបែរទៅរកទ្វារធំ ជាតំណែងដែលមើលបានឆ្ងាយដោយមិនបាច់បារម្ភខាងក្រោយ និងអាចមើលបានគ្រប់ទិសទី បានឮសំឡេងពីគ្រប់កន្លែង ប្រៀបបីដូចមេទ័ពដែលអាចគ្រប់គ្រងស្ថានការណ៍បានគ្រប់ទិសទីនោះឯង។

ចំណែកអ្នកដែលមានតំណែងទាបជាង ត្រូវអង្គុយទល់មុខនឹងតំណែងដែលល្អបំផុត ជាកន្លែងដែលមិនអាចគ្រប់គ្រងស្ថានការណ៍បានទេ ពេលដែលអ្នកបម្រើលើកអាហារមកត្រូវចាំគេច។

ទើបអ្នកក្ររមែងបានទីតាំង ឬតំណែងមិនសូវល្អ ប្រថុយជាមួយគ្រោះថ្នាក់មុនគេ ហើយបើមានប្រយោជន៍មកនៅចំពោះមុខ អ្នកក្រនឹងបានទទួលប្រយោជន៍នោះក្រោយគេ។ ឋានៈរបស់អ្នកក្រ ជាគ្រឿងកំណត់ថាគេជាមនុស្សទន់ខ្សោយ និងគ្មានគុណសម្បត្តិគ្រប់គ្រាន់ ដូច្នេះរាល់លើក

ដែលសង្គមផ្លាស់ប្តូរ  អ្នកក្រគឺជាអ្នកដែលទទួលការខូចខាតច្រើនបំផុត ហើយបានទទួលនូវឱកាសល្អៗតិចបំផុត។

អ្នកក្រចង់ក្លាយទៅជាអ្នកមាន  អ្នកក្រចង់ឡើងពីកន្លែងទាបទៅកាន់កន្លែងខ្ពស់ គឺជាស្ថានការណ៍មួយពិបាកនឹងធ្វើខ្លាំងណាស់ អ្នកខ្លះត្រូវព្យាយាមយ៉ាងយូរពីមួយជំនាន់ទៅមួយជំនាន់ទៀតផង។


ដើរប្រមូលប្រាក់ ពិតជាងាយមែន
ស្រួលជាងធ្វើការងារច្រើនណាស់!
អ្ហាក ! ចាញ់ល្បិចគេហើយ
នេះជាប្រាក់របស់ខ្ញុំទេ
យើងមិនព្រមចុះចាញ់ឯងទៀតទេ
កុយ! ពួកកូនមាន់ក្នុងកណ្ដាប់ដៃ
នាយទុន

# ៣២

## អ្នកក្រគឺជាអ្នកទន់ខ្សោយជានិច្ច

អ្នកក្រជាអ្នកដែលចាញ់ប្រៀបជានិច្ច ទើបអ្នកក្រក្លាយទៅជាអ្នកដែលទន់ខ្សោយរហូតមក។

នៅក្នុងផ្សារភាគហ៊ុន អ្នកជំនួញតូចៗ ដូចជាអ្នកក្រត្រូវផ្ទៀងត្រចៀកស្តាប់គ្រប់ពេល ព្យាយាមរកប្រភពព័ត៌មានឱ្យបានច្រើន រំពឹងថានឹងតាមឱ្យទាន់ព័ត៌មាន ដើម្បីប្រមូលយកផលប្រយោជន៍ ប៉ុន្តែ ជាច្រើនលើកច្រើនសា ការនេះបានក្លាយទៅជាចំណីដ៏ឆ្ងាញ់មាត់របស់អ្នកកំណត់សកម្មភាពដោយស្វ័យប្រវត្តិទៅវិញ។

«ព័ត៌មាន» ក្នុងផ្សារភាគហ៊ុនគឺជាអ្វី? និយាយដោយងាយទៅគឺជាមនុស្សក្រុមតូចៗ ដែលជំនាញក្នុងការក្រឡុកភាគហ៊ុន អាចជាអង្គភាពគណៈបុគ្គល ឬក្រុមហ៊ុនដែលនៅក្នុងផ្សារភាគហ៊ុននោះ ដែលប្រាកដនោះគឺ ពួកគេទាំងនេះមិនបានមកជួយពួកអ្នកក្រទេ ព្រោះគ្រប់គ្នាសុទ្ធតែស្វែងរកកម្រៃទាំងអស់។

ប៉ុន្តែ ទីផ្សារភាគហ៊ុនគ្រាន់តែជាទីផ្សារ ដែលមានប្រាក់ដើមទុនបង្វិលចេញចូលប៉ុណ្ណោះ ប្រាក់ចេញពីកាបូបរបស់អ្នកទៅចូលក្នុងកាបូបរបស់អ្នកដទៃ ឬចេញពីកាបូបរបស់អ្នកដទៃមកចូលក្នុងកាបូបរបស់អ្នក។

វិធីស្វែងរកកម្រៃរបស់ «ព័ត៌មាន» គឺ «*បញ្ឆោត អូសទាញ និងសម្លាប់*» គឺជាវិធីប្រើសម្រាប់សម្លាប់ «អ្នកដែលគ្មានបទពិសោធ» ដូចជាអ្នកក្រហ្នឹងឯង។

ទីផ្សារស្ទើរតែគ្រប់ប្រភេទ សុទ្ធតែមានអ្នកក្របណ្ដាក់ទុនទាំងអស់ ហើយអ្នកក្រចាញ់ប្រៀបជានិច្ច បើទិន្នន័យដែលបានទទួលមកមិនត្រឹមត្រូវ។ អ្នកក្រនឹងមិនអាចវាយតម្លៃពីហានិភ័យបានទេ ក្លាយទៅជាភាគីដែលត្រូវគេដេញតាមសម្លាប់ ហើយអ្នកក្រតាមមិនទាន់ល្បិចកលរបស់ពួកដែលមានជំនាញដែលមានប្រាក់មហាសាល និងមានបក្សពួកទេ។

អ្នកដែលទន់ខ្សោយនៅក្នុងផ្សារភាគហ៊ុន គឺជាអ្នកជំនួញតូចតាច អ្នកទន់ខ្សោយនៅក្នុងសង្គមគឺជាអ្នកក្រ អ្នកក្រតែងតែត្រូវគេធ្វើបាបជានិច្ច ព្រោះប្រាជ្ញាខ្សោយនិងខ្វះបទពិសោធ។


គ្មានប្រាក់ទិញឧបករណ៍សិក្សាឱ្យកូនទេ
ថ្លៃទិញនេះទិញនោះរបស់កូនជាច្រើនទៀត!
ថ្លៃចូលរៀនរបស់កូន
ត្រូវសុំខ្ចីលុយគេទៀតហើយ!
មក
ប្រណាំង
គ្នា
កូនរបស់ប៉ា
បានចូល
មហាវិទ្យាល័យហើយ

# ៣៣

## អ្នកក្រមានការសិក្សាទាប

អ្នកមានអាចបញ្ជូនកូនរបស់ខ្លួនឱ្យរៀនបានខ្ពស់ ចំណែកអ្នកក្រវិញគ្រាន់តែបញ្ជូនកូនឱ្យបានចូលរៀនថ្នាក់មូលដ្ឋាននៅពិបាកផង។

គ្រួសារអ្នកក្រជនជាតិចិន ជាពិសេសនៅតាមជនបទ និងកន្លែងដាច់ស្រយាល បើឪពុកម្តាយចង់បញ្ជូនកូនឱ្យបានចូលរៀន គឺបានត្រឹមតែរៀននៅក្នុងសាលារៀនដែលចាស់ទ្រុឌទ្រោម ខ្វះខាតគ្រូ និងឧបករណ៍សិក្សាប៉ុណ្ណោះ ចង់រៀនឱ្យពូកែជាងអ្នកដទៃនោះ គឺពិបាកខ្លាំងណាស់។

អ្នកក្រព្រមលក់របស់របរគ្រប់យ៉ាង គ្រាន់តែដើម្បីឱ្យកូនបានចូលរៀនថ្នាក់មូលដ្ឋានប៉ុណ្ណោះ ទោះបីជាដឹងថា ការសិក្សាត្រឹមកម្រិតនេះ មិនគ្រប់គ្រាន់ក្នុងការផ្លាស់ប្តូរវាសនារបស់កូនៗក៏ដោយ តែក៏ប្រសើរជាងមិនបានទទួលការសិក្សាអ្វីទាល់តែសោះដែរ។

ការសិក្សារបស់អ្នកក្រសម័យនេះ ច្រើនតែបញ្ចប់នៅត្រឹមថ្នាក់មធ្យមសិក្សាបឋមភូមិ ធ្វើឱ្យការប្រកួតប្រជែងគ្នារវាងអ្នកក្រ និងអ្នកមានមិនបានចាប់ផ្តើមត្រង់ «ចំណុចចាប់ផ្តើម» តែមួយទេ។

កម្រិតសិក្សាទាប គឺជាចំណុចខ្សោយរបស់អ្នកក្រ ហើយក៏ជាចំណុចខ្សោយរបស់សង្គមដែរ។ ភាពអយុត្តិធម៌ក្នុងការសិក្សា ធ្វើឱ្យមនុស្ស

យើងមានឱកាសក្នុងការអភិវឌ្ឍខ្លួនខុសគ្នាស្រឡះ។ ភាពមិនស្មើភាពគ្នាក្នុងការសិក្សាធ្វើឱ្យអ្នកមានអំណាចកាន់តែមានអំណាចខ្លាំងឡើង ហើយអ្នកក្រកាន់តែក្រឡើងជារឿយៗ។ យ៉ាងណាក៏ដោយ ទោះបីជាបានទទួលការសិក្សាស្មើគ្នាក៏ដោយ ប៉ុន្តែអ្នកដែលមានឋានៈល្អជាងតែងតែមានឱកាសបានអភិវឌ្ឍខ្លួនក្រោយពីរៀនចប់ច្រើនជាងដែរ។

ការសិក្សាអាចផ្លាស់ប្តូរវាសនាបាន ហើយការសិក្សាស្មើរតែជាក្តីសង្ឃឹមតែមួយគត់របស់អ្នកក្រ។ តែតាមពិតនោះ ពេលខ្លះអ្នកក្រដែលមានបរិញ្ញាបត្រក៏នៅតែគ្មានការងារធ្វើដែរ។



ប្រើហ្គាសដូច្នេះ គ្រោះថ្នាក់ណាស់!
មិនអីទេ! ប្រើយូរហើយ
ប្រើទៀនដូច្នេះ គ្រោះថ្នាក់ណាស់!
មិនអីទេ! ប្រើយូរហើយ
ចាក់សោផ្ទះបែបនេះ គ្រោះថ្នាក់ណាស់!
មិនអីទេ ធ្វើដូច្នេះមកយូរហើយ!
ផ្ទះទ្រុឌទ្រោមដូច្នេះ គ្រោះថ្នាក់ណាស់!
មិនអីទេ! នៅសុខមករហូត
អ្ហូក! រ៉ុកម៉ក់ដឹកអេតចាយរបស់ខ្ញុំបាត់ទៅណាហើយ
ជីវិត មិនមាន សុវត្ថិភាពរហូតទេ

# ៣៤

## អ្នកក្រមានជីវិតដែលគ្មានសុវត្ថិភាព

អ្នកក្រមានទ្រព្យសម្បត្តិត្រឹមតែមួយចានកំបែកប៉ុណ្ណោះ ប៉ុន្តែអ្នកមាន មានទ្រព្យសម្បត្តិមហាសាល ទើបយើងតែងតែគិតថា អ្នកមានគួរតែមានឱកាសបាត់បង់ទ្រព្យសម្បត្តិច្រើនជាងអ្នកក្រ។ ប៉ុន្តែ ជោគវាសនាមិនកាន់ជើងនរណាទេ របស់តែបន្តិចដែលអ្នកក្រមាននោះ អាចនឹងត្រូវអ្នកដែល «ក្រជាង» លួចទៅក៏ថាបាន។

នៅក្នុងប្រទេសដែលប្រើកង់ច្រើន ក៏មានមនុស្សដែលត្រូវបានគេលួចកង់ជាច្រើនដែរ លួចច្រើនជាងឡានទៅទៀត ព្រោះការលួចឡានគឺជារឿងធំ ពាក់ព័ន្ធនឹងមនុស្សច្រើន ទីបំផុត ប៉ូលីសអាចនឹងស៊ើបរកឡាននោះត្រឡប់មកវិញបាន ឬក្រុមហ៊ុនធានារ៉ាប់រងដែលម្ចាស់ឡានបានធ្វើកិច្ចសន្យានឹងមកទទួលខុសត្រូវទៅតាមលក្ខខណ្ឌ។ អ្នកមានស្ទើរតែមិនបាច់ខាតបង់អ្វីឡើយ ប៉ុន្តែ បើកង់បាត់វិញ តើនរណានឹងមកចាប់អារម្មណ៍?

*សម្រាប់អ្នកក្រ កង់មួយគ្រឿង ចាត់ទុកថា ជាសម្បត្តិដ៏មានតម្លៃយ៉ាងខ្លាំង។*

ក្តីទុក្ខរបស់អ្នកក្រគឺ មានតែអ្នកក្រប៉ុណ្ណោះដែលដឹង ព្រោះរស់នៅក្នុងបរិបទដែលច្របូកច្របល់ ពោរពេញទៅដោយភាពគំរោះគំរើយ និងភាពហិង្សាមកជាយូរ ធ្វើឱ្យអ្នកក្រមានវិធីក្នុងការរស់នៅរបស់ខ្លួន។

នៅក្នុងប្រទេសចិន អ្នកក្រមិនជឿច្បាប់ទេ តែងតែមើលពីលទ្ធផលប៉ុណ្ណោះ ដូច្នេះភាពហិង្សានៅក្នុងក្រុមអ្នកក្រគួរឱ្យខ្លាចខ្លាំងណាស់។

បើមានទ្រព្យសម្បត្តិតិច ក្តីកង្វល់ក៏តិចដែរ។ ពេលដែលក្តីកង្វល់តិច ភាពក្លាហាននឹងមានច្រើន អាចនឹងគិតធ្វើអំពើអាក្រក់តែម្តង។

អ្នកក្រគួរឱ្យអាណិតណាស់ ការការពារខ្លួនឱ្យរស់នៅប្រកបដោយសុវត្ថិភាពនោះពិបាកជាងអ្នកមានទៅទៀត។

នេះសមដូចអ្នកសេដ្ឋសាស្ត្រនិយាយថា " Money is Security លុយជាសន្តិសុខ"។


ប្រកាសថា មានតែមនុស្ស ១០ នាក់ប៉ុណ្ណោះដែលបាន
បស់នេះ យើងសំណាងណាស់!
អស់ទាស់!
ចុះទុនអស់ ១៥០០ ដុល្លារ ពិតជាចំណេញមែន!
យើងនឹងក្លាយជាសេដ្ឋីហើយ!
ភ្ញាក់ផ្អើលខ្លាំងណាស់!
មែនហើយ!
របស់មានតម្លៃគេខ្ចប់បែបនេះហើយ!
ជិតបានហើយ!
យើញហើយ
យើងមានហើយ
ប្រាកដជាមានមិនខាន គ្រាន់តែរកអាល្ងង់ដូចឯងឱ្យបាន ១០០ តែប៉ុណ្ណោះ!

# ៣៥

## អ្នកក្រងាយនឹងត្រូវគេបោកប្រាស់ណាស់

យើងរមែងតែឃើញការប្រកាសបបួល និងជំរុញឱ្យ «ឆាប់មាន» តាមទំព័រកាសែតឬគេហទំព័រ ដែលនិយាយថា មិនបាច់ចុះដើមទុន មិនចាំបាច់ត្រូវនឿយហត់ នៅស្ងៀមៗ ធ្វើការងារស្រួលៗ នៅតែផ្ទះក៏អាចមានបានដែរ។ នៅលើលោកនេះមានការងារស្រួលៗបែបនេះដែរឬ?

ល្បិចបោកបញ្ឆោតទាំងនេះ មានតែអ្នកក្រខ្វះប្រាជ្ញា និងចង់មានតាមផ្លូវកាត់ប៉ុណ្ណោះដែលជឿ។ ការងារដែលរកប្រាក់បានច្រើន តែនៅទំនេរៗនោះ សបញ្ជាក់ថា ការងារនោះមានហានិភ័យខ្ពស់ខ្លាំងណាស់ ភាពប្រថុយ និងផលប្រយោជន៍តែងតែប្រែប្រួលទៅតាមគ្នាដែរ។

តាមពិតទៅ ល្បិចបោកបញ្ឆោតគ្រប់ប្រភេទ តែងមានមាយាការ និងមានបច្ច័យមួយចំនួន ដែលមិនអាចត្រួតពិនិត្យឬសង្កេតឃើញបាន មិនអាចគ្រប់គ្រងបាន ហើយគឺជាចំណុចសំខាន់ទៀតផង។ ល្បិចបោកបញ្ឆោតរមែងរៀបចំផែនការយ៉ាងល្អ តែអ្នកក្រភាគច្រើននៅតែជឿតាមផលប្រយោជន៍បោកប្រាស់ ហើយមើលរំលងគ្រោះថ្នាក់ជានិច្ច។

អ្នកក្រមិនដែលទៅនៅក្នុងទីផ្សារបណ្តាក់ទុន ទើបមិនដឹងទេថា នាយទុនសម្លឹងរកតែផលប្រយោជន៍ជាសំខាន់។ អ្នកក្រតែងតែគិតថា អ្នក

ទេមានបំណងល្អ និងមកជួយរំដោះទុក្ខ។ សេចក្តីរីករាយបានធ្វើឱ្យអ្នកក្រភ្លេចថា ខ្លួនកំពុងតែបណ្តាក់ទុន។ ថ្វីត្បិតតែប្រើប្រាក់បណ្តាក់ទុនមិនច្រើនក៏ដោយ តែក៏ជាប្រាក់សន្សំដែលខំសន្សំមកអស់មួយជីវិតដែរ។

បើសេដ្ឋីដែលមានទឹកប្រាក់រាប់រយលានម្នាក់ នឹងបណ្តាក់ទុនធ្វើអ្វីមួយនោះ គេត្រូវតែរៀបចំគម្រោងបណ្តាក់ទុនឱ្យបានល្អិតល្អន់ តែអ្នកក្របែរជាមិនគិតដូចអ្នកមានទេ នៅពេលដែលគិតចង់មានក៏យកប្រាក់ទៅបណ្តាក់ទុនដោយមិនបានពិចារណាឱ្យបានច្បាស់លាស់ ទម្រាំតែដឹងខ្លួនថាចាញ់បោកគេនោះ ត្រូវគេយកប្រាក់រត់បាត់ទៅហើយ ទីបំផុតបានត្រឹមតែបន្ទោសមេឃដីប៉ុណ្ណោះ។

អ្នកក្រមានដើមទុនតិចស្រាប់ទៅហើយ បើត្រូវគេបោកប្រាស់ត្រឹមតែម្តងនោះអាចនឹងមិនអាចស្រោចស្រង់ឡើងវិញបានឡើយ។


សរសេររបាយការណ៍ ជាបន្ទាន់!
ទៅបើកប្រាក់ជាបន្ទាន់!
ធ្វើបញ្ជីនេះជាបន្ទាន់!
យកទៅទុកជាបន្ទាន់!
លោកចៅហ្វាយធ្វើការច្រើនបែបនេះ មិនគិតសម្រាកខ្លះទេឬ?
បញ្ជារួចអញសម្រាកហើយ មិនឃើញទេឬ?

# ៣៦

## អ្នកក្រធ្វើការមិនបានសម្រាក

កសិករគឺជាមនុស្សដែលអស្ចារ្យបំផុត ព្រោះមិនថាអ្នកណាធំមកពីទីណាទេ ត្រូវតែហូបបាយទាំងអស់ កសិករគឺជាអ្នកផលិតអង្ករឱ្យ ប៉ុន្តែបែរជាក្រលំបាកបំផុត និងមានឋានៈទាបបំផុតទៅវិញ។

*ហេតុអ្វីទើបទៅជាយ៉ាងដូច្នេះ?*

ពន្លឺព្រះអាទិត្យចាំបាច់សម្រាប់មនុស្សក៏ពិតមែន តែមនុស្សបានវាមកដោយទទេៗ ទើបពន្លឺព្រះអាទិត្យគ្មានតម្លៃអ្វីឡើយ។ ហើយទោះជាស្រូវដុះឡើងពីធម្មជាតិ ជាធនធានដែលមានតម្លៃយ៉ាងខ្លាំងក៏ដោយ តែដែលអាចឱ្យយើងយកមកបរិភោគបាននោះ ក៏ត្រូវអាស្រ័យលើកម្លាំងរបស់មនុស្ស។ ដូច្នេះធនធានដែលមានតម្លៃបំផុតគឺ «មនុស្ស» នេះឯង។

ដោយសារតែធនធានមនុស្សមានតម្លៃជាងធនធានវត្ថុ ទើបអ្នកដែលទាញយកប្រយោជន៍ពីមនុស្សមានជាងអ្នកដែលទាញយកប្រយោជន៍ពីវត្ថុ ហើយអ្នកមាន គឺជាអ្នកគ្រប់គ្រងធនធានមនុស្សនេះឯង។

នៅក្នុងទ្វីបអាមេរិក មានស្រមោចមួយប្រភេទដែលមានឈ្មោះថា «ស្រមោចអាម៉ាហ្សូន» ពួកវាស្វែងរកចំណីដោយការប្លន់ពីសំបុកស្រមោចដែលនៅក្បែរៗនោះ និងបានកេណ្ឌយកស្រមោចជាច្រើនទៅធ្វើជាទាសករ

របស់វាទៀតផង។ ស្រមោចដែលជាទាសករទាំងនេះវេទនាខ្លាំងណាស់ត្រូវធ្វើការងារគ្រប់យ៉ាងដើម្បីរស់ ទីបំផុត ពួកវាក៏ទម្លាប់ទៅនឹងភាពជាទាសករ ហើយខិតខំប្រឹងប្រែងធ្វើការដូចកាលដែលនៅសំបុកចាស់ដែរ។

ប៉ុន្តែ អ្វីដែលមិនគួរឱ្យជឿនោះគឺ រាល់លើកដែលពួកស្រមោចអាម៉ាហ្សូនទៅប្លន់ចំណី ពួកវានឹងមិនសម្លាប់ភាគីម្ខាងទៀតឱ្យអស់ទេ គឺនឹងទុកជីវិតឱ្យស្រមោចញីខ្លះឈ្មោលខ្លះដើម្បីបន្តពូជតទៅទៀត ដើម្បីជាការធានាថា នឹងមានស្រមោចដែលជាទាសករសម្រាប់ឱ្យពួកវាបានប្រើរហូតទៅ។

ធម្មជាតិរបស់សត្វពេលខ្លះក៏ជាគំរូសម្រាប់បង្រៀនមនុស្សដែរ។


តើទិញទឹកដោះគោម្សៅម៉ាកអ្វីទៅ?
ទិញបែបថោក ៗទៅ
តើទិញឈុតគេងម៉ាកអ្វីទៅ?
ទិញបែបថោក ៗទៅ
តើចង់ញ៉ាំអ្វី?
ញ៉ាំបែបថោក ៗទៅ
ថោក ៗ ៗ! មិនដឹងទេឬថារបស់ថោកនោះ
វាអន់ដល់កម្រិតណា?
ដឹង...តែប្រាក់ខែរបស់ខ្ញុំវាថោកបំផុត

# ៣៧

## តើអ្នកក្រនឹងទិញរបស់ដែលថ្លៃៗបានយ៉ាងដូចម្ដេចទៅ?

នរណាៗក៏ស្អប់អ្នកជំនួញដែលផលិតទំនិញ ដែលមានគុណភាពអន់ដែរ តែហេតុអ្វីទើបអ្នកជំនួញទាំងនោះនៅតែសោយសុខដដែល? ព្រោះនៅមានអតិថិជនថ្នាក់ទាបជាច្រើនទៀត ដែលទិញទំនិញទាំងនោះ ដែលអ្នកទាំងនោះគឺ «អ្នកក្រ»។ ការដែលអ្នកក្រទិញទំនិញគុណភាពអន់នោះគឺជាការបំផ្លាញខ្លួនឯង និងជួយគាំទ្រអ្នកជំនួញទាំងនោះទៅវិញទេ។

អ្នកក្រមិនអាចមិនទិញទំនិញដែលមានគុណភាពអន់បានទេ ព្រោះគ្មានប្រាក់គ្រប់គ្រាន់ដើម្បីទិញទំនិញល្អៗប្រើ ដូចជា ទឹកដោះគោម្សៅ ត្រូវឆុងឱ្យទារកញ៉ាំជាច្រើនដបក្នុងមួយថ្ងៃៗ គេញ៉ាំតិចមិនបានទេ ដូច្នេះទើបចាំបាច់ត្រូវកាត់បន្ថយគុណភាពទឹកដោះគោ ទិញតែទឹកដោះគោដែលមានតម្លៃថោកមកឆុងដើម្បីឱ្យបានច្រើន។ ទឹកដោះគោដែលនាំចូលពីបរទេសមានតម្លៃថ្លៃ មានគុណភាពមែនហើយ តែទឹកដោះគោគុណភាពអន់ដែលមានតម្លៃថោកជាង នឹងសន្សំសំចៃបានច្រើនជាង។

អ្នកក្រចាំបាច់ត្រូវបរិភោគទំនិញដែលមានតម្លៃថោក ទោះបីដឹងច្បាស់ថា ទំនិញដែលមានតម្លៃថោកនោះ មានគុណភាពមិនល្អយ៉ាងណាក៏ដោយ រហូតដល់ពេលខ្លះ សុំទៅនឹងទំនិញដែលមានតម្លៃថោកទៅហើយ សុំកុំឱ្យប៉ះពាល់ដល់សុខភាពខ្លាំងពេក ឬកុំឱ្យប៉ះពាល់ដល់សុខភាពភ្លាមៗ

នឹងប្រើបណ្ដោះអាសន្នសិនហើយ មានប្រើប្រសើរជាងមិនមាន។ អ្នកខ្លះផល់ថ្នាក់អរគុណដល់ទំនិញគុណភាពអន់ទាំងនេះទៀតផង។

បើអ្នកទៅមើលតាមផ្សារនៅក្បែររោងចក្រ ឬនៅជាយក្រុងនោះ អ្នកនឹងយល់ហើយ ព្រោះជាកន្លែងប្រមូលផ្ដុំទំនិញតម្លៃថោកៗ ហើយភាគច្រើន គឺជាទំនិញដែលមានគុណភាពអន់ ប៉ុន្ដែបែរជាមានការនិយមយ៉ាងខ្លាំង តើមកពីហេតុអ្វីទៅ?

*ដោយសារតែមានតម្លៃថោកខ្លាំងនោះអី!*

អ្នកក្រចូលចិត្តទំនិញថោកៗ មិនមែនព្រោះគេល្ងង់ទេ តែដោយសារតែគេគ្មានប្រាក់។


ហាត់ឈឺ!
ផ្ដាសសាយហើយ!
ផ្នែកនេះត្រូវលក់បន្លែផង
ប្រញាប់ទៅរកគ្រូពេទ្យភ្លាម!
អូនសម្លាញ់ បងលែងហ៊ានឈឺ
ទៀតហើយ !
ជំងឺផ្ដាសាយកំពុងរាត្បាត ត្រូវពិនិត្យឈាម
ពិនិត្យឈាម
២៥ ដុល្លារ
ថ្លៃសៀវភៅកូន
មួយឆមាស
ថ្លៃ
បង់
សោភ
ពិនិត្យចលនាបេះដូង ៥០ ដុល្លារ
ថ្លៃចាយវាយ
ក្នុង ១ ខែ
ឆ្លុះអេកូ ១០០ ដុល្លារ
ប្រាក់ខែ
១ ខែ
ការគ្មាន
រោគពិ
ជាលាភ
ដ៏ប្រសើរ
ពិតមែន
ពិនិត្យ NMR...
ទិញបាយហូប
បានមួយឆ្នាំ
ពិនិត្យ...
អូយ...

# ៣៨

## អ្នកក្រមិនអាចឈឺបានទេ

ជាច្រើនឆ្នាំកន្លងមកនេះ ប្រជាជនមានប្រាក់ចំណូលកើនឡើង តែនៅមិនគ្រប់គ្រាន់ថ្លៃព្យាបាលជំងឺដែលកាន់តែថ្លៃឡើងដែរ។ ពាក្យថា មិនអាចឈឺបានទេ» ក្លាយទៅជាជំងឺផ្លូវចិត្តរបស់អ្នកក្រដោយស្វ័យប្រវត្តិ។

តាមពិតទៅ ថ្លៃព្យាបាលជំងឺដែលកើនឡើងហួសពីការចាំបាច់នោះគឺ ដោយសារតែមានមនុស្សមួយចំនួន ឆ្លៀតឱកាសលើកកម្ពស់ដើមទុនរបស់ការព្យាបាលឱ្យខ្ពស់ឡើង។

«ភាពគ្មានគុណធម៌ក្នុងការព្យាបាល» គឺជារឿងដែលពិភពលោកបានដឹងយ៉ាងច្បាស់។ តាមពិតនោះ អ្នកជំងឺមិនបានឈឺអ្វីធ្ងន់ធ្ងរទេ តែគ្រូពេទ្យនិយាយ ឱ្យមើលទៅគួរឱ្យខ្លាច ហើយក៏បញ្ជាឱ្យយើងទៅពិនិត្យនេះពិនិត្យនោះ ព្រោះគេនឹងបានប្រាក់កម្រៃពីថ្លៃត្រួតពិនិត្យនានា និងការចេញវេជ្ជបញ្ជា ដូច្នេះពេលណាដែលអ្នកជំងឺទៅជួបពេទ្យ ភារៈរបស់អ្នកជំងឺកាន់តែកើនឡើងក្នុងពេលនោះដែរ។

តាមពិតនោះ យើងមិនខ្វះថ្នាំសង្កូវទេ នៅតាមផ្លូវមានឱសថស្ថានជាច្រើន តែបែរជាមានថ្នាំដែលថោកតិចទៅវិញ។ ទោះបីជារដ្ឋាភិបាលប្រកាសបញ្ចុះតម្លៃថ្នាំសាមញ្ញដែលប្រើនៅតាមផ្ទះក៏ដោយ តែអ្នកក្រនៅតែ

មានអារម្មណ៍ថា មិនបានចុះថោកប៉ុន្មានទេ ហើយក្រោយមកថ្នាំល្អៗតម្លៃថោកក៏បាត់ពីទីផ្សារទៀត ព្រោះបានកម្រៃតិច ទើបអ្នកផលិតគេលែងផលិត។

ពេលដែលមុខរបរដែលទាក់ទងនឹងប្រយោជន៍សាធារណៈ ធ្វើដំណើរឆ្ពោះទៅរកវិថីធុរកិច្ចនោះ នឹងឃើញច្បាស់ថាមុខរបរទាំងនោះមានគោលដៅស្វែងរកកម្រៃតែម្យ៉ាង មិនមែនដើម្បីគុណភាពជីវិតទេ។

អ្នកក្រ គ្មានសិទ្ធិកំណត់គោលនយោបាយរដ្ឋ និងមិនមានឥទ្ធិពលចំពោះការផ្លាស់ប្តូរទីផ្សារធុរកិច្ចទេ ទើបអ្នកក្រមានសិទ្ធិត្រឹមតែការពារកុំឱ្យឈឺប៉ុណ្ណោះ ដូចពាក្យលោកពោលថា «មានអ្វីក៏បានដែរ តែកុំឱ្យមានជំងឺ គ្មានអ្វីក៏បានដែរ តែកុំឱ្យគ្មានប្រាក់»។

អ្វីដែលអ្នកក្រត្រូវចាំគឺ «ការគ្មានរោគជាលាភដ៏ប្រសើរ»។


ចង់រករឿងដាក់ខ្លួនឬ?
ខ្ញុំនឹងប្ដឹងហើយ!
បើចង់ប្ដឹង
ទៅរកមេធាវីមក!
អំ...ត្រូវស្នកបាន់អ្នកកាត់ក្ដី
ត្រៀមថ្លៃសម្រាប់មេធាវី
ហើយយកស្រាទៅពិនិត្យនៅ...
ត្រៀមថ្លៃត្រួតពិនិត្យឱ្យ
មេធាវីយកទៅជានា...
អ្នកមាន
រឿងច្រើនណាស់
ខ្ញុំឈប់ប្ដឹងហើយ
ទៅទិញស្រាក្លែងក្លាយ
មួយដបថ្មីមក ហើយទៅប្ដឹង
ប៉ុលិសម្ដងទៀត
ត្រៀមថ្លៃបណ្ដឹង
រង់ចាំតុលាការ
ហើយបញ្ជូនមេធាវីទៅចរចា

# ៣៩

## អ្នកក្រមិនមានសមត្ថភាពប្តឹងតវ៉ារឿងក្តីទេ

អ្នកក្រខ្លាចការបង្ករឿងណាស់ ព្រោះអ្នកក្រគ្មានអំណាចតវ៉ាទេ ទោះបីជាច្បាប់មានភាពយុត្តិធម៌យ៉ាងណាក៏ដោយ ប៉ុន្តែក៏មិនមែនថាគ្រប់គ្នាសុទ្ធតែបានទទួលភាពយុត្តិធម៌ពីច្បាប់ទាំងអស់ដែរ។ មួយវិញទៀត ការបញ្ជាក់ពីភាពយុត្តិធម៌របស់ច្បាប់ មានដំណាក់កាលនានា ដែលគួរឱ្យខ្លាច និងច្របូកច្របល់ជាច្រើន ដែលមើលទៅហាក់ដូចជាគាំទ្រភាពយុត្តិធម៌ តែបែរជារាំងអ្នកទន់ខ្សោយមិនឱ្យចូលទៅដល់ភាពយុត្តិធម៌ទៅវិញ។

ឧទាហរណ៍ដូចជា «ការការពារសិទ្ធិ» ចាំបាច់ត្រូវប្រើប្រាក់ ប៉ុន្តែអ្នកក្រមិនដែលមានប្រាក់ទៅតវ៉ារឿងក្តីឡើយ គ្រាន់តែថ្លៃចាយវាយដែលកើតឡើងក្នុងអំឡុងពេលមានរឿងក្តីនោះ ពួកគេមិនអាចរែកអម្រែកនោះរួចទៅហើយ។

នៅក្នុងឆ្នាំ ២០០២ កាសែតបានចុះព័ត៌មានថា នៅភូមិ ប៉ៃទាន ស្រុក ណានជិង នៃប្រទេសចិន អ្នកចម្ការសង្ស័យថា រោងចក្រគីមីមួយកន្លែង នៅក្នុងភូមិជាមូលហេតុដែលបង្កឱ្យដំណាំ នៅក្នុងសួនរបស់ពួកគេងាប់ ទើបព្យាយាមទៅប្តឹង។ ប៉ុន្តែពេលទៅសាកសួរនៅកន្លែងត្រួតពិនិត្យជាតិពុលនោះមានការភ្ញាក់ផ្អើលជាខ្លាំងពេលដែលបានដឹងថា ថ្លៃចាយវាយក្នុងការត្រួតពិនិត្យជាតិពុលនៅក្នុងបន្លែមួយប្រភេទមានតម្លៃខ្ពស់ ដល់ទៅ

ជាង ៣ ពាន់ដុល្លារ បើត្រួតពិនិត្យច្រើនប្រភេទត្រូវចំណាយប្រាក់អស់ជាច្រើន។ អ្នកចម្ការដែលក្នុងមួយជីវិតនេះ មិនដែលរកប្រាក់បានច្រើនដូច្នេះ បានត្រឹមតែឈរស្រទឡាំងកាំងប៉ុណ្ណោះ។

ក្រៅអំពីឈរស្រទឡាំងកាំងហើយ ថែមទាំងធ្វើអ្វីមិនបានទៀតផង បានត្រឹមតែចុះចាញ់នឹងវាសនារបស់ខ្លួន។ មិនមែនថា អ្នកក្រមិនជឿច្បាប់ទេ ប៉ុន្តែស្ថានការណ៍ពិត ធ្វើឱ្យពួកគេចាំបាច់ត្រូវតែលះបង់សិទ្ធិក្នុងការការពារខ្លួនជាច្រើនលើកច្រើនសា ច្បាប់នៅក្នុងខ្សែភ្នែករបស់អ្នកដែលគ្មានឱកាស គឺបានត្រឹមតែជាមនុស្សចំបើង (ទីងមោង) សម្រាប់ដេញចាបតែប៉ុណ្ណោះ។


អាក្រក់ណាស់
លោកនាយក XX
យកប្រាក់ ៥ លាន រត់ទៅ
ប្រទេសអូស្ត្រាលីបាត់ហើយ!
ពិតជាអាក្រក់មែន
ត្រូវតែជាប់គុក
អភិបាលខេត្ត XX
យកប្រាក់ ១០ លាន
រត់ទៅអង់គ្លេសបាត់ហើយ
ពិតជាអាក្រក់មែន
ត្រូវតែកាប់ជាដុំៗ
ទេសរដ្ឋមន្ត្រី XX
យកប្រាក់ ១០០ លាន
រត់បាត់ហើយ...
មន្ត្រីរាជការអាក្រក់ៗ
នាំគ្នាគេចរួចខ្លួនអស់ហើយ
រដ្ឋមន្ត្រី XX
យកប្រាក់ ២០០ លាន
រត់បាត់ហើយ...
មិនមែនជាប្រាក់យើងទេ
ទៅខឹងធ្វើអ្វី ?
មិនដឹងទេឬ
សុទ្ធតែជាពន្ធរបស់អ្នកក្រ
ទាំងអស់ហ្នឹង!
អ៊ីចឹងហើយ ទើបជីវិតរបស់ពួកយើង
កាន់តែអាក្រក់ឡើងជាលំដាប់

# ៤០

## អ្នកក្រត្រូវទទួលរងកម្មពីពួកពុករលួយ

អំពើពុករលួយរបស់ពួកអ្នកមាន ពិតជាប៉ះពាល់ដល់ពួកអ្នកក្រពិតប្រាកដមែន។

អំពើពុករលួយ គឺជាការបៀតបៀនផលប្រយោជន៍រួម ដែលឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ដែលនោះបានមកពីប្រជាជនទូទៅក្នុងសង្គម។ នេះគឺជាបញ្ហាថ្នាក់ជាតិទាំងមូល ព្រោះសុទ្ធតែជាពន្ធរបស់ប្រជាជនទាំងអស់ដែលត្រូវគេកេងប្រវ័ញ្ច ហើយទីបំផុត អ្នកដែលទទួលរងគ្រោះនោះគឺជាប្រជាជន។

ពីស្ថិតិក្នុងរយៈពេល ២០ ឆ្នាំកន្លងមកនេះ មានជនជាតិចិនដែលកេងប្រវ័ញ្ច ហើយរត់ទៅក្រៅប្រទេសជាង ៤.០០០ នាក់ ដោយយកប្រាក់ទៅអស់ជាង ៥០.០០០ លានដុល្លារ។ បើគិតជាមធ្យម យកប្រាក់ចេញ ២.៥០០ លានដុល្លារក្នុងមួយឆ្នាំ ស្មើនឹងក្នុងម្នាក់ ១២,៥ លានដុល្លារ បើគិតជាលុយយ័ន គឺស្មើនឹងរាប់សែនលានយ័ន។ បើធៀបទៅប្រាក់ដែលប្រើសាងទំនប់ «សានស៊ា» នៅមិនទាន់ដល់ ២០០.០០០ លានយ័នផង ដូច្នេះ ប្រាក់ដែលកេងយកទៅនោះអាចសាងទំនប់ «សានស៊ា» បានដល់ទៅពីរកន្លែងឯណោះ។

នៅក្នុងប្រទេសចិនមានកសិករ ៨០០ លាននាក់ នៅក្នុងឆ្នាំ ២០០៤ រដ្ឋាភិបាលចិន បានប្រកាសគោលនយោបាយកាត់បន្ថយអម្រែក របស់កសិករ ៨០០ លាននាក់ ដោយលើកលែង និងកាត់បន្ថយពន្ធ កសិកម្ម រួមទាំងអស់គិតជាទឹកប្រាក់ជាង ២៨.០០០ លានយ័ន គឺស្មើនឹង ចំនួនប្រាក់ដែលពួកពុករលួយយកចេញទៅក្រៅប្រទេសក្នុងឆ្នាំនោះ។

ក្រៅពីនេះនៅមានពួកពុករលួយដែលមិនបានរត់គេចជាច្រើននាក់ ទៀតដែលត្រួតពិនិត្យហើយមិនមានភស្តុតាង។

ឃើញថា អំពើពុករលួយមានមិនចេះចប់ទេ បើយកប្រាក់ដែលពុក រលួយនោះមករួមគ្នាតើនឹងច្រើនដល់កម្រិតណាទៅ?

ដូច្នេះ ការពុករលួយនឹងប៉ះពាល់ដល់អ្នកក្រដោយផ្ទាល់ ព្រោះបើ ប្រទេសជាតិបាត់បង់ផលប្រយោជន៍ អត្រានៃភាពមានបានរបស់សង្គមនឹង ថយចុះ គម្រោងការទាំងឡាយត្រូវជាប់គាំងទាំងអស់ ហើយកម្មករនឹងបាត់ បង់ការងារ ប្រាក់ដើមទុនរបស់ធនាគារនឹងក្លាយទៅជា «បំណុលស្អុយ» សង្គមនឹងអន់ថយ ឯអ្នកក្រនឹងអស់សង្ឃឹម។


ដល់វេនពេលណាអស់រាល់លើក
មានស្រាប់ហើយត្រូវតែមាន
ឱ្យកប់ពពកថែមទៀត
ពួកអ្នកក្ររង់ចាំសិនទៅ
ដើរលេងនៅសួន
កម្សាន្តហ្វ្រី
ដល់វេនពេលណា
សម្រាករាល់លើក
រដ្ឋបាល
ដល់ម៉ោងសម្រាកហើយ
ដល់វេនពេលណាគ្រប់រហូត
គ្រប់ហើយ
ក្រែងថាឱ្យពួកយើងមានតាម
នោះអី ហេតុអ្វីបានជាមិន
ដល់វេនយើងសោះអ៊ុចឹង?
មនុស្សពេញហើយ
ចាំវេនក្រោយទៀត

# ៤១

## អ្នកក្រចាំមានតាមក្រោយ

អ្នកមានភាគច្រើនធ្លាប់ជាអ្នកក្រមកពីមុន អាចជាកូនរបស់អ្នកក្រ តែពេលមានហើយមិនជួយអ្នកក្រទេ បែរជាកេងប្រវ័ញ្ចទៅវិញ ហើយទុកឱ្យអ្នកក្ររកស៊ីដោយកម្លាំងរបស់ខ្លួនឯងតទៅទៀត។

ពេលដែលមនុស្សមួយក្រុមមានមុនហើយនោះ អ្នកដែលនៅសល់តែងតែគិតថា បន្តិចទៀតឱកាសនឹងមកដល់ហើយ តើដឹងឬទេថា វាគ្រាន់តែជាក្តីស្រមៃកណ្តាលថ្ងៃត្រង់តែប៉ុណ្ណោះ។

ភាពមានបានមិនមែនជា «សម្បត្តិដែលអាចផ្លាស់ប្តូរគ្នាមាន» ទេ។ ពាក្យដែលថា «វាសនាផ្លាស់ប្តូរទៅជានិច្ច» ឬ «ភាពយុត្តិធម៌ជាគូនឹងសង្គម» គ្រាន់តែជាការគិតរបស់អ្នកក្រតែប៉ុណ្ណោះ ព្រោះមិនធ្លាប់មានអ្នកមានណាម្នាក់មានអារម្មណ៍ថា មានរហូតដល់ធុញ ហើយចង់ចែកចាយភាពមានបានទៅឱ្យអ្នកក្រទេ។

នៅលើវិថីនៃភាពមានបាន ម្នាក់ៗសុទ្ធតែរត់យ៉ាងពេញទំហឹងដោយមិនគិតពីជីវិតឡើយ គ្មាននរណាបន្ថយល្បឿនដើម្បីរង់ចាំអ្នកទេ។ អ្នកដែលមានមុនតែងតែដឹងពីបច្ចេកទេស និងវិធីរកប្រាក់យ៉ាងច្បាស់ ពួកគេបានសាងនូវលក្ខណៈ គុណតម្លៃ និងវិធីក្នុងការរកប្រាក់ទុកជាស្រេច

ហើយ។ ចំណែកឯអ្នកដែលមិនទាន់មានបានត្រឹមតែដើរតាម ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកមានប៉ុណ្ណោះ។

នៅពេលដែលយើងមិនអាចផ្លាស់ប្តូរលំដាប់នៃភាពមានបាន បានទេនោះ យើងគួរតែព្រមទទួលស្គាល់នូវការពិតប្រសើរជាង។

អ្នកក្របានត្រឹមតែលួងលោមខ្លួនឯងថា «ចាំមានតាមក្រោយពួកគេទៅចុះ»។

តើអ្នកក្រអាចនឹងទាមទារអ្វីបានទៀត បើដឹងទាំងដឹងហើយថា លទ្ធផលនៃការប្រកួតប្រជែង ត្រូវបានកំណត់ទុកតាំងពីមិនទាន់ចាប់ផ្តើមប្រកួតម្ល៉េះ។


ស្ពានអាកាសចាប់ផ្តើម សាងសង់ហើយ
សាងលឿន យើងក៏រីកចម្រើនឡើងដែ
ពេលសាងរួចហើយ ជីវិតនឹងប្រសើរឡើង
នឹងមានអគារខ្ពស់ៗ តំបន់ឧស្សាហកម្ម ហាងស្អាតៗ...
ចាំអស់ជាច្រើន ឆ្នាំហើយ បានត្រឹមតែជាតិពុល
ក្តីស្រមៃត្រូវ រលាយអស់... មិនយុត្តិធម៌ សម្រាប់ អ្នកក្រឡើយ

# ៤២

## អ្នកក្រចង់បានភាពរីកចម្រើន

បច្ចុប្បន្ននេះ បច្ចេកវិទ្យាមានភាពរីកចម្រើនជាខ្លាំង ធ្វើឱ្យកម្លាំងមនុស្សត្រូវជំនួសដោយគ្រឿងម៉ាស៊ីន ទើបតម្លៃរបស់អ្នកក្រត្រូវកាត់បន្ថយជាលំដាប់។

សម្រាប់អ្នកក្រ ភាពរីកចម្រើនមិនបានចាត់ទុកថា ជារឿងល្អទាំងអស់ទេ ព្រោះភាពរីកចម្រើនខ្លះធ្វើឱ្យអ្នកក្រត្រូវធ្លាក់នៅក្នុងភាពគ្រោះថ្នាក់។ ដូចជាពេលដែលចាប់ផ្ដើមកសាងស្ពានអាកាស អ្នកដែលរស់នៅតាមស្ពានអាកាសនាំគ្នាសប្បាយចិត្ត ប៉ុន្តែពេលដែលស្ពានអាកាសបានសាងរួច ក្រៅអំពីមានផ្សែងពុល និងសំឡេងរំខានកាន់តែខ្លាំងឡើងហើយ អ្នកក្រក៏មិនបានទទួលប្រយោជន៍អ្វីពីការសាងស្ពានអាកាសនេះឡើយ ហើយជីវភាពកាន់តែធ្លាក់ចុះជាងមុនទៅទៀត ព្រោះថាទីនេះមិនមែនជាផ្លូវសំខាន់របស់គមនាគមន៍តទៅទៀតទេ ហើយក៏មិនមែនជាកន្លែងចំណាតសំខាន់តទៅទៀតដែរ។ ដូច្នេះអ្នកក្រនឹងកាន់តែឃ្លាតឆ្ងាយពីមនុស្ស វត្ថុ និងព័ត៌មានជាលំដាប់។

អ្នកដែលបានទទួលនូវប្រយោជន៍ច្រើនបំផុតពីការសាងស្ពានអាកាសនោះគឺ ខេត្តធំៗដែលស្ពានអាកាសបានទៅដល់។ ដូចគ្នានេះដែរ

ទិន្នន័យទាំងឡាយនៅក្នុងអ៊ិនធើណែត ក៏មិនមែនថា នឹងទៅដល់មនុស្សគ្រប់គ្នាដែរ ហើយទីបំផុតអ្នកក្រនឹងត្រូវគេមើលរំលង។

នៅក្នុងសម័យបច្ចុប្បន្ននេះ នរណាៗក៏នឹកស្រមៃដល់បាដិហារិយ៍ដែរ។ យើងតែងតែភ្ញាក់ផ្អើលពេលដែលបានឮថា មានមនុស្សជាច្រើនអាចមានបានក្នុងពេលយ៉ាងឆាប់រហ័ស តែបែរជាគិតមិនដល់ថា ក៏មានមនុស្សជាច្រើនទៀតដែរ ដែលក្រក្នុងរយៈពេលយ៉ាងឆាប់រហ័ស។

បើចន្លោះរវាងអ្នកមាន និងអ្នកក្រនៅតែឆ្ងាយពីគ្នាខ្លាំងនោះ អ្នកក្រក៏ពិបាកនឹងសង្ឃឹមថា នឹងបានភាពរីកចម្រើនដែរ។


បើមនុស្សទូទាំងស្រុកបរិច្ចាគឱ្យខ្ញុំ
ម្នាក់ត្រឹមតែ ១០០ រៀលនោះ ខ្ញុំនឹង
មិនបាច់មកអង្គុយធ្វើស្រែទេ
បើមនុស្សទូទាំងខេត្តបរិច្ចាគ
ឱ្យខ្ញុំម្នាក់ត្រឹមតែ ១០០ រៀលនោះ
ខ្ញុំនឹងក្លាយទៅជាសេដ្ឋីហើយ
គ្រាន់តែម្នាក់បរិច្ចាគមួយជីទូទាំងប្រទេស
នោះខ្ញុំនឹងក្លាយទៅជាមហាសេដ្ឋីហើយ
បើការយល់សប្តិនេះក្លាយទៅ
ជាការពិតនោះ
យល់សប្តិទាំងថ្ងៃ
អេយពិតងងឹតហើយ
ត្រឡប់ទៅផ្ទះវិញងូតទឹក
ហើយគេងទៅ
ថ្ងៃស្អែកនៅមានការងារ
ជាច្រើនទៀត
ហ៊ឺ !!!

# ៤៣

## អ្នកក្រមួយថ្ងៃៗគិតតែពីស្រមើស្រមៃ

«ប្រជាជនកម្ពុជាមានប្រហែលជា ១៥ លាននាក់ បើគ្រប់គ្នាបរិច្ចាគប្រាក់ឱ្យខ្ញុំក្នុងម្នាក់តែ ១០០ រៀលនោះ ខ្ញុំប្រាកដជាមានហើយ» អ្នកក្រតែងតែស្រមើស្រមៃបែបនេះ។

រឿងបែបនេះអាចទៅរួច ប៉ុន្តែ បើចង់ឱ្យគ្រប់គ្នាប្រមូលប្រាក់ម្នាក់ ១០០ មកឱ្យអ្នកនោះ អ្នកត្រូវតែមានមូលហេតុឱ្យបានល្អនោះគឺ ត្រូវរៀបចំគម្រោង ត្រូវប្រាប់ពីរឿងលម្អិតឱ្យគ្រប់គ្នាបានដឹង ហើយត្រូវឃោសនាជាសាធារណៈ ត្រូវរកមនុស្សទៅប្រមូលប្រាក់ ត្រូវប្រើមនុស្សច្រើន និងថ្លៃចាយវាយជាច្រើនទៀត។ បើការទៅប្រមូលប្រាក់ម្នាក់ ១០០ រៀល អ្នកត្រូវចំណាយថ្លៃជួលមនុស្សទៅប្រមូលម្នាក់ ៥០០ រៀល នោះមានន័យថា រាល់ប្រាក់បរិច្ចាគមួយរយលាន អ្នកត្រូវចំណាយថ្លៃឈ្នួលដល់ទៅ ៥០០ លានរៀល...តើចំណេញឬទេ?

តាមពិតទៅ អ្នកក្រមិនមែនល្ងង់ល្ងីល្ងើទេ ប៉ុន្តែពេលខ្លះរឿងដែលអ្នកក្រគិតឃើញ មិនថាជាគំនិតដែលល្អបំផុតប៉ុនណាទេ ក៏មិនអាចធ្វើឱ្យក្លាយទៅជាការពិតបានដែរ។ ទាំងនេះគឺដោយសារតែ «ដើមទុន» របស់អ្នកក្រទាបពេក នៅទីបំផុតត្រូវយកគំនិតល្អៗនេះ ទៅប្រគល់ឱ្យអ្នកមាន។

អ្នកក្របានត្រឹមតែជាអ្នកជួយ ឬជាទីប្រឹក្សាដែលគាំទ្រអ្នកមានឱ្យរកស៊ីយកប្រៀបអ្នកក្រដូចគ្នា ហើយចាំទទួលចំណែកពីប្រាក់ដែលអ្នកមានរកបានប៉ុណ្ណោះ។

ប្រាក់ដើមទុនប្រៀបដូចជាក្តារលោតទឹក ធ្វើកាន់តែខ្ពស់ប៉ុនណាកាន់តែមានកន្លែងទុកឱ្យបង្អួតក្បាច់ល្អៗច្រើនប៉ុណ្ណោះដែរ។

អ្នកមាននឹងកាន់តែមានឡើង ចំណែកឯអ្នកក្របានត្រឹមតែមើលគេធ្វើភ្នែកភ្លឹះៗតែប៉ុណ្ណោះ។

ទោះបីជាអ្នកក្រចង់សាកល្បងមើលមួយក្តារក៏ដោយ តែវាប្រៀបដូចជាបើកឡានលើដីខ្សាច់ ប្រើកម្លាំងខ្លាំងប៉ុនណាក៏ឡាននៅតែរត់យឺតដូចអណ្តើកដដែល បានត្រឹមតែសម្លឹងមើលឡានដែលបើកនៅក្បែរៗនោះវ៉ាទៅម្តងមួយៗ ហើយដកដង្ហើមធំ ព្រោះមិនអាចធ្វើអ្វីបានឡើយ។



ជួយផង!
ខ្ញុំមកជួយហើយ!
ខ្ញុំមកជួយហើយ!
ខ្ញុំមានសុភនិច្ឆ័យ
ខ្ញុំមានចិត្តមេត្រី
ខ្ញុំគិតមើលសិន
តើខ្ញុំអាចជួយអ្វីលោកបានខ្លះ
អរគុណអ្នកសារព័ត៌មានគ្រប់ប៉ុស្តិ៍
ខ្ញុំបូជាខ្លួនដើម្បីរឿងនេះ!
អ្នកសម្បើមណាស់ អ្នកធ្លាប់ក្រ
អរគុណដែលបានខំស្តោះទឹកមាត់ជួយខ្ញុំ!

# ៤៤

## អ្នកក្រចេះជួយអ្នកក្រដូចគ្នា

នៅពេលដែលអ្នកក្រឃើញអ្នកមានចាយវាយខ្ជះខ្ជាយ តែងគិតថា «ស្បែកជើងស្បែកមួយគូរបស់គេមានតម្លៃស្មើនឹងប្រាក់ខែរបស់ខ្ញុំមួយខែ... បាយមួយពេលរបស់គេ ខ្ញុំអាចឱ្យកូនរៀនបញ្ចប់ថ្នាក់បឋមបាន»។

មានសៀវភៅជាច្រើន ដែលសរសេរបកអាក្រាតពីរឿងអាក្រក់ៗ របស់លទ្ធិមូលធននិយម ដោយនិយាយថា អ្នកមានសុខចិត្តចាក់ទឹកដោះគោដែលនៅសល់ចូលក្នុងទន្លេ មិនព្រមចែកចាយឱ្យអ្នកក្រទេ។ គេធ្វើទៅតាមវិធីគ្រប់គ្រងតាមច្បាប់សេដ្ឋកិច្ច ព្រោះបើដកដើមទុនចេញពីប្រាក់លក់ទឹកដោះគោហើយនោះ «ខាតដើម» គឺគ្មានកម្រៃឬបានកម្រៃតិច មិនត្រូវតាមគោលដៅ គេសុខចិត្តចាក់ទឹកដោះគោដែលនៅសល់ចោល។

អ្នកដែលអាណិត និងយល់ចិត្តអ្នកក្រ ហើយដាក់ទានឱ្យអ្នកក្រនោះ គឺមានតែអ្នកក្រដូចគ្នាតែប៉ុណ្ណោះ ដែលព្រមយកប្រាក់ក្នុងហោប៉ៅដែលមានតែបន្តិចបន្តួចឱ្យ ព្រមជាមួយនឹងពាក្យសម្ដីដ៏កក់ក្ដៅថា «បើខ្ញុំមានសម្លពេញឆ្នាំង វាក៏ត្រូវតែមាននៅក្នុងចានរបស់លោកដែរ»។ម្យ៉ាងទៀត បើមានគ្រោះធម្មជាតិកើតឡើង អ្នកដំបូងគេដែលជួយបរិច្ចាគប្រាក់ និងរបស់របរនោះច្រើនតែជាអ្នកក្រដូចគ្នា។

អ្នកក្របរិច្ចាគប្រាក់ ព្រោះមានទឹកចិត្តពិត ជួយចេញពីក្រអៅបេះដូង ព្រោះគេឃើញស្រមោលខ្លួនឯងពីអ្នកក្រដទៃទៀត។ ចំណែកអ្នកមានជួយព្រោះសេដ្ឋកិច្ច។ អ្នកក្រប្រើ «ដៃនិងចិត្ត» ជួយ ចំណែកអ្នកមានប្រើ «ប្រាក់ដើម្បីកេរ្តិ៍ឈ្មោះ» ជួយ។ ដូច្នេះ នៅទីបំផុត ក៏ប្រែក្លាយទៅជាផលប្រយោជន៍ ព្រោះការបរិច្ចាគរបស់អ្នកមានចាត់ទុកថា ជាការវិនិយោគទុនម្យ៉ាង និងបានជួយស្អិតស្អាង ឬតុបតែងបុគ្គលិកលក្ខណៈរបស់គេបន្ថែម។ ដូចបានឃើញតាមកញ្ចក់ទូរទស្សន៍ឬកាសែតជាញឹកញាប់ ពេលអ្នកមានចុះចែកអំណោយ តែងមានអ្នកកាសែតតាមសម្ភាស ហើយយកមកចាក់ផ្សាយតាមកញ្ចក់ទូរទស្សន៍ ឬចុះលើទំព័រកាសែត ឱ្យអ្នកក្រទស្សនា ឬអានដែលនេះនឹងអាចជួយដល់អាជីវកម្ម ឬមុខមាត់របស់ពួកគេបាន។

អ្នកក្រចូលចិត្តជួយគ្នាទៅវិញទៅមក ប្រៀបដូចជា មនុស្សដែលពាក់អាវស្តើងៗពីរនាក់ឱបគ្នា និងពឹងពាក់អាស្រ័យគ្នានៅកណ្តាលខ្យល់ដែលរងា បរិយាកាសជុំវិញប្រៀបដូចជាកាំបិតដែលជ្រៀកយកការឃើញតែប្រយោជន៍ផ្ទាល់ខ្លួនចេញ នៅសល់ត្រឹមតែក្តីសង្ឃឹមឱ្យបានរស់ប៉ុណ្ណោះ ស្ថានភាពដូច្នេះហើយដែលធ្វើឱ្យអ្នកក្រមានចិត្តសាមគ្គីគ្នា។



ព្រះជាម្ចាស់អើយ ខ្ញុំខំប្រឹងមក ១០ ឆ្នាំហើយ!
ចូរបណ្ដាល ឱ្យអ្នកមាន បាយហូប
ព្រះជាម្ចាស់អើយ ខ្ញុំខំប្រឹងបន្ថែម ១០ ឆ្នាំទៀត ហើយ!
ចូរបណ្ដាឱ្យអ្នក មានអាវពាក់
ព្រះជាម្ចាស់អើយ ខ្ញុំខំប្រឹងមក ៣០ ឆ្នាំហើយ!
ចូរបណ្ដាលឱ្យអ្នក បានប្រពន្ធ
ព្រះជាម្ចាស់អើយ ខ្ញុំខំប្រឹងមក អស់មួយជីវិតហើយ!
ឱ្យផ្ទះអ្នកមួយខ្នង យ៉ាងម៉េចដែរ?
ប្រហែលជា ត្រូវចាំជាតិ ក្រោយហើយ
ព្រះជាម្ចាស់ ខ្ញុំខំប្រឹងមក រហូតដល់ចាស់ហើយ តើពេលណា ទើបមាននឹងគេ?
ជោគជតា
ខំប្រឹង

# ៤៥

## ព្រះជាម្ចាស់បោះបង់ចោលអ្នកក្រ

ពេលដែលអ្នកឃើញសភាពរបស់អ្នកក្រ អ្នកនឹងមានអារម្មណ៍ហាក់រាថយ អស់សង្ឃឹមជាខ្លាំង។ ពួកគេនៅឆ្ងាយពីភាពរីកចម្រើននៅលើលោកនេះខ្លាំងណាស់ ឬអាចនិយាយបានថា គ្មានថ្ងៃអាចឈានដល់ភាពរីកចម្រើនបានឡើយ។ អ្នកក្ររស់នៅឱ្យរួចតែពីមួយថ្ងៃទៅមួយថ្ងៃប៉ុណ្ណោះ រហូតដល់អ្នកមានអារម្មណ៍ថា ពួកគេរស់នៅម្នាក់មួយភពពីយើង ជាពិភពដែលព្រះជាម្ចាស់មិនយកចិត្តទុកដាក់។

«គ្រប់គ្នាស្មើភាពគ្នាទាំងអស់» នេះគ្រាន់តែជាទស្សនៈប៉ុណ្ណោះ តាមពិតទៅ យើងគ្រប់គ្នាមិនស្មើភាពគ្នាទេ។ បើអ្នកសំណាងអាក្រក់កើតនៅក្នុងទ្វីបអាហ្វ្រិក ឬជាចិនដីគោក នៅក្នុងជនបទដែលនៅឆ្ងាយពីភាពរីកចម្រើននោះ ជីវិតអ្នកក៏ចាត់ទុកថា ត្រូវជោគវាសនាកំណត់មករួចទៅហើយដែរ។ បើអ្នកទៅជនបទដែលដាច់ស្រយាលនោះ នឹងឃើញថា ការខិតខំប្រឹងប្រែងរបស់អ្នកក្រផ្តល់ភាពជោគជ័យតែចំពោះកន្លែងដែលពួកគេរស់នៅតែប៉ុណ្ណោះ។ អ្នកក្រភាគច្រើនកើតនិងស្លាប់ នៅក្នុងស្ថានភាពក្រដដែល មានមួយចំនួនតូចតែប៉ុណ្ណោះ ដែលអាចគេចផុតពីភាពក្រលំបាកបាន។

ហ្វ្រែង ណៃ (Frank Knight) អ្នកសេដ្ឋសាស្ត្រនៃលទ្ធិសេដ្ឋកិច្ចសេរីនិយមថ្មី ជាជនជាតិអាមេរិកយល់ថា «មនុស្សម្នាក់អាចក្លាយជាអ្នកមាន ឬអ្នកក្រនោះអាស្រ័យលើបច្ច័យ ៣ ប្រការគឺ ៖

- ជាតិកំណើត
- ជោគវាសនា
- ការខិតខំប្រឹងប្រែង

គាត់នៅបានបញ្ជាក់ទៀតថា «បច្ច័យដែលសំខាន់តិចបំផុតគឺ ការខិតខំប្រឹងប្រែង» នេះគឺជាការពិត ដែលស្ទើរតែនិយាយមិនចេញ។ ប៉ុន្តែអ្នកមានខ្លះ បែរជាទម្លាក់អម្រែកនៃភាពក្រីក្រទៅឱ្យអ្នកក្រ ដោយពាក្យថា «អ្នកក្រខ្ជិល»។ ការផ្តល់ភាពសំខាន់ទៅលើការខិតខំព្យាយាមតែម្យ៉ាងដូច្នេះ វាគឺជាការទម្លាក់អម្រែកការទទួលខុសត្រូវរបស់អ្នកដែលមានអំណាច និងព្យាយាមកាត់បន្ថយដើមទុន ដែលសង្គមនឹងជួយអ្នកក្រ ដោយប្រើភាពតូចទាបរបស់អ្នកក្រធ្វើជា «លេសឬជាឧបករណ៍» ប៉ុណ្ណោះ។

# ជំពូកទី ៣

សិក្សាអំពី

# ទស្សនៈរបស់អ្នកក្រ


ដើម្បីប្រាក់ មិនបាច់សម្រាកទេ
ដើម្បីប្រាក់ មិនបាច់សេពគប់មិត្តភក្តិទេ
ដើម្បីប្រាក់
មិនចាប់អារម្មណ៍
នឹងប្រពន្ធទេ
ដើម្បីប្រាក់
មិនរវល់នឹងកូនទេ
ចោលផ្ទះសំបែង
ហើយ
អស់ភាពជាមនុស្សហើយ
ទីបំផុតមានប្រាក់ហើយ
តែអ្វីៗផ្សេងទៀតត្រូវបាត់បង់ទាំងអស់

# ៤៦

## អ្នកក្រចាប់អារម្មណ៍តែពីរឿងប្រាក់

ជនជាតិចិន មានវិធីចាប់ស្វាដោយចោះប្រហោងពីរកន្លែង នៅលើក្តារប្រហោងនោះធំល្មមដែលអាចឱ្យស្វាលូកដៃចូលទៅបាន ចំណែកក្តារម្ខាងទៀតដាក់សណ្តែងដី។ ពេលស្វាឃើញសណ្តែកដី នឹងឈោងដៃទៅយក ពេលដែលស្វាចាប់សណ្តែក វានឹងយកដៃចេញពីប្រហោងនោះមិនរួច ដូច្នេះក្តារជាអន្ទាក់សម្រាប់ចាប់ស្វានេះឯង។ ស្វាដែលក្តាប់សណ្តែកដីជាប់មិនព្រមលែង នឹងត្រូវអ្នកស្រុកចាប់បានយ៉ាងងាយ។

*អ្នកក្រក៏មានសភាពមិនខុសពីស្វាដែរ។*

នៅពេលដែលគ្មានប្រាក់ អ្នកក្រនឹងលំបាកវេទនា ទើបប្រាក់គឺជាគោលដៅសំខាន់របស់អ្នកក្រ ហើយក្លាយទៅជាវត្ថុល្បួងចិត្តអ្នកក្រមករហូត។ គ្មានអ្នកក្រណាម្នាក់ដែលមិនចាប់អារម្មណ៍នឹងប្រាក់ទេ តែការផ្តល់ភាពសំខាន់ទៅលើប្រាក់ «ខ្លាំងពេក» នឹងធ្វើឱ្យមើលរំលងវត្ថុដទៃទៀតទីបំផុត អ្វីដែលបានមកវិញនោះ មិនសមនឹងអ្វីដែលបាត់បង់ឡើយ។ ការខ្វះខាតប្រាក់ គឺវេទនាចិត្តខ្លាំងក្លាជាងខ្វះខាតអ្វីទាំងអស់។

អ្នកក្រដែលពូកែយករួចខ្លួន និងមានការខិតខំប្រឹងប្រែង ដើម្បីយកឈ្នះភាពលំបាកបាន ធ្វើឱ្យមនុស្សជាច្រើនមានការចាប់អារម្មណ៍ ប៉ុន្តែផល

តបស្នងពីការព្យាយាមយ៉ាងខ្លាំងនោះ អាចនឹងមានតម្លៃស្មើនឹងសណ្តែកដីមួយក្តាប់តែប៉ុណ្ណោះ។

អ្នកដែលគ្មានប្រាក់គ្រប់គ្រាន់សម្រាប់ចម្អែតក្រពះ តែងតែផ្តោតទៅលើរឿងអត់ឃ្លាន រហូតដល់ក្លាយទៅជាការលោភលន់ ទោះបីជាហូបឆ្អែតហើយក៏ដោយ តែក៏អត់ទ្រាំនឹងមិនហូបមិនបាន ព្រោះខ្លាចថា នឹងត្រូវត្រឡប់ទៅរស់នៅបែបអត់ឃ្លានម្តងទៀត។


នៅមិនទាន់ជក់អស់ផង
គួរឱ្យស្តាយណាស់
ស្បែកជើងថ្មី
ឡូយណាស់
តើពេលណាទើបបានញ៉ាំទឹកខនិចនឹងគេមួយដបដល់ទៅ
៥០០០ រៀលឯណោះ
អូយ! ពេជ្រធំណាស់ ដើមទ្រូងក៏ធំដែរ
ស្អីធំ នាយល្ងង់អើយ
មើលឱ្យបានឆ្ងាយបន្តិចទៅ
ឆ្ងាយៗឬ?
អ៊ូយ! ហាងគេកំពុងតែបញ្ចុះតម្លៃ
ឆាប់នាំគ្នាទៅ

# ៤៧

## អ្នកក្រតែងតែមើលមិនបានវែងឆ្ងាយ

មនុស្សដែលគិតតែរឿងឥតបានការ ផ្តោតលើរឿងកំប៉ិកកំប៉ុកនៅក្នុងជីវិតខ្លាំងពេក រីករាយនឹងផលប្រយោជន៍បន្តិចបន្តួច និងលួងលោមចិត្តខ្លួនឯងថា «បក្សីតូចធ្វើសំបុកឱ្យល្មមនឹងខ្លួន» លុះយូរៗទៅអ្នកទាំងនោះនឹងមិនត្រឹមតែខ្វះខាតប្រាក់ប៉ុណ្ណោះទេ ចិត្តក៏ទន់ខ្សោយទៅតាមនោះដែរ។

នៅពេលដែលអ្នកក្រគ្មានប្រាក់ ងាយនឹងធ្វើអំពើអាក្រក់ណាស់។ ពេលដែលគ្មានប្រាក់ នឹងមិនអាចទទួលបានជោគជ័យដ៏ធំធេងបានទេ ព្រោះរវល់តែគិតពីបញ្ហាក្រពះ។

ពេលដែលអ្នកក្រគ្មានប្រាក់ នឹងមិនហ៊ានបោះចោលបាយដែលនៅបាតឆ្នាំងដើម្បីទៅរកអ្វីដែលប្រសើរជាងនេះទេ។

ពេលដែលអ្នកក្រគ្មានប្រាក់ នឹងមិនអាចចូលទៅក្នុងសង្គមរបស់មនុស្សដែលមានប្រាក់បានទេ បានត្រឹមតែវិលវល់នៅក្នុងសង្គមរបស់អ្នកក្រប៉ុណ្ណោះ។

ជាតិកំណើតដែលថោកទាប ធ្វើឱ្យមិនអាចឈរនៅកន្លែងខ្ពស់ និងមើលឱ្យវែងឆ្ងាយបាន ដូច្នេះ ទើបអ្នកក្រមានគំនិតរាក់ៗ «មើលមិនបានវែងឆ្ងាយ» រហូតដល់ភ្លាត់ឱកាសនានាចូលមកក្នុងជីវិត ទើបមួយជីវិតរបស់

អ្នកក្រ បានត្រឹមតែងើយមើលអ្នកដទៃ និងបានត្រឹមតែជាអ្នកជួយបំពេញបន្ថែមឱ្យធុរកិច្ចរបស់អ្នកមានតែប៉ុណ្ណោះ។

ភាពអត់ធ្មត់របស់អ្នកក្រ គឺមានតែអ្នកក្រដូចគ្នាប៉ុណ្ណោះ ទើបអាចដឹងបាន ព្រោះគ្មានប្រាក់ ទើបគ្មានមូលដ្ឋានផ្នែកខាងធុរកិច្ច ព្រោះគ្មានប្រាក់ ទើបមិនបានសិក្សានៅសាលារៀនល្អៗ ព្រោះគ្មានប្រាក់ ទើបមានផលប៉ះពាល់ដល់ផ្លូវចិត្ត ព្រោះគ្មានប្រាក់ ទើបមិនអាចចូលទៅក្នុងសង្គមថ្នាក់ខ្ពស់បាន ... សរុបទៅ «ការមិនមានប្រាក់» ធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្ត ទស្សនៈ ការរស់នៅ និងអនាគតជាខ្លាំង។

ដូច្នេះ អ្នកក្រមិនគួរកំណត់ព្រំដែនគំនិតរបស់ខ្លួនទេ ត្រូវចេះមើលឱ្យបានវែងឆ្ងាយ។



តើមានក្រុមហ៊ុនចូលភាគហ៊ុនទេ ?
មិនមានទេ
តើមានរោងចក្រទេ ?
គ្មានទេ
តើមានកូនចៅប៉ុន្មាននាក់ ?
គ្មានទេ
ចង់លេងភាគហ៊ុនទេ ?
អត់ទេ
តើមានមរតកទេ ?
អត់ទេ
តើមានមរតកចាស់ ៗទេ ?
អត់ទេ
តើមានអចលនទ្រព្យទេ ?
អត់ទេ
អ្វីក៏គ្មាន ៗ អាមោម !
ព្រៃ
អ្នកមាន សង្ឃឹម អញ្ជើញ មកខាង នេះ
តែខ្ញុំមាន សង្ឃឹម

# ៤៨

## អ្នកក្រខ្វះខាតគ្រប់យ៉ាងថែមទាំងអស់សង្ឃឹមទៀតផង

បច្ច័យដែលធ្វើឱ្យអ្នកក្រខ្វះការតាំងចិត្ត និងក្ដីប្រាថ្នា គឺជារឿងដែលកើតឡើងជាធម្មតា ហើយអ្នកក្រខ្វះសតិបញ្ញាទៀតផង ដែលនេះធ្វើឱ្យមិនមានចក្ខុវិស័យវែងឆ្ងាយ គ្មានវិធីដែលល្អ និងខ្វះគុណសម្បត្តិក្នុងការ «ធ្វើកិច្ចការធំ»។ ដូច្នេះទោះបីជាអ្នកក្រមានក្ដីស្រមៃ និងខិតខំប្រឹងប្រែងច្រើនប៉ុនណាក៏ដោយ ក៏មិនមានបច្ច័យគ្រប់គ្រាន់ក្នុងការជំរុញឱ្យរួចផុតពីស្ថានភាពដដែលៗហើយត្រូវទ្រាំលំបាកធ្វើជាអ្នកក្រអស់មួយជីវិត។

ដូច្នេះ មិនថាអ្នកជានរណាទេ បើអ្នកអស់ផ្លូវធ្លាក់នៅក្នុងស្ថានភាពលំបាក អស់សង្ឃឹមចំពោះរឿងប្រាក់ រឿងការងារ និងអនាគតនោះ អ្នកនឹងសោកសៅ ហើយនឹងភ័យខ្លាចដូចអ្នកក្រដែរ។

ផ្ទុយទៅវិញ មិនថាអ្នកជានរណាទេ បើនៅមានក្ដីសង្ឃឹម មានក្ដីស្រមៃ និងក្រោកឡើងតស៊ូនោះក៏មិនចាត់ទុកថា អ្នកគឺជាអ្នកក្រទៀតដែរ។

ការមិនមានប្រាក់ គ្រាន់តែជាចំណែកមួយ នៃក្ដីទុក្ខនៅក្នុងជីវិតតែប៉ុណ្ណោះ ហើយអ្នកដែលអស់ផ្លូវនោះក៏មិនមែនមានតែអ្នកក្រដែរ។

អ្នកក្រមានក្ដីសង្ឃឹមបែបអ្នកក្រ មានចំណុចមានប្រៀបបែបអ្នកក្រ អ្វីដែលអ្នកក្រមានអាចជាអ្វីដែលអ្នកមានមិនមានក៏ថាបាន។ អ្នកមានយ៉ាង

ណាក៏មានមិនលើសពី ៣ ជំនាន់ដែរ ចំណែកអ្នកក្រទោះជាក្រយ៉ាងណាក៏ក្រមិនលើសពី ៣ ជំនាន់ដូចគ្នា។

រឿងទាំងឡាយនៅលើលោកនេះ ប្រព្រឹត្តទៅតាមហេតុ និងផលរបស់វា ដូច្នេះអ្នកក្រមិនគួរបោះបង់ចោលនូវក្ដីសង្ឃឹម និងមិនគួរឈប់គិតទេ អ្នកក្រត្រូវដឹងពីមូលហេតុថា ខ្លួនឯងក្រព្រោះអ្វី ហើយត្រូវរកច្រកចេញឱ្យបាន។

បើអ្នកបានសិក្សាពីជីវប្រវត្តិរបស់បុគ្គលជំរុញចិត្ត* អ្នកនឹងឃើញថាបុគ្គលទាំងនោះ ជាដំបូងសុទ្ធតែធ្លាក់ខ្លួនក្នុងភាពក្រីក្រ ហើយប្រឹងតស៊ូដោយក្ដីសង្ឃឹម រហូតបានក្លាយជាបុគ្គលជំរុញចិត្ត និងជាបុគ្គលជោគជ័យលំដាប់ពិភពលោក។

* សូមអានបន្ថែមនៅសៀវភៅ: បុគ្គលជំរុញចិត្ត នៃគ្រឹះស្ថានបោះពុម្ពផ្សាយដាំដើមជីវិត



មានបាយឱ្យហូបនោះប្រសើរណាស់ហើយ
ចង់ប្រថុយធ្វើធុរកិច្ចធ្វើអ្វី?
ការបង្កើតក្រុមហ៊ុនពិតជាពិបាកមែន
មានដីស្រែឱ្យធ្វើនោះគឺប្រសើរណាស់ហើយ
កម្ម៉ង់របស់មកលក់ធ្វើអ្វីច្រើនយ៉ាងនេះ?
ក្រុមហ៊ុនរលំហើយ ឃើញទេប្រាប់ហើយ
នៅមិនទាន់រាង
ចាលទៀតឬ
នៅមកប្រថុយ
លក់បានទៀត?
ប្រថុយឬ?
កាន់តែក្រ កាន់តែប្រថុយ

# ៤៩

## អ្នកក្រខ្លាចការប្រថុយ

អ្នកក្រដឹងច្បាស់ថា ការបណ្តាក់ទុនគ្រប់យ៉ាង សុទ្ធតែមានការប្រថុយ។ ប៉ុន្តែ ពួកគេគ្មានផ្លូវជ្រើសរើសទេ ព្រោះបើមិនបណ្តាក់ទុន និងមិនមានការងារធ្វើជាបន្តបន្ទាប់ទេ អាចនឹងត្រូវត្រឡប់ទៅធ្វើជាអ្នកក្រដូចដើមវិញ។

ពេលដែលអ្នកក្រឃើញអ្នកមានរកប្រាក់បានមួយលានដុល្លារ គេតែងតែគិតថា «មានប្រាក់ច្រើនបែបនេះ ប្រហែលជាដេកស៊ីមិនបាច់ធ្វើអ្វីទៀតទេមើលទៅ»។

ប៉ុន្តែប្រាក់ប៉ុណ្ណោះមិនគ្រប់គ្រាន់សម្រាប់អ្នកមានទេ ព្រោះលក្ខណៈនៃការរស់នៅរបស់អ្នកមានខុសគ្នាពីអ្នកក្រស្រឡះ។ មានអ្នកមានជាច្រើនដែលពីមុនធ្លាប់ក្រ ប៉ុន្តែ នឹងមិនព្រមត្រឡប់ទៅធ្វើជាអ្នកក្រវិញទៀតជាដាច់ខាត ដូច្នេះទើបពួកគេហ៊ានប្រថុយ។ ទោះបីជាអ្នកមានត្រូវបរាជ័យ ឬត្រូវរលាយរហូតដល់អស់ពីខ្លួនក៏ដោយ តែតម្រូវការ និងទស្សនៈនៅតែជាអ្នកមានដដែល ហើយបើទោះបីជាអ្នកមានគ្មាននៅសេសសល់អ្វីសោះក៏ដោយ ក៏នៅតែខុសពីអ្នកក្រដែរ ព្រោះពួកគេមិនព្រមចុះចាញ់អ្វីដោយងាយៗទេ និងតែងគិតជានិច្ចថា ត្រូវតែព្យាយាមក្រោកឈរឡើងសាជាថ្មីឱ្យបាន។

អ្នកក្រនៅពេលដែលឃើញអ្នកមានរលំរលាយអស់ពីខ្លួន តែងតែត្រេកអរ លួចពេបជ្រាយនៅក្នុងចិត្ត។ ពួកអ្នកក្រចូលចិត្តដាស់តឿនអ្នកមានថា ប្រថុយឱ្យហត់ធ្វើអ្វី ថែមទាំងនិយាយដោយពើងទ្រូងថា «លែងលោភលន់ពេលណា នឹងមានសេចក្ដីសុខពេលនោះហើយ»។

អ្នកក្រខ្លាចការប្រថុយគ្រប់យ៉ាង រហូតដល់គ្មានថ្ងៃយល់បានឡើយថា ការប្រថុយដ៏ធំបំផុតរបស់ពួកគេនោះគឺ «ការធ្វើជាអ្នកក្រ» អស់មួយជីវិតនោះឯង។ មនុស្សយើងមានជីវិតតែមួយទេ គិតមើលឱ្យបានល្អ បើបានដឹងច្បាស់អំពីរឿងនេះហើយ អ្នកក្រនឹងមានកម្លាំងក្រោកឡើងតស៊ូដើម្បីឱ្យជីវិតកាន់តែប្រសើរឡើង។



ពិធីស្វាគមន៍បុគ្គលិកថ្មី
គ្រប់គ្នាប្រៀបដូចជាក្បាល
ឡោស៊ីតូច ៗ
ត្រូវតែជឿស្តាប់
អង្គភាព
មកធ្វើការមុនគេជានិច្ច
មិនដែលឈប់ឡើយ
បោសសម្អាតកន្លែង
ធ្វើការរាល់ថ្ងៃ!
ធ្វើតួនាទីជាសន្តិសុខឱ្យអស់ពីសមត្ថភាព
កត់ត្រាអ្នកចេញចូល
មិនមានភ្លាំងភ្លាត់
ឡើយ
កក់ក្តៅនៅក្នុងចិត្ត
ប្រាប់មិនត្រូវទេ
មានការងារគង់វង្ស
និងគេអើយ
ខ្ញុំស្រលាញ់អង្គភាព
នេះណាស់
ធ្វើជាសន្តិសុខដ៏ក្លាហាន
ប្រយុទ្ធជាមួយចោរ
មិនខ្លាចស្លាប់
តែពេលចាស់ទៅ
អង្គភាព
បែរជាក្បត់
ទៅវិញ
អញ្ជើញ
ចេញ
ទៅ
ពួកយើងប្រៀបដូចជាក្បាល
ឡោស៊ីដែលជុះស្នឹម បើព្រម
ពេលពប់ដោយខ្លួនឯងនោះ
នឹងបានប្រាក់ខែ ១០ ដង
អាក្បាលឡោស៊ីចម្លែក
ឯងនេះធ្វើបាបយើងខ្លាំងណាស់!

# ៥០

## អ្នកក្រប្រៀបដូចជាក្បាលឡោស៊ីមួយ

អ្នកក្រតែងតែអាក់អន់ស្រពន់ចិត្តនឹងវាសនារបស់ខ្លួន មានអារម្មណ៍ថា ជីវិតគ្មានស្ថិរភាព ទើបសង្ឃឹមថានឹងមានគេទទួលស្គាល់និងក្លាយទៅជាផ្នែកសំខាន់មួយនៅក្នុងអង្គភាពខ្នាតធំ។

នៅពេលដែលអ្នកក្រ បានក្លាយទៅជាសមាជិករបស់អង្គភាពណាមួយហើយ ពួកគេនឹងជួយអង្គភាពនោះយ៉ាងអស់ពីសមត្ថភាព ព្រោះគិតខ្លាចថា នឹងបាត់បង់តំណែងនោះទៅវិញ ដែលជាលទ្ធផលខ្លួននឹងក្លាយទៅជារោមសត្វដែលអណ្តែតត្រសែតគ្មានគោលដៅ។ ដូច្នេះ ទើបអ្នកក្រប្រកាន់ខ្ជាប់មាត្រដ្ឋានរបស់អង្គភាពជាគោល ដោយព្យាយាមលាក់និស្ស័យរបស់ខ្លួនទុក ព្រមផ្លាស់ប្តូរបុគ្គលិកលក្ខណៈរបស់ខ្លួនឱ្យត្រូវតាមមាត្រដ្ឋានរបស់អង្គភាព។ ម្យ៉ាងទៀត ព្រមធ្វើការគ្រប់យ៉ាង និងសុខចិត្តប្តូរកន្លែងស្នាក់នៅដើម្បីផលប្រយោជន៍របស់អង្គភាពទៀតផង។ ការធ្វើការនៅក្នុងអង្គភាពដែលមានកេរ្តិ៍ឈ្មោះរយៈពេលយូរ តាំងពីធ្វើជាអ្នកហ្វឹកហាត់ការងាររហូតក្លាយទៅជាអ្នកគ្រប់គ្រងថ្នាក់ខ្ពស់នោះ ចាត់ទុកថា ជាក្តីស្រមៃដ៏ខ្ពស់បំផុតរបស់អ្នកក្រហើយ។

*ដោយហេតុដូច្នេះហើយទើបអ្នកក្រចាញ់កលអ្នកមានជានិច្ច។*

អ្នកមានចូលចិត្តបញ្ចូលជំនឿថា «សាមគ្គីគឺជាកម្លាំង» ទៅក្នុងខួរក្បាលរបស់អ្នកក្រ។ ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះ ពួកគេក៏មិនដែលឈប់ទទួលយកបុគ្គលិកថ្មីៗដែរ ហើយបណ្តុះបណ្តាលបុគ្គលិកថ្មីៗ ឱ្យមកជំនួសកន្លែងរបស់អ្នកជានិច្ច។

ស្ថិតនៅក្នុងកន្លែងដែលអ្វីៗគ្រប់យ៉ាងជារបស់អ្នក តែអ្នកបែរជាគ្រាន់តែជាក្បាលឡោស៊ីតូចមួយទៅវិញ ហើយផ្នែកធនធានមនុស្សបានត្រៀមរកក្បាលឡោស៊ីដែលមានគុណភាពល្អបំផុត ឱ្យអង្គភាពគ្រប់ពេលបើក្បាលឡោស៊ីមួយណាដុះស្នឹម ពួកគេនឹងដកចេញភ្លាមដោយមិនប្រណីឡើយ។ ផ្នែកធនធានមនុស្សក៏ត្រូវតែរៀសរវៃដែរ ព្រោះគេត្រូវការពារតំណែងរបស់ពួកគេដែរ។

អ្នកក្រត្រូវចាញ់ប្រៀបគេជានិច្ច ទោះបីជាធ្វើការលេចធ្លោខ្លាំងប៉ុនណាក៏ដោយ តែវាសនាតែងតែលេងកំប្លែងជាមួយជានិច្ច។


ការងាររវល់ខ្លាំងត្រូវតែរត់ធ្នត់
ប្រយ័ត្នអត់ការងារធ្វើ
បន្តិចហើយ ងាកលើ ងាកណា
ក្តៅខ្លួន សុំច្បាប់ ១ ថ្ងៃ
ប្រហែលជាមានអ្នកមកធ្វើជំនួសហើយ
សម្រាកយូរពេកទេដឹង ត្រឡប់មកវិញ
ធ្វើការបន្ថែមម៉ោងរាល់ថ្ងៃ
សុំឈប់សម្រាកខ្លះមក
ឈប់សម្រាក
សំខាន់ជាងការងារឬ?
ធ្វើការរកលុយណាស់
បើពុំអីបានប្រាក់ខែ
តែប៉ុណ្ណឹង?
ប្រសើរជាងអត់ដែរ
ខ្ញុំសុំតវ៉ា
តើនរណានឹងស្តាប់ទៅ?
បរិភោគជាំឆ្ងាញមិនរួច
សុំថ្លៃជម្ងឺចិត្តផង
ប្រាក់ឈ្នួលពិតជាថ្លៃសង
ជម្ងឺចិត្តជំប្លេបំផុតហើយ
ជាតិនេះបានត្រឹមតែជាកូនឈ្នួលគេ
ជាតិក្រោយសុំឱ្យកើតលើគំនរមាសគំនរប្រាក់

# ៥១

## អ្នកក្រខ្លាចបាត់បង់ការងារ

មានអាណាព្យាបាលម្នាក់បាននិយាយថា «ទម្រាំតែបានឱ្យកូនរៀនចប់មហាវិទ្យាល័យនោះលំបាកខ្លាំងណាស់។ តែពេលដែលកូនរៀនចប់បែរជារកការងារធ្វើមិនបានទៅវិញ។ សម័យនេះ បើរើសខ្លាំងពេក នឹងគ្មានការងារធ្វើទេ បើដឹងថាអ៊ីចឹង មិនឱ្យរៀនមហាវិទ្យាល័យទេប្រហែលជាអាចរកការងារធ្វើបានខ្លះ ធ្វើជាកម្មករក៏ល្អដែរ ព្រោះមានឈ្មោះថាមានការងារធ្វើ»។

ការរៀនមហាវិទ្យាល័យត្រូវចំណាយប្រាក់ស្ទើរតែអស់ពីផ្ទះ ពេលដែលរៀនចប់បែរជាគ្មានការងារធ្វើទៅវិញ តែអ្វីដែលអាក្រក់ជាងនេះទៅទៀតនោះគឺ ឪពុកម្ដាយក៏អាចនឹងបាត់បង់ការងារបានដែរ។ បើដូច្នេះ តើគ្រួសារទាំងមូលនឹងអាចទទួលនូវសម្ពាធនេះបានដោយរបៀបណាទៅ?

*មានការងារ ទើបមានបាយហូប ការងារជាសិទ្ធិមូលដ្ឋានរបស់មនុស្ស។*

រដ្ឋាភិបាលបានផ្ដល់នូវភាពសំខាន់ចំពោះសិទ្ធិ ដល់អ្នកធ្វើការងារដូចជា សិទ្ធិក្នុងការសម្រាក សិទ្ធិក្នុងការទទួលព័ត៌មាន សិទ្ធិក្នុងការទទួលនូវថ្លៃតបស្នង និងសិទ្ធិក្នុងភាពជាមនុស្ស តែទាំងអស់នេះពេលខ្លះគ្រាន់តែ

ជាខ្យល់ប៉ុណ្ណោះ។ ថ្ងៃបុណ្យទាន បើអ្នកមិនធ្វើការបន្ថែមម៉ោងទេ អ្នកដទៃគេនឹងមកធ្វើជំនួស បើអ្នកមិនពេញចិត្តនឹងថ្លៃតបស្នងទេ អ្នកដទៃគេពេញចិត្ត។ ដូច្នេះ ក្នុងទស្សនៈរបស់និយោជក អ្នកធ្វើឬមិនធ្វើ គឺស្រេចតែចិត្ត បើពូកែណាស់សុំឈប់ចុះ ព្រោះតំណែងនេះមានអ្នកដទៃតម្រង់ជួរចាំជាច្រើននាក់ទៀត។

ដោយសារសង្គមបែបនេះ ទើបក្លាយទៅជាទម្លាប់នៃការអែបអបដើម្បីប្រាក់និងអំណាច។ តើអ្នកគិតថាសៀវភៅដែលនិយាយពីគ្រប់គ្រង ឬអភិវឌ្ឍខ្លួន ដែលលក់ដាច់ជាងគេនោះ តើមនុស្សប្រភេទណាដែលទិញច្រើនបំផុត?

គឺម្ចាស់ធុរកិច្ចនោះអី ទិញយកទៅចែកបុគ្គលិក ដើម្បីឱ្យបុគ្គលិកធ្វើការ ដោយភាពស្មោះត្រង់ តាំងចិត្ត អត់ធ្មត់ និងមិនមានលេសអ្វីទាំងអស់។

បើគ្មានការងារធ្វើទេ គ្រប់យ៉ាងនឹងត្រូវចប់ ដូច្នេះព្រមទទួល និងអត់ធ្មត់បន្តទៀតចុះ។



ក្រុមហ៊ុនរលំហើយ
ទៅស្នាក់នៅជាមួយសាច់ញាតិក្រ ៗ
មួយរយៈសិន
មិនមែនរកបានដូចមុនទេ
ចាំគេបញ្ចុះតម្លៃសិនទៅ
ខ្ញុំសុំឱ្យអ្នកជិតខាងមើលវិញ
មិនមែនរកបានដូចមុនទេ ទិញស៊េរីចាស់បានហើយ
ត្រូវទិញកន្លែងដែលអាចតថ្លៃបាន
មិនមែនរកបានដូចមុនទេ
ប៉ុន្តែសុំបកក្រោយជប់បានហើយ
នៅផ្ទះកោលថ្ងៃទៀត
តោះទៅទិញបន្លែផ្លែ ៗជាមួយគ្នា
សុំភ្លេកជញ្ជីងទេ សុំមួយដើមទៀតមក
អ្នកក្រគេមិន
រិះដល់ថ្នាក់នេះទេ

# ៩២

## អ្នកក្រលិចលង់នៅក្នុងសង្គមរបស់អ្នកក្រ

គ្រប់គ្នាសុទ្ធតែមានសង្គមក្នុងការរស់នៅជារបស់ខ្លួន ហើយសង្គម និងជោគវាសនារមែងមានទំនាក់ទំនងនឹងគ្នា ដោយហេតុផល និងប្រទាក់ក្រឡាគ្នា។

ជីវិតរបស់អ្នកក្រភាគច្រើន ច្រើនតែរស់នៅក្នុងសង្គមរបស់អ្នកក្រដូចគ្នា ដែលប្រាកដណាស់ថា សភាពផ្លូវចិត្ត ការគិត ការប្រតិបត្តិ ក៏ជារបៀបអ្នកក្រដែរ ព្រោះជុំវិញខ្លួនមានតែអ្នកក្រ មួយថ្ងៃៗនិយាយតែពីរឿងទំនិញបញ្ចុះតម្លៃ គិតរកតែវិធីសន្សំសំចៃ។ ទោះបីជារឿងទាំងនេះនឹងជួយបង្ហាត់បង្រៀនពីសមត្ថភាពក្នុងការរស់នៅក៏ដោយ តែនឹងធ្វើឱ្យអ្នកក្រគិតតែពីរឿងកំប៉ិកកំប៉ុក ហើយមិនតាំងចិត្តធ្វើរឿងធំឡើយ។

អ្នកក្រច្រណែនអ្នកមាន ហើយក៏មានគំនិតប្រឆាំងនឹងអ្នកមានដែរ។ ពេលដែលអ្នកក្រនិយាយដល់អ្នកមានតែងតែនិយាយដោយសំឡេងចំអក និងចាក់ដោត ប្រៀបដូចជាលាក់កាំបិតមួយដើមនៅក្នុងចិត្ត ត្រៀមដើម្បីពន្លះភាពអាក្រក់របស់អ្នកមានគ្រប់ពេល។

ការរស់នៅក្នុងសង្គមអ្នកក្រ ធ្វើឱ្យអ្នកក្រមិនអាចយល់ពីអ្នកមានដោយចិត្តជាកណ្តាលបានទេ ហើយក៏មិនអាចសិក្សាពីអាថ៌កំបាំងនៃភាពមានបានរបស់អ្នកមានបានដែរ។

បើទោះបីជាអ្នកមានល្ងង់ដល់កម្រិតណាក៏ដោយ តែការដែលគេក្លាយជាអ្នកមានបាននោះ មិនមែនជារឿងងាយទេ្បីយ។

អ្នកក្រមានចំណេះដឹងជារបស់ខ្លួន ប៉ុន្តែភាគច្រើនជាចំណេះដឹងដើម្បីឱ្យអាចរស់បានប៉ុណ្ណោះ បើចង់ឡើងទៅនៅស្មើនឹងអ្នកមាន គឺត្រូវតែលាចេញពីស្ថានភាពបច្ចុប្បន្នរបស់ខ្លួនជាមុនសិន។

*ការធ្វើដូច្នេះ មិនមែនជាការឃោរឃៅជាមួយនឹងអ្នកក្រដូចគ្នាទេ ប៉ុន្តែគឺជាការផ្លាស់ប្តូរខ្លួនឯង។*



មើលទៅគួរឱ្យអាណិតណាស់ ខ្ញុំឱ្យក្របីឯង ១ ក្បាលទុកធ្វើស្រែ
អរគុណលោកខ្លាំងណាស់
ក្របីស៊ីស្មៅ មនុស្សហូបបាយ លក់ក្របីទៅទិញចៀម
មកចិញ្ចឹមប្រសើរជាង
នឹងបានសម្លាប់ចៀមមកចិញ្ចឹមជីវិត
លក់ចៀមទៅទិញមាន់ប្រសើរជាង មាន់ពងហើយ
អាចភ្ញាស់កូនបានទៀត
មានមាន់ជាច្រើន ភ្លៅមាន់ច្រើនណាស់
នៅសល់តែមាន់មួយក្បាល
លក់មាន់ ទៅទិញស្រាផឹកប្រសើរជាង
មិនស្រវឹងមិនឈប់ទេ
ខ្ញុំសុំក្របី ១ ក្បាលទៀតបានទេ
ពុទ្ធោ ឈឺក្បាលខ្លាំងណាស់

# ៥៣

## ឱ្យគេជួយរុញពីក្រោយរមែងដើរមិនបានឆ្ងាយ

រឿងនិទានចិនបាននិទានថា មានមនុស្សម្នាក់ក្រខ្លាំងណាស់ អ្នកមានឃើញក៏អាណិតចង់ជួយឱ្យគាត់មាន។ អ្នកមានបានឱ្យក្របីមួយក្បាលទៅអ្នកក្រម្នាក់នោះ ហើយប្រាប់ឱ្យគាត់យកទៅភ្ជួរស្រែ ប្រមូលផលទៅលក់ដើម្បីឱ្យបានរួចផុតពី «ភាពក្រលំបាក» នឹងគេ។

អ្នកក្រចាប់ផ្ដើមតស៊ូពុះពារឧបសគ្គ ដោយកម្លាំងចិត្តដែលពេញប្រៀប តែរំលងទៅមិនបានប៉ុន្មានថ្ងៃផង ជីវិតមើលទៅហាក់ដូចជាលំបាកជាងមុនទៅទៀត ព្រោះក្របីត្រូវការស៊ីស្មៅ មនុស្សក៏ត្រូវការហូបបាយ គិតហើយគិតទៀត ទីបំផុតក៏សម្រេចចិត្តលក់ក្របី ហើយទៅទិញចៀមមកចិញ្ចឹមដើម្បីអាចហូបសាច់បានខ្លះ ចិញ្ចឹមចៀមរហូតដល់កូនចៀមធំហើយ ក៏យកទៅលក់ទៀត រំពឹងថា នឹងបានប្រាក់មួយជាន់ទៀត។

ផែនការរបស់អ្នកក្រប្រព្រឹត្តទៅតាមដែលគាត់បានរំពឹងទុក។ ប៉ុន្តែពេលដែលហូបចៀមអស់មួយក្បាល ចៀមដទៃទៀតមិនព្រមកើតកូនទាល់តែសោះ ជីវិតចាប់ផ្ដើមលំបាកទៀតហើយ ដូច្នេះចាំបាច់ត្រូវសម្លាប់ចៀមមួយក្បាលទៀត ហើយអ្នកក្រនោះគិតថា មើលទៅដូចជាមិនល្អទេ យកចៀមទៅលក់ឱ្យអស់ ហើយទិញមាន់មកចិញ្ចឹម យកពងទៅលក់ប្រសើរជាង ប្រហែលជាអាចមាន។

ផែនការប្រព្រឹត្តទៅតាមអ្វីដែលបានគ្រោងទុកហើយ តែហេតុអ្វីជីវិតនៅតែមិនប្រសើរឡើង ថែមទាំងលំបាកជាងមុនទៅទៀត អ្នកក្រត្រូវតែយកមាន់មកហូប លុះដល់មាន់សល់តែមួយក្បាល ក្ដីស្រមៃបានរលាយអស់ ជាតិនេះប្រាកដជាមិនមាននឹងគេទេ ... យកមាន់មួយក្បាលចុងក្រោយនេះទៅលក់ ហើយទិញស្រាមកផឹកកាត់សាញប្រសើរជាង។

កន្លងហួសទៅមិនយូរប៉ុន្មាន អ្នកមានបានយកពូជស្រូវមកឱ្យអ្នកក្រ តែត្រូវភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលដែលបានឃើញអ្នកក្រផឹកស្រាក្របីបាត់អស់ ហើយផ្ទះនៅតែទ្រុឌទ្រោមដដែល។

ឱ្យគេរុញពីក្រោយរមែងដើរមិនបានឆ្ងាយ ការជួយពីអ្នកដទៃរបស់អ្នកក្រគ្រាន់តែជាឱកាសប៉ុណ្ណោះ ប៉ុន្តែយើងនឹងឆ្លៀតយកឱកាសនេះដើម្បីផ្លាស់ប្ដូរវាសនារបស់យើងបាន ឬអត់នោះ គឺស្ថិតនៅលើខ្លួនរបស់យើង។

បើអ្នកក្រមិនអាចយកឈ្នះនូវភាពខ្ជិលច្រអូសរបស់ខ្លួនបានទេគឺគ្មានផ្លូវនឹងទៅដល់គោលដៅបានឡើយ ហើយទីបំផុតនឹងនៅសល់តែភាពទទេស្អាតប៉ុណ្ណោះ។


នៅទីនេះពិតជាស្រួលមែន! មានប្រាក់ខែប្រចាំទៀត
នៅទិនេះពិតជាស្រួលមែន! មានចែកប្រេង អង្ករទៀត
នៅទីនេះ ពិតជាស្រួលមែន! ជួយចេញថ្លៃម៉ាស៊ីនកម្តៅទៀត
នៅទីនេះពិតជាស្រួលមែន! មិនបាច់ធ្វើស្រែទេ
នៅទីនេះពិតជាស្រួលមែន! ដូកជាផ្ទះរបស់ខ្លួនឯងអញ្ចឹង
ប៉ុន្តែ... អង្គភាពក៏អាចរលំរលាយបានដែរ
កសិករ

# ៥៤

## អ្នកក្រផ្ញើជីវិតលើអង្គភាព

បុគ្គលិកធ្វើការនៅក្នុងអង្គភាពភាគច្រើន ពឹងតែទៅលើប្រាក់ខែដែលមានកំណត់ ទើបមិនអាចធ្វើអ្វីដោយខ្លួនឯងបាន។ ពួកគេជឿថា ភាពរីកចម្រើនរបស់អង្គភាព គឺជាបច្ច័យសំខាន់ដែលធ្វើឱ្យខ្លួនអាចរស់នៅមានសេចក្ដីសុខ។

បើស្ថានភាពរបស់អង្គភាពគង់វង្ស បុគ្គលិកបានប្រាក់ខែខ្ពស់ ជីវភាពរបស់បុគ្គលិកនឹងល្អប្រសើរឡើង។ ប៉ុន្តែបើស្ថានភាពរបស់អង្គភាពមិនល្អ នឹងបានប្រាក់ខែតិច ពេលខ្លះបើកប្រាក់ខែហួសថ្ងៃកំណត់ទៀតផង ដូច្នេះ ល្មមនឹងអាចទ្រទ្រង់ជីវភាពបានប៉ុណ្ណោះ។ អង្គភាពដែលល្អបំផុតនោះជាអង្គភាព ដែលបុគ្គលិកគ្រប់គ្នាមិនបាច់ព្រួយបារម្ភថា នឹងគ្មានការងារធ្វើ មិនបាច់បារម្ភថា នឹងធ្វើការងារច្រើនពេក ពេលដាច់ខែប្រាក់ខែត្រូវបានបញ្ចូលទៅក្នុងបញ្ជីធនាគារ ពេលចូលឆ្នាំសកល ឬចូលឆ្នាំចិនមានប្រាក់លើកទឹកចិត្តឱ្យ។

អ្នកដែលមិនបានធ្វើការនៅក្នុងអង្គភាព ដែលមានស្ថានភាពគង់វង្សនោះ ត្រូវធ្វើការងារបន្ថែម ដូចជា លេងភាគហ៊ុន ឬធ្វើការងារក្រៅម៉ោង ។ល។ ប៉ុន្តែ ការងារទាំងនេះត្រូវមានចំណេះដឹងជាដើមទុន សម័យនេះមិនមែនថា គ្រាន់តែមានខ្សែ នឹងអាចរកភាគហ៊ុនទិញបានដោយងាយ អង្គុយ

រាប់លុយស្រួលៗទេ ពេលនេះផ្សារភាគហ៊ុនមានហានិភ័យខ្ពស់ណាស់ បើមើលមិនបានល្អទេ នឹងមិនបានចំណេញឡើយឬអាចនឹងមិនបានដើមទុនត្រឡប់មកវិញទៀតផង។

មួយទៀត ទោះជាបានអង្គុយធ្វើការក្នុងអង្គភាពដ៏ល្អ និងមានស្ថិរភាពហើយក៏ដោយ ត្រូវតែមានតំណែងដ៏ល្អទៀត ព្រោះក្រៅពីប្រាក់ខែហើយអាចនឹងមានឱកាសបានទទួលនូវប្រយោជន៍ពីក្រោមតុទៀតដែរ ដែលអ្នកសេដ្ឋសាស្ត្រហៅផលប្រយោជន៍បែបនេះថា «ប្រាក់ចំណូលពុករលួយ» ជាផលប្រយោជន៍ដ៏មហាសាល ដែលមានការប្រថុយជាងការលេងភាគហ៊ុនទៅទៀត ព្រោះថា បើអ្នកវិនិយោគទុននៅក្នុងផ្សារភាគហ៊ុនខុស អាចនៅមានឱកាសកែខ្លួនបាន ប៉ុន្តែ បើភ្លាំងភ្លាត់ក្នុងតំណែងការងារដែលយកអំណាចទៅប្តូរជាមួយនឹងប្រាក់នោះ ត្រូវដើរចេញពីការងារតែម្យ៉ាងគត់។


កម្លាំងមិនគ្រប់គ្រាន់
ខ្សោយប្រាជ្ញា
សមត្ថភាពមិនដល់
គ្មានពេល
ទីបំផុត មានប្រាក់ខែដែលស្រមៃហើយ តែបែរជាបាត់ឱកាសមានទៅវិញ

# ៥៥

## អ្នកក្ររំពឹងតែប្រាក់ខែ

ក្នុងសៀវភៅមួយក្បាលទៀតរបស់គូគូ ឈ្មោះថា «សេដ្ឋសាស្ត្របែបគូគូ» មានរូបតុក្កតាដែលគួរឱ្យចាប់អារម្មណ៍មួយរឿង។ ក្នុងនោះ គូគូ និងភរិយាអង្គុយនៅក្នុងសួនច្បារ ភរិយាពោលឡើងថា «មាត់ប្រាប់ថាស្រលាញ់ខ្ញុំ តែមិនឃើញមានលះបង់អ្វីដើម្បីខ្ញុំឡើយ» គូគូគិតនៅក្នុងចិត្តថា «យ៉ាងហោចណាស់ក៏បងអស់ឱកាសញ៉ែស្រីព្រោះតែអូនដែរ»។

នៅលើលោកនេះ គ្មានអ្វីដែលបានមកដោយទទេឡើយ បើអ្នកចង់បានអ្វីមួយមក អ្នកក៏ត្រូវព្រមលះបង់អ្វីមួយទៅវិញដែរ។ ដូចគ្នានឹងពេលដែលអ្នកមានភរិយាហើយ អ្នកក៏លែងមានឱកាសទៅស្រលាញ់ស្រីដទៃទៀតដែរ។ ការខូចខាតនេះតាមពិតទៅ គឺជា «ការបាត់បង់ដើមទុនឱកាស» នោះឯង។

បើអ្នកជាមនុស្សដែលមានគុណសម្បត្តិពេញលេញ ហើយកំពុងតែបើកក្រុមហ៊ុនធ្វើធុរកិច្ចជារបស់ខ្លួន*។ តែនៅសុខៗក៏មានការងារដែលបានប្រាក់ខែខ្ពស់យ៉ាងខ្លាំង មកល្បួងចិត្តរបស់អ្នក តើអ្នកនឹងជ្រើសរើសយកមួយណា?

---

* សូមអានបន្ថែមនៅសៀវភៅ: មាន ដោយការធ្វើអាជីវកម្មខ្នាតតូច នៃគ្រឹះស្ថានបោះពុម្ពផ្សាយដាំដើមជីវិត

បើអ្នកជ្រើសរើសការងារដែលមានប្រាក់ខែខ្ពស់ អ្នកនឹងត្រូវបាត់បង់ឱកាសធ្វើធុរកិច្ចដែលជារបស់ខ្លួន អ្នកនឹងត្រូវបាត់បង់ប្រាក់ដែលនឹងរកបាននៅក្នុងពេលអនាគតរបស់អ្នក ដែលបានកំណត់គោលដៅទុកថានឹងត្រូវរកឱ្យបាន ១ លានដុល្លារ ១០ លានដុល្លារ ។ល។

*សម័យនេះ គ្មានការងារណាដែលអ្នកអាចពឹងពាក់បានអស់មួយជីវិតនោះទេ។*

យើងមិនអាចពឹងលើប្រាក់ខែតែម្យ៉ាងទេ។ បើអ្នកពឹងតែលើប្រាក់ខែនោះ អ្នកនឹងគ្មានថ្ងៃបានក្លាយទៅជាអ្នកមានពិតប្រាកដឡើយ។ បើអ្នកនៅតែស្តាយប្រាក់ខែច្រើន ដែលមកល្បួងចិត្ត នោះបង្ហាញថា អ្នកនៅគិតបែបអ្នកក្រនៅឡើយ នៅដើរផ្លូវខុសនៅឡើយ នោះនឹងគ្មានថ្ងៃអាចនឹងរីកចម្រើនបានទេ។

ដើមទុនរបស់មនុស្សម្នាក់ៗ មិនថានោះជាកម្លាំងចិត្ត សតិប្រាជ្ញាសមត្ថភាព មាសប្រាក់ ឬពេលវេលាទេ សុទ្ធតែមានកំណត់ទាំងអស់។ ពេលដែលយើងកំពុងតែផ្តោតធ្វើអ្វីមួយ នោះយើងនឹងមិនអាចធ្វើអ្វីផ្សេងបានទេ បើអ្នកជ្រើសរើសយកការងារណាមួយហើយនោះ អ្នកនឹងត្រូវបាត់បង់ផលប្រយោជន៍ពីការងារដទៃទៀត។


មិនដឹងជាប់ស្អីទេ
ឈឺណាស់លោកគ្រូពេទ្យ
ទ្រាំឈឺបន្តិចទៅណា!
អ្ហាក!
ប្រយ័ត្នមានផលប៉ះពាល់
ពិតមែនឬ?
ថ្លៃវះកាត់ថ្លៃណាស់
អញ្ចឹង!
មិនបាច់យកចេញទេ ទុកវាអញ្ចឹងហើយ!

# ៥៦

## អ្នកក្រពូកែបារម្ភ

ពេលដែលអ្នកក្រចង់ក្លាយជាអ្នកមាន មិនមែនថាពួកគេមិនដឹងពីវិធីទេ គ្រាន់តែពួកគេមិនហ៊ានធ្វើតែប៉ុណ្ណោះ។

ព្រោះថា អ្នកក្រគិតច្រើនពេក ថែមទាំងគិតតែពីហេតុការណ៍ដែលមិនប្រាកដនៅក្នុងអនាគត ដែលនេះនាំឱ្យកាន់តែគិតកាន់តែខ្លាច លទ្ធផលចុងក្រោយគឺ ភាពដែលអាចទៅរួចទាំងឡាយ ត្រូវរលាយនៅក្រោមការស្ទាក់ស្ទើរ និងការរង់ចាំ។

ពេលដែលមនុស្សយើងដោះស្រាយបញ្ហាទាំងឡាយនៅក្នុងជីវិតប្រចាំថ្ងៃ យើងរមែងអាស្រ័យលើបទពិសោធ និងសញ្ជាតិញ្ញាណដោយដឹងជាស្វ័យប្រវត្តិថា ខ្លួនមិនអាចឈរនៅលើថ្មដែលផ្អៀងបានទេ ខ្លួននឹងមិនលូកដៃចូលទៅក្នុងគំនរភ្លើងទេ ព្រោះខ្លួនធ្លាប់មានបទពិសោធដែលឈឺចាប់ និងធ្លាប់បានទទួលមេរៀនដ៏មានតម្លៃរួចមកហើយ ទើបភាពបរាជ័យគឺជាបទពិសោធដ៏មានតម្លៃ ដែលធ្វើឱ្យមនុស្សយើងទទួលបានបទពិសោធនឹងកាន់តែឆ្លាតឡើង។

*ការធ្វើកំហុស មិនមែនជារឿងដែលគួរឱ្យខ្លាចទេ។ អ្វីដែលគួរឱ្យខ្លាចជាងការធ្វើកំហុសនោះគឺ ការភ័យខ្លាចហួសហេតុពីការធ្វើកំហុស។*

មនុស្សជាច្រើន ខ្លាចជួបនឹងភាពបរាជ័យ ខ្លាចបាត់បង់ប្រាក់ចំណូលដែលស្ថិតស្ថេរទៅ។ ដូច្នេះពាក្យថា «ប្រាក់ចំណូលដែលស្ថិតស្ថេរ» ជាឧបសគ្គសំខាន់នៃភាពរីកចម្រើនរបស់មនុស្សយើង ឆ្លុះបញ្ចាំងឱ្យឃើញពីការខ្វះទំនុកចិត្ត។ អ្នកក្រគួរដឹងថាការពឹងពាក់ទៅលើប្រាក់ខែនោះ គ្រាន់តែតបស្នងនឹងតម្រូវការមូលដ្ឋានរបស់ជីវិតតែប៉ុណ្ណោះ ព្រោះការដែលថៅហ្វាយជួលអ្នកមកនេះ មិនមែនឱ្យអ្នកមកមានជាមួយនឹងគេទេ។

ដូច្នេះ ការសាងសេចក្ដីសុខឱ្យខ្លួនឯងនោះគឺ អាស្រ័យលើខ្លួនអ្នក ហើយថា តើនឹងជ្រើសរើសផ្លាស់ប្ដូរទៅរកអ្វីដែលប្រសើរជាងនេះ ឬនៅដដែល។


លោកធ្វើម្ហូបឆ្ងាញ់ណាស់
បើបើកហាងប្រាកដជាលក់ដាច់មិនខាន
ខ្លាចរលំ
នៅម៉ុំនេះ ថ្លៃជួលថោក បើបើកចំណេញណាស់
នៅមិនទាន់ដល់ពេលទេ
គ្រប់គ្រងហាងរវល់ណាស់
ខ្លាចអីទៅ?
ចប់ហើយ
តើមានអ្វីញុំាទៅ?
ដល់ពេលបើកហាងហើយ...
ថ្លៃជួលថ្លៃ មានការប្រកួតប្រជែងខ្លាំង នៅបើកទៀតឬ?

# ៥៧

## អ្នកក្រខ្លាចនេះខ្លាចនោះជានិច្ច

មិនមែនថាអ្នកក្រនៅតែក្រព្រោះគ្មានក្ដីស្រមៃទេ តែដោយសារតែគេមិនធ្វើឱ្យក្ដីស្រមៃនោះក្លាយទៅជាការពិតនោះឯង។

បទពិសោធអាចសន្សំបានមកពីការប្រតិបត្តិពិត អ្នកដែលមានបទពិសោធនៃភាពជោគជ័យ សុទ្ធតែធ្លាប់បរាជ័យមកហើយ បើយើងមិនធ្វើដោយខ្លួនឯងទេ នឹងគ្មានថ្ងៃដឹងឡើយថា តាមពិតទៅ វាយ៉ាងណានោះទេ។

មនុស្សជាច្រើនចង់សាងអាជីព ប៉ុន្តែខ្លាចភាពបរាជ័យ ហើយតែងតែគិតថា រង់ចាំឱ្យដល់ពេលដែលសមរម្យសិន។

តាមពិតនោះ រឿងខ្លះមិនចាំបាច់ត្រូវរង់ចាំរហូតដល់ពេលដែលសមរម្យទេ ព្រោះពេលដែលយើងចាប់ផ្ដើមប្រតិបត្តិ គ្រប់យ៉ាងនឹងមានភាពសមរម្យ រៀបរយ និងពេញលេញជាបណ្ដើរៗដោយស្វ័យប្រវត្តិ។

និយាយទៅ អ្នកក្រគឺគ្មានដើមទុនអ្វីស្រាប់ទៅហើយ។ ដូច្នេះមិនចាំបាច់ត្រូវខ្លាចអ្វីទាំងអស់។ អ្នកក្រមានត្រឹមតែពងមាន់មួយគ្រាប់ នៅក្នុងដៃ ហើយពងមាន់មួយគ្រាប់នេះ គឺជាក្ដីសង្ឃឹមទាំងអស់របស់គេ គេត្រូវតែ

កាន់វាដោយប្រុងប្រយ័ត្នបំផុត មិនឱ្យធ្លាក់បែកទេ ព្រោះបើពងមាន់បែក គេនឹងត្រូវទទួលខុសត្រូវចំពោះកំហុសនេះ។

អ្នកក្រតែងតែខ្លាចនេះខ្លាចនោះជានិច្ច បើនិយាយទៅក៏ប្លែកដែរ មនុស្សយើងកាន់តែក្រកាន់តែខ្លាច កាន់តែខ្លាចកាន់តែក្រ ព្រោះត្រូវរង់ចាំរហូតដល់ពងមាន់មួយគ្រាប់នោះបែក ទើបព្រមចេញមកសាកល្បងរស់នៅបែបថ្មី។ ប៉ុន្តែ ដល់ពេលនោះ ឱកាសទាំងឡាយត្រូវបានអ្នកដទៃដណ្តើមយកទៅអស់ ហើយសមត្ថភាពរបស់គេនឹងចាប់ផ្តើមធ្លាក់ចុះជាបណ្តើរៗ នៅក្រោមការរង់ចាំដ៏យូរអង្វែង ហើយការតស៊ូនៅក្នុងការប្រកួតដ៏ក្តៅគគុក នៅក្នុងពេលនោះ មិនមែនជាការងាយទៀតឡើយ។

*បើពងមាន់មិនបែកទេ នឹងមិនហ៊ានធ្វើអ្វីទេឬ?*

ចូរឈប់ពឹងពាក់លើក្តីសង្ឃឹមដ៏តិចតួចនេះតទៅទៀតទៅ សាកល្បងប្រតិបត្តិជាក់ស្តែងមើល មុននឹងហួសពេល។ ព្យាយាមរកវិធីដោះស្រាយបញ្ហា ចាប់ផ្តើមប្រតិបត្តិជាក់ស្តែងចាប់តាំងពីថ្ងៃនេះទៅ ធ្វើមុនប្រសើរជាងធ្វើក្រោយ។


ពេលដែលថៅកែទទួលម៉ៅការ
ខ្ញុំនឹងថ្វាយជីវិតធ្វើការឱ្យគេម្តង
ពេលដែលថៅកែបង្វិលប្រាក់មិនទាន់
ខ្ញុំនឹងបោកកូនជ្រូកយកប្រាក់មកជួយណា
អ្នកដែលជួយទារបំណុលថៅកែនោះ គឺខ្ញុំ
ពេលដែលមានបញ្ហា អ្នកឡើងតុលាការជំនួសគឺ ខ្ញុំ
មនុស្សដែលហាត់ស្ទើរតែលេះខ្លួន នោះគឺខ្ញុំ
ពេលមាន
ហើយ ចង់ទាត់
ខ្ញុំចោលឬ?
ខ្ញុំលែងមានតម្លៃហើយ ចង់ទាត់ខ្ញុំចោលមែនទេ?
លោកហត់
ណាស់ហើយ
គួរសម្រាក
ខ្លះហើយ!

# ៥៨

## អ្នកក្របានត្រឹមតែជួយសាងអំណាច

ពេលអ្នកក្រមិនអាចសាងអំណាចរបស់ខ្លួនឯងបាន ក៏ជួយសាងអំណាចឱ្យអ្នកដទៃជំនួសវិញ។ អ្នកក្ររំពឹងថា នឹងបានជួបចៅហ្វាយនាយដ៏ល្អ ព្រោះបើចៅហ្វាយនាយទទួលបានជោគជ័យហើយ នឹងផ្តល់រង្វាន់ដល់ខ្លួនដែរ។ ប៉ុន្តែ អ្នកក្រដែលជំរុញឱ្យអ្នកដទៃមានអំណាច បែរជាមិនដែលបានទទួលនូវគុណសម្បត្តិអ្វីនឹងគេឡើយ ថែមទាំងគ្មានឱកាសបានសោយសុខពីភាពជោគជ័យរបស់អ្នកដទៃនោះទៀតផង។

ការសាងអំណាចមួយដែលរឹងមាំ ត្រូវប្រើពេលវេលា ត្រូវពុះពារឆ្លងកាត់សូម្បីគ្រាប់កាំភ្លើងពីសត្រូវ ប្រយុទ្ធជាមួយនឹងអ្នកខាងក្នុង-ក្រៅ និងត្រូវយល់ពីឧបនិស្ស័យរបស់ចៅហ្វាយនាយ ដែលខ្លួនចាំបម្រើទៀតផង។ ក្នុងរយៈពេលនេះ មនុស្សជាច្រើននឹងត្រូវគេកម្ចាត់ចោល។ ទោះបីជាអ្នកអាចគេចគ្រាប់កាំភ្លើងបាន ហើយជាមនុស្សសំណាងល្អដែលនៅរហូតដល់ថ្ងៃដែលចៅហ្វាយនាយទទួលបានជោគជ័យក៏ដោយ តែអ្នកអាចនឹងមិនបានប្រយោជន៍អ្វីពីភាពជោគជ័យនោះឡើយ។

ទើបការសាងអំណាចចាំបាច់ត្រូវមាន «ក្រុមស្ម័គ្រស្លាប់» ដែលសុខចិត្តលះបង់គ្រប់យ៉ាងសូម្បីតែជីវិត។ អំណាចឬអាណាចក្រទាំងឡាយបានមកដោយវិធីនេះឯង នេះជាសច្ចៈនៃលោកសន្និវាសនេះ។

ប៉ុន្តែក្រោយពីបានអំណាចមកហើយ ភារកិច្ចក៏ត្រូវផ្លាស់ប្តូរ និងក្លាយទៅជាការងារដែលត្រូវកែប្រែទម្រង់សាជាថ្មីវិញ។ ដូច្នេះអ្នកដែលចេះកាន់តែកាំភ្លើង កាន់ធ្នូ តែម្យ៉ាងនោះ គេនឹងលែងត្រូវការតទៅទៀតហើយ ទុកនាំតែស្មុគស្មាញ អស់តែបាយ អាចនឹងសាងបញ្ហាដល់ម្ចាស់អាណាចក្រទៀតផង។ ដូច្នេះការដែលក្រុមស្មុគ្រស្លាប់ត្រូវគេកម្ចាត់នោះ គឺជារឿងធម្មតាព្រោះភារកិច្ចថ្មីត្រូវប្រើមនុស្សថ្មីទាំងអស់។

អ្នកក្រដែលជួយឱ្យអ្នកដទៃទទួលបានជោគជ័យនោះ នៅមិនប្រាកដក្នុងចិត្តទេថា ខ្លួនឯងនឹងទទួលបានជោគជ័យឬទេ ហើយទោះបីជាទទួលបានជោគជ័យហើយក៏ដោយ ក៏អាចនឹងត្រូវគេទាត់ចោលដែរ។


ទិញបន្ទែសល់ប្រាក់ ផ្សងសំណាងលមើល៍
បើត្រូវរង្វាន់លេខ១
និងបាន ៥ លាន
មិនបាច់បង់រម្លួសផ្ទះហើយ
អាចទិញឡានបានទៀត
ទិញឡាន Rang Rover ប្រសើរជាង
ត្រូវពីរលេខចុងក្រោយក៏ល្អដែរ
និងបានប្តូរទូរទស្សន៍ថ្មី
ប៉ុន្តែ Vigo ក៏ម៉្យាងដែរ
បើមិនត្រូវទេ ចាត់ទុកថា
សងលុយប្រទេសជាតិវិញចុះ
ឆ្នោតស៊ីអស់

# ៥៩

## អ្នកក្រតែងតែទិញឆ្នោត

អ្នកសាកដើរទៅមើលនៅកន្លែងលក់ឆ្នោតលមើល តើអ្នកមាន ឬអ្នកក្រដែលទិញច្រើនជាងគេបំផុត?

អ្នកក្រចង់ផ្លាស់ប្តូរវាសនារបស់ខ្លួនខ្លាំងណាស់ សុំឱ្យតែមានក្តីសង្ឃឹមខ្លះៗ នោះនឹងមានកម្លាំងក្រោកឡើងតស៊ូតទៅទៀតហើយ ចុះទម្រាំតែឆ្នោតដែលផ្តល់ក្តីសង្ឃឹមជាប្រាក់រាប់សែនរាប់លាននោះ បើពិតជាត្រូវមែន មិនដឹងថានឹងសប្បាយចិត្តរហូតដល់ថ្នាក់ណាទេ។

«មាន់ពងយកពងទៅភ្ញាស់ជាកូនមាន់» អ្នកក្រវិលវល់ជាមួយនឹងពាក្យមួយឃ្លានេះអស់មួយជីវិត ពួកគេតែងតែគិតថា យកប្រាក់មកទិញឆ្នោតអាចត្រូវរង្វាន់បាន។ ដូច្នេះទើបអ្នកក្រផ្ញើក្តីសង្ឃឹមទៅលើឆ្នោត ដោយគិតថា យ៉ាងណាក៏ដោយ នឹងត្រូវមានអ្នកដែលត្រូវរង្វាន់ធំម្នាក់ដែរ ... ម្នាក់ដែលថានោះអាចជាខ្លួនក៏ថាបានដែរ នរណានឹងអាចដឹងបានទៅ!

និយាយទៅ ឆ្នោតគឺជា «ល្បែង» ម្យ៉ាង ហើយថែមទាំងត្រូវចិត្តអ្នកក្រទៀតផង។ អ្នកមាននឹងមិនប្រើឆ្នោតដើម្បីធ្វើជាសេដ្ឋីទេ មានតែអ្នកក្រប៉ុណ្ណោះដែលស្រក់ទឹកមាត់ចំពោះប្រាក់រង្វាន់ទាំងនោះ។

គិតឱ្យបានច្បាស់ ប្រាក់ដែលអ្នកក្រទិញឆ្នោតនោះ រួមទៅច្រើនជាងប្រាក់ដែលអ្នកមានមានច្រើនដងណាស់ កាន់តែសង្ឃឹមខ្លាំងប៉ុនណាក៏កាន់តែឈឺចាប់ខ្លាំងប៉ុណ្ណោះដែរ។ សាកមើលមនុស្សដែលនៅជុំវិញខ្លួនយើងមើល តើមានប៉ុន្មាននាក់ដែលអាចផ្លាស់ប្តូរវាសនាបានដោយសារតែឆ្នោត?

កាន់តែទិញកាន់តែក្រ អ្នកលក់ឆ្នោតដែលលួងលោមឱ្យអ្នកទិញនោះគេពិតជាមានបំណងល្អនឹងអ្នកពិតមែនឬ?

បើអ្នកយល់ពីរឿងនេះបានច្បាស់លាស់ហើយ អ្នកក៏នឹងយល់ពីរឿងដទៃជាច្រើនទៀតដោយស្វ័យប្រវត្តិដែរ។


ហេតុអ្វីចាំបាច់រៀន វៃយូឡុង ផងចាំ
វាជាសិល្បៈ
ហេតុអ្វីចាំបាច់រៀនគូររូបផងចាំ
វាជាសិល្បៈ
ហេតុអ្វីចាំបាច់រៀនអុកផងចាំ
វាជាសិល្បៈ
ហេតុអ្វីត្រូវហាត់បោះបាល់ផងចាំ
វាជាសិល្បៈ
ហេតុអ្វីចាំបាច់រៀនធ្វើម្ហូបផងចាំ
វាជាសិល្បៈ
តើរៀនសិល្បៈច្រើនពេកធ្វើអ្វី?
ដើម្បីកុំឱ្យក្រដូចចាំ
ហេតុដូច្នេះហើយទើបគ្មានសិល្បករណា
បានជាសេដ្ឋីនឹងគេ

# ៦០

## អ្នកក្រផ្តល់ភាពសំខាន់ចំពោះសិល្បៈនិងវិជ្ជាជីវៈ

អ្នកក្រត្រូវគេអប់រំប្រៀនប្រដៅមកតាំងពីនៅក្មេងថា ឱ្យខិតខំរៀនសូត្រ ហើយការដែលបានអ្វីមកដោយទទេៗ គឺជារឿងដែលគួរឱ្យអាម៉ាស់ណាស់។

និយាយតាមត្រង់ទៅ ទោះបីជាអ្នកក្រចង់ដេកស៊ី ក៏មិនអាចធ្វើបានដែរ ពួកគេត្រូវតស៊ូ។ ការស្វែងរកភាពរីកចម្រើនរបស់អ្នកក្រ គឺជាការព្យាយាមលើកតម្កើងខ្លួនឯង ឱ្យឆ្ពោះទៅរកស្ថានភាពដែលប្រសើរជាងនេះ ទាំងផ្នែកខាងចំណូល និងតំណែងការងារ ដូច្នេះហើយទើបគោលបំណងក្នុងការតស៊ូរបស់អ្នកក្រត្រូវតែមានភាពច្បាស់លាស់ជាខ្លាំង។

ដើម្បីធ្វើឱ្យគោលបំណងក្លាយទៅជាការពិតបាននោះ ត្រូវធ្វើនូវរឿងដែលជាការជាក់ស្តែង ទើបអ្នកក្រត្រូវសិក្សាពីអ្វីដែលមានប្រយោជន៍ ជ្រើសរើសយកមុខវិជ្ជាដែលមានប្រយោជន៍ រៀនមុខវិជ្ជាដែលផ្តល់នូវប្រយោជន៍ ក្រែងលោអាចរកប្រាក់កម្រៃបានបន្ថែមទៀត។

អ្នកក្រតែងឱ្យកូនរៀនតន្ត្រី ដើម្បីឱ្យបានក្លាយទៅជាអ្នកចម្រៀងនឹងអាចរកប្រាក់ចំណូលបានច្រើននាពេលអនាគត ឬឱ្យកូនទៅចូលរួម

ប្រកួតសមត្ថភាពផ្សេងៗ។ ការធ្វើដូច្នេះ គឺដើម្បីឱ្យកូនមានអនាគតភ្លឺស្វាង មានដើមទុនដ៏ល្អ។

កូនរបស់អ្នកក្រអានកាសែតច្រើនតាំងពីនៅតូច មើលទៅអាចនិពន្ធសៀវភៅបានល្អ លេងវីយ៉ូឡុងក៏ពីរោះ ចង់យកធ្វើជាអាជីពក៏បានដែរ មិនចាំបាច់ខ្លាចថាគ្មានការងារធ្វើទេ។

សិល្បៈនិងវិជ្ជាជីវៈគ្រប់យ៉ាង ត្រូវឆ្លងកាត់ការហ្វឹកហាត់ ដូច្នេះហើយ ទើបអ្នកក្រខំប្រឹងប្រែងហ្វឹកហាត់តាំងតែពីតូច (ខុសពីអ្នកមានដែលដើរឡូយឆាយ មិនប្រញាប់ប្រញាល់ឱ្យកូនរៀនសិល្បៈ ឬវិជ្ជាជីវៈអ្វី) នោះគឺដើម្បីកុំឱ្យកូនគ្មានការងារធ្វើក្នុងពេលអនាគត។

បច្ចុប្បន្ននេះ កេរ្តិ៍ឈ្មោះគ្រប់យ៉ាងសុទ្ធតែផ្លាស់ប្តូរទៅជាប្រាក់បានទាំងអស់កាន់តែរកប្រាក់បានច្រើនកាន់តែមានកេរ្តិ៍ឈ្មោះ ទីបំផុតគឺ មានតែអ្នកមានប៉ុណ្ណោះដែលដើរនៅជួរមុខរបស់សង្គម។

យ៉ាងណាក៏ដោយ បើមនុស្សយើងពូកែលើមុខវិជ្ជាណាមួយនោះ នឹងមិនអត់ឃ្លានស្លាប់ទេ (គ្រាន់តែមិនអត់ឃ្លានស្លាប់ប៉ុណ្ណោះ!)។



# ៦១

## អ្នកក្រត្រូវបានគេជ្រើសរើស

ផ្សារណាត់ពលករនៅតាមស្រុកនានានៃប្រទេសចិន យើងតែងតែឃើញពលករជាច្រើនឈរលើកផ្លាកក្រដាសនៅពីមុខផ្សារ។ នៅលើផ្លាកបានសរសេរថា «ជាងស៊ីម៉ង់ត៍ ជាងដែក ជាងផ្សារ និងកម្មករ» ជាដើម។ មូលហេតុដែលអ្នកទាំងនេះត្រូវមកឈរនៅខាងក្រៅ ព្រោះមិនចង់បង់ថ្លៃពន្ធ។ ក្នុងនោះ មានកម្មករជាច្រើនមកឈរចាំនិយោជក មកជ្រើសរើសពួកគេទៅធ្វើការ ហើយអ្នកក្ររមែងប្រើវិធីបែបនេះរកការងារធ្វើ។

*សម្រាប់អ្នកក្រ ការងារសំខាន់បំផុត។ បើគ្មានការងារទេ ទាំងខ្លួន និងប្រពន្ធកូននៅឯផ្ទះក៏គ្មានអ្វីហូបដែរ។*

គោលបំណងសំខាន់ដែលអ្នកក្រត្រូវតែរៀននោះគឺ ព្យាយាមហ្វឹកហាត់ធ្វើយ៉ាងណាឱ្យខ្លួនមានការត្រៀមលក្ខណៈពេញលេញជានិច្ច ដូចជាស្នាដៃដែលលេចធ្លោ ឬកពាថ្លៃថ្នូរ ប្រាជ្ញាដ៏ឈ្លាសវៃ និងសមត្ថភាពពេញខ្លួន ដើម្បីឱ្យអ្នកដទៃចាប់អារម្មណ៍ ជ្រើសរើសយកគេទៅធ្វើការបានគ្រប់ពេល។

ប៉ុន្តែ ហេតុអ្វីបានជាអ្នកក្រមិនគិតថា អ្នកមានអាចនឹងទៅជ្រើសរើសអ្នកដទៃ។ បើអ្នកគិតតែពីហ្វឹកហាត់សមត្ថភាពរបស់ខ្លួន ដើម្បីឱ្យអ្នក

ដទៃងាយនឹងជ្រើសរើសយកអ្នកនោះ ក្នុងមួយជីវិតរបស់អ្នកនឹងគ្មានថ្ងៃបានក្លាយទៅជាអ្នកមានបានឡើយ។

តើការមានមហាសាលគឺជាអ្វី? ចម្លើយគឺ លទ្ធផលរួមនៃភាពមានបានបន្តិចបន្តួច។ បើអ្នកក្រប្រមូលកម្លាំងទាំងអស់ពីអ្នកដទៃមកធ្វើជារបស់ខ្លួនបាននោះ មាសប្រាក់នឹងហូរចូលមករកអ្នកក្រ ដោយគ្មានឈប់ឈរនោះអ្នកក្រនឹងអាចមានហើយ។

ការសិក្សាគឺជារឿងសំខាន់ ការងារក៏សំខាន់ដែរ។ ប៉ុន្តែ មិនមែនសំខាន់បំផុតទេ អ្វីដែលសំខាន់បំផុតនោះគឺ «រៀនអ្វី» ឬ «ធ្វើការងារដើម្បីនរណា» ទៅវិញទេដែលសំខាន់ជាង (តើគួរធ្វើដើម្បីខ្លួន ឬដើម្បីអ្នកដទៃ?)។


គ្មានទេ
គ្មានទេ
យើងត្រូវផ្លាស់ប្រែកសនា
មកចាប់ផ្ដើមពីការធ្វើជាការក្មេង
ជាមុនសិន
មិនចង់ទេ
គ្មានទេ
ចង់ណាស់

# ៦២

## អ្នកក្រស្រមៃចង់ក្លាយជាតារា

អ្នកក្រគ្មានប្រាក់ទេ ដើមទុនដែលសំខាន់បំផុតរបស់ពួកគេគឺ «ខ្លួនប្រាណ» និង «ជីវិត»។

នៅក្នុងសហរដ្ឋអាមេរិក ក្មេងជនជាតិស្បែកខ្មៅដែលរស់នៅក្នុងតំបន់ក្រីក្រសុទ្ធតែស្រមៃចង់ក្លាយទៅជា ម៉ៃឃើល ចរ៍ដេន (Michael Jordan) ឬ ម៉ៃ ថៃសាន់ (Mike Tyson) ច្រើនបំផុត ប្រាថ្នាសុំឱ្យមានសាច់ដុំធំៗ និងមានថ្ងៃដែលបន្តិចបន្តួចនោះ ក៏អាចចេញទៅតស៊ូជាមួយនឹងឧបសគ្គរហូតដល់ក្លាយទៅជាសេដ្ឋីបានហើយ។

មិនថាជាកីឡាករ ឬជាតារាទេ បើល្បីពិតមែននោះ អ្នកនឹងក្លាយទៅជាម៉ាស៊ីនបោះពុម្ពប្រាក់ គ្រាន់តែចុចកុងតាក់តែបន្តិច ប្រាក់នឹងហូរចេញមកភ្លាម។ បច្ចុប្បន្ននេះ តារាមិនត្រឹមតែអាចរកប្រាក់បានប៉ុណ្ណោះទេ នៅអាចធ្វើជាគណៈកម្មការ ឬជាអ្នកផ្សាយពាណិជ្ជកម្ម នៅក្នុងអង្គភាពផ្សេងៗទៀតផង។ ស្ថានភាពហិរញ្ញវត្ថុ និងស្តង់ដារស់នៅក្នុងសង្គមក៏ប្រសើរជាងពីមុនជាខ្លាំងដែរ។ តារាគឺជាអ្នកនាំមុខគេផ្នែកខាងសម័យនិយម ជាវីរបុរសនៃសម័យកាល ប្រៀបដូចជាមជ្ឈមណ្ឌលនៃក្តីស្រមៃ និងកម្លាំងចិត្តរបស់យុវវ័យ។ ជាងនេះទៅទៀត ការធ្វើជាតារាក៏មិនបាច់ត្រូវប្រើប្រាក់

ដើម្បីចុះទុនដូចបើកហាងលក់ទំនិញដែរ ទើបជនជាតិចិនស្រមើស្រមៃចង់ក្លាយជាតារា។

តែប្រាកដណាស់ ការក្លាយជាតារាដែលមានឈ្មោះល្បីនោះមិនមែនជារឿងងាយទេ។

សិស្សនៅក្នុងសាលាវិចិត្រសិល្បៈ ឬនៅក្នុងសាលាកីឡាអាចនឹងគិតថារៀនលេងៗពីមួយថ្ងៃទៅមួយថ្ងៃដើម្បីសប្បាយ ប៉ុន្តែឪពុកម្ដាយបែរជារំពឹងឱ្យកូនបានក្លាយទៅជាតារាល្បីដើម្បីឱ្យជីវិតល្អប្រសើរឡើង។

អ្នកក្រជឿថា មនុស្សដែលឆ្លងកាត់ការលំបាកវេទនាយ៉ាងខ្លាំងនោះចាត់ទុកថាជាកំពូលមនុស្ស។ ការពិតមួយចំណុចនេះ អាចទទួលយកបាន។

មនុស្សយើងកើតមកសុទ្ធតែមានសមត្ថភាព និងមានជំនាញខុសគ្នា អ្នកក្រក៏ជាមនុស្សដែរ។ ដូច្នេះបើអ្នកក្រតាំងចិត្តអភិវឌ្ឍខ្លួនឯងឱ្យបានល្អនោះ ប្រាក់នឹងមិនទៅណាឆ្ងាយឡើយ។



# ៦៣

## ការវិនិយោគទុនរបស់អ្នកក្រ

អ្នកក្រចង់ផ្លាស់ប្តូរជីវិតរបស់ខ្លួនឯងខ្លាំងណាស់ ទើបចង់វិនិយោគទុនភ្លាមពេលដែលមានឱកាស។ សៀវភៅដែលបង្ហាញផ្លូវមានឱ្យអ្នកក្រសុទ្ធតែគាំទ្រឱ្យអ្នកក្រវិនិយោគទុនស្ទើរតែគ្រប់សៀវភៅទាំងអស់។

ការវិនិយោគទុន គឺការយកប្រាក់ទៅពង្រីក ចំណែកការដែលអាចយកប្រាក់ត្រឡប់មកវិញបាន ឬអត់នោះ គឺជារឿងដែលសំខាន់បំផុត អ្នកក្រជាច្រើនត្រូវបានការវិនិយោគទុនធ្វើបាប ធ្វើឱ្យកាន់តែក្រខ្លាំងឡើង។

អ្នកក្រចូលចិត្តការពុះពារតស៊ូ ប៉ុន្តែ ពេលដែលមានដើមទុនទាបជាងអ្នកដទៃ តស៊ូមិនឈ្នះអ្នកដទៃ ទីបំផុតក៏ត្រូវអស់ពីខ្លួន។

នៅក្នុងសង្គមចិន មានវិធីមានដែលមនុស្សចូលចិត្តជាច្រើនដូចជា ធុរកិច្ចលក់ផ្ទាល់ ធុរកិច្ចប្រមូលដើមទុនជាដើម។ គ្រាន់តែផ្សាយពាណិជ្ជកម្មតែមួយភ្លែត នឹងមានមនុស្សចាប់អារម្មណ៍នាំគ្នាទៅធ្វើជាច្រើន តែលទ្ធផលចុងក្រោយគឺ ប្រាក់របស់អ្នកក្រត្រូវបាត់បង់ ចង់មុកអង្គុយយំក៏មិនអាចធ្វើឱ្យអ្វីល្អប្រសើរឡើងបានដែរ។

អ្នកក្រចាញ់ប្រៀបគេទាំងផ្នែកគុណសម្បត្តិ និងស្ថានភាពខាងហិរញ្ញវត្ថុ ទើបធ្វើអ្វីៗតែងតែភ្លាំងភ្លាត់ជានិច្ច។ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចបែប

មូលធននិយមក៏ដូចគ្នាដែរ អ្នកក្រគឺជាភាគីដែលចាញ់ប្រៀបដោយមិនអាចគេចផុតបានឡើយ ដឹងទាំងដឹងហើយថា គឺជាប្រព័ន្ធត្រីធំស៊ីត្រីតូច តែក៏នៅតែរឹងរូស ចង់ចូលរួមជាមួយ យកខ្លួនទៅឱ្យគេពន្លះដល់កន្លែងដើម្បីអ្វី?

របបមូលធននិយមផ្តល់នូវភាពសំខាន់ទៅលើលទ្ធផល ច្រើនជាងអ្វីៗទាំងអស់។

អ្នកវិនិយោគទុននឹងទទួលបានផលឬអត់នោះគឺ មើលទៅលើថាអ្នក «មិនត្រូវខាតដើម» ទេ ហើយត្រូវធ្វើឱ្យ «ប្រាក់ដើមទុនអាចរីកលូតលាស់បាន» ត្រង់ចំណុចនេះសំខាន់បំផុត។

បើគ្មានការជឿជាក់លើការវិនិយោគទុនទេ ចូរកុំធ្វើប្រសើរជាង ព្រោះជ័យជម្នះនឹងក្លាយជារបស់អ្នកដែលភ្លាំងភ្លាត់តិចបំផុត។


ស៊ូតី
បើកហាងស៊ូតីប្រសើរជាង

# ៦៤

## អ្នកក្រមិនចេះរៀបចំគម្រោង

*អ្នកក្រចង់មានឆាប់ តែបែរជាមិនមានគម្រោងឱ្យបានល្អិតល្អន់។*

នៅក្នុងខួរក្បាលរបស់អ្នកក្រ «ប្រាក់ចំនួនមហាសាល» គឺជាវត្ថុវិសេសយ៉ាងខ្លាំង។ ពេលដែលនិយាយដល់ប្រាក់មហាសាល ទឹកមាត់ចាប់ផ្តើមហៀរ ហើយក៏ប្រញាប់ដកដាវចេញមកប្រយុទ្ធភ្លាម។

ប៉ុន្តែ តើដាវនៅឯណា? ប្រយុទ្ធជាមួយនរណា? ប្រយុទ្ធដូចម្តេច? អ្នកក្រមិនបានគិតពីរឿងនេះសោះឡើយ។

អ្នកក្រគ្មានប្រាក់ទេមានតែចបប៉ុណ្ណោះ ទើបពួកគេគិតចង់ជីកនេះជីកនោះ មិនប្រាកដទេអាចនឹងជីករកឃើញមាសផងក៏ថាបាន។ ប៉ុន្តែអ្នកក្រភាគច្រើនជីកមិនដែលជួបអ្វីឡើយទើបនៅតែក្ររហូត។ ចំណែកអ្នកដែលជីកឃើញមាសក៏មិនឃើញថានឹងមានឡើងដែរ ព្រោះពេលដែលដឹងគ្រប់គ្នាទៅ មនុស្សបាននាំគ្នាទៅជីក ប្រើទាំងចបកាប់ និងចបជីក ដណ្តើមគ្នាជីក ឃើញខ្លះមិនឃើញខ្លះ រហូតដល់មាសសឹករេចរឹលអស់ ទីបំផុត គ្មានសេសសល់ទ្រព្យសម្បត្តិអ្វីជាប់ខ្លួនទាល់តែសោះ។

ប៉ុន្តែ អ្នកមានគេមិនកាន់ចបដោយខ្លួនឯងទេ បើគេចង់បានមាសគេនឹងបង្កើតក្រុមជំនាញ ដើម្បីទៅស្រាវជ្រាវរកអណ្តូងរ៉ែមាស ត្រួតពិនិត្យ

យ៉ាងលម្អិត រហូតដល់បានដឹងច្បាស់ កំណត់ដំណាក់កាលនៃការជីកឱ្យបាន រៀបរយ និងជាប្រព័ន្ធ។ បន្ទាប់មក នឹងរកអ្នកយាមមកការពារសន្តិសុខ ហើយរកជាងដែលជំនាញទៅជីកមាស រំលាយមាសដោយប្រើបច្ចេកវិទ្យា តាមប្រព័ន្ធវិទ្យាសាស្ត្រ ហើយបើជីកឃើញមាសពិតមែន ក៏មិនមែនមាស ត្រឹមតែមួយដុំឬពីរដុំដែរ តែជាមាសចំនួនមហាសាល ដែលបានមកមិន ចេះដាច់ ប្រៀបបីដូចជាផលិតចេញពីម៉ាស៊ីនជារៀងរាល់ថ្ងៃ។

ការមានប្រាក់នោះ មិនមែនជារឿងចៃដន្យទេ ចំណែកអ្នកក្រវិញ ទោះបីជាមានប្រាក់ក៏ដោយ តែមិនអាចកាន់បានយូរឡើយ ទាំងនេះព្រោះ គ្មានគម្រោង។



# ៦៥

## អ្នកក្រតែងតែអាងលើវាសនា

អ្នកក្រសង្ឃឹមលើសំណាង និងសង្ឃឹមលើវាសនា ពេលដែលមានរបស់ហ្វ្រីធ្លាក់នៅចំពោះមុខនោះ នឹងប្រញាប់ចូលទៅស្រវាទុក។

អ្នកក្រតែងតែយករឿងផ្សេងៗ មកពាក់ព័ន្ធជាមួយនឹងវាសនា ដូចជា អ្នកដទៃគេសំណាងល្អណាស់ដែលមុខរបររីកចម្រើនរុងរឿង អ្នកនេសាទសំណាងល្អដែលរកបានគុជខ្យង។ អ្នកក្រនិយាយរឿងរ៉ាវទាំងនេះ និងស្ដាប់រឿងរ៉ាវទាំងនេះ ដើម្បីសេចក្ដីសុខបន្តិចបន្តួច ព្រោះមានតែវាសនាប៉ុណ្ណោះ ដែលជាលេសដ៏ល្អបំផុត និងធ្វើឱ្យខ្លួនឯងរួចផុតពីសម្ពាធនៃភាពក្រលំបាកបាន។

ពាក្យថា «សំណាងមិនល្អ» ចាត់ទុកថាជាថ្នាំព្យាបាលរបួសចិត្តដ៏ពូកែសម្រាប់អ្នកដែលបរាជ័យ។

ភាពជឿជាក់របស់មនុស្សយើង តែងតែកើតឡើងពីភាពជោគជ័យ បើបរាជ័យម្ដងហើយម្ដងទៀតនោះ ការជឿជាក់នឹងថយចុះជាលំដាប់។ តាមពិតទៅ អ្នកក្រតែងតែខ្វះខាតនូវការជឿជាក់ រហូតដល់មើលមិនបានវែងឆ្ងាយ និងមានឥរិយាបថមិនក្លាហាន។

នៅពេលដែលខ្វះការជឿជាក់ មនុស្សយើងនឹងមានការភ័យខ្លាច ពេលខ្លះនឹងមានការសង្ស័យ ឬគិតថា គ្រប់គ្នាយកប្រៀបលើខ្លួន ឬក៏បើមិនដូច្នោះទេ នឹងមានគំនុំនៅក្នុងចិត្ត ពេលដែលជួបអ្នកមាននឹងស្រែកដាក់អ្នកមានថា «ឯងហ្នឹងខ្លាំងមកពីណា?»។

អ្នកក្ររាងចាលនឹងភាពក្រីក្រ មួយថ្ងៃៗ ពិបាកចិត្តនឹងបញ្ហាក្រពះ មើលទៅជុំវិញខ្លួនមានតែអ្នកក្រ ទើបស៊ាំទៅនឹងការគិតពីរឿងកំប៉ិកកំប៉ុក ដូចជា ខ្លាចអ្នកលក់បន្លែស៊ីភ្នែកជញ្ជីង ខ្លាចចោរមកឆក់កាបូបទើបចាប់កាន់កាបូបរបស់ខ្លួនយ៉ាងណែន។ អ្នកក្ររស់នៅក្រោមអំពើទុច្ចរិតជារៀងរាល់ថ្ងៃ បើដូច្នេះនឹងឱ្យពួកគេមើលពិភពលោកក្នុងផ្លូវវិជ្ជមានដូចម្ដេចទៅ?

អ្នកក្រ គឺជាក្រុមមនុស្សទន់ខ្សោយ មិនដែលបានធ្វើជាអ្នកគ្រប់គ្រងស្ថានការណ៍ទេ ពេលខ្លះនៅមិនអាចគ្រប់គ្រងខ្លួនឯងបានផង។ សម្រាប់មនុស្សដែលបរាជ័យមកជាច្រើនលើកច្រើនសា និងមិនអាចកំណត់អនាគតរបស់ខ្លួនបាននោះ បើអ្នកមិនឱ្យគេជឿលើរឿងវាសនាទាល់តែសោះនោះក៏ពិបាកដែរ។


ភ្នាល់ថា ភ្លៀងមិនខ្លាំងទេ
គ្មានបុយប៉ះដំបូលផ្ទះទេ
ភ្នាល់ថា ភ្លៀងមិនធ្លាក់ទេ
ភ្នាល់ថា ភ្លៀងនឹងឈប់
ភ្នាល់ថា ភ្លៀងមិនយូរទេ
ភ្នាល់ថា ទឹកជន់ត្រឹមចង្កេះប៉ុណ្ណោះ
ភ្នាល់ថា ទឹកមិនជន់ទេ
សូមភ្នាល់ដោយលើកចុងក្រោយថា...

# ៦៦

## អ្នកក្រចូលចិត្តលេងល្បែងភ្នាល់គ្នា

*អ្នកក្រគិតជានិច្ចថាជីវិតគឺជាល្បែងទើបចូលចិត្តផ្សងសំណាង។*

ល្បែងធ្វើឱ្យយើងមើលឃើញពីនិស្ស័យរបស់មនុស្សម្នាក់ៗ ព្រោះពួកលេងល្បែងណាក៏ដូចពួកលេងល្បែងណាដែរ មើលឃើញតែលទ្ធផលនៅចំពោះមុខ និងសម្រេចចិត្តជ្រើសរើសតែលទ្ធផលនៅចំពោះមុខតែប៉ុណ្ណោះ។

អ្នកខ្លះចូលចិត្តភ្នាល់គ្នាច្រើនៗ ចាក់លុយច្រើនៗ តែអ្នកខ្លះក៏ប្រយ័ត្នប្រយែងគ្រប់ជំហានដែរ។ អ្នកដែលហ៊ានស៊ីហ៊ានសងក្នុងការប្រថុយខ្ពស់នោះ ក៏ត្រូវប្រឈមមុខនឹងហានិភ័យខ្ពស់ដែរ បើចាញ់នឹងចាញ់អស់ពីខ្លួន តែបើឈ្នះក៏នឹងឈ្នះបានច្រើនមហាសាលដែរ។ ចំណែកអ្នកដែលប្រយ័ត្នប្រយែង នឹងទទួលបានជោគជ័យឃីតបន្តិច សន្សំប្រយោជន៍ដែលទទួលបានម្តងបន្តិចៗ រហូតដល់ទីបំផុត នឹងទទួលបានជោគជ័យពេញលេញ។

ប៉ុន្តែ អ្វីដែលគួរឱ្យខ្លាចបំផុតនោះគឺ មនុស្សប្រភេទដំបូង ដែលហ៊ានស៊ីហ៊ានសងក្នុងការប្រថុយខ្ពស់នោះ ពួកគេតែងតែបារម្ភ អង្គុយអ៊ុតរហូតដល់បែកញើស ពេលខ្លះភ្លេចខ្លួនចាក់រហូតដល់អស់ពីខ្លួន។ លទ្ធផល

ចុងក្រោយច្រើនតែបរាជ័យ គឺចាញ់ច្រើនជាងឈ្នះ តែបើឈ្នះអាចនឹងសប្បាយចិត្តរហូតដល់ភ្លេចខ្លួនក៏មានដែរ។

ការលេងល្បែងមិនមែនជារឿងដែលពិបាកទេ តែត្រូវគិតឱ្យបានល្អិតល្អន់ពីផលអាក្រក់ជាសំខាន់ បន្ទាប់មកចាំគិតពីរឿងវិធី។ បើមើលបែបសើៗទៅ នឹងឃើញថា ការលេងល្បែងគឺអាស្រ័យលើសំណាង ប៉ុន្តែស្តេចល្បែងដែលពិតប្រាកដនោះ ត្រូវប្រើប្រាជ្ញា មានឧបនិស្ស័យពិសេសដែលអ្នកដទៃមិនមាន។ ប៉ុន្តែ ក្នុងលោកនេះ គ្មាននរណាចម្រើនរុងរឿងដោយសារការលេងល្បែងទេ។



# ៦៧

## អ្នកក្រចង់រកប្រាក់ឱ្យបានច្រើន

សៀវភៅមួយក្បាលដែលមានឈ្មោះថា «ឪពុកអ្នកមាន» ដែលនិពន្ធដោយ រ៉ូប៊ីត ឃិយ៉ូសាគិ (Robert Kiyosaki) ជនជាតិជប៉ុនលក់ដាច់យ៉ាងឆាប់រហ័ស បានធ្វើឱ្យ រ៉ូប៊ីត ឃិយ៉ូសាគិ ល្បីល្បាញយ៉ាងខ្លាំង មិនថាគាត់ធ្វើដំណើរទៅផ្សព្វផ្សាយដល់ទីណាទេ មនុស្សជាច្រើនមករង់ចាំជួបគាត់ និងទិញសៀវភៅរបស់គាត់ ភ្លេចខ្លួនតែមួយភ្លែតប៉ុណ្ណោះអាចប្រមូលប្រាក់បានយ៉ាងច្រើនមហាសាល។

គ្រាន់តែនិពន្ធសៀវភៅមួយក្បាល ក៏អាចធ្វើឱ្យមនុស្សក្លាយជាសេដ្ឋីបានដែរ។ ប៉ុន្តែ ទម្រាំតែបានមកប៉ុណ្ណោះ ត្រូវមានការរៀបចំគម្រោង មានការរៀបចំប្រព័ន្ធនិងត្រូវមានគោលដៅ។ ទោះបីជាសៀវភៅមានតម្លៃមិនថ្លៃក៏ដោយ ប៉ុន្តែ បើមានមនុស្សទិញច្រើន នឹងអាចក្លាយទៅជាប្រាក់ចំនួនមហាសាលបាន។

ភាពឈ្លាសវៃរបស់អ្នកមាន គឺពួកគេមានវិធីអូសទាញប្រាក់បន្តិចបន្តួចពីអ្នកក្រមកដាក់ក្នុងហោប៉ៅរបស់ខ្លួនបាន វិធីនេះអាចប្រតិបត្តិបានពិត ប៉ុន្តែមានភាពច្របូកច្របល់ និងមានរឿងលម្អិតជាច្រើន ដែលទាមទារឱ្យមានការសិក្សាយ៉ាងលម្អិត។

អ្នកក្រតែងតែគិតថា បើចង់មានត្រូវធ្វើកិច្ចការធំ ត្រូវរៀបចំគម្រោងការធំៗទុកជានិច្ច។ ពួកគេមិនសូវគិតថា ប្រាក់ជាច្រើនកើតឡើងពីប្រាក់បន្តិចបន្តួចទេ។ អ្នកក្រគិតធ្វើកិច្ចការធំ ព្រោះស្ថានការណ៍បង្ខំ បើមិនដូច្នោះទេ ធ្វើបណ្ដើរអ៊ូបណ្ដើរ បន្ទោសតែភាពក្រីក្រ ដែលមិនអាចឱ្យគេធ្វើកិច្ចការធំបាន គិតតែពីថា ត្រូវមានប្រាក់ជាមុនសិនទើបអាចធ្វើកិច្ចការធំបាន។

ការធ្វើកិច្ចការធំមិនមែនជារឿងងាយដូចដែលអ្នកក្របានគិតទេ បើខ្វះបទពិសោធនោះ ទោះបីជាមានមនុស្សចេញប្រាក់ដើមទុនឱ្យក៏ដោយ ក៏គេមិនអាចទទួលបានជោគជ័យដែរ។

អ្នកក្រចង់រកប្រាក់ឱ្យបានច្រើនៗក្នុងមួយប៉ប្រិចភ្នែក ប៉ុន្តែតើដឹងពីវិធីដែលធ្វើឱ្យកើតឡើងបានឬអត់នោះ គឺជារឿងមួយផ្សេងទៀត។

ជំនួញនៅក្នុងសម័យនេះ បានកម្រៃមិនច្រើនទេ កាំបិតរឹលៗរបស់អ្នកក្រមួយដើម តើអាចធ្វើអ្វីបានទៅ?

លទ្ធផលចុងក្រោយគឺ អ្នកក្រនោះឯងដែលសម្លាប់ទេវតានាំលាភដោយដៃរបស់ខ្លួនឯង។



# ៦៨

## កូនអ្នកក្រចាប់ផ្ដើមយឺត

គេតែងនិយាយថា កូនអ្នកក្របើមានឱកាសរៀននឹងមានអនាគតល្អជាងកូនអ្នកមាន។ ប៉ុន្តែ តាមពិតនោះ គឺផ្ទុយស្រឡះទៅវិញទេ។

ក្មេងដែលកើតនៅក្នុងគ្រួសារអ្នកក្រ សិក្សាដើម្បីជីវភាព ដូច្នេះធ្វើយ៉ាងណាឱ្យបានចូលរៀននៅក្នុងសាលាល្អៗ បានការងារល្អៗ និងមានអនាគតដ៏ល្អ។ ដូច្នេះ ទើបកូនអ្នកក្រខំប្រឹងសិក្សាតែម្យ៉ាងគត់ មិនធ្វើអ្វីផ្សេងឡើយ។

អ្នកមានគិតថា ចំណេះដឹងទាំងឡាយដែលទាក់ទងនឹងជីវភាព គឺជារឿងដែលត្រូវសិក្សាទាំងអស់ ប៉ុន្តែអ្នកក្រជាច្រើននាក់បែរជាយល់ច្រឡំថា អ្វីដែលមាននៅក្នុងសៀវភៅ សុទ្ធតែជាចំណេះដឹង ទើបមិនចាប់អារម្មណ៍ពីចំណេះដឹងទូទៅ ដែលមានប្រយោជន៍ចំពោះជីវិតប្រចាំថ្ងៃរបស់ខ្លួន។

ដូច្នេះ «សមត្ថភាពក្នុងការគ្រប់គ្រងភាពមានបានឱ្យនៅគង់វង្ស» បានប្រែក្លាយទៅជាកំពូលអាថ៌កំបាំង ដែលមានប្រយោជន៍ក្នុងការរស់នៅក្នុងសម័យនេះទៅហើយ។

ទម្លាប់ គឺជាអ្នកកំណត់ឧបនិស្ស័យ ហើយឧបនិស្ស័យ គឺជាអ្នកកំណត់ជីវិត ដូចជា ទម្លាប់ក្នុងការនិយាយនិងទង្វើ គឺជាការឆ្លុះបញ្ចាំងពីការចិញ្ចឹមបីបាច់ថែរក្សា។

ចុះទម្លាប់ក្នុងការវិនិយោគ និងការគ្រប់គ្រងហិរញ្ញវត្ថុវិញគឺជាអ្វី?

គេនិយាយថា កូនៗគ្រប់គ្នារបស់មហាសេដ្ឋីប្រេង រ៉ក់គី ហ្វេឡឺរ៍ (Rockefeller) ត្រូវលាងចាន បោសផ្ទះ ដើម្បីប្តូរជាមួយថ្លៃទៅសាលារៀន។ អ្នកអាចនឹងគិតថា គាត់គឺជាមហាសេដ្ឋីកំណាញ់ស្វិត ចិញ្ចឹមកូនហាក់ដូចជាកូនកម្មករនៅក្នុងក្រុមហ៊ុន។ ក៏ប៉ុន្តែ ផ្ទុយទៅវិញ គាត់កំពុងបណ្តុះនូវសម្បជញ្ញៈនៃភាពមានបាន និងសមត្ថភាពក្នុងការគ្រប់គ្រងប្រាក់ឱ្យកូនៗរបស់គាត់ទៅវិញទេ។

អ្នកក្រមិនដែលបណ្តុះសម្បជញ្ញៈ នៃភាពមានបានឱ្យកូនឡើយ ផ្តល់ភាពសំខាន់តែលើពិន្ទុប្រឡងរបស់កូនប៉ុណ្ណោះ។ ទោះបីជាកូនអ្នកក្រប្រឡងបានលេខមួយក៏ដោយ តែបែរជាយកចំណេះដឹងទៅប្រើនៅក្នុងការរស់នៅមិនសូវបានផលទៅវិញ។ ហើយពេលដែលត្រូវចាប់ផ្តើមធ្វើការងារនោះ ពួកគេបែរជាចាញ់អ្នកដទៃ និងបរាជ័យយ៉ាងខ្លាំងទៀតផង។


អ្នកលក់ FRANCHISE
អ្នកជំនាញភាគហ៊ុន
គ្រាន់តែ ៦ ឆ្នាំ

# ៦៩

## អ្នកក្រស្រមើស្រមៃខ្ពស់ហួសមាឌ

អ្នកក្រតែងតែបានឮរឿងដែលនិយាយទាក់ទងនឹងភាពមានបានរបស់អ្នកដទៃជាច្រើន ហើយឃើញអ្នកដែលនៅជុំវិញខ្លួនទទួលបានភាពជោគជ័យម្នាក់ហើយម្នាក់ទៀត ធ្វើឱ្យខ្លួនឯងមានគំនិតចង់ធ្វើធុរកិច្ចធំដូចអ្នកដទៃដែរ។ ប៉ុន្តែ តាមពិតនោះ វាមិនដូចនឹងអ្វីដែលរំពឹងទុកប៉ុន្មានទេ ប្រាក់ប្រៀបដូចជានារីសិចស៊ីដែរ គ្រាន់តែជាអាហារភ្នែកប៉ុណ្ណោះ មិនអាចប៉ះពាល់បានទេ បានត្រឹមតែឈរមើល និងលេបទឹកមាត់ប៉ុណ្ណោះ។

ការធ្វើគ្រប់ឱកាសឱ្យក្លាយទៅជាការពិតនោះ គឺអាស្រ័យទៅលើការត្រៀមជើងការជាស្រេច និងវិធីដ៏វៃឆ្លាត។ ប៉ុន្តែអ្នកក្រគ្មានបទពិសោធក្នុងផ្នែកនេះឡើយ អ្វីដែលបានឃើញ និងឮភាគច្រើន ជាលទ្ធផលនៃភាពជោគជ័យដ៏ស្រស់ស្អាតតែមួយផ្នែកប៉ុណ្ណោះ មិនមែន «ជាដំណាក់កាលមុននឹងទទួលបានជោគជ័យទេ» អ្នកក្រត្រូវចាំត្រង់ចំណុចនេះឱ្យច្បាស់។

ពេលដែលអ្នកមានអួតពីភាពជោគជ័យរបស់ខ្លួន រមែងធ្វើឱ្យអ្នកក្រកោតសរសើរពីលទ្ធផលនៃការខិតខំប្រឹងប្រែងរបស់អ្នកមាន និងចង់ក្លាយទៅជាដូច្នោះ។

ដូច្នេះទើបអ្នកក្រចង់យកគំរូតាម និងកំណត់គោលដៅថា ត្រូវតែរកប្រាក់ឱ្យបានប៉ុណ្ណេះឱ្យបានប៉ុណ្ណោះ គិតថាភាពជោគជ័យអាចទទួលបានដោយងាយ ហើយស្រមើស្រមៃថាពេលដែលមានហើយ នឹងបានឡើងទៅនិយាយពីបទពិសោធនៃភាពជោគជ័យដូចគេដែរ។

អ្នកក្រស្រមើស្រមៃអ្វីដែលមិនអាចទៅរួច ដូច្នេះទើបមិនមានគម្រោងការ ដែលអាចយកទៅប្រតិបត្តិបានជាក់ស្ដែង ដែលអាចជាចំណែកមួយក្នុងការជួយជំរុញទៅរកភាពជោគជ័យនាពេលអនាគត។

នៅពេលដែលមិនបានទទួលជោគជ័យ អ្នកក្រនឹងមានចិត្តក្ដៅឆេវឆាវ ហើយពេលដែលឃើញរបស់ថ្មីតែងតែភ្លេចរបស់ចាស់។ ទីបំផុតធ្វើអ្វីមិនបានសម្រេចសូម្បីតែមួយយ៉ាង។


ក្រុមហ៊ុនផលិតដូងរបស់យើង
មានដើមដូងលើសពី ៥០០ ពាន់
ទាំងអស់
ប្រាក់ចំណេញរបស់យើងក្នុង ១ ឆ្នាំ

# ៧០

## អ្នកក្រតែងតែជឿអ្នកធំ

នៅក្នុងពិភពគុន អ្នកធំមិនចាំបាច់ចេញប្រយុទ្ធដោយខ្លួនឯងទេ គ្រាន់តែឈរស្ងៀមៗយ៉ាងក្លាហាន ក៏អាចធ្វើឱ្យអ្នកក្រដែលថោកទាបស្រាប់ទៅហើយនោះ កាន់តែមានអារម្មណ៍ថា កាន់តែថោកទាបថែមទៀត ធ្វើឱ្យអស់កម្លាំងក្នុងការប្រយុទ្ធ។ បើចង់ប្រយុទ្ធពិតមែននោះ អ្នកធំនឹងមានអ្នកក្រនៅចាំជួយជាច្រើន។

នៅពេលដែលអ្នកក្រនិងអ្នកក្រ ចាប់ផ្តើមបើកឆាកប្រយុទ្ធគ្នា អ្នកទាំងពីរមានកម្លាំងធាតុប្រហាក់ប្រហែលគ្នា ទើបមិនអាចប៉ាន់ស្មានបានទេថានរណាជាអ្នកចាញ់នរណាជាអ្នកឈ្នះ។ លើកលែងតែថា នឹងជួបអ្នកក្របោកប្រាស់ ដែលមានសំបកក្រៅជាអ្នកមាន បើបែបនេះអ្នកក្រដែលស្មោះត្រង់ត្រូវបរាជ័យមុនពេលចាប់ផ្តើមប្រយុទ្ធគ្នាជាប្រាកដ។

«កលល្បិច» ទាំងឡាយប្រើបោកបញ្ឆោតមនុស្សបានជានិច្ច ព្រោះមើលទៅមិនដូចជាល្បិចទេ។ ច្រើនឆ្នាំមុន មានមនុស្សជាច្រើនជឿពួកអ្នកឱ្យបណ្តាក់ទុន បាននាំគ្នាយកប្រាក់ទៅបណ្តាក់ទុនដោយងាយ ដោយមិនត្រួតពិនិត្យឱ្យបានច្បាស់លាស់ថា ក្រុមហ៊ុននោះមានប្រភពមកពីណាទេ។ ពេលដែលដើរចូលទៅក្នុងអគារដ៏ស្កឹមស្កៃ ឃើញបណ្ណកិត្តិយសព្យួរនៅលើជញ្ជាំងជាច្រើន ក៏មានអារម្មណ៍ថា ប្រាក់របស់ខ្លួនដែលយកមកនោះតិច

តូចណាស់ គ្រាន់តែគេព្រមទទួលយកប្រាក់របស់យើងនោះ ចាត់ថាជាបុណ្យណាស់ទៅហើយ។

អ្នកក្រភាគច្រើនគិតថា ខ្លួនឯងគឺជាអ្នកបម្រុង ពេលដែលឃើញអ្នកដែលមានបុណ្យសក្តិធំដើរចូលមកនោះ ក៏ទន់ដៃទន់ជើងអស់បាត់ទៅហើយ បើដូច្នេះ តើអ្នកក្រមានអ្វីទៅតស៊ូជាមួយនឹងគេទៅ?

កុំគិតថា អ្នកធំអស្ចារ្យជានិច្ចឱ្យសោះ នៅក្នុងពិភពគុនមួយនេះមានគ្រោះថ្នាក់ជាច្រើនដែលបង្កប់នៅក្នុងនោះ អ្នកក្រដែលជាភាគីចាញ់ប្រៀបជានិច្ចនោះ ត្រូវតាំងស្មារតីឱ្យបានល្អ ប្រយ័ត្នប្រយែងអំពីគ្រោះថ្នាក់គ្រប់ជំហាន ពិចារណាមើលថា តើនរណាពិត នរណាក្លែងក្លាយ តើនរណាដែលមានបំណងមកបោកបញ្ឆោត ជាពិសេស អ្នកធំពិតប្រាកដ អ្នកក្រក៏មិនត្រូវជឿដោយងាយដែរ។


ឱ្យ ១០០
ឱ្យ ៥០០
ប្តូរទូរទស្សន៍ និង ទូទឹកកកប្រសើរជាង

# ៧១

## ប្រាក់របស់អ្នកក្រមិនមែនជាប្រាក់ដើមទុនទេ

មនុស្សម្នាក់យកប្រាក់ចូលនិវត្តមួយខែ ៥០ ដុល្លារ ទៅទិញស្បែកជើងផ្ទាត់បាន ៥០ គូ យកទៅក្រាលកន្ទេលលក់បានមួយគូ ២ ដុល្លារ បានកម្រៃដល់ទៅ ១០០ ដុល្លារ។ ចំណែកម្នាក់ទៀតបានទទួលប្រាក់ចូលនិវត្តមួយខែ ៥០ ដុល្លារ ពីរដ្ឋាភិបាល តែយកទៅទិញអង្ករ និងអាហារកំប៉ុងរហូតដល់អស់។ មនុស្សពីរនាក់មានប្រាក់ ៥០ ដុល្លារដូចគ្នា តែអ្នកទី ១ យកធ្វើជា «ដើមទុន» យកទៅបណ្តាក់ទុនដើម្បីពង្រីកប្រាក់។ ប៉ុន្តែអ្នកទី ២ យកទៅចាយវាយតែម្យ៉ាងគត់ មិនបានធ្វើឱ្យប្រាក់រីកលូតលាស់ឡើយ។

រឿងដែលគួរឱ្យសោកសៅរបស់ជនជាតិចិនគឺ ប្តូរប្រាក់ថ្លៃចាយវាយប្រចាំថ្ងៃទៅជា «ដើមទុន» មិនបាន។ បើយើងឱ្យប្រាក់ទៅអ្នកក្រ ១០០ ដុល្លារ គេនឹងយកទៅទិញសម្លៀកបំពាក់ស្អាតៗពាក់។ បើនៅសល់ ២០ ដុល្លារ គេនឹងយកទៅទិញឆ្នោតផ្សងសំណាងទៀត។

អ្នកក្រ គឺក្ររហូតដល់ធ្លាប់ខ្លួន ពេលមានប្រាក់បន្តិចបន្តួច ក៏គិតចង់ផ្លាស់ប្តូរស្ថានភាពរស់នៅ។ ទោះបីជាពួកគេមានប្រាក់ដល់ទៅ ១ លានដុល្លារក៏ដោយ ក៏ពួកគេមិនគិតយកប្រាក់ទាំងនេះទៅបណ្តាក់ទុនដែរ តែ

នឹងប្រញាប់យកប្រាក់ទៅទិញឡានមកបង្អួតគេ ដើម្បីប្រកាសឱ្យគ្រប់គ្នាដឹងថា ខ្ញុំលែងជាអ្នកក្រតទៅទៀតហើយ។

តើដឹងដែរឬទេថា ពេលដែលមានឡាននឹងត្រូវអស់ថ្លៃសាំង-ប្រេង ថ្លៃធានារ៉ាប់រង ថ្លៃជួសជុល ។ល។ ហើយទោះជាចតចោលមិនប្រើការក៏អាចនឹងត្រូវបង់ថ្លៃចំណតទៀតផងដែរ។ ថ្លៃកំប៉ិកកំប៉ុកទាំងនេះ អ្នកក្រអាចហូបបាយបានជាច្រើនថ្ងៃ និយាយដោយងាយទៅ បើអ្នកក្រ «មានតែចំណាយ មិនមានចំណូល» ថ្ងៃណាមួយប្រាក់នឹងត្រូវអស់ជាមិនខាន។

ប្រាក់របស់អ្នកក្រមិនមែនជាប្រាក់ដើមទុនទេ គឺមានល្មមនឹងអាចចិញ្ចឹមជីវិតប៉ុណ្ណោះ នៅមិនទាន់គ្រប់គ្រាន់ដើម្បី «បណ្ដាក់ទុន» ទេ ទើបអ្នកក្រមើលមិនឃើញ «ថាមពលនៃប្រាក់ដើមទុន»។ អ្វីដែលគួរឱ្យសោកសៅជាងនេះទៅទៀតនោះគឺ អ្នកក្រមិននឹកឃើញពីរឿងប្រាក់ដើមទុនទេ ហើយខ្វះបទពិសោធ និងបច្ចេកទេសក្នុងការគ្រប់គ្រងរឿងប្រាក់ដើមទុនទៀតផង។


គ្មានធុរៈទេ
ហេតុអ្វីប្រញាប់ទៅម្លេះ?

# ៧២

## ពេលវេលារបស់អ្នកក្រគ្មានតម្លៃ

នរណាថាពេលវេលារបស់អ្នកក្រគ្មានតម្លៃ?

អ្នកក្រមានពេលច្រើនជ្រុល រហូតដល់មិនដឹងថា ត្រូវធ្វើអ្វីដើម្បីកុំឱ្យទំនេរទៀតផង។

អ្នកក្រមិនគិតថា «ពេលវេលាគឺជាមាសប្រាក់ទេ» ព្រោះគេគ្មានកិច្ចសន្យា ១០០ លានឱ្យចុះហត្ថលេខា និងគ្មានធុរកិច្ចសំខាន់អ្វីដែលថាបើយឺតត្រឹមតែមួយវិនាទីនោះ អ្នកដទៃនឹងដណ្ដើមទៅទេ។

«ប្រាក់» និង «ពេលវេលា» មានតម្លៃមិនដូចគ្នាទេរវាងអ្នកក្រ និងអ្នកមាន បើអ្នកក្រស្ទះចរាចរណ៍បានត្រឹមតែរអ៊ូប៉ុណ្ណោះ ព្រោះត្រូវអង្គុយចាំនៅក្នុងឡានយូរ។

កម្រិតនៃតម្លៃរបស់វត្ថុអាស្រ័យទៅលើកម្រិតនៃភាពខ្វះខាត សម្រាប់អ្នកក្រ អ្វីដែលពួកគេខ្វះខាតជាខ្លាំងនោះគឺប្រាក់ មិនមែនពេលវេលាទេ។

មនុស្សម្នាក់មិនថានឹងប្រើវិធីអ្វីក្នុងការរកប្រាក់ ឬមិនថានឹងរកប្រាក់បានច្រើន ឬតិចយ៉ាងណាទេ ត្រូវចំណាយពេលជាយូរ។

បើអ្នកទិញស្ពៃក្តោបដែលថ្លៃជាងតម្លៃធម្មតា ១០០ រៀល ហើយគិតតែពីខឹងដោយមិនព្រមធ្វើអ្វីទាល់តែសោះពេញមួយថ្ងៃនោះ នេះហើយគឺគំនិតបែបអ្នកក្រដ៏ពិតប្រាកដ ព្រោះយកពេលវេលាទៅគិតរឿងឥតបានការ និងគ្មានតម្លៃ។

អ្នកខ្លះអាចនឹងរកលេសសម្រាប់ខ្លួនឯង ដូចជា «មើលចុះ! ពួកអ្នកមាន ធ្វើការបណ្តើរដើរលេងបណ្តើរ មានតែអ្នកក្រប៉ុណ្ណោះដែលធ្វើការពេញមួយថ្ងៃ»។

តែអ្នកត្រូវចាំទុកថា ការដើរលេងរបស់អ្នកមាន ក៏ជាវិធីធ្វើការងារម្យ៉ាងដែរ។ ពួកគេដើរលេងដោយមានគោលបំណង មិនមែនដើរលេងដើម្បីឱ្យពេលវេលាកន្លងហួសទៅ ដោយឥតប្រយោជន៍ដូចមនុស្សទូទៅទេ។ អ្នកមានទំនេរចំពោះរាងកាយតែប៉ុណ្ណោះ សម្រាកតែកាយដើម្បីឱ្យមានកម្លាំងតស៊ូបន្តទៀតតែប៉ុណ្ណោះ ប៉ុន្តែ ខួរក្បាលរបស់ពួកគេមិនដែលទំនេរសូម្បីតែមួយនាទី។ ចំណែកអ្នកក្រវិញគឺផ្ទុយគ្នា ខួរក្បាលទំនេរ តែដៃនិងជើងត្រូវបញ្ចេញកម្លាំងគ្រប់ពេល ហត់ស្ទើរតែរលេះខ្លួន ទីបំផុតបានប្រាក់ខែតែបន្តិចប៉ុណ្ណោះ។

បើអ្នកមានអារម្មណ៍ថា សល់ពេលច្រើន បង្ហាញថាអ្នកចាប់ផ្តើមមានបញ្ហានិងជិតក្លាយជាអ្នកក្រមែនទែនហើយ។



# ៧៣

## អ្នកក្រស្អប់ភាពមិនស្មើភាពគ្នា

ពួកអឺរ៉ុបតែងតែមានវិធីល្អៗក្នុងការធ្វើធុរកិច្ច។ McDonals & KFC គឺជាធុរកិច្ចហាង fast food ដែលអ្នកក្រចូលចិត្តបំផុត។

នៅក្នុងហាង McDonals & KFC មិនមានបន្ទប់ VIP និងមិនមានកន្លែងអង្គុយដែលបែងចែកវណ្ណៈទេ គ្រប់គ្នាត្រូវអង្គុយនៅក្នុងបន្ទប់ជាមួយគ្នាទាំងអស់ ចុងភៅត្រូវនៅក្រោយហាង ភ្ញៀវត្រូវកុម្ម៉ង់ម្ហូប ហើយត្រូវបង់ប្រាក់សុទ្ធនៅកន្លែងគិតលុយ គ្មានបុគ្គលិកចាំអុចបារីឱ្យទេ។

ទោះបីជាអ្នកស្គាល់បុគ្គលិកនៅក្នុងហាងក៏ដោយ ក៏មិនអាចធ្វើឱ្យប៊ឺហ្គ័ររបស់អ្នកធំជាងរបស់អ្នកដទៃបានដែរ។ មិនថា អ្នកធំមកពីទីណាទេ ក៏ត្រូវតម្រង់ជួរកុម្ម៉ង់ម្ហូប បង់ប្រាក់ និងលើកថាសទៅរកកន្លែងអង្គុយដោយខ្លួនឯងដែរ។

ចំណែកឯកន្លែងអង្គុយនៅក្នុងហាង នឹងមានកំណត់កន្លែងឱ្យជាស្រេច តុកៅអីមិនអាចរំកិលបានឡើយ បើទោះបីជាអ្នកធាត់ប៉ុនណា ចូលចិត្តអង្គុយសាឡុងឬកៅអីឈើក៏ដោយ។ ប៉ុន្តែ ពេលដែលចូលមកហាងប្រភេទនេះ គ្រប់គ្នាត្រូវតែ «ស្មើភាពគ្នាទាំងអស់»។

អ្នកក្រខ្លាចភាពមិនស្មើភាពគ្នាបំផុត ទើបមានអារម្មណ៍ថា នេះមានភាពស្មើគ្នា មានអារម្មណ៍ថាជឿជាក់លើខ្លួនឯង និងមានកិត្តិយសជាខ្លាំងពេលដែលនៅក្នុងហាង fast food ប្រភេទនេះ។ ហេតុនេះ ទើបអ្នកក្រចូលចិត្តទៅហាង McDonals & KFC ធ្វើឱ្យហាង fast food របស់ជនជាតិអាមេរិកកាំង ទទួលការនិយមរហូតក្លាយទៅជានិមិត្តសញ្ញា នៃការនិយមចូលចិត្តនៅទូទាំងពិភពលោក។

មនុស្សជាច្រើនដឹងច្បាស់ថា អាហារ fast food គឺជា «អាហារសម្រាម (អាហារដែលគ្មានប្រយោជន៍)» ប៉ុន្តែក្នុងពេលជាមួយគ្នា ពួកគេបានយកភ្លៅមាន់មកហូបយ៉ាងស្មើភាពគ្នា។

ម្ចាស់ហាង McDonals & KFC ក្លាយទៅជាអ្នកមានដែលកាន់តែមានឡើងៗ ដែលត្រូវនឹងការពិតដែលថា «អ្នកមានរកស៊ីជាមួយនឹងអ្នកក្រ» នោះឯង។

# ជំពូកទី ៤

សិក្សាអំពី

# វិធីយកឈ្នះភាពក្រីក្រ


គុយទាវអ្នកក្រ

# ៧៤

## អ្នកគឺជាអ្នកក្រ តើអ្នកខ្លាចអ្វីទៅ?

អ្នកក្រចង់ក្លាយជាអ្នកមានឱ្យបានឆាប់ទើបខិតខំប្រឹងប្រែង។ ប៉ុន្តែក្នុងពេលជាមួយគ្នាក៏ខ្លាចដែរ ព្រោះមិនដែលធ្លាប់បានគ្រប់គ្រងវាសនាដោយខ្លួនឯងឡើយ ថែមទាំងខ្វះបទពិសោធក្នុងការធ្វើធុរកិច្ចទៀតផង។ អ្នកក្រគឺដូចគ្នានឹងអ្នកដែលមិនធ្លាប់ប្រើកុំព្យូទ័រដែរ ពេលដែលបានប្រើក៏ខ្លាចថា keyboard ខូច ឬពេលលេងអ៊ិនធើណែតខ្លាចមេរោគស៊ី។

តាមពិតទៅ គ្មានអ្វីដែលគួរឱ្យខ្លាច ឬលើសពីសមត្ថភាពរបស់មនុស្សយើងទេ។ មនុស្សដែលខ្លាចកុំព្យូទ័រគប្បីយល់ថា អ្វីដែលសំខាន់បំផុតគឺ ត្រូវចេះដោតឌុយ និងចេះបើកម៉ាស៊ីន។ ចំណែកអ្នកក្រដែលចង់មានរបរជារបស់ខ្លួន អ្វីដែលសំខាន់បំផុតនោះគឺ «ត្រូវសាកល្បង» លទ្ធផលយ៉ាងណានោះចាំនិយាយគ្នាពេលក្រោយ។

ក្នុងករណីដែលថាបើយើងរស់តែពន្យារពេលនោះ ពេលខ្លះបរិបទអាចនឹងផ្លាស់ប្តូរក៏ថាបាន ឬនៅមិនទាន់បានអ្វីមកផង បញ្ហាថ្មីក៏កើតឡើង។ ហើយទីបំផុតការព្យាយាមនឹងត្រូវរលត់បាត់ទៅវិញ។

អ្នកក្របានត្រឹមតែរង់ចាំអស់មួយជីវិត រង់ចាំឱកាស រង់ចាំរហូតដល់សក់ស្កូវ រង់ចាំរហូតដល់ចិត្តស្រពោន។ បើទោះបីជាទីបំផុត គេមាន

វិធានហើយក៏ដោយ តែអាចនឹងខ្វិលក៏ថាបាន។ ដូច្នេះត្រូវគិតថា «យើងអាចសាងឱកាសឡើងបានដោយខ្លួនឯង» បើមិនដូច្នោះទេនឹងគ្មានឱកាសអស់មួយជីវិត។

«សាកល្បងមួយក្តារហើយចាំនិយាយគ្នា» គួរតែធ្វើបណ្តើរស្វែងរកឱកាសបណ្តើរ សាងវិធានបណ្តើរ ដោះស្រាយបណ្តើរ ហើយផ្លាស់ប្តូរទៅបណ្តើរៗដែរ។ ព្រោះតែជាអ្នកក្រនេះហើយ ទើបអ្នកគ្មានអ្វីដែលត្រូវខូចខាត សុំឱ្យតែដើរផ្លូវត្រូវ អ្នកក៏អាចទទួលបានជោគជ័យដែរ។ ទោះបីជាពេលដំបូងៗមើលទៅដូចជាមិនសូវមានសង្ឃឹមក៏ដោយ។



១
២
៣
គ្មានប្រាជ្ញាឡើយ
៤
មិនមានសមត្ថភាពពិសេស
៥
តែនៅមានខួរក្បាល
៦
ខ្ញុំនៅមានគំនិត
ពិតជាប្រសើរណាស់ នៅពេលសង្ឃឹម

# ៧៥

## អ្នកក្រត្រូវមានគំនិត

អ្នកខ្លះនិយាយថា «គំនិតរបស់ជាងសម្អាតស្បែកបីនាក់មិនឈ្នះគំនិតរបស់ ខុងបេង តែម្នាក់បានទេ»។ ប៉ុន្តែ តើអ្នកដឹងឬទេថា ទោះបីជាជាងសម្អាតស្បែករាប់ពាន់រាប់ម៉ឺននាក់ក៏មិនអាចឈ្នះ ខុងបេង[*] បានដែរ។

សម័យណាក៏ដោយ «គំនិតនិងប្រាជ្ញា» មិនអាចវាស់ជាតួលេខបានទេ។ នៅក្នុងសម័យបុរាណបើអ្នកប្រាជ្ញម្នាក់ធ្លាក់ខ្លួនក្រ ហើយឱ្យគេទៅរែកទឹក ភ្ជួរស្រែ គេអាចនឹងរអ៊ូថា ឈឺក្បាល ឬឈឺចង្កេះ ប៉ុន្តែគេនឹងសម្របខ្លួនបានយ៉ាងរហ័ស។ ផ្ទុយទៅវិញ បើយើងឱ្យមនុស្សល្ងង់ម្នាក់ឡើងធ្វើជាមន្ត្រី បញ្ជូនគេឱ្យទៅសិក្សាពីសិល្បៈ និងកំណាព្យនោះ គេនឹងគ្មានថ្ងៃអាចតែងកំណាព្យបានល្អទេ។ ដូច្នេះ ប្រាជ្ញារបស់មនុស្សពូកែលើសអ្វីទាំងអស់ ទើបមូលដ្ឋាននៃចំណេះដឹងត្រូវបានបណ្តុះបណ្តាលមកតាំងពីសម័យបុរាណម្ល៉េះ។

ពេលដែលឧស្សាហកម្មអភិវឌ្ឍមកដល់ចំណុច ដែលប្រើគ្រឿងម៉ាស៊ីនមកជំនួសកម្លាំងមនុស្ស ធ្វើឱ្យគេមើលឃើញពីគំនិតច្នៃប្រឌិតរបស់មនុស្សកាន់តែច្បាស់ឡើង។ នេះហើយគឺជាពិភពនៃ «សម័យបច្ចេកវិទ្យា» ឬសម័យ IT។

---

[*] សូមអានបន្ថែមនៅសៀវភៅ: តម្រាពិជ័យសង្គ្រាម សាមកុក និង តម្រាពិជ័យសង្គ្រាម ខុងបេង

បច្ចេកវិទ្យាគឺជាវត្ថុដែលជាលទ្ធផលរបស់ចិត្ត ហើយចិត្តបានក្លាយទៅជាទ្រព្យសម្បត្តិនៅក្នុងសង្គមទៅហើយ ដូច្នេះគំនិត និងប្រាជ្ញារបស់មនុស្សសព្វថ្ងៃនេះត្រូវបានគេមើលឃើញថាជា «វត្ថុ» ដែរ។

សម័យនេះ គំនិតមិនត្រឹមតែជាភោគទ្រព្យផ្នែកផ្លូវចិត្តប៉ុណ្ណោះទេ តែជាភោគទ្រព្យដែលជារូបធម៌ អាចប៉ះបាន កំណត់តម្លៃបាន និងអាចយកទៅលក់បានទៀតផង។ គំនិតមួយអាចបង្កើតជាទ្រព្យសម្បត្តិដែលជារូបធម៌ម្យ៉ាងបាន ហើយក៏អាចធ្វើឱ្យមានការផ្លាស់ប្តូរ ដែលមិនធ្លាប់មានពីមុនមកដែរ។

**តើធនធានដែលមានតម្លៃបំផុតរបស់អ្នកក្រគឺជាអ្វី?**

មិនមែនជាប្រាក់សន្សំបន្តិចបន្តួចទេ ហើយក៏មិនមែនជាសុខភាពមាំមួនដែរ ប៉ុន្តែគឺជា «ខួរក្បាល»។


ពេលគេសរសើរ
សប្បាយចិត្តណាស់ហ្ន៎
បញ្ចុះតម្លៃ
ទាំងអស់
៥០
ភាគរយ
ឃើញអំពើល្អឈ្នះអំពើអាក្រក់
មានការរីករាយជាខ្លាំង

# ៧៦

## អ្នកក្រត្រូវតែមានមហិច្ឆតា

មនុស្សយើងអាចសម្រេចកិច្ចការធំឬអត់នោះអាស្រ័យថា តើមានមហិច្ឆតាឬអត់។

អ្នកក្រដែលមួយថ្ងៃៗគិតតែពីអង្គុយសោកសៅ បើគេមិនធ្លាប់ជួបនឹងភាពបរាជ័យធំៗពីមុនមកទេ នឹងគ្មានផ្លូវអាចចាប់ផ្ដើមធ្វើកិច្ចការធំបានទេ ហើយអ្នកក៏គ្មានផ្លូវបានឃើញពួកគេមានសេចក្ដីសុខដែរ។ កុំរំពឹងឱ្យពួកគេធ្វើជា «គំរូ» ឱ្យអ្នកដទៃនោះ ព្រោះគេរស់នៅបែបរកព្រឹកខ្វះល្ងាច ចិត្តស្ងិតស្រពោន មិនខ្នះខ្នែងទេ។ មនុស្សប្រភេទនេះគ្មានថ្ងៃហ៊ានប្រថុយ មិនអាចទ្រាំនឹងការគាបសង្កត់ ឬយកឈ្នះភាពលំបាក និងមិនអាចផ្លាស់ប្ដូរវាសនាខ្លួនបានទេ។

មហិច្ឆតារបស់អ្នកក្រ គឺជាការភ្ញាក់ផ្អើល និងរីករាយចំពោះស្ថានការណ៍ ដូចជា ពេលដែលចៅហ្វាយនាយសរសើរ នឹងសប្បាយចិត្ត ពេលឃើញហាងបញ្ចុះតម្លៃមានការរីករាយជាខ្លាំង ពេលមើលទូរទស្សន៍ឃើញគូស្នេហ៍ដែលបែកគ្នា ត្រឡប់មកត្រូវគ្នាវិញ ក៏ស្រក់ទឹកភ្នែក ។ល។ អ្វីដែលអ្នកក្របង្ហាញចេញមក គ្រាន់តែជាអារម្មណ៍ប៉ុណ្ណោះ មិនមែនជាមហិច្ឆតានៃការតស៊ូដើម្បីឱ្យជីវិតប្រសើរឡើងឡើយ។

«ចាបតូចៗក៏អាចមានបំណងប្រាថ្នាក្លាយជាហង្សបានដែរ» បើអ្នកក្រតិតបានដូច្នេះ ចាត់ទុកថា មានមហិច្ឆតា អាចនឹងមិនក្រតទៅទៀតទេ។

មហិច្ឆតាគឺជាសញ្ជាតិញ្ញាណម្យ៉ាង ហើយក៏ជានិមិត្តសញ្ញានៃភាពរស់រវើកដែរ។ ពេលដែលមនុស្សយើងមានមហិច្ឆតា នឹងមានកម្លាំងក្នុងការតស៊ូ មានកម្លាំងជំរុញចិត្ត ជឿជាក់លើខ្លួនឯង ជាគំរូដ៏ល្អដល់អ្នកដទៃបាន ហើយនឹងមានប្រាជ្ញាក្នុងការដោះស្រាយបញ្ហាទៀតផង។




ពេលអ្នកដែលតស៊ូ និង អ្នកដែលតែនៅស្ងៀមៗ ពេលវេលាក៏ខុសគ្នាដែរ



# ៧៧

## អ្នកក្រត្រូវតស៊ូ

ពេលដែលមនុស្សយើង លើកតម្កើងឋានៈរបស់ខ្លួនឡើងមករហូតដល់ស្ថានភាពមួយហើយ នឹងបានទទួលនូវផលតបស្នងទៅតាមស្ថានភាព និងសមត្ថភាពដែលមាន ដែលទាំងពីរយ៉ាងនេះនឹងប្រែប្រួលទៅតាមគ្នា។

ទម្រាំតែទទួលបានជោគជ័យមិនមែនជារឿងងាយទេ ប៉ុន្តែពេលដែលទទួលបានជោគជ័យហើយ ក៏មិនមែនជាមនុស្សធម្មតាទៅទៀតដែរ ព្រោះពូកែជាងអ្នកដទៃហើយ និងមានមនុស្សជឿជាក់លើខ្លួនយើងយ៉ាងស្មោះត្រង់ទៀតផង។

អ្នកដែលមានសមត្ថភាពលើសអ្នកដទៃ ឬបុគ្គលដែលសំខាន់ ទោះបីជាធ្លាក់នៅក្នុងស្ថានភាពដែលអាក្រក់បំផុត ក៏នៅតែបានទទួលការគោរពលើកតម្កើងពីអ្នកដទៃដែរ។ បើមេទ័ពនិងពលទាហាន ក្លាយទៅជាឈ្លើយសឹកដូចគ្នា សត្រូវរមែងប្រតិបត្តិចំពោះអ្នកទាំងពីរនេះខុសគ្នា យ៉ាងហោចណាស់ ក៏មេទ័ពមិនត្រូវបានសត្រូវវាយ និងបង្អត់បាយបង្អត់ទឹកដែរ។

«មនុស្សថ្នាក់ខ្ពស់» និង «មនុស្សថ្នាក់ទាប» ខុសគ្នាដូចមេឃនិងដីតាំងពីដើមមកហើយ។

នៅក្នុងប្រទេសខ្លះ ទោះបីជាអ្នកមានត្រូវបានគេចាប់ដាក់គុកក៏ដោយ តែក៏អាចរស់នៅក្នុងគុកយ៉ាងហ៊ឺហារ មានទូរទស្សន៍ពណ៌ មាន

ទូទឹកកក បន្ទប់ទឹក អ្នកខ្លះអាចលេងវាយកូនហ្គោល និងមានសិទ្ធរួមភេទតាមពេលវេលាដែលកំណត់ទៀតផង។ ទោះបីជាអ្នកក្រមិនធ្លាប់ជាប់គុកក៏ដោយ តែក៏មិនធ្លាប់បានរស់នៅសុខសប្បាយដូច្នេះដែរ ហើយបើទោះបីជាអ្នកមានត្រូវមានទោសប្រហារជីវិតក៏ដោយ ក៏ត្រូវសម្លាប់ដោយការចាក់ថ្នាំ មិនមែនដោយការបាញ់សម្លាប់ទេ ជាការស្លាប់ដែលសុខស្រួល និងមានកិត្តិយសជាងអ្នកក្រ។

ដូច្នេះមនុស្សយើងត្រូវឧស្សាហ៍ព្យាយាម ត្រូវតស៊ូ ពេលដែលដើរទៅដល់ចំណុចដែលខ្ពស់បំផុតហើយ ជីវិតនិងកិត្តិយសនឹងមានការធានាយ៉ាងគង់វង្ស យ៉ាងហោចណាស់ ពេលដែលស្ថិតនៅក្នុងស្ថានភាពដែលអាក្រក់បំផុតក៏មិនចាំបាច់ត្រូវឈឺចាប់ដែរ។

សរុបទៅ អ្នកក្រត្រូវតែព្យាយាមឡើងទៅឱ្យដល់ចំណុចដែលខ្ពស់បំផុតឱ្យបាន។



# ៧៨

## អ្នកក្រត្រូវតែមានកម្លាំងជំរុញដើម្បីឱ្យផ្លាស់ប្តូរជីវិត

អ្នកដែលមានកម្លាំងគាបសង្កត់នៅក្នុងចិត្តខ្លាំង តែងចង់ផ្លាស់ប្តូរប្រវាក់ដែលកំពុងតែចាក់ចិត្តរបស់ពួកគេ ដូច្នេះហើយទើបមិនមានអ្វីប្លែកទេ ដែលតំណែងសំខាន់ៗនៅក្នុងទីក្រុងធំៗច្រើនតែជារបស់អ្នកស្រុកផ្សេងដែលប្តូរមករស់នៅក្នុងទីនោះ។

ហាមមើលរំលងអ្នកក្រដែលមកពីកន្លែងឆ្ងាយដាច់ស្រយាលដាច់ខាត ទោះបីជាពួកគេគ្មានសមត្ថភាពតាំងពីកំណើត សិក្សាមិនបានខ្ពស់ និងមិនធ្លាប់ធ្វើការងារនៅក្នុងប្រព័ន្ធក៏ដោយ តែពួកគេក៏មានក្តីស្រមៃដ៏ខ្លាំងក្លាក្នុងការមករកភាពជោគជ័យនៅក្នុងទីក្រុង ដោយចាប់ផ្តើមពីតំណែងដែលទាបបំផុត ហើយចាប់ផ្តើមឡើងជាបណ្តើរៗដោយការខិតខំព្យាយាម រហូតដល់ទីបំផុត អាចគ្រប់គ្រងតំណែងសំខាន់ៗបាន។

«ការមិនមានអ្វីទាល់តែសោះ» ជាដើមទុននៃភាពមានបានម្យ៉ាងជាកម្លាំងជំរុញ ដែលធ្វើឱ្យអ្នកក្រចង់ផ្លាស់ប្តូរវាសនា និងចង់ទទួលបានជោគជ័យនៅក្នុងការងារ ហើយបើយើងគ្មានអ្វីទាល់តែសោះនោះ យើងក៏មិនចាំបាច់ព្រួយបារម្ភពីអ្វីដែរ ពេលដែលមិនបារម្ភយើងនឹងអាចមានពេលអភិវឌ្ឍសមត្ថភាពរបស់ខ្លួនបានយ៉ាងពេញទំហឹង។

បើកសិករចង់ទៅធ្វើការនៅក្នុងទីក្រុង គឺគ្រាន់តែបោះចបចោលប៉ុណ្ណោះ ប៉ុន្តែ សម្រាប់អ្នកទីក្រុងដែលមានជីវិតសុខសប្បាយ បើចង់ទៅសាងអាជីពថ្មីនោះ មានអ្វីជាច្រើនដែលត្រូវបោះបង់ចោល។ ហេតុដូច្នេះហើយ ទើបមិនព្រមបោះបង់ចោល បានត្រឹមតែស្រមៃដោយមិនធ្វើអ្វីឡើយ។

ដូច្នេះ មិនថាអ្នកមានឬក្រទេ ពេលដែលបរិដ្ឋានជុំវិញគាបសង្កត់រហូតដល់ចំណុចដែលអ្នកគ្មានអ្វីនៅសេសសល់ទាល់តែសោះនោះ បង្ហាញថាអ្នកមានឧបករណ៍នាំផ្លូវទៅជីករកសម្បត្តិហើយ។ បើអ្នកចេះបោះចោលនូវអ្វីដែលអ្នកមាន នោះអ្នកនឹងតស៊ូបន្តទៀតបាន ហើយអ្នកនឹងប្រទះថាចិត្តឬខួរក្បាលរបស់យើងនេះហើយដែលជាទ្រព្យសម្បត្តិដ៏មានតម្លៃបំផុត។


ដូច្នេះថ្លៃ ៥០០ បានទេ
ដូច្នេះថ្លៃ ១ ០០០ បានទេ
៥.០០០
កើតឬទេ ?
កន្លងមកនេះគ្មាននរណាហ៊ានតថ្លៃពី
១០.០០០ ឱ្យនៅត្រឹមតែ ១.០០០ ទេ
ខ្ញុំមិនមែនទេ តែ...
ទៅវិញ
ព្រមទទួលស្គាល់ការពិតទៅ

# ៧៩

## អ្នកក្រត្រូវតែហ៊ានទទួលស្គាល់ការពិត

អ្នកក្រមិនដែលឈប់គិតឡើយ ពួកគេគិតគ្រប់ពេល គ្រាន់តែពួកគេមិនហ៊ានទទួលនូវលទ្ធផលដែលខ្លួនបានគិតឡើងមកតែប៉ុណ្ណោះ។

អ្នកក្រមិនហ៊ានប្រឈមមុខនឹងការពិតទេ ប្រៀបដូចជាពេលដែលយើងទទួលរងរបួសយ៉ាងធ្ងន់ធ្ងរដែរ យើងតែងតែមិនហ៊ានមើលរបួសរបស់ខ្លួនឯងដូច្នោះដែរ។ ដូច្នេះទើបឃើញសៀវភៅភាគច្រើនដែលសរសេរឱ្យអ្នកក្រ ច្រើនតែជាសៀវភៅប្រភេទ «លួងលោមចិត្ត» ដែលអ្នកក្រអានចប់ហើយ មិនមានការភ័យខ្លាច ឬជាប្រភេទសៀវភៅ «វិធីក្លាយជាអ្នកមាន» ដែលមិនអាចធ្វើបានពិត អ្នកក្រគ្រាន់តែអានឱ្យសប្បាយចិត្តប៉ុណ្ណោះ។

អ្នកនិពន្ធដឹងច្បាស់ថា មិនគួរប្រើពាក្យថា «ក្រ» ទេ ព្រោះនិយាយចំៗពេក ធ្វើឱ្យអ្នកក្រខ្មាសគេ។ម្យ៉ាងទៀត បើអ្នកនិពន្ធសរសេរអ្វីដែលធ្វើឱ្យអ្នកក្រមិនពេញចិត្តនោះ សៀវភៅអាចនឹងលក់មិនដាច់ ខាតដើមទទេៗ។

បើនារីម្នាក់កើតមកមានមុខមាត់មិនស្អាត អ្នកដទៃចង់និយាយថា នាងមានមុខមាត់អាក្រក់នោះមិនបានទេ ព្រោះនេះជាសុជីវធម៌។ ក្នុងន័យនេះដែរ បើគ្មាននរណាប្រាប់ថា អ្នកក្រខ្លាំងប៉ុនណាទេ នោះអ្នកនឹងកាន់តែក្រខ្លាំងឡើងប៉ុណ្ណោះដែរ។

មានតែអ្នកមានប៉ុណ្ណោះដែលហ៊ាននិយាយពី ជីវិតដ៏លំបាក និងភាពគ្មានអ្វីហូបរបស់ខ្លួនកាលពីអតីតកាល។ ក៏ប៉ុន្តែ ពេលនេះអ្នកមានគេហូបម្ហូបសមុទ្ររហូតដល់ធុញហើយ ទើបចង់ប្រាប់គ្រប់គ្នាថា ពេលនេះគេចូលចិត្តហូបបន្លែផ្លែឈើដូចអ្នកក្រវិញម្តង។

ពាក្យថា «ក្រលំបាក» សម្រាប់អ្នកក្រជាពាក្យសម្ដីដែលត្រូវហាម។

ការដែលត្រូវប្រឈមមុខជាមួយនឹងការពិតរបស់ខ្លួនឯងនោះត្រូវប្រើភាពក្លាហានយ៉ាងខ្លាំង។

ហេតុអ្វីទើបអ្នកគឺជាអ្នកក្រ? តើអ្វីដែលធ្វើឱ្យអ្នកក្រ? តើមានវិធីដោះស្រាយបញ្ហាដែរឬទេ?

កាន់តែសួរថា «ហេតុអ្វី» កាន់តែញាប់ កាន់តែមានផលល្អចំពោះខ្លួនឯង។



# ៨០

## អ្នកក្រត្រូវរកមុខរបរធំដុំ

បើអ្នកចង់បានប្រាក់ច្រើន យ៉ាងហោចណាស់ អ្នកត្រូវមានគំនិតជាមូលដ្ឋានមួយ នោះគឺ «ត្រូវឱ្យអ្នកដទៃទៅរកប្រាក់មកឱ្យអ្នក» បើអ្នកពឹងតែលើដៃទាំងពីររបស់ខ្លួននោះ ធ្វើរហូតដល់ស្លាប់ គឺបានត្រឹមតែចិញ្ចឹមជីវិតប្រចាំថ្ងៃប៉ុណ្ណោះ។

បើអ្នកសាកល្បងប្រៀបធៀបកន្លែងរកស៊ីជាជង្រុកស្រូវនោះ អ្នកដែលមានចានបាយនៅក្នុងដៃ នឹងអាចដួសអង្ករបានមួយចាន អ្នកដែលមានធុងនៅក្នុងដៃ នឹងដួសអង្ករបានមួយធុង ប្តូរធុងទៅជារថយន្ត ប្តូរពីរថយន្តទៅជារថភ្លើង ដើម្បីឱ្យបានអង្ករកាន់តែច្រើនឡើង។ ហើយការដែលធ្វើឱ្យចានមានទំហំធំបានឬអត់នោះ គឺអាស្រ័យលើ «យុទ្ធសាស្ត្រ» និង «វិធីគិត»។

នរណាៗក៏ចង់ឱ្យអ្នកដទៃទៅរកស៊ីមកឱ្យយើងដែរ តែអ្នកដទៃនឹងបានអ្វីពីការរកប្រាក់មកឱ្យយើង? ពួកគេមិនមែនជាមនុស្សល្ងង់ទេ ពួកគេជួយអ្នកធ្វើការ អ្នកត្រូវឱ្យប្រាក់ឈ្នួលដល់គេ។ អ្នកដែលដឹងត្រឹមតែថាត្រូវតែរកប្រាក់មកដាក់ក្នុងហោប៉ៅរបស់ខ្លួន តែបែរជាខ្លាចការចំណាយប្រាក់បន្តិចបន្តួចទៅឱ្យអ្នកដទៃវិញ មិនអាចប្រកបមុខរបរធំដុំបានទេ។ ហើយបើអ្នកជាមនុស្សដូច្នេះ អ្នកនឹងត្រូវធ្វើការដោយភាពលំបាកអស់មួយជីវិត។

អ្នកក្រគិតត្រឹមតែថា នឹងទទួលយកប្រាក់ពីអ្នកដទៃប៉ុណ្ណោះ តែថ្ងៃមួយពេលដែលត្រូវយកប្រាក់ទៅជូលអ្នកដទៃ បែរជាមានអារម្មណ៍ចម្លែកទៅវិញ។

ការដែលឱ្យអ្នកដទៃធ្វើការឱ្យអ្នកនោះ ជារឿងសំខាន់ខ្លាំងណាស់ ប៉ុន្តែការដែលធ្វើឱ្យក្លាយជារឿងពិតបាននោះ អ្នកត្រូវតែបង្កើតការងារជារបស់ខ្លួនឯងជាមុនសិន ព្រោះពេលដែលបង្កើតការងារហើយ រមែងមានមនុស្សមកជួយធ្វើការងារឱ្យអ្នក ដែលនោះចាត់ទុកថា អ្នកបានឈានទៅមួយជំណាក់កាលទៀតហើយ។


មើលព្យាករណ៍អាកាសធាតុ
មើលតម្លៃប្រេងនៅក្នុងទីផ្សារពិភពលោក

# ៨១

## អ្នកក្រត្រូវតែលេងអ៊ិនធើណែត

តើអ្នកដឹងឬទេថា អ៊ិនធើណែតមានតម្លៃចំពោះអ្នកក្រជាខ្លាំង?

នៅក្នុងពិភពអ៊ិនធើណែត គឺជាទឹកដីដែលគ្រប់គ្នា «ស្មើភាពគ្នា»។ អ្នកក្រមានសិទ្ធិធ្វើអ្វីគ្រប់យ៉ាងតាមដែលចង់ មានសិទ្ធិដូចគ្នានឹងអ្នកមានគ្រប់យ៉ាង មិនថាជាការអានព័ត៌មាន ស្រាវជ្រាវរកទិន្នន័យ ចំណេះដឹង លក់ដូរ ជេរគ្នា រិះគន់អ្នកដទៃ ឈ្លោះប្រកែកគ្នាជាមួយនរណាក៏បានដែរ នៅក្នុងពិភពដែលគ្មានព្រំដែននេះ។

*ចុះអ្នកក្រមានសិទ្ធិធ្វើអ្វីបានខ្លះនៅក្នុងពិភពអ៊ិនធើណែត?*

ចម្លើយគឺ ធ្វើបានគ្រប់យ៉ាងតាមដែលអ្នកគិត និងស្រមើស្រមៃ។ អ៊ិនធើណែត ចាត់ទុកថា ជាទំនាក់ទំនងដ៏ពិតប្រាកដរបស់មនុស្សគ្រប់គ្នា ធ្វើឱ្យអ្នកក្រមានសិទ្ធិស្មើគ្នាជាមួយនឹងអ្នកមាន ដោយអ្នកក្រមិនបាច់ត្រូវចំណាយអ្វីច្រើនទេ។ ម្យ៉ាងទៀត ម្នាក់ៗមានភាពស្មើគ្នាទាំងផ្នែកសតិបញ្ញា និងស្មារតី គ្មាននរណាគំរាមកំហែង ឬបង្ខំនរណាបានឡើយ។

បើអ្នកមិនអាចបញ្ចេញសមត្ថភាពចេញមកឱ្យបានពេញទំហឹង សូម្បីតែពេលនៅក្នុងអ៊ិនធើណែតក៏ដោយនោះ អ្នកត្រូវតែពិចារណាពីខ្លួនឯងហើយថា តើមានសមត្ថភាពពិតមែនឬអត់?

អ្នកមានគេមានវិធីដ៏ល្អក្នុងការរកប្រាក់ ទើបអ្នកក្រចាំបាច់ត្រូវសិក្សាពីអ្នកមាន ឬបើមិនដូច្នោះទេ ធ្វើតាមវិធីរបស់អ្នកមានតែម្តងទៅ។ នរណាដែលរៀនតាមបានលឿនបំផុត ចន្លោះរវាងមនុស្សម្នាក់នោះជាមួយនឹងអ្នកមាន នឹងតូចទៅជាលំដាប់ ហើយអ៊ិនធើណែត គឺជាប្រភពសិក្សាដ៏ល្អបំផុត ព្រោះការផ្សព្វផ្សាយទិន្នន័យតាមរយៈអ៊ិនធើណែតរហ័សជាងល្អប្រសើរជាង និងមានប្រសិទ្ធិភាពជាងសារព័ត៌មានដទៃ ដូច្នេះទើបអ៊ិនធើណែតមានតម្លៃចំពោះអ្នកក្រជាខ្លាំង។

អ៊ិនធើណែត ប្រៀបដូចជាឋានសួគ៌ក្នុងការសាងអាជីពឱ្យអ្នកក្រ និងជាកន្លែងដែលបំភ្លឺក្តីស្រមៃរបស់យុវវ័យ ប្រៀបដូចជារឿងព្រេងទេវតាដែលផ្តល់ក្តីសង្ឃឹមដ៏ភ្លឺថ្លាដល់អ្នកដែល «ចេះប្រើ» គ្រប់គ្នា។


ប្រធានផ្នែក
អ្នកគ្រប់គ្រង
ធ្វើការបែបនេះមិនបានទេ
ល្ងង់មែន
ដើម្បីកូន ត្រូវតែអត់ធ្មត់
អត់ធ្មត់...

# ៨២

## អ្នកក្រត្រូវអត់ធ្មត់

មនុស្សយើងនឹងមិនផ្ទុះកំហឹងចេញមកដោយងាយទេ បើនៅមិនទាន់អស់ភាពអត់ធ្មត់ទេនោះ ដែលយើងមិនផ្ទុះកំហឹងចេញមកភ្លាមៗនោះព្រោះយើងត្រូវការពារខ្លួន។ អ្នកដែលត្រូវអត់ធ្មត់នោះច្រើនតែជាមនុស្សដែលទន់ខ្សោយ ហើយការផ្ទុះកំហឹងរបស់អ្នកទន់ខ្សោយ គឺប្រៀបដូចជាយកពងមាន់ទៅជល់នឹងថ្មនោះឯង...យ៉ាងណាក៏ត្រូវតែបែកដែរ។

ដូច្នេះ ក្នុងនាមជាអ្នកក្រ យើងត្រូវអត់ធ្មត់ ព្រោះការចងគំនុំមិនបានបង្កឱ្យកើតជាប្រយោជន៍អ្វីទេ កំហឹងពីការខឹងនោះ នឹងកាន់តែធ្វើឱ្យខ្លួនឯងក្លាយទៅជាអ្នកចាញ់ប្រៀបវិញ។ យើងត្រូវតែជឿជាក់ថា ទីបំផុតអំពើល្អត្រូវតែឈ្នះអំពើអាក្រក់។

នៅក្នុងប្រទេសចិន បើនរណាចង់បកអាក្រាតអ្នកនយោបាយដែលពុករលួយឱ្យអន្តរាយបាននោះ ត្រូវធ្វើឱ្យបាននូវរឿង ៣ ប្រការគឺ ៖

**ប្រការទី១** ប្រមូលភស្តុតាងដើម្បីបកអាក្រាតពីកំហុសរបស់ពួកពុករលួយទាំងនោះ

**ប្រការទី២** មានបុគ្គលថ្នាក់ខ្ពស់គាំទ្រយើងពីខាងក្រោយ (ដើម្បីឱ្យធំជាងពួកពុករលួយ)

**ប្រការទី៣** ធ្វើឱ្យពួកគេមានជម្លោះផ្ទៃក្នុង ដោយប្រើប្រយោជន៍ជានុយ ព្រោះពេលដែលនាំគ្នាឃើញតែពីប្រយោជន៍ផ្ទាល់ខ្លួនរៀងៗខ្លួន ហើយបែងចែកផលប្រយោជន៍មិនស្មើគ្នា នឹងមានការឈ្លោះគ្នាយ៉ាងខ្លាំង។ ទីបំផុត គ្រប់យ៉ាងនឹងវិនាសខ្ទេចខ្ទីអស់ ពួកគេនឹងបែរមកខាំគ្នាឯងវិញ។

នៅលើលោកនេះ គ្មានអ្វីដែលបានមកដោយទទេៗទេ បើមានមនុស្សព្យាយាមយកប្រាក់មកឱ្យអ្នក បង្ហាញថាគេចង់ឱ្យអ្នករកប្រាក់ឱ្យគេឱ្យបានច្រើនជាងនេះ ហើយពេលដែលអ្នកត្រូវគេចងជាប់ហើយនោះ អ្នកក៏មិនមែនជាមនុស្សដែលមានចិត្តល្អដែរ ព្រោះហ៊ានដើរ នៅលើផ្លូវដែលខុសនឹងសីលធម៌ទៅហើយ។

មូលហេតុទាំង ៣ ប្រការនេះ អាចជាវដ្តៈបាន «បើយើងធ្វើតែអំពើអាក្រក់ យើងខ្លួនឯងគឺជាអ្នកដែលវិនាស»។

អ្នកក្រមិនចាំបាច់ត្រូវបារម្ភពីបញ្ហារឿងអយុត្តិធម៌ នៅក្នុងសង្គមទេ ព្រោះវាមាននៅគ្រប់ទិសទីនៅក្នុងលោកនេះទៅហើយ ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះគឺ អ្នកត្រូវប្រញាប់ធ្វើភារកិច្ចរបស់ខ្លួនឯងឱ្យបានសម្រេច ដើម្បីធ្វើឱ្យជីវិតកាន់តែល្អប្រសើរឡើង។


សន្សំតែអស់ជាច្រើនឆ្នាំ
មានប្រាក់សន្សំខ្លះហើយ
គិតគម្រោងបណ្ដាក់ទុនទេ ?
ទិញភាគហ៊ុនយ៉ាងម៉េចដែរ ?
មួយរយៈនេះភាគហ៊ុនឡើងរហូត
ទិញមាសសន្លឹកក៏បានដែរ
តម្លៃមាសនៅក្នុងទីផ្សារពិភពលោក
ឡើងជាប់ជាប់
ទិញរបស់ចាស់ៗមកទុកក៏ល្អម្យ៉ាងដែរ
អាចចំណេញបាន
តែដែលពេញនិយមបំផុតនោះគឺ ទិញផ្ទះ
ទិញដី ព្រោះឡើងថ្លៃរហូត
កុំធ្វើនូវអ្វីដែលមិនជំនាញឡើយ
ខ្ញុំគិតថាគូររូបតុក្កតាឱ្យបានស្អាតនោះ
ក៏ជាការបណ្ដាក់ទុនដែរ

# ៨៣

## បណ្តាក់ទុនជាមួយអ្វីដែលខ្លួនជំនាញគឺល្អបំផុត

ពេលដែលនិយាយអំពីរឿងបណ្តាក់ទុន មនុស្សទូទៅតែងតែគិតដល់ភាគហ៊ុន ឬអចលនទ្រព្យ[*] ហើយទិញលក់ដើម្បីកេងយកកម្រៃ។

តាមពិតទៅ កម្រៃដែលថានេះ អាចមិនមែនជាមាសប្រាក់ដែលនឹងបានមកងាយៗទេ បើសំណាងអាក្រក់ បូកដកដើមទុនហើយ អាចនឹងខាតដើមក៏ថាបាន។ ការខូចខាតដោយការបណ្តាក់ទុននេះ អាចនឹងត្រូវបាត់បង់ប្រាក់ដែលសន្សំមកអស់មួយជីវិត ដូច្នេះពេលដែលអ្នកក្របណ្តាក់ទុនត្រូវតែប្រយ័ត្នប្រយែងឱ្យបានល្អ។

ពេលដែលអ្នកក្រឃើញអ្នកដទៃបណ្តាក់ទុន ហើយទទួលបានជោគជ័យនោះតែងតែច្រណែនឈ្នានីសគេ តាមពិតទៅ អ្នកដែលទទួលបានជោគជ័យមិនមានច្រើនទេ នោះដោយសារតែសង្គមមិនដែលបង្ហាញអ្នកដែលបរាជ័យឱ្យយើងឃើញប៉ុណ្ណោះ តាមពិតអ្នកបរាជ័យមានច្រើនជាងអ្នកជោគជ័យទៅទៀត អ្វីដែលបានឃើញនេះគ្រាន់តែជាការបញ្ឆោតឱ្យយើងគិតថា ការបណ្តាក់ទុនបានកម្រៃមកដោយងាយៗតែប៉ុណ្ណោះ។

. .

ពាក្យណែនាំដែលល្អបំផុតគឺ មិនថាយើងបណ្តាក់ទុនលើអ្វីទេ ត្រូវធ្វើឱ្យអស់ពីសមត្ថភាព ហើយក្នុងមួយជីវិតរបស់មនុស្សម្នាក់ សុំត្រឹមតែចេះ

---

[*] សូមអានបន្ថែមនៅសៀវភៅ: មាន ដោយការធ្វើអាជីវកម្មអចលនទ្រព្យ ដោយមិនបាច់ចំណាយលុយសូម្បីមួយរៀល

បណ្តាក់ទុនក្នុងអ្វីមួយឱ្យបានល្អបំផុតនោះ គឺគ្រប់គ្រាន់ហើយ មិនបាច់ធំប៉ុនមេឃប៉ុនដីក៏បាន។

ក្នុងន័យនេះដែរ ការធ្វើការងារដែលខ្លួនស្ទាត់ជំនាញឱ្យបានល្អបំផុត ចាត់ទុកថាជាការធានាដែលល្អបំផុត បើជំនាញខាងលក់ទំនិញ ត្រូវលក់ដូរឱ្យបានល្អបំផុត បើជំនាញខាងច្រៀង ត្រូវច្រៀងឱ្យបានល្អបំផុត។

ការបណ្តាក់ទុនក្នុងអ្វីដែលខ្លួនជំនាញ គឺជា «ការធានា» ដែលជឿជាក់បាន ច្រើនជាងការយកប្រាក់ទៅបណ្តាក់ទុនចំពោះមុខរបរដែលមិនជំនាញ។ ការបណ្តាក់ទុនជាមួយនឹងអ្វីដែលខ្លួនជំនាញ ចាត់ទុកថាជាការបណ្តាក់ទុនដែលចំណាយប្រាក់តិចតែបានកម្រៃច្រើន គង់វង្ស និងយូរអង្វែង សូម្បីតែមនុស្សឆ្លាតដូចជា ប៊ីល ហ្គេត ក៏មិនលេងភាគហ៊ុននៅក្នុងក្រុមហ៊ុនរបស់ខ្លួនដែរ។

កុំលេងភាគហ៊ុនដើម្បីគ្រាន់តែសប្បាយឱ្យសោះ ក្រៅអំពីថាវាគឺជាការងារគោលរបស់អ្នកប៉ុណ្ណោះ។



# ៨៤

## ចង់ក្លាយជាអ្នកមានត្រូវមានគុណសម្បត្តិគ្រប់យ៉ាង

បើអ្នកក្រចង់ក្លាយទៅជាអ្នកមាន វិធីដែលអាចទៅរួចខ្ពស់បំផុតគឺការបណ្ដាក់ទុនក្នុងផ្នែកដែលបានទទួលផលតបស្នងខ្ពស់ តែក៏ប្រឈមនឹងហានិភ័យខ្ពស់ដែរ ដូច្នេះអ្នកក្រត្រូវមានគុណសម្បត្តិ «ជាអ្នកប៉ិនប្រសប់» ផងដែរ ដែលគុណសម្បត្តិមួយចំណុចនេះគឺជាចំណុចខ្សោយរបស់អ្នកក្រ។

ណូបែល (Nobel) បរិច្ចាគប្រាក់ចំនួន ៩,៨ លានដុល្លារសហរដ្ឋអាមេរិកដើម្បីជាដើមទុនក្នុងការបង្កើតមូលនិធិណូបែល ប៉ុន្តែ ប្រាក់រង្វាន់ដែលត្រូវចំណាយឱ្យអ្នកដែលបានទទួលរង្វាន់ណូបែលក្នុងមួយឆ្នាំៗ នោះខ្ពស់រហូតដល់ទៅ ៥ លានដុល្លារឯណោះ ធ្វើឱ្យនៅក្នុងឆ្នាំ ១៩៥៣ ខាងមូលនិធិមានប្រាក់នៅសល់ត្រឹមតែ ជាង ៣ លានដុល្លារតែប៉ុណ្ណោះ ហើយក្នុងឆ្នាំនេះហើយ ដែលមូលនិធិបានរៀបចំការគ្រប់គ្រងហិរញ្ញវត្ថុសាជាថ្មីដោយយកប្រាក់ដែលផ្ញើនៅធនាគារ ទៅទិញសញ្ញាបណ្ណរដ្ឋាភិបាលបណ្ដាក់ទុននៅក្នុងផ្សារភាគហ៊ុន និងទិញអចលនទ្រព្យ លុះដល់ឆ្នាំ ១៩៩៣ ទ្រព្យសម្បត្តិទាំងអស់របស់មូលនិធិមានតម្លៃកើនឡើងជាង ២០០ លានដុល្លារ។

អ្នកគ្រប់គ្រងហិរញ្ញវត្ថុរបស់មូលនិធិ សុទ្ធតែជាអ្នកជំនាញក្នុងការបណ្ដាក់ទុន និងមានគុណសម្បត្តិក្នុងការបណ្ដាក់ទុន។ សាកល្បងមើលអ្នកនៅជុំវិញខ្លួនអ្នកលមើល អ្នកដែលយកប្រាក់ទៅបណ្ដាក់ទុនអចលនទ្រព្យភាគច្រើនគឺជាអ្នកមាន។ ចំណែកអ្នកក្រដែលយកប្រាក់ទៅទិញផ្ទះនោះគឺ

វិញដើម្បីស្នាក់នៅប៉ុណ្ណោះ អ្នកក្រដែលយកប្រាក់ទៅបណ្ដាក់ទុននៅក្នុងផ្សារភាគហ៊ុននោះ ក៏មានមិនតិចដែរ តែក៏មិនឃើញថា មាននរណាមានពីការលេងភាគហ៊ុនឡើយ មានតែអ្នកខាតដើមប៉ុណ្ណោះ។ អ្នកមាននិងអ្នកក្រដើរនៅលើផ្លូវតែមួយ ដែលផ្លូវមួយខ្សែនេះមានហានិភ័យខ្ពស់ខ្លាំងណាស់។

ឧទាហរណ៍ភាពជោគជ័យពីការបណ្ដាក់ទុន ដែលយើងបានស្ដាប់បានឮនោះ សុទ្ធតែជាករណីពិសេស ដែលត្រូវគេលើកឡើងមកដើម្បីធ្វើជាគំរូឱ្យអ្នកក្រតែប៉ុណ្ណោះ។

ដូច្នេះ ការបណ្ដាក់ទុនដើម្បីគ្រប់គ្រងហិរញ្ញវត្ថុ នឹងអាចទទួលបានជោគជ័យឬអត់នោះ គឺមានតែ «គុណសម្បត្តិ» ប៉ុណ្ណោះដែលជាអ្នកវិនិច្ឆ័យ ទើបអ្នកមានចាំបាច់ត្រូវព្យាយាម «លើកតម្កើងគុណសម្បត្តិការបណ្ដាក់ទុន» របស់ខ្លួនឱ្យស្ថិតនៅក្នុងកម្រិតខ្ពស់បំផុត។

*គុណសម្បត្តិដែលថានោះ មានដូចជា... ពេលវេលា ដើមទុន ឱកាស និងសម្ពន្ធភាព ជាដើម។*


ដល់ពេល
ពាក់ស្បែកជើង
ស្បែកហើយ
ខំរៀនអស់ជាង ១០ ឆ្នាំ
ទីបំផុតរៀនចប់ហើយ
មិនបាច់ធ្វើជាកសិករ
តទៅទៀតទេ
មកជិះឡានហើយ

# ៨៥

## ការសិក្សាអាចផ្លាស់ប្តូរជីវិតបាន

កម្រិតវប្បធម៌អាចជាកត្តាផ្លាស់ប្តូរវាសនារបស់អ្នកក្របាន។

កាលពីជាង ២០ ឆ្នាំមុននៅក្នុងភូមិមួយនៅលើភ្នំ មានបងប្អូនពីរនាក់ នៅក្នុងផ្ទះក្រលំបាកជាខ្លាំង។ ឪពុកម្តាយអាចឱ្យកូនរៀនបានតែម្នាក់ប៉ុណ្ណោះ ទើបម្តាយឱ្យពីរនាក់បងប្អូននោះទស្សន៍ទាយថា តើចំបើងគឺជាអ្វី? នរណាទាយត្រូវនឹងបានចូលរៀន លទ្ធផលគឺ ប្អូនជាអ្នកទាយត្រូវទើបបានចូលរៀន ចំណែកឯបងស្រីត្រូវទទួលខុសត្រូវកិច្ចការផ្ទះដ៏សែននឿយហត់បន្តទៀត។

ច្រើនឆ្នាំកន្លងទៅ ប្អូនស្រីបានរៀនចប់មហាវិទ្យាល័យ ដោយលទ្ធផលល្អ នាងបានសាងសង់ផ្ទះនៅទីក្រុង ហើយបានធ្វើការងារល្អៗ។ ចំណែកបងស្រីក៏បានរៀបការ តែនាងគ្រាន់តែជានារីជនបទម្នាក់ប៉ុណ្ណោះ កូនរបស់នាងក៏ត្រូវរស់នៅជនបទដែរ។ ដោយសារតែចំបើងមួយខ្សែសោះ ធ្វើឱ្យពីរនាក់បងប្អូនមានវិថីជីវិតខុសគ្នាដូចមេឃនិងដី។

ប្អូនស្រីក្លាយទៅជាអ្នកទីក្រុង បានធ្វើការងារដែលអ្នកជនបទច្រណែន។ នាងមានសំណាងជាខ្លាំង ទោះបីជាត្រូវចំណាយពេលជាយូរទៀត ទម្រាំតែមានក៏ដោយ តែយ៉ាងហោចណាស់ កូនរបស់នាងក៏មានចំណុចចាប់ផ្តើមដែលខ្ពស់ជាងនាងជាខ្លាំងដែរ។ កូនរបស់នាងគឺ ជាអ្នក

ទីក្រុងតាំងពីកំណើត ការដែលបានសិក្សានៅកន្លែងល្អៗ មិនមែនជារឿងលំបាកទៀតទេ។

អ្នកក្រមិនមែនក្រតែម្នាក់ឯងទេ កូនចៅក៏អាចក្លាយជាអ្នកក្រទាំងអស់ដែរ នេះហើយគឺជាក្តីទុក្ខដ៏ធំបំផុតរបស់អ្នកក្រ។

ដូច្នេះ ទើបនៅក្នុងសង្គមចិនមានគេនិយាយថា «ក្រចុះតែកុំឱ្យក្រការសិក្សា» ការសិក្សាគឺជាការបន្ថែមចំណេះដឹងតែមួយវិធីគត់សម្រាប់កូនអ្នកក្រ។ ពេលដែលពួកគេមានចំណេះដឹង នឹងអាចតស៊ូពុះពារឧបសគ្គនិងអាចផ្លាស់ប្តូរជីវិតដែលលំបាករបស់ខ្លួនឱ្យប្រសើរឡើងបាន។


ធ្វើជាជាងកំបោរហត់ណាស់
ទៅធ្វើជាជាងឡានប្រសើរជាង
ធ្វើជាជាងឡានហត់ណាស់ ទៅធ្វើជា
មុខរបរនេះស្ងប់ស្ងាត់ពេក
ការងារនេះគ្រោះថ្នាក់ពេក ទៅរកការងារ
ដែលមានសុវត្ថិភាពជាងនេះប្រសើរជាង
ត្រូវការជាងកំបោរ

# ៨៦

## ចូរធ្វើការងារមួយៗរហូតដល់ជំនាញ

ធុរកិច្ចដែលអ្នកក្រធ្វើ តែងតែចាប់ផ្ដើមដោយភាពលំបាក និងមិនអាចសាងឋានៈរបស់ខ្លួនបានឡើយ ទើបជនជាតិចិនត្រូវស្វែងរករហូតអស់មួយជីវិត។ អ្នកក្រតែងតែគិតថា អ្វីដែលមាននៅក្នុងដៃនោះមិនមែនជាអ្វីដែលល្អបំផុតទេ ដូច្នេះ មិនថានឹងមានឱកាសអ្វីចូលមកទេ ពួកគេត្រូវតែស្រវាយកមកទុកនៅក្នុងដៃឱ្យបាន ដើម្បីអាចសាងបាដិហារិយ៍ដូចជាអ្នកដទៃ។

តម្លៃរបស់ធុរកិច្ចនីមួយៗរមែងត្រូវចំណាយពេលជាយូរ ទម្រាំអ្នកដទៃគេមើលឃើញ ដូចគ្នានឹងការលះបង់ដើម្បីអ្វីមួយដែរ អាចនឹងមិនបានផលតបស្នងត្រឡប់មកវិញទាំងអស់ទេ ដូចជា អ្នកទិញភាគហ៊ុនចំនួន ១០ ហ៊ុន លទ្ធផលគឺ ៨០% នៃកម្រៃទាំងអស់ដែលអ្នកបាន អាចនឹងបានមកពីភាគហ៊ុន ២ ដំបូងប៉ុណ្ណោះ បើអ្នកមិនស្រវាយកភាគហ៊ុនទាំងពីរនេះឱ្យជាប់ហើយរកកម្រៃពីវាទេ ការខូចខាតដែលកើតឡើងពីភាគហ៊ុន ៨ ទៀតដែលនៅសល់ អាចនឹងច្រើនជាងកម្រៃដែលទទួលបានពីភាគហ៊ុនពីរដំបូងនោះក៏ថាបាន។

ជីវិតរបស់មនុស្សយើងមិនចេះគ្រប់គ្រាន់ទេ ភាគហ៊ុនពីរដែលរកកម្រៃឱ្យអ្នកនោះ អាចនឹងមិនធ្វើឱ្យអ្នកខាតពេលច្រើនប៉ុន្មានទេ តែភាគ

ហ៊ុន ៨ ទៀតដែលធ្វើឱ្យអ្នកខាតដើមនោះ បែរជាធ្វើឱ្យអ្នកត្រូវហត់នឿយទាំងកាយនិងចិត្ត។

ដូច្នេះ ការធ្វើការងារមួយៗឱ្យជំនាញនោះ ទើបចាត់ទុកថា ជាផ្លូវកាត់ឆ្ពោះទៅរកភាពជោគជ័យនៅក្នុងជីវិត កុំរវល់តែគិតថា មានឱកាសគ្រប់ទិសទីឱ្យសោះ។ ការងារដែលយើងធ្វើរហូតមកអស់មួយជីវិតនោះ គ្រាន់តែជាមូលដ្ឋានគ្រឹះឆ្ពោះទៅរកភាពជោគជ័យប៉ុណ្ណោះ តែការងារដែលសំខាន់ពិតប្រាកដនោះ បែរជាមានតិចតួចណាស់។ ពេលដែលមានឱកាសនៅក្នុងដៃរបស់អ្នកហើយ ទោះជាលំបាកយ៉ាងណាក៏ត្រូវតែចាប់ឱ្យជាប់ដែរ ព្រោះមិនប្រាកដទេ បើអាចធ្វើការងារនេះបានសម្រេច អ្នកអាចនឹងទទួលបានជោគជ័យខ្ពស់បំផុតនៅក្នុងជីវិតក៏ថាបាន។

អ្វីដែលសំខាន់បំផុត មិនមែនជាការសម្រេចចិត្តថា នឹងធ្វើអ្វីទេ តែត្រូវសម្រេចចិត្តថា នឹង «មិនធ្វើ» អ្វី។ ហើយបើសម្រេចចិត្តថា នឹងធ្វើហើយត្រូវតែធ្វើរហូតដល់ជំនាញតែម្ដងទៅ។


ត្រូវតែជីករហូតទាល់តែឃើញទឹក
ស៊ូ!
ពូកែមែន
ជីករហូតដល់រកឃើញ
ប្រភពទឹក
បើយើងរាថយ
ហើយឈប់នោះ
ការងារនេះនឹងគ្មានថ្ងៃបាន
ជោគជ័យទេ

# ៨៧

## ការព្យាយាមគឺជាជ័យជម្នះ

នៅក្នុងរឿងនិទានមួយបាននិយាយថា ព្រះរាជានឹងប្រទានរង្វាន់ដល់មន្ត្រីម្នាក់ ដែលបានសាងនូវគុណសម្បត្តិ ទើបទ្រង់ឱ្យមន្ត្រីម្នាក់នោះនិយាយមកថា តើចង់បានអ្វី។ មន្ត្រីនោះបាននិយាយថា «ទូលព្រះបង្គំសុំមិនច្រើនទេ គ្រាន់តែសុំឱ្យព្រះអង្គដាក់ស្រូវនៅលើតារាងក្តារអុក ប្រឡោះទី ១ ដាក់ ១ គ្រាប់ ប្រឡោះទី ២ ដាក់ ២ គ្រាប់ ប្រឡោះទី ៣ ដាក់ ៤ គ្រាប់ និងប្រឡោះទី ៤ ដាក់ ៨ គ្រាប់ ធ្វើដូច្នេះរហូតដល់គ្រប់ ៦៤ ប្រឡោះ» ព្រះរាជាទ្រង់ព្រះសណ្តាប់ហើយ ក៏ល្មួចញញឹម ទើបមានបន្ទូលថាមន្ត្រីម្នាក់នេះសុំតិចម្ល៉េះ?

មិនយូរប៉ុន្មាន តារាងអុកក៏ពេញ ទើបត្រូវប្តូរមកដាក់ស្រូវក្នុងបាវនិងរទេះម្តង តែមិនយូរប៉ុន្មាន រទេះក៏ពេញទៀត ពេលនេះស្រូវនៅក្នុងជង្រុកជិតអស់ហើយ អ្នករាប់ក៏ចាប់ផ្តើមនឿយហត់ដែរ ទើបព្រះរាជាដឹងថា ត្រូវគេបោកហើយ។ របស់អ្វីក៏ដោយ ដែលកាលពីដំបូងមានចំនួនតិចតែបើបន្ថែមឡើងទ្វេដងជានិច្ចនោះ ទីបំផុត នឹងក្លាយទៅជាតួលេខចំនួនមហាសាលបាន។

ខ្ញុំគិតថា មន្ត្រីនោះត្រូវគេប្រហារជីវិត ព្រោះហ៊ានលេងជាមួយនឹងព្រះរាជា។

ពេលដែលអ្នកក្រចង់សាងឋានៈរបស់ខ្លួន ត្រូវចាប់ផ្ដើមពីចំណុចទាបដូច្នេះឯង។ ស្រូវ ១-២ គ្រាប់មិនខុសគ្នាច្រើនទេ តែវាជាគ្រឹះសម្រាប់តំណាក់កាលចុងក្រោយ ដូចគ្នានឹងតារាងអុកប្រឡោះដំបូងៗដូច្នោះដែរ។ ប៉ុន្តែ ដើម្បីឱ្យបានជោគជ័យនោះ ត្រូវប្រើការព្យាយាម និងការអត់ធ្មត់ ព្រោះចំណុចសំខាន់រមែងស្ថិតនៅលើជំហានចុងក្រោយ។ បើសន្សំអ្វីមួយដល់ជំហានចុងក្រោយហើយនោះ ជំហានមុននេះគឺប្រៀបដូចជាការក្រាលមូលដ្ឋានគ្រឹះសម្រាប់ឆ្ពោះទៅរកភាពជោគជ័យនោះឯង។

ការក្រាលមូលដ្ឋានគ្រឹះ គឺជាវិធីដែលចាប់ផ្ដើមពីការផ្លាស់ប្ដូរផ្នែកខាងបរិមាណទៅរកការផ្លាស់ប្ដូរផ្នែកខាងគុណភាព បើគ្មានស្រូវគ្រាប់ទី១ទេ នឹងមិនអាចមានស្រូវជាបាវ ឬជារទេះនៅពេលក្រោយបានទេ។ រយៈពេលនៃការផ្លាស់ប្ដូរនេះ ត្រូវចំណាយពេលយូរ និងលំបាកខ្លាំងណាស់ តើអ្នកអាចរង់ចាំរហូតដល់ថ្ងៃចុងក្រោយបានដែរឬអត់នោះ អាស្រ័យលើការព្យាយាមរបស់អ្នកហើយ។



# ៤៨

## អ្នកក្រត្រូវហ៊ានធ្វើកិច្ចការធំ

មិនថាយើងប្រកបរបរធំ ឬតូចទេ ពេលខ្លះអាចនឹងត្រូវចំណាយពេលធ្វើការច្រើនដូចគ្នាដែរ។ កុំគិតថា មុខរបរតូចៗធ្វើបានងាយ ទើបជ្រើសរើសយកមុខរបរតូចៗនោះ។ ពិតមែនហើយ បច្ច័យដែលប្រើក្នុងការសម្រេចចិត្តថា «តើត្រូវប្រកបរបរអ្វីនោះ» មិនគួរមើលទៅលើទំហំនៃរបរនោះទេ តែគួរមើលថា «ខ្លួនយើងសក្តិសម» នឹងរបរនោះដែរឬអត់?

ប៉ុន្តែជីវិតរបស់មនុស្សយើងប្រៀបដូចជាល្ខោនមួយរឿង បើយើងត្រូវមកសម្តែងល្ខោន ហើយត្រូវអស់កម្លាំងក្នុងការសម្តែងដូចគ្នាដដែលនោះ សូវទៅសម្តែងនៅលើវេទិការធំៗ ឬសម្តែងជាតួដែលលេចធ្លោតែម្តងមិនប្រសើរជាងទេឬ?

យើងគ្រប់គ្នារមែងមានសក្តានុពលជាច្រើនបង្កប់នៅក្នុងខ្លួន កាន់តែបានប្រឈមមុខនឹងការប្រកួតប្រជែងច្រើនប៉ុនណា ឱកាសដែលរកឃើញសក្តានុពលនៅក្នុងខ្លួន នឹងកាន់តែច្រើនឡើងប៉ុណ្ណោះដែរ ហើយយើងនឹងកាន់តែអាចសាងស្នាដៃដ៏លេចធ្លោបន្ថែមឡើងទៀត។

ឧបនិស្ស័យរបស់មនុស្សម្នាក់ ច្រើនតែត្រូវបណ្តុះបណ្តាលពីការងារដែលគេធ្វើជារៀងរាល់ថ្ងៃ ហើយបទពិសោធទាំងនោះនឹងឆ្លាក់ជាប់នៅក្នុងខ្លួនគេជាដរាប។

តែការដឹងពីឧបនិស្ស័យរបស់ខ្លួននោះ មិនមែនស្ថិតនៅលើថា យើងយល់ពីខ្លួនច្រើនប៉ុនណានោះទេ តែស្ថិតនៅលើទស្សនៈនិងបុកពារដែលអ្នកដទៃមានចំពោះយើងទៅវិញទេ។ ពេលដែលអ្នកដទៃឃើញថា យើងជាមនុស្សសំខាន់ ពួកគេនឹងគោរពលើកតម្កើងយើង ហើយយើងនឹងមានមោទនភាពដោយមិនដឹងខ្លួន។ ប៉ុន្តែ ពេលដែលអ្នកនៅជុំវិញខ្លួនយល់ថា យើងជាមនុស្សមិនសំខាន់ បើយើងមិនអាចទប់ចិត្តខ្លួនឯងទេ យើងអាចនឹងខឹងអ្នកទាំងនោះដាច់ក្បាលដាច់កន្ទុយ។

ដូច្នេះ អ្នកក្រត្រូវចេះបង្ហាញចេញថា ខ្លួនអាចធ្វើការធំដុំបាន ខ្លួនជាមនុស្សសំខាន់ ... រហូតកើតជាឧបនិស្ស័យដើម្បីឱ្យអ្នកដទៃជឿជាក់លើខ្លួន។ ដូច្នេះ នៅទីបំផុត ប្រាកដជាអាចធ្វើការធំដុំបានពិតមែន។


សិក្សាគ្រប់យ៉ាង ហើយសង្ឃឹមថា
នឹងជោគជ័យជាងលោកទៅទៀត
មហាសេដ្ឋី

# ៨៩

## អ្នកក្រត្រូវតែហ៊ានប្រឈមមុខនឹងអ្នកមាន

អ្នកក្របើមិនកោតសរសើរអ្នកមានទេ គឺនឹងស្អប់អ្នកមានតែម្ដង។ តាមពិតទៅ អ្នកក្រត្រូវតែហ៊ានប្រឈមមុខនឹងអ្នកមានប្រសើរជាង ព្រោះអ្នកក្រ នឹងអាចមើលឃើញពីចំណុចខ្សោយរបស់ខ្លួនបាន លុះត្រាតែត្រូវឆ្លងកាត់កញ្ចក់មួយផ្ទាំងនេះ។

ប្រាកដណាស់ថា មានអ្នកមានជាច្រើនដែលបានប្រាក់មកដោយមិនសុចរិត កេងប្រវ័ញ្ចអ្នកក្រ សុទ្ធតែជាញើសឈាមរបស់អ្នកក្រទាំងអស់។ ប៉ុន្តែ ដោយសារតែស្ថានភាពសេដ្ឋកិច្ចល្អប្រសើរឡើង ទើបច្បាប់ទម្លាប់ទាំងឡាយអភិវឌ្ឍទៅជាប្រព័ន្ធជាបណ្ដើរៗ ភាពរីកចម្រើនខាងផ្នែកវត្ថុ ក៏កាន់តែច្រើនឡើង ធ្វើឱ្យកម្រិតនៃភាពក្រីក្រនៅក្នុងសង្គមថយចុះ។

សង្គមនិងសេដ្ឋកិច្ចដ៏ច្របូកច្របល់ ប្រៀបដូចផ្លូវបត់បែន ដែលមានមនុស្សជាច្រើនប្រភេទដើរទៅដើរមកនៅក្នុងនោះ អ្នកខ្លះរកច្រកចេញឃើញ អ្នកខ្លះនៅតែវង្វេងនៅក្នុងនោះនៅឡើយ។ ដូច្នេះ អ្នកមិនគួរទាក់ទងជាមួយនឹងមនុស្សដែលនៅក្នុងនោះច្រើនពេកទេ អ្វីដែលសំខាន់បំផុតសម្រាប់អ្នកគឺ «រកច្រកចេញសម្រាប់ខ្លួនឯង»។

បើផ្លូវនេះ មិនអាចចេញបានទេ មិនថានឹងមានមនុស្សរារាំងផ្លូវ ឬច្រកចេញចុងក្រោយទេ សុំឱ្យតែមានលក្ខន្តិកត្រឹមត្រូវ សុំឱ្យតែអ្នកឆ្លាត

ពិតមែននោះ អ្នកប្រាកដជាអាចរកច្រកចេញបាន បើអ្នកដទៃគេចេញបាន អ្នកក៏ត្រូវតែអាចចេញបានដែរ។ ហើយបើទោះបីជាលក្ខន្តិកមិនយុត្តិធម៌ក៏ដោយ វិធីដែលល្អបំផុតនោះគឺ ចូរធ្វើខ្លួនឱ្យស៊ាំជាមួយនឹងវា។ ទោះបីជាការធ្វើដូច្នេះ អាចនឹងមិនជួយឱ្យអ្នកក្លាយទៅជាវីរបុរសបានក៏ដោយ តែអ្នកនឹងមានឈ្មោះថា ឈរនៅលើគោលការណ៍នៃការពិត និងជាក់ស្តែង។

អ្នកក្រត្រូវសិក្សាពីអ្នកមាន ហើយអ្នកក្រត្រូវតែប្រឈមមុខនឹងអ្នកមាន មិនចាំបាច់ដល់ថ្នាក់ត្រូវគោរពលើកតម្កើងគេទេ តែយ៉ាងហោចណាស់ អ្នកក្រត្រូវតែបើកចិត្តព្រមទទួលអ្នកមានឱ្យបាន។



វិថីសេដ្ឋី

# ៩០

## អ្នកក្រត្រូវមានចំណេះដឹងជាអាវុធ

ការដែលអ្នកក្រនៅតែជាអ្នកក្រនោះ មានមូលហេតុជាច្រើន ភាពខុសគ្នាដែលឃើញបានយ៉ាងច្បាស់របស់មនុស្សយើង មិនស្ថិតនៅលើ ខ្ពស់-ទាប ខ្មៅ-ស ធាត់-ស្គម ទេ ប៉ុន្តែ ស្ថិតនៅលើ ចំណេះដឹង ឧបនិស្ស័យ និងគំនិត។

ឧបនិស្ស័យ និងគំនិតរបស់យើង មានភាពច្របូកច្របល់ជាខ្លាំង និងមិនអាចផ្លាស់ប្តូរបានដោយងាយទេ ប៉ុន្តែ ចំណេះដឹងអាចបន្ថែមបានដោយការសិក្សា។

ប្រយោជន៍នៃចំណេះដឹង ក្រៅតែពីធ្វើឱ្យជីវិត និងការរស់នៅកាន់តែពេញលេញឡើងហើយនោះ ចំណេះដឹងនៅអាចយកទៅប្រើការបានជាក់ស្តែង និងអាចជួយលើកកម្ពស់សមត្ថភាពរបស់មនុស្សម្នាក់ៗបានទៀតផង។ ការងាររបស់អ្នកដែលមានចំណេះដឹង និងអ្នកដែលគ្មានចំណេះដឹងធ្វើនោះរមែងខុសគ្នា ហើយលទ្ធផលក៏មិនដូចគ្នាដែរ ព្រោះថាសមត្ថភាពមិនស្មើគ្នា តម្លៃនៃការច្នៃប្រឌិតក៏ខុសគ្នាដែរ ហើយផលប្រយោជន៍ដែលបានទទួលក៏ខុសគ្នាដែរ។

មនុស្សម្នាក់កាន់តែមានសមត្ថភាពច្រើនប៉ុនណា ប្រាក់ខែដែលគេបានទទួល ក៏កាន់តែខ្ពស់ឡើងប៉ុណ្ណោះដែរ ដែលវាជារឿងសមហេតុផល

ណាស់។ម្យ៉ាងទៀត កម្រិតនៃសមត្ថភាពរបស់បុគ្គលម្នាក់នោះ អាស្រ័យលើ ការសន្សំ «មូលធនមនុស្ស» របស់មនុស្សម្នាក់នោះផងដែរ។

មូលធនមនុស្សដែលថានេះ មានដូចជា ៖

- ចំណេះវិជ្ជា
- សុខភាព
- ចិត្តសាស្ត្រ
- សមត្ថភាពក្នុងការធ្វើការងារ

ដូច្នេះ អ្នកក្រកាន់តែត្រូវផ្តល់ភាពសំខាន់និងត្រូវជឿថា ចំណេះដឹងគឺ «និមិត្តសញ្ញានៃថាមពល» ព្រោះថា អ្នកមានគេមានមុនយើងទៅហើយ សុំឱ្យអ្នកក្រមានការព្យាយាមតាមអ្នកមានឱ្យទាន់ នោះនឹងជួយធ្វើឱ្យចន្លោះនៃភាពខុសគ្នាតូចជាងមុនបានយ៉ាងពិតប្រាកដ។


ខ្ញុំសុំពេក
ដោយខ្លួនឯង ជាភាពញាតិនឹងគ្នា
ប្រហែលជាមិនអាចធ្វើកិច្ចសន្យាទេ
កិច្ច សន្យា
ម្យ៉ាងទៀត យើងធ្លាប់ធ្វើការជាមួយគ្នា
ហើយយើងស្រុកមួយគ្នា
ត្រូវតែជឿជាក់គ្នា
ចុះកិច្ចសន្យាទៅ
ខ្ញុំគ្មានយើងទាំងពីរនាក់

# ៩១

## ផ្ដល់ភាពសំខាន់លើឯកសារកិច្ចសន្យា

អ្នកមានឃើញ «កិច្ចសន្យា» ឬ «ឯកសារកិច្ចសន្យា» សំខាន់ជាងជីវិតរបស់ខ្លួនទៅទៀត ជាវិធីធ្វើការងារទៅតាមច្បាប់ទម្លាប់ និងហេតុផល។ ពួកគេនឹងព្យាយាមរក្សាចម្ងាយពីអ្នកដទៃ មិនឱ្យស្និទ្ធស្នាលខ្លាំងពេក ហើយក៏មិនឱ្យឆ្ងាយខ្លាំងពេកដែរ។

ប៉ុន្តែអ្នកក្រចូលចិត្តរាប់ជាសាច់ញាតិ ដើម្បីបង្ហាញចេញពីភាពស្មើគ្នា និងសាងមិត្តភាពក្នុងការរួមដៃគ្នា។ ដូច្នេះ មុននឹងធ្វើការងារអ្វីមួយ អ្នកក្រនឹងគិតពីភាពស្និទ្ធស្នាលជាលំដាប់ដំបូង មើលមិនឃើញពីភាពសំខាន់របស់ហេតុផលទេ។

តាមពិតទៅ អ្នកក្រយល់ច្រឡំហើយ ព្រោះមិនថាជាការរួមដៃគ្នាធ្វើអ្វីទេ «ផលប្រយោជន៍» នឹងមកមុនគេជានិច្ច។ ប៉ុន្តែ ការដែលអ្នកក្រចូលចិត្តរាប់ជាសាច់ញាតិ ក៏ជាល្បិចក្នុងការប្រើមិត្តភាព ជាស្ពានផ្សះផ្សារស្នាមប្រេះឆាទុកជាមុនដែរ។

បើគិតឱ្យត្រូវតាមលក្ខណៈសកលនោះ តើយើងនឹងប្រើអ្វីជាលក្ខខណ្ឌក្នុងការជួយផ្សះផ្សារការរួមដៃគ្នាទៅ?

ចម្លើយគឺ ផលប្រយោជន៍ ភាពស្និទ្ធស្នាល និងការចងដោយកិច្ចសន្យានោះឯង។

អ្នកក្រភាគច្រើនមិនចូលចិត្តធ្វើកិច្ចសន្យាទេ ព្រោះមិនជំនាញក្នុងការធ្វើអ្វីដែលជាលាយលក្ខណ៍អក្សរ ហើយខ្លាចអ្នកដទៃគិតថា ខ្លួនមិនស្និទ្ធស្នាល និងមិនជឿទុកចិត្តគ្នា។ ប៉ុន្តែ តើដឹងឬទេថា ជាច្រើនលើកច្រើនសាដែលកើតមានបញ្ហា គឺដោយសារគ្មានអ្វីដែលជាភស្តុតាងនេះឯង ពេលខ្លះឈ្លោះគ្នារហូតដល់មើលមុខគ្នាមិនចំ ឬវាយគ្នារហូតដល់ចេញឈាមក៏មាន។

មុននឹងយើងធ្វើការជាមួយគ្នា ត្រូវកំណត់ច្បាប់នានាឱ្យបានច្បាស់លាស់ជាមុនសិន ព្រោះបើមានរឿងកើតឡើងពិតមែន នឹងមានវិធីដោះស្រាយបញ្ហា ប៉ុន្តែបើប្រើមិត្តភាពក្នុងការធ្វើការនោះ បញ្ហានឹងគ្មានថ្ងៃអាចដោះស្រាយបានឡើយ។

ដូច្នេះ ពេលធ្វើធុរកិច្ច អ្នកក្រត្រូវផ្ដល់ភាពសំខាន់ដល់ការរួមដៃគ្នា និងធ្វើជាលិខិតកិច្ចសន្យាទើបបាន។



# ៩២

## គួរតែសាងគ្រួសារឱ្យបានគង់វង្ស

ការរៀបការផ្ដល់ផលល្អក្នុងការគ្រប់គ្រងប្រាក់កាក់នៅក្នុងគ្រួសារ។

ពេលដែលគូស្វាមីភរិយាជួយគ្នាទទួលខុសត្រូវថ្លៃចាយវាយ នៅក្នុងជីវិតប្រចាំថ្ងៃបាននោះ នឹងអាចជួយសន្សំសំចៃថ្លៃចាយវាយបាន។ ការរៀបការជួយសាងកម្លាំងជំរុញដល់យើង ព្រោះពេលដែលមានគ្រួសារ យើងត្រូវចិញ្ចឹមគ្រួសារ និងចិញ្ចឹមកូនៗ។ ការរៀបការជំរុញឱ្យយើងមានការទទួលខុសត្រូវ មិនអាចចាយវាយ «តាមអំពើចិត្ត» ដូចកាលពីមុនបានតទៅទៀតទេ ព្រោះត្រូវខិតខំរកប្រាក់ និងសន្សំប្រាក់ទុកដើម្បីអនាគត។

សរុបទៅ អ្នកដែលរៀបការ នឹងមានការរៀបចំគម្រោងរយៈពេលវែង និងដំណើរការទៅតាមគម្រោងដែលបានកំណត់ទុក ធ្វើឱ្យមានឱកាសសាងភាពមានបានច្រើនជាងអ្នកដែលនៅលីវ។

ពាក្យបុរាណចិនបាននិយាយថា «គ្រួសារចុះសម្រុង គ្រប់យ៉ាងនឹងចម្រើនរុងរឿង» គឺមានន័យថា បើសមាជិកនៅក្នុងគ្រួសារសាមគ្គីគ្នាគ្រប់គ្នានឹងជួយគ្នាធ្វើការ និងទទួលខុសត្រូវចំពោះតួនាទីរៀងៗខ្លួន ដែលនេះនឹងជួយឱ្យកើតមានកម្លាំងជំរុញក្នុងការធ្វើការងារផង និងជួយឱ្យកើតមានកម្លាំងជំរុញក្នុងការដោះស្រាយបញ្ហាកាន់តែប្រសើរឡើង។

សរុបទៅគឺ អ្នកក្រត្រូវរៀបការ ប្រការទី១ ដើម្បីសន្សំសំចៃថ្លៃចាយវាយ ចំណុចនេះអាចមិនសំខាន់ទេសម្រាប់អ្នកមាន ប៉ុន្តែ សំខាន់ជាខ្លាំងសម្រាប់អ្នកក្រ។ ប្រការទី២ ដើម្បីបន្ថែមសក្ដានុពលនៃការទទួលខុសត្រូវ។ ប្រការទី៣ ដើម្បីសេចក្ដីសុខ មានអារម្មណ៍ថា មានសុវត្ថិភាព និងមានតម្លៃនៅក្នុងជីវិត។

ម្យ៉ាងទៀត សម្រាប់អ្នកក្រដែលត្រូវមនុស្សនៅក្នុងសង្គមមើលរំលងនោះ ការរៀបការអាចចាត់ទុកថាជាការលួងលោមចិត្តដ៏ធំនៅក្នុងជីវិត ដែលនេះជាផលល្អក្នុងការព្យាបាលផ្លូវចិត្តឱ្យល្អប្រសើរឡើង ដើម្បីឱ្យមានថាមពលក្នុងការប្រកបរបររកស៊ីបន្តទៀត។


ដើរលក់នៅក្នុងភូមិ តើបានប៉ុន្មានទៅ
ទៅលក់នៅក្នុងក្រុងប្រសើរជាង
លក់មិនដាច់ទេ ទៅបើកហាងនៅ
ទីក្រុងប្រសើរជាង
ពង្រីកហាងគឺពិបាកណាស់ ទៅបើក
ក្រុមហ៊ុននៅក្នុងក្រុងប្រសើរជាង
ទំនិញលក់ដាច់ណាស់ ខ្ញុំត្រូវពង្រីកបន្ថែមទៀត
ពេលដែលធ្វើធុរកិច្ចហើយ
មិនអាចឈប់បានទេ
យើងត្រូវតែរក្សាទីផ្សារឱ្យបាន
នៅក្នុងប្រទេសលក់ដាច់ណាស់ទៅហើយ
ចាំបាច់ត្រូវបញ្ចេញទៅលក់នៅ
ឯបរទេសនាំតែស្មុគស្មាញធ្វើអ្វី?

# ៩៣

## អ្នកក្រត្រូវធ្វើតាមបក្សីផ្លាស់លំនៅ

បើមនុស្សម្នាក់អាចរស់នៅកន្លែងដដែលអស់មួយជីវិតបាន នោះបង្ហាញថា មនុស្សម្នាក់នោះទទួលបានជោគជ័យនៅក្នុងជីវិត ឬបើមិនដូច្នោះទេ ក៏ជាបុគ្គលសំខាន់នៅក្នុងវិស័យណាមួយដែរ។ ប៉ុន្តែ បើមនុស្សម្នាក់ក្នុងមួយជីវិតនេះផ្លាស់ប្ដូរលំនៅដ្ឋានរហូតនោះ ក៏មិនមែនមានន័យថាគេនឹងមិនបានជោគជ័យដែរ ព្រោះគេនឹងអាចបានជួបឱកាសជាច្រើន ហើយនឹងបានឃើញអ្វីៗកាន់តែច្រើនឡើងទៀតផង។ ដូច្នេះយើងមិនអាចប្រាប់បានទេថា តើបែបណាល្អប្រសើរជាង ព្រោះទាំងពីរបែបនេះសុទ្ធតែមានចំណុចល្អរៀងៗខ្លួន។ ប៉ុន្តែដោយសារសង្គមសម័យនេះទូលាយខ្លាំង ទើបមានឱកាសគ្រប់គ្រាន់សម្រាប់យើងគ្រប់គ្នា។

បើអ្នកនៅមិនទាន់បានសាកល្បងទេ អ្នកអាចនឹងមិនដឹងថាតើអ្នកមានសមត្ថភាពបង្កប់នៅក្នុងខ្លួនកម្រិតណាទេ ហើយតើខ្លួនឯងអាចមានឱកាសល្អជាងនេះដែរឬទេ?

ហេតុដូច្នេះ ការរស់នៅរបៀបបក្សីផ្លាស់ប្ដូរលំនៅក៏គួរតែជាវិធីដ៏ល្អសម្រាប់អ្នកក្រដែរ។

«រើដើមឈើ អាចធ្វើឱ្យដើមឈើងាប់បាន មនុស្សផ្លាស់ប្ដូរលំនៅអាចនឹងរស់»។ អ្នកក្រតែងតែបរាជ័យ ព្រោះប្រកាន់ខ្ជាប់នឹងអ្វីដដែលៗ ធ្វើ

ឱ្យភ្ញាក់ឱកាសក្នុងការរីកចម្រើនដ៏គួរឱ្យស្តាយ ប៉ុន្តែយើងមិនអាចបន្ទោសអ្នកក្រតែម្ខាងបានទេ ព្រោះការដែលឱ្យអ្នកស្រែអ្នកភ្នំដែលជាមនុស្សក្រីក្រចូលទៅធ្វើការនៅក្នុងទីក្រុងធំ ពេលខ្លះវាអាចនឹងពិបាកខ្លាំង ដែលមនុស្សនៅក្នុងទីក្រុងដូចជាពួកយើងនេះមិនអាចយល់បាន។

បក្សីដែលរើលំនៅដ្ឋាន គឺជាបក្សីដែលរឹងប៉ឹងនិងអត់ធ្មត់ ដូច្នេះការរស់នៅរបៀបបក្សីប្តូរលំនៅដ្ឋាននោះ មិនមែនជារឿងងាយទេ។ យើងត្រូវមានកម្លាំង និងការអត់ធ្មត់ឱ្យបានច្រើន ទើបអាចហើរឆ្លងកាត់សមុទ្របាន។ម្យ៉ាងទៀត ត្រូវដឹងពីទិសដៅដ៏ច្បាស់លាស់ និងមានភាពឈ្លាសវៃ ទើបអាចគេចផុតពីគ្រោះថ្នាក់នៅតាមផ្លូវបាន។ បក្សីដែលប្តូរលំនៅដ្ឋានមិនមានពេលបានសោយសុខទេ ព្រោះពេលដែលចេញដំណើរហើយ ត្រូវចេញទៅរកចំណីរាល់ថ្ងៃ ហើយក៏ត្រូវគេងនៅតាមផ្លូវរាល់ថ្ងៃដែរ។


ហេតុអ្វីមិនទៅធ្វើការ?
ហេតុអ្វី ត្រូវធ្វើការ?

# ៩៤

## ទោះយ៉ាងណា អ្នកក្រក៏ត្រូវតែពឹងប្រាក់ដែរ

ការសន្ទនារបស់រូបភាពនេះ ដកស្រង់មកពីរឿងនិទានរបស់ជនជាតិចិន បើអានដោយមិនយកចិត្តទុកដាក់ទេនោះ ឃើញថាបុរសពនេចរមើលទៅហាក់ដូចជាឆ្លាតជាងសេដ្ឋី ហើយប្រហែលជាមានអ្នកក្រមិនតិចទេ ដែលមានមោទនភាពពេលដែលបានអានរឿងនេះ ប៉ុន្តែ តាមពិតទៅទស្សនៈខុសៗក្នុងរឿងប្រាក់កាក់របស់អ្នកក្រនោះ ប្រៀបដូចជាឧបសគ្គដែលកំពុងតែរាំងភាពរីកចម្រើនរបស់ពួកគេ ហើយនៅផ្តល់ផលប៉ះពាល់ដល់ការតស៊ូដើម្បីផ្លាស់ប្តូរវាសនារបស់ពួកគេទៀតផង។

ប៉ុន្តែ បើយើងសាកល្បងសួរអ្នកក្របន្តទៀតថា «តើការហាលថ្ងៃគឺជាអ្វីៗគ្រប់យ៉ាងនៅក្នុងជីវិតរបស់អ្នកឬ?» «បើព្រះអាទិត្យលិចហើយ តើអ្នកនឹងធ្វើយ៉ាងណា? ចុះប្រពន្ធកូនរបស់អ្នកនោះ?»។

តើអ្នកគិតថា អ្នកក្រនឹងឆ្លើយយ៉ាងណា?

អ្នកក្រត្រូវការប្រាក់ ជាពិសេសអ្នកក្រដែលនៅក្នុងប្រទេសក្រីក្រ ព្រោះសេវាសាធារណៈ ដែលសង្គមបានឱ្យអ្នកក្រនោះ អន់ខ្លាំងណាស់។ សម្រាប់អ្នកក្រនៅក្នុងប្រទេសអ្នកមាននោះ ភាពក្រីក្រគ្រាន់តែជាបញ្ហារឿងកិត្តិយសប៉ុណ្ណោះ ចំណែកអ្នកក្រនៅក្នុងប្រទេសក្រីក្រវិញ ភាពក្រីក្រគឺជាបញ្ហាក្រពះ។ គ្រាន់តែរឿងក្រពះសោះ នៅមិនទាន់បានទទួលនូវការ

ដោះស្រាយផង តើនឹងយកកិត្តិយសមកធ្វើអ្វី? ដូច្នេះបញ្ហារឿងក្រពះគឺជារឿងដែលសំខាន់ជាងអ្វីៗទាំងអស់។

គ្រាន់តែអ្នកក្រហ៊ានប្រឈមមុខជាមួយនឹងភាពក្រីក្ររបស់ខ្លួននោះនឹងអាចរកវិធីគេចផុតពីភាពក្រីក្របានហើយ ដើម្បីកុំឱ្យហាលថ្ងៃដោយភាពអត់ឃ្លាន និងមិនបាច់គេងនៅតាមកៀនជញ្ជាំងតទៅទៀត។ អ្នកក្រចាំបាច់ត្រូវក្រោកឡើងតស៊ូ យ៉ាងណាក៏ដោយ មនុស្សយើងត្រូវរស់នៅជាមួយនឹងបច្ចុប្បន្ន ហើយភាពក្រីក្រនិងភាពមានបាន មានឥទ្ធិពលចំពោះសេចក្តីសុខរបស់យើងជាខ្លាំង។


ត្រូវចំណាយប្រាក់ច្រើនណាស់
សាកទៅទិញ
អ៊ិនធើណែត
បោសសម្អាត
ទឹក-ភ្លើង
សំរាម
ខ្សែកាប
ហ្គាស

# ៩៥

## ចូរស្រឡាញ់ប្រាក់ឱ្យដូចស្រឡាញ់ខ្លួនឯង

ជាទូទៅ មនុស្សស្រីមិនសូវពូកែក្នុងការរកប្រាក់កាក់ទេ ពួកគេគិតថា «ខំប្រឹងធ្វើការ ស៊ូរៀបការជាមួយនឹងបុរសអ្នកមានមិនបានទេ» ឬ «ស្វាមីគឺជាអ្វីៗគ្រប់យ៉ាងនៅក្នុងជីវិត»។

តាមពិតទៅ មនុស្សស្រីត្រូវគិតគូពីរឿងការរកប្រាក់ឱ្យបានច្រើន ព្រោះបើជីវិត ឬការងាររបស់ពួកស្វាមីនាងមានការផ្លាស់ប្តូរនោះ ពួកនាងត្រូវប្រឈមមុខនឹងវិបត្តិខាងហិរញ្ញវត្ថុ។ ជាពិសេស សង្គមឬគ្រួសារដែលមនុស្សប្រុសជាអ្នកគ្រប់គ្រងប្រាក់។

មនុស្សស្រីសម័យមុនច្រើនតែខ្វះភាពជឿជាក់ អ្នកដទៃគេថាយ៉ាងណា គឺតាមគេទាំងអស់ ហើយថែមទាំងមិនយល់ពីស្ថានភាព និងតម្រូវការផ្នែកខាងហិរញ្ញវត្ថុរបស់ខ្លួនទៀតផង ទើបរមែងបណ្តាក់ទុនតាមសាច់ញាតិដោយមិនបានសាកសួរពីមូលហេតុឡើយសូម្បីតែបន្តិច។ បើខាតដើមវិញច្រើនតែគិតថាអ្នកដទៃក៏ខាតដើមដែរ មិនបានក្តៅក្រហាយអ្វីទេ នេះគឺជាគំនិតរបស់មនុស្សដែលទន់ខ្សោយ។

មនុស្សស្រីជាច្រើន តែងតែប្រគល់សិទ្ធិក្នុងការគ្រប់គ្រងប្រាក់កាក់ឱ្យទៅបុរស ដោយសារតែសម្ពន្ធភាព ធ្វើឱ្យខ្លួនក្លាយទៅជាភាគីចាញ់ប្រៀប។ សាកល្បងគិតមើលថា បើថៅហ្វាយនាយប្រុសស្រឡាញ់លេខាស្រី នោះ

លេខាស្រីតែងតែធ្វើតាម និងយកចិត្តចៅហ្វាយនាយ ប៉ុន្តែបើជាចៅហ្វាយស្រីស្រឡាញ់លេខាប្រុសវិញ លេខាប្រុសនឹងមិនធ្វើតាមទេ តែនឹងប្តូរតួនាទីមកធ្វើជាចៅហ្វាយនាយជំនួសវិញ។ រវាងសម្ផស្សភាព និងប្រាក់កាក់មនុស្សស្រីច្រើនតែជ្រើសរើសយកសម្ផស្សភាព ចំណុចនេះអាចជាប្រភពនៃហាយនភាពរបស់មនុស្សស្រីបាន។

បើមនុស្សស្រីចង់ផ្លាស់ប្តូរជីវិតរបស់ខ្លួន ឱ្យប្រសើរឡើងនោះ ត្រូវតែយកចិត្តទុកដាក់លើរឿងប្រាក់កាក់ ឱ្យដូចនឹងយកចិត្តទុកដាក់លើផ្ទៃមុខរបស់ខ្លួនដែរ ត្រូវឈ្លាសវៃក្នុងការរកប្រាក់កាក់ទាំងដើម្បីខ្លួនផង និងដើម្បីកូនផង។


ប្រាក់ធនាគារ
ម៉េចបានធ្វើឫកខ្លួនបែបនេះ?

# ៩៦

## អ្នកក្រកុំធ្វើខ្លួនឱ្យដូចជាអ្នកក្រ

បច្ចុប្បន្ននេះ មានអ្នកមានកើនឡើងជារឿយៗ អ្នកមានប្រាក់មិនខ្លាចថាខ្លួននឹងមានគ្រោះថ្នាក់ទេ បែរជាដណ្ដើមគ្នាប្រាប់ឱ្យអ្នកដទៃដឹងថាខ្លួនជាអ្នកមានទៅវិញ ហេតុអ្វីទៅឬ? ព្រោះថាពេលដែលមនុស្សយើងកាន់តែមានប្រាក់ នឹងកាន់តែមានមនុស្សចង់យកប្រាក់មកឱ្យ ហើយបើចង់ឱ្យអ្នកដទៃយកប្រាក់មកឱ្យ អ្នកត្រូវធ្វើខ្លួនឱ្យមើលទៅ «មិនក្រ»។

ធនាគារ គឺជាធុរកិច្ចដែលទាក់ទងនឹងប្រាក់កាក់ ផ្ដល់ការប្រាក់ចំពោះប្រាក់ដែលផ្ញើក្នុងអត្រាទាប ហើយយកប្រាក់ទៅឱ្យអ្នកដទៃខ្ចីដោយអត្រាការប្រាក់ខ្ពស់។ បើមិនមានមនុស្សត្រូវការប្រាក់របស់ធនាគារទេ ធុរកិច្ចធនាគារក៏មិនអាចនៅតទៅទៀតបានដែរ តើអ្នកគិតថា ធនាគារនឹងយកប្រាក់ទៅឱ្យអ្នកក្រឬ? ធនាគារមិនមែនជាអង្គការមនុស្សធម៌ទេ។

ការដែលអ្នកដទៃយកប្រាក់មកឱ្យយើងនោះ ព្រោះគេចង់បានផលតបស្នងលើសពីប្រាក់ដែលគេយកមកឱ្យយើង។ ភាពក្រីក្រចាត់ទុកថាជានិមិត្តសញ្ញានៃភាពបរាជ័យនៅក្នុងសង្គមសេដ្ឋកិច្ច អ្នកបរាជ័យមិនអាចធ្វើឱ្យអ្នកដទៃទុកចិត្តបានទេ ហើយពេលដែលមនុស្សមិនទុកចិត្តហើយ គេនឹងមិនយកប្រាក់មកឱ្យយើងទេ ដូចដែលគេនិយាយថា «ជួយអ្នកដែលក្ដៅក្រហាយ តែមិនជួយអ្នកក្រ»។

អ្នកក្រប្រើភាពក្រីក្រទៅលួងលោមចិត្តរបស់អ្នកដទៃមិនបានទេ ប្រាកដជាក្លាយជាអ្នកសុំទានមិនខាន ត្រូវអ្នកដទៃមើលងាយ និងមើលមិនឃើញពីអនាគតឡើយ។

បើអ្នកចង់ឱ្យអ្នកដទៃយកប្រាក់មកឱ្យដោយពេញចិត្ត ថែមទាំងញញឹមដាក់អ្នកទៀតនោះ អ្នកត្រូវតែរកតម្រូវការរបស់អ្នកដទៃឱ្យឃើញ ហើយតបស្នងនូវតម្រូវការរបស់ពួកគេដោយខ្លួនរបស់អ្នកផ្ទាល់។

មនុស្សគ្រប់គ្នាសុទ្ធតែមានតម្លៃទាំងអស់ តែអ្វីដែលសំខាន់បំផុតនោះគឺ អ្នកត្រូវធ្វើឱ្យអ្នកដទៃជឿនូវតម្លៃដែលមាននៅក្នុងខ្លួនអ្នកឱ្យបាន។


ឈាបនកិច្ច
អរគុណ
លើកក្រោយ
អញ្ជើញមកទៀត
អរគុណ
បងមិនមកទេ

# ៩៧

## អ្នកក្រមិនចាំបាច់ដឹងគុណអ្នកមានច្រើនពេកទេ

ពេលដែលអ្នកមានទៅទិញទំនិញរបស់អ្នកក្រ អ្នកក្រតែងតែគិតថាអ្នកមានពិតជាចង់មកទិញពិតមែន ទើបអ្នកក្រក្រាលព្រំក្រហម និងឈរវៀងគ្នាចាំទទួល ថែមទាំងជប់លៀងទទួលអ្នកមានដោយម្ហូបអាហារល្អៗ ដូចជា ជ្រូក មាន់ ទា និងម្ហូបសមុទ្រ សុំឱ្យតែអ្នកមានគេមានសេចក្តីសុខនោះគឺគ្រប់គ្រាន់ហើយ។

ប៉ុន្តែ អ្វីដែលអ្នកមានត្រូវការបំផុតនោះមិនមែនជាការហូបឱ្យឆ្អែតទេ តែជាការញាត់លុយបំពេញហោប៉ៅរបស់ខ្លួនទៅវិញ។ អ្នកក្រយល់ច្រឡំទាំងស្រុងថា អ្នកមានមកជួយទិញ និងវិនិច្ឆ័យអ្នកមានដោយគំនិតរបស់ខ្លួនឯង។ លទ្ធផលគឺ «សាច់មិនបានស៊ី ស្បែកមិនបានទ្រាប់អង្គុយ តែបែរជាយកឆ្អឹងមកព្យួរក» ទៅវិញ។ មានតែអ្នកក្រប៉ុណ្ណោះដែលខិតខំដើម្បីចម្អែតក្រពះ តែតម្រូវការរបស់អ្នកមានខុសពីតម្រូវការអ្នកក្រស្រឡះ។

ពេលដែលអ្នកមានយល់ថា សក្តិសមនឹងបណ្តាក់ទុន ទើបពួកគេធ្វើ បើពួកគេយល់ថា មិនសមនឹងបណ្តាក់ទេ ទោះបីជាអ្នកលុតជង្គង់អង្វរគេយ៉ាងណាក៏ពួកគេគ្មានផ្លូវបណ្តាក់ទុនដែរ។ អ្នកមានរស់នៅជាមួយប្រាក់មកជាយូរ ទើបតែងតែធ្វើតាមច្បាប់សេដ្ឋកិច្ច បើនិយាយថា អ្នកមានគឺជាពួកពូកែអែបអបក៏មិនខុសដែរ ព្រោះនោះគឺជាឧបនិស្ស័យរបស់ពួកគេ។

ដូច្នេះ អ្នកក្រមិនចាំបាច់ត្រូវដឹងគុណអ្នកមានច្រើនពេកទេ តែអ្វីដែលអ្នកក្រត្រូវធ្វើនោះគឺ សិក្សាពីអ្នកមាន ហើយប្រញាប់អភិវឌ្ឍខ្លួនឱ្យឆ្លាតនិងមានសមត្ថភាពឱ្យដូចអ្នកមាន។ ពេលណាដែលអ្នកអាចផ្លាស់ប្តូរស្ថានភាពរបស់ខ្លួនបាន បាវខ្សាច់របស់អ្នក នឹងអាចក្លាយទៅជាទូដែកនៅក្នុងពេលនោះភ្លាម។ លុះដល់ពេលនោះ អ្នកមានដែលក្រអឺតក្រទមនឹងត្រូវមកក្រាបអ្នក ឬចង់ឱ្យអ្នកទៅបណ្តាក់ទុនជាមួយនឹងគេទៀតផង។



# ៩៨

## កុំឱ្យគេមកបោកប្រាស់យើងបាន

មានទិន្ន័យជាច្រើនដែលនៅជុំវិញខ្លួនរបស់អ្នកក្រស្ទើរតែរាល់ថ្ងៃ ព្រោះអ្នកក្រត្រចៀកស្រាល ឆាប់ជឿគេ។ អ្នកដែលព្យាយាមសាងការនិយម ទាំងឡាយនោះ មិនមែនបង្កើតឡើងមកលេងៗទេ តែមានបំណងអូសទាញ យកប្រាក់ពីហោប៉ៅរបស់អ្នកក្រ។

ជាច្រើនលើកច្រើនសា ដែលអ្នកក្រត្រូវបានគេនិយាយអុចអាល (បែបបោកប្រាស់) ដោយ «ពាក្យពេចន៍ប្រកបដោយហេតុផល» ពោលគឺ ត្រូវគេអុចអាលថា នៅក្នុងជីវិតរបស់មនុស្សយើងមានគ្រោះថ្នាក់ នៅជុំវិញ ខ្លួន បើមិនគិតរកវិធីការពារទេ អ្នកនឹងត្រូវស្លាប់ ហើយមានវិធីការពារតែ មួយគត់គឺ «ការទិញ» ។

ឧទាហរណ៍ដូចជា បើអ្នកមិនទិញ talking dictionary ឱ្យកូនទេ បង្ហាញថា អ្នកចង់ឱ្យកូនល្ងង់។ បើអ្នកមិនទិញឡេការពារកម្ដៅថ្ងៃម៉ាកនេះ ទេ អ្នកនឹងកើតមហារីកស្បែក។ បើមិនហូបថ្នាំបំប៉ននេះទេ រាងកាយនឹង ខ្វះសារធាតុ អាយុខ្លី ហើយជីវិតក៏គ្មានសេចក្ដីសុខដែរ។ ចំណែកបុរសវិញ ត្រូវហូបថ្នាំនេះដើម្បីកុំឱ្យជីវិតស្នេហា និងការរួមភេទរបស់អ្នក ... សរុបទៅគឺ អ្នកត្រូវតែទាន់សម័យ ហាមឈឺ ហាមកើតទុក្ខ។ ទោះបីវាជាការអុចអាល ដោយប្រយោលក៏ដោយ តែមានគោលបំណងតែមួយគឺ «យកប្រាក់មក ទិញទំនិញរបស់ខ្ញុំភ្លាម»។

ទំនិញគ្រប់ប្រភេទតែងផ្សាយពាណិជ្ជកម្មអូសទាញ «ចំណង់» ដែលមាននៅក្នុងខ្លួនរបស់អ្នក ហើយបញ្ឆោតឱ្យអ្នកទិញដោយមិនដឹងខ្លួន។ អ្នកក្រនឹងក្លាយទៅជានុយរបស់ពួកគេបានដោយងាយ។ អ្នកធុរកិច្ចរកមូលហេតុដែលធ្វើឱ្យអ្នកភ័យខ្លាចបានគ្រប់យ៉ាង ឱ្យអ្នកសាកល្បងទិញយកទៅប្រើ ទីបំផុត អ្នកនឹងក្លាយទៅជាមនុស្សដែលមិនអាចខ្វះនូវទំនិញនោះបានឡើយ។ ភាពជឿជាក់ និងអារម្មណ៍សុវត្ថិភាពដែលមាននៅក្នុងខ្លួនអ្នក នឹងត្រូវគេបំផ្លាញរហូតដល់គ្មានសល់។

លទ្ធផលចុងក្រោយគឺ អ្នកនឹងកាន់តែក្រឡើងៗ!


លក់ផ្ទះ
លក់ឧបករណ៍ប្រើប្រាស់
ដកប្រាក់រហូតដល់អស់ពីបញ្ជី
ដើរខ្ចីប្រាក់គេគ្រប់គ្នា
ហើយយកទៅទិញភាគហ៊ុន

ភាគហ៊ុន

# ៩៩

## អ្នកក្រមិនគួរចំណាយរហូតអស់ពីខ្លួនទេ

អ្នកក្រចង់មានចង់ល្បី មានក្តីស្រមៃដ៏ខ្លាំងក្លា ទើបមើលឃើញឱកាសដែលចូលមកបន្តិចបន្តួចថាជារបស់ដែលមានតម្លៃខ្ពស់។ ហេតុនេះពួកគេនឹងចំណាយប្រាក់រហូតដល់អស់ពីខ្លួន ដោយមិនគិតមុខគិតក្រោយឡើយពេលដែលមានឱកាស ដូច្នេះអ្នកក្រចាញ់ល្បិចរបស់អ្នកដទៃបានងាយណាស់ ព្រោះគិតដល់តែក្តីស្រមៃរបស់ខ្លួនឯង រហូតដល់មើលរំលងក្តីស្រមៃរបស់អ្នកដទៃ ដែលអាចនឹងបំផ្លាញក្តីស្រមៃរបស់ខ្លួនបាន។

ការក្រាញននៀលតស៊ូរបស់អ្នកក្រ តែងតែប្តូរទៅជាល្បែងស៊ីសងដោយប្រើអារម្មណ៍ និងពឹងលើជោគវាសនា ព្រោះគេយល់ថា ការពឹងពាក់លើជោគវាសនាក៏អាចមានឱកាសទទួលបានជោគជ័យខ្លះដែរ។

ឧបមាថា ឱ្យកាំភ្លើងទៅអ្នកមួយដើមដោយមិនប្រាប់ថា នៅក្នុងកាំភ្លើងនោះមានគ្រាប់ឬអត់ទេ ហើយឱ្យអ្នកបាញ់ក្បាលខ្លួនឯង បើនៅក្នុងកាំភ្លើងគ្មានគ្រាប់ទេ អ្នកនឹងបានទទួលប្រាក់រង្វាន់ជាច្រើន តែបើនៅក្នុងកាំភ្លើងមានគ្រាប់ ចាត់ទុកថា អ្នកសំណាងអាក្រក់។

ករណីនេះបើជាអ្នកតើអ្នកនឹងធ្វើយ៉ាងណា?

ទោះបីជាការចំណាយអស់ពីខ្លួន ត្រូវប្រើភាពក្លាហានក៏ដោយ តែវិធីដែលល្អបំផុតនោះ គួរតែគិតឱ្យបានល្អសិនមុននឹងកេះកៃ។ សាកល្បង

គិតមើលថា បើមានគ្រាប់ពិតមែននោះ ជីវិតរបស់អ្នកនឹងត្រូវរលត់ភ្លាម ប៉ុន្តែ បើអ្នកមិនមានអ្វីកើតឡើងទេ តើអ្នកនឹងបានប្រាក់រង្វាន់នោះពិតមែនឬទេ? ហើយអ្នកនឹងមានសេចក្តីសុខអស់មួយជីវិតឬទេ?

រាល់លើកដែលអ្នកក្រចំណាយរហូតអស់ពីខ្លួននោះគឺ មានតែបរាជ័យប៉ុណ្ណោះ គ្មានផ្លូវបានជោគជ័យឡើយ។

ស្លាប់ទៅ អាចនឹងឈឺចាប់ ប៉ុន្តែមនុស្សដែលកាន់តែក្រ លទ្ធភាពដែលគេនឹងជ្រើសរើសបាញ់ក្បាលខ្លួនឯង ក៏មានកាន់តែច្រើនដែរ ទោះបីនោះគឺជាទង្វើដ៏ល្ងង់ខ្លៅយ៉ាងណាក៏ដោយ។



# ១០០

## អ្នកក្រមិនគួរដើរផ្លូវខុសទេ

អ្នកក្រស្ថិតនៅក្នុងស្ថានភាពតូចទាបនិងខ្វះទីពឹង។ បើអ្នកក្រគ្មានផ្លូវអាចរកស៊ីបានទេ ពួកគេអាចនឹងរំពឹងអ្វីដែលឥតប្រយោជន៍ រំពឹងថានឹងបានទទួលលាភដោយចៃដន្យ ទើបអ្នកក្រតែងតែខ្វះសតិ និងដើរផ្លូវខុសទៅធ្វើអាជីពដែលអាចនឹងមានតាមផ្លូវកាត់។

នៅក្នុងប្រទេសចិន បើកន្លែងណាកាន់តែក្រីក្រខ្លាំង កន្លែងនោះកាន់តែបង្កើតភាពសាហាវឃោរឃៅខ្លាំងដែរ ដូចជា ថ្នាំញៀន ស្រាខុសច្បាប់ អង្ករខុសច្បាប់ តៅហ៊ូខុសច្បាប់ និងទំនិញដែលខុសច្បាប់ជាច្រើនទៀតរាប់មិនអស់។ ភាពក្រលំបាកអាចធ្វើឱ្យមនុស្សឆ្កួតបាន ប៉ុន្តែ បញ្ហាដែលធំជាងនេះទៀតនោះគឺ ការឆ្កួតដែលមិនអាចដោះស្រាយបញ្ហាអ្វីបាន។

ពេលខ្លះ លាភដែលបានមកដោយចៃដន្យ គឺប្រៀបបីដូចជាក្តារមឈូសដែលដាក់នៅចំពោះមុខអ្នកក្រ។

ជំនួញខុសច្បាប់នោះមើលទៅហាក់ដូចជារកប្រាក់បានលឿន តែប្រាក់ដែលបានមកលឿន ក៏អស់ទៅវិញលឿនដែរ។ ជំនួញខុសច្បាប់ចាំបាច់ត្រូវអាស្រ័យទៅលើលក្ខខណ្ឌ និងផ្លូវពិសេស ត្រូវពឹងពាក់មនុស្សជាច្រើន បើចំណុចណាមួយមានបញ្ហានឹងមិនអាចធ្វើការងារនោះបាន

តទៅទៀតទេ ប្រាក់ដែលរកបានមក នឹងត្រូវរលាយទៅវិញយ៉ាងឆាប់រហ័ស លទ្ធផលចុងក្រោយគឺ ត្រូវត្រឡប់ទៅចាប់ផ្ដើមសាជាថ្មីម្ដងទៀត។

អ្នកធ្វើជំនួញខុសច្បាប់ នឹងគ្មានថ្ងៃបានឃើញពន្លឺព្រះអាទិត្យទេ ព្រោះពួកគេត្រូវធ្វើដំណើរនៅក្រោមភាពងងឹតគ្រប់ពេល នឹងជួបតែពួកព្រាយបិសាច មិនថាពួកគេនឹងធ្វើអ្វីទេ រមែងមានការប្រថុយច្រើនជាងការធ្វើការងារសុចរិត ហើយដែលសំខាន់នោះគឺ នរណាដែលបានភ្លក្សរសជាតិផ្អែមពីការធ្វើជំនួញខុសច្បាប់ហើយនោះ ពួកគេនឹងគ្មានថ្ងៃត្រឡប់ទៅធ្វើការងារសុចរិត ឬត្រឡប់ទៅធ្វើការងារដែលគង់វង្សទៀតទេ។

កុំភ្លេចថា ជំនួញខុសច្បាប់គ្មានថ្ងៃធ្វើឱ្យនរណាម្នាក់បានរីកចម្រើនទៅមុខឡើយ បើអ្នកចង់ធ្វើកិច្ចការធំ និងចង់រីកចម្រើននោះ អ្នកត្រូវធ្វើជាមនុស្សល្អ និងធ្វើការងារសុចរិតប៉ុណ្ណោះ។

# សេចក្ដីបញ្ចប់

## ក្ដីរំពឹងមួយចំនួន

បញ្ហារបស់អ្នកក្រ គឺជាបញ្ហាដែលគួរតែយកចិត្តទុកដាក់ពិចារណាដោយសមាជិកនៅក្នុងសង្គមគ្រប់គ្នា។

ភាពក្រលំបាក មិនមែនជាត្រាបាបដែលជាប់ខ្លួន មិនអាចកែខៃបាននោះទេ។

ខ្ញុំរំពឹងថា សង្គមទាំងមូល និងបុគ្គលដែលពាក់ព័ន្ធ នឹងត្រួតពិនិត្យមើលបញ្ហាគ្រប់យ៉ាងរបស់អ្នកក្រ សង្ឃឹមថានឹងបានទទួលនូវការយល់ចិត្ត ការគាំទ្រ និងការជួយពីអ្នកគ្រប់គ្នា។

ខ្ញុំរំពឹងឱ្យអត្ថបទ និងគំនូរដែលអធិប្បាយពីជីវិតរបស់អ្នកក្រ បានផ្សព្វផ្សាយក្នុងលក្ខណៈជាសកលតាមបណ្ដាញសារព័ត៌មានផ្សេងៗ ឱ្យកាន់តែច្រើនឡើង ដើម្បីឱ្យគ្រប់គ្នាដឹងពីឫសគល់របស់អ្នកក្រ។

**ទីបញ្ចប់នេះ ខ្ញុំរំពឹងយ៉ាងខ្លាំងថា ...**

«អ្នកក្រដ៏អស្ចារ្យ» នឹងព្យាយាមផ្លាស់ប្ដូរវាសនាខ្លួន រហូតដល់ទទួលបានជោគជ័យតាមដែលប្រាថ្នាក្នុងពេលឆាប់ៗ។

# ប្រវត្តិអ្នកនិពន្ធ

## គូគូ

Gugu ជាអ្នកនិពន្ធដ៏ល្បីល្បាញ ដែលរស់នៅទីក្រុងប៉េកាំង។

ជាអ្នកក្រើនរំឭកចំពោះអ្នកក្រឱ្យមានការតស៊ូឡើង គាត់ប្រៀបដូចជាបិតាផ្នែកខាងហិរញ្ញវត្ថុរបស់អ្នកក្រ។

គ្រប់ទីកន្លែងដែលគាត់បានទៅ សុទ្ធតែកើតមានការនិយមក្នុងភាពមានបានឡើងជានិច្ច។

គ្រប់សៀវភៅដែលគាត់បាននិពន្ធ សុទ្ធតែបាននិយាយអំពីគំនិតមិនទាន់សម័យរបស់អ្នកក្រយ៉ាងឈឺផ្សារ តែជំរុញអ្នកក្រយ៉ាងក្រៃលែង។

ស្នាដៃរបស់គាត់បានទទួលរង្វាន់ជាញឹកញាប់ និងមានអ្នកដែលតាមដានអានជាច្រើន នេះអាចពិសោធបានពីការលក់ដាច់ចំនួនរាប់លានក្បាលនៅក្នុងប្រទេសចិន និងត្រូវបានបកប្រែជាភាសាបរទេសជាច្រើនភាសាទៀត មានកេរ្តិ៍ឈ្មោះបោះសំឡេងយ៉ាងខ្លាំងនៅ ហុងកុង, តៃវ៉ាន់ សិង្ហបុរី និងកូរេខាងត្បូង។

# ប្រវត្តិអ្នកគូររូបតុក្កតា

## យ៉ាងស៊ីឆឹង

កើតនៅក្នុងស្រុកដែលក្រលំបាកដូចអ្នកក្រដទៃទៀតនៅក្នុងប្រទេសចិនដែរ។ មានមុខមាត់ធម្មតាៗ (ភ្នែកតូចបំផុត) មិនបានសិក្សាខ្ពង់ខ្ពស់ទេ (មិនយកចិត្តទុកដាក់សិក្សា គិតតែពីលេងដីដើម្បីសូនរូប) ថែមទាំងគ្មានកេរមរតកអ្វីបន្សល់ពីដូនតាទេ (បុព្វបុរសជាកសិករក្រីក្រទាំងអស់)។

ក្រោយពីបញ្ចប់ការសិក្សាផ្នែកខាងសិល្បៈមក គាត់បានធ្វើការងារចេញម៉ូដឃោសនា រចនាម៉ូដទស្សនាវដ្តី និងជាបណ្ណាធិការសិល្បកម្ម មានបទពិសោធគូររូបភាពតុក្កតាជាង ១០ ឆ្នាំ និងបង្កើតគេហទំព័រតុក្កតាផ្ទាល់ខ្លួនដែលមានឈ្មោះថា http://www.xwmh.net

មានបាវចនាថា «គូរៗៗ បន្តទៀត បន្តិចទៀតនឹងបានកុំព្យូទ័រ Apple ហើយ»។

អ្នកជោគជ័យ អានសៀវភៅ ដាំដើមជីវិត

# ១០០ គំនិត
# យកឈ្នះភាពក្រីក្រ

- បង្ហាញពីចំណុចខ្សោយរបស់អ្នកក្រ
- ទស្សនៈរបស់អ្នកក្រ
- វិធីយកឈ្នះភាពក្រីក្រ

១០០ គំនិតដ៏មជ្ឈតលោយទ្បំនឹងភាពកំប្លែងលេង
អមជាមួយនឹងរូបភាពគំនូរថ្លុក ដែលនឹងជំរុញឱ្យអ្នកក្រហ៊ានក្រោកឡើង
មកផ្លាស់ប្តូរជីវិតដែលហួសសម័យ!

## បើអ្នក...

ស្រមើស្រមៃឥតប្រយោជន៍
សង្ឃឹមតែប្រាក់ខែ មិនមើលឱ្យបានវែងឆ្ងាយ
ខ្ជាចនេះខ្ជាចនោះ គ្មានគម្រោងការច្បាស់លាស់។ល។

## សាកល្បង...

ផ្លាស់ប្តូរនិស្ស័យដែលនាំឱ្យក្រក្នុងពេលនេះ
ដើម្បីឱ្យអាចស្រែកឡើងថា ជយោ! ខ្ញុំមានហើយ!

ISBN 978-999-63-42-912
9789996342912